ដាំដើមជីវិត LIFE GROWTH

# វ័យក្មេង វ័យរៀន
## របស់
# អច្ឆរិយបុគ្គល



ចេញពីក្មេងធម្មតាតែអាចក្លាយជាបុគ្គលដ៏ល្បីល្បាញទូទាំងពិភពលោក

គ្រឹះស្ថានបោះពុម្ពផ្សាយ ដាំដើមជីវិត

# វ៉ៃក្មេង វ៉ៃរៀន

របស់

# អច្ឆរិយបុគ្គល

បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY
R.U.P.P.
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
00026457

គ្រឹះស្ថានបោះពុម្ព ដាំដើមជីវិត

**ដាំដើមជីវិត**

| | |
|---|---|
| ចាងហ្វាងបោះពុម្ពផ្សាយ | ប្រាជ្ញ វិជ័យ |
| នាយកប្រតិបត្តិ | ខុំ ដារុយ |
| ទីប្រឹក្សា | សាស្ត្រាចារ្យ ចេះ ប្រាថិន |
| អ្នកប្រែសម្រួល | មាស សុមិនា |
| បណ្ណាធិការ | ស៊ូ សាមាន |
| ពិនិត្យអក្ខរាវិរុទ្ធ | គណៈកម្មការដាំដើមជីវិត |
| រចនាក្រប | មាស តុលា និង មាស ចន្ថា |
| ទីផ្សារ | ស៊ុំ ភារ៉ា, ផៀវ ចន្ធា, ឆាយ ណាទី |
| តម្លៃ | ១១000 រៀល |
| លេខ ISBN | ៩៧៨ ៩៩៩ ៦៣ ៤២ ៧២២ |

រក្សាសិទ្ធិដោយគ្រឹះស្ថានបោះពុម្ពដាំដើមជីវិត

ធ្វើនៅភ្នំពេញឆ្នាំ ២០១៤

ចែកចាយដោយក្រុមផលិតសៀវភៅ **ដាំដើមជីវិត**

ទំនាក់ទំនងជាវដុំនិងរាយតាមទូរសព្ទលេខ:

០១៧ ៨១៥ ៦១៥/ ០១០ ៨១៥ ៦១៥/ ០២៣ ៦៦ ៧៥ ១៦៨

www.read4growth.com

www.Facebook.com/read4growth

Email ✉ Lifegrowthbooks@yahoo.com

# គ្រឹះស្ថានបោះពុម្ព ដាំដើមជីវិត

ហេតុអ្វីបានជាបុត្រធីតារបស់យើងរៀនសូត្រមិនបានការសោះ?

ហេតុអ្វីបុត្រធីតារបស់យើង មិនយកចិត្តទុកដាក់ចំពោះការសិក្សារៀនសូត្រ? មួយថ្ងៃទៅមួយថ្ងៃគិតតែនាំគ្នាវក់លេងហ្គេមឥតប្រយោជន៍ ឬដើរលេងជួបជុំពួកម៉ាកបនភឿនសេពគ្រឿងញៀនញ៉ាម បង្កបញ្ហាក្នុងសង្គម។

តើកូនរបស់យើងគេចសាលាទៀតហើយមែនទេ?

ទាំងអស់នេះ ជាសំណួរដែលកំពុងតែពេញនិយមក្នុងចំណោមអាណាព្យាបាលទាំងឡាយ ដែលបុត្រធីតាទទួលបានលទ្ធផលនៃការសិក្សាមិនគាប់ប្រសើរ ឬបើមិនដូច្នោះទេ ក៏គេចសាលាខ្ជិលច្រអូសមិនយកចិត្តទុកដាក់សិក្សារៀនសូត្រដែរ។ រីឯសំណួរដ៏ពេញនិយមរបស់សិស្សានុសិស្ស ឬនិស្សិតក៏គឺ «ហេតុអ្វីមុខវិជ្ជានេះគួរឲ្យធុញយ៉ាងនេះ» លោកគ្រូម្នាក់នេះបង្រៀនគ្មានបានការសោះ ចូលរៀនពេលណាងងុយតែដេក ហេតុអ្វីលោកគ្រូម្នាក់នេះកាចម្ល៉េះ...? តើនេះជាសាលារៀនឬក៏ជាមណ្ឌលកែប្រែ...?

តើសំណួរទាំងអស់នេះ យើងស្វែងរកចម្លើយនៅទីណា? ទើបអ្នករៀបរៀង សូមគោរពអញ្ជើញអស់លោកអ្នកអាន, អាណាព្យាបាល សិស្សានុសិស្ស និងនិស្សិតជាទីគោរពស្រឡាញ់ទាំងឡាយសាកល្បងចំណាយពេលវេលាខ្លះៗដើម្បីអានសៀវភៅមួយក្បាលនេះ ក្រែងលោ

លោកអ្នកអាចស្វែងរកឃើញចម្លើយដ៏សមស្រប នៅក្នុងសៀវភៅមួយក្បាលនេះក៏អាចថាបាន។ ការដែលបុត្រធីតា ឬជាខ្លួនអ្នកផ្ទាល់រៀនមិនពូកែ ឬក៏ព្យាយាមរៀនដែរ តែមិនបានលទ្ធផលល្អដូចបំណាងប្រាថ្នា មិនមែនមានន័យថាខួរក្បាលខ្សោយ ឬមានអៃឃ្យូ(IQ)ទាបនោះទេ។

បញ្ហាដែលលោកអ្នកជួបប្រទះដូចខាងលើ អាចបណ្តាលមកពីកត្តាផ្សេងៗទៀតជាច្រើនរួមគ្នាដូចជា ឧបនិស្ស័យ ចំណង់ចំណូលចិត្ត បរិស្ថានជុំវិញខ្លួន បរិស្ថាននៅសាលារៀន ស្ថានភាពក្នុងគ្រួសារ ឬក៏បរិយាកាសសង្គមខាងក្រៅដែលកើតឡើង និងវិវត្តទៅជារៀងរាល់ថ្ងៃអាចជាកត្តាអូសទាញឲ្យយើងងាកចេញពីការសិក្សាបាន។

បញ្ហាដែលយើងរាល់គ្នាគួររំឭកជារឿយៗ នោះក៏គឺ មិនថាយុគសម័យចេះតែវិវត្តទៅមុខយ៉ាងណាក៏ដោយ ប៉ុន្តែមនុស្សនៅតែជាមនុស្សដដែល ចំពោះបញ្ហាដែលបានកើតឡើងចំពោះអ្នកសិក្សារៀនសូត្រ និងយុវជនក្នុងសម័យអតីតកាលកន្លងទៅ ពោលគឺ ក៏នៅតែកើតមានឡើងក្នុងលក្ខណៈស្រដៀងគ្នានាពេលបច្ចុប្បន្នកាលនេះដែរ គ្រាន់តែខុសប្លែកដោយរូបភាពទៅតាមសម័យកាលខ្លះៗតែប៉ុណ្ណោះ។

យើងមិនអាចបដិសេធបានទេថាប្រភពផ្តល់ចំណេះដឹង និងការសិក្សាអប់រំទូន្មានប្រៀនប្រដៅដ៏សំខាន់បំផុតនៅក្នុងសម័យបច្ចុប្បន្ននេះ គឺសាលារៀនដែលជាថ្នាលសាបព្រោះបណ្តុះវិជ្ជាដ៏សំខាន់បំផុតមិនអាចខ្វះបាន ប៉ុន្តែនេះមិនមែនមានន័យថាអ្នកដែលគ្មានឱកាសបានចូលរៀន

សាលាដែលជាថ្នាលបណ្ដុះវិជ្ជាដ៏ខាន់នេះក្លាយជាបុគ្គលអវិជ្ជា ងងឹតងងុល ឬត្រូវជួបភាពបរាជ័យក្នុងឆាកជីវិតនោះទេ។

ក្នុងនាមខ្ញុំជាអ្នករៀបរៀងយល់ឃើញថា ការមានទេពកោសល្យធម្មជាតិឬការមិនមានទេពកោសល្យធម្មជាតិរបស់មនុស្សម្នាក់ៗ ពិតជាមានសារសំខាន់ចំពោះភាពជោគជ័យ ឬបរាជ័យនៅក្នុងឆាកជីវិតរបស់មនុស្សគ្រប់រូប។ ពេលខ្លះបុគ្គលដែលរៀននៅសាលាពូកែគ្រប់បែបយ៉ាងក៏អាចជួបប្រទះការបរាជ័យក្នុងឆាកជីវិតដូចគ្នាដែរ។ សមដូចមានពាក្យមួយឃ្លាពោលថា «ចេះរបេះក្បាច់ ឬដំរីជើងបួនគង់មានភ្លាត់ អ្នកប្រាជ្ញចេះស្ទាត់គង់មានភ្លេច»។ ប៉ុន្តែក៏វាអាចផ្ទុយគ្នាក្នុងករណីខ្លះៗ ដូចជាបុគ្គលដែលរៀនមិនពូកែ ឬមិនចូលចិត្តសាលារៀនសោះ ឬក៏មិនមានឱកាសបានសិក្សារៀនសូត្រនៅតាមសាលារៀន ឬស្ថាប័នបណ្ដុះបណ្ដាលវិជ្ជាណាមួយឡើយ ស្រាប់តែថ្ងៃណាមួយក៏ក្លាយជាបុគ្គលអច្ឆរិយៈ មានឈ្មោះល្បីល្បាញពេញពិភពលោក ដូចជា លោក អាល់បឺត អ៊ែនស្តែន, វីនស្តុន ឆឺឆៀល ឬ ចីន-ចាកស៍ រ៉ូហ្សូ ក៏ថាបាន។

ប្រសិនជាលោកអ្នកបានអានសៀវភៅមួយក្បាលនេះ លោកអ្នកនឹងបានយល់កាន់តែច្បាស់ថាអច្ឆរិយបុគ្គលដ៏ល្បីៗនៅក្នុងលោក មិនថាជាអ្នកដែលមានប្រវត្តិការសិក្សារៀនសូត្រពូកែឬខ្សោយ ស្រឡាញ់ឬស្អប់សាលារៀន ឬសូម្បីបុគ្គលដែលមិនធ្លាប់បានសិក្សារៀនសូត្រទាល់តែសោះសុទ្ធតែមានចំណុចអច្ឆរិយៈដូចៗគ្នាគឺ «សេចក្ដីតាំងចិត្តខ្ជាប់ខ្ជួន» និងសេចក្ដីឧស្សាហ៍ព្យាយាមពុះពារឧបសគ្គគ្រប់បែបយ៉ាង ដើម្បីទទួលបានជោគជ័យក្នុងឆាកជីវិតទាល់តែបាននៅថ្ងៃណាមួយ។

បើសិនលោកអ្នក ឬបុត្រធីតារបស់អស់លោកអ្នកមានការតាំងចិត្តមោះមុត និងប្រកបដោយសេចក្តីឧស្សាហ៍ព្យាយាមយ៉ាងម៉ឺងម៉ាត់នោះ ភាពអច្ឆរិយៈក៏ប្រហែលមិនមែនជារឿងដែលហួសវិស័យសម្រាប់យើងនោះដែរ។

# អារម្ភកថា

នៅក្នុងពិភពលោកទាំងមូលគេទទួលស្គាល់ថា «ការសិក្សា» ធ្វើឲ្យមនុស្សកាន់តែឆ្លាតឈ្លាសវៃឡើង ដូច្នឹងហើយនៅគ្រប់ប្រទេសទាំងអស់ក្នុងសកលលោក គេបានរៀបចំឲ្យប្រជាជនរបស់ខ្លួនបានទទួលការសិក្សារៀនសូត្រថ្នាក់មូលដ្ឋានគ្រឹះតាមគោលការការណ៍ច្បាប់ ដែលបានកំណត់។ សម្រាប់ក្នុងប្រទេសកម្ពុជារបស់យើងមានក្រសួងអប់រំយុវជន និងកីឡាជាស្ថាប័នទទួលខុសត្រូវចំពោះការសិក្សាអប់រំគ្រប់កម្រិតដែរ។

កាលនៅសម័យដើមពិភពលោកកំពុងស្ថិតនៅក្នុងការអភិវឌ្ឍ ពុំទាន់មានច្បាប់សម្រាប់គ្រប់គ្រងលើប្រព័ន្ធសិក្សាអប់រំនៅឡើយទេ បុគ្គលណាចង់រៀនឬមិនចង់រៀនក៏ស្រេចតែចិត្តរៀងៗខ្លួន តែក្នុងយុគសម័យនោះបែរជាសម្បូរទៅដោយអ្នកប្រាជ្ញព្រឹទ្ធបណ្ឌិតវិទូ កវីនិពន្ធល្បីល្បាញ និងអ្នកចម្បាំងដ៏អង់អាចក្លាហានជាច្រើនរូបក្នុងលោកទៅវិញ។ បុគ្គលទាំងអស់នោះ ពិភពលោកបានឲ្យតម្លៃយ៉ាងខ្ពង់ខ្ពស់ថាជាបុគ្គលមានខួរក្បាលអច្ឆរិយៈដូចជា អាល់បឺត អ៊ែនស្តែន (Albert Einstan) អាឌុហ្វ ហ៊ីត្លែ (Adolf Hitler) ថូម៉ាស់ អាល់វ៉ា អេឌិសាន់ (Thomas Alva Edison) វ៉ូលហ្វ៍កាង អាមេដៀស ម៉ូសាទ (Wolf Kang Amadeus Mozart) ព្រះបាទអាឡិចសាន់ឌ័រ មហារាជ (Alexander the Great) និងអច្ឆរិយៈបុគ្គលជាច្រើនរូបផ្សេងទៀត ... ថាតើពួកគាត់ទាំងនោះមានមូលដ្ឋានគ្រឹះការសិក្សាអប់រំយ៉ាងដូចម្តេចកាលនៅក្នុងវ័យកុមារ និងវ័យសិក្សា?

សៀវភៅវ័យកុមារ វ័យសិក្សារបស់បុគ្គលអច្ឆរិយៈនឹងពិពណ៌នារៀបរាប់ពីព្រឹត្តិកម្មគ្រប់បែបយ៉ាងរបស់អច្ឆរិយជនទាំងអស់នោះ ដែលមនុស្សក្នុងលោកកោតស្ញប់ស្ញែង និងលើកម្ពស់ថាជាបុគ្គលដែលមានខួរក្បាលអច្ឆរិយៈ ពួកគាត់បានស្រាវជ្រាវរកឃើញនិងបង្កើតឡើងនូវវត្ថុផ្សេងៗ និងរកឃើញនូវគោលគំនិតអប់រំដ៏ស៊ីជម្រៅ ឬទស្សនវិជ្ជាអប់រំដែលបានបន្សល់ទុកដល់មនុស្សលោកគ្រប់រូបបានប្រើប្រាស់ និងអនុវត្តតាមរហូតមកទល់នឹងបច្ចុប្បន្នកាលសព្វថ្ងៃនេះ។

សៀវភៅវ័យក្មេង វ័យរៀនរបស់បុគ្គលអច្ឆរិយៈរៀបរៀងឡើងដោយការសិក្សាស្រាវជ្រាវយ៉ាងយកចិត្តទុកដាក់ខ្ពស់ជាទីបំផុត យើងខ្ញុំសង្ឃឹមជឿជាក់ថា ប្រវត្តិនៃការសិក្សារៀនសូត្ររបស់បុគ្គលអច្ឆរិយៈក្នុងសៀវភៅមួយក្បាលនេះ នឹងបានជាប្រយោជន៍ដល់អស់លោកអ្នកអានជាពិសេសយុវជនជំនាន់ថ្មី ដែលជាទំពាំងស្នងឬស្សីដែលកំពុងស្វែងរកចំណេះវិជ្ជាដាក់ខ្លួន ដើម្បីអភិវឌ្ឍសង្គមជាតិមាតុភូមិឲ្យរីកចម្រើនរុងរឿងជានិរន្តរ៍តទៅ។

តែទោះយ៉ាងណាក៏ដោយ ជីវប្រវត្តិនៃបុគ្គលអច្ឆរិយៈដែលមាននៅក្នុងសៀវភៅនេះ មិនបាននាំយកមកអធិប្បាយឱ្យល្អិតល្អន់ពិស្ដារពីដំណើរជីវិតទាំងអស់ទេ ព្រោះថាមានការអធិប្បាយយ៉ាងច្រើននៅក្នុងសៀវភៅនានា ដូច្នេះនៅក្នុងទីនេះសូមលើកយកតែការតស៊ូដើម្បីជីវិតជោគជ័យខ្លះៗ នៃអច្ឆរិយបុគ្គលទាំងនោះប៉ុណ្ណោះ។ ប្រសិនបើមិត្តអ្នកអានចង់អានជីវិតអច្ឆរិយបុគ្គលទាំងនេះឱ្យល្អិតល្អន់ សូមចូលទៅក្នុងវិគីភីឌា ( Wikipedia ) នឹងមានសេចក្ដីលម្អិតពីបុគ្គលអច្ឆរិយៈទាំងនេះ។

ម្យ៉ាងវិញទៀត សូមប្រសិទ្ធពរជ័យសិរីបវរមហាប្រសើរជូនដល់មិត្តអ្នកអានគ្រប់រូប ជួបប្រទះតែនឹងសេចក្តីសុខសេចក្តីចម្រើន សម្រេចតាមគោលបំណងប៉ងប្រាថ្នា។ ជាពិសេសសូមឲ្យសម្រេចបានជោគជ័យក្នុងភារកិច្ចការងារនិងការសិក្សារៀនសូត្រ។

# មាតិការឿង

## មេរៀនទី ១

អាល់បឺត អ៊ែនស្តែន ( Albert Einstan )....................................២
រីចឆាត វ៉ាកណើរ ( Richard Wagner )....................................៩
ហ្វ្រង់ ស៊ូបឺត( Franz Schubert )........................................១៣
អាឌុហ្វ ហ៊ីត្លែ ( Adolf Hitler )..............................................១៦
ហ៊ែនរី ឃិសស៊ិងចឺ ( Henry Kissinger )..............................២២

## មេរៀនទី ២

### នៅក្នុងចិត្តស្អប់សាលារៀន រហូតក្លាយជាអស់សង្ឃឹម

វិនស្តុន ឆឺឈើល( Winston Churchill )..................................២៥
ចច បឺណាត សរ៍( George Bernard Shaw ).........................៣៣
ហ្វ្រង់ ខាហ្វខា( Franx kafka ).............................................៣៨
ឆាលស៍ បូដឺលែរ៍( Charles Baudelaire )............................៤៣
ហូណោរេ ដឺ បាល្ស៊ាក( Honere De Balxac )..........................៤៥
ហ្គតហ្វ្រែត ឃែលឡឺ( Gottfried Keller )..............................៥២
ហឺមែន ហ៊ែស្សេ( Herrmann Hesse )..................................៥៥
ថូម៉ាស់ ម៉ាន់ន៍( Thomas Mann )........................................៦០

## មេរៀនទី ៣

ឆាលស៍ ដាវីន( Charles Darwin )......................................៦៤
មហាត្មៈគន្ធី( Mahatma Kandhi )........................................៦៨
ម៉ាទីន លូធឺរ៍( Martin Luther )..............................................៧០

ជេម ចយស៍(James Joyce)........................................៧៩
ខាល ម៉ាក្ស(Karl Marx)................................................៨១

## មេរៀនទី ៤

## រៀនសូត្របានពេញលេញ ពោរពេញដោយភាពស្ទាត់ជំនាញ

អ៊ិមម៉ានុអែល ខានត៍(Immanuel Kant)..............................៨៥
វ៉ល់ធៀរ៍(Voltaire)........................................................៨៧
រេនេ ឌែសកាតស៍(Rene Descartes)...............................៩០
ម៉ុក្ស៊ីមីលៀន ឌឺ រ៉ូប៉េសពីអែរ (Maximillion de Robespierre)
..................................................................................៩៣
ចច វិលហែម ហ្វ្រីតរីច ហេហ្គេល (George Wilhelm Friedrich Hegel)..........................................................................៩៨
វ្លាឌិមៀរ៍ អ៊ិលជៀត ឡេនីនឆ៍(Wladimir Iljitsch Lenin) ......១០៣
ចូសេហ្វ ស្តាលីន(Josep Starlin) ..................................១០៨
ម៉ារី យូរី(Marie Curie)...............................................១១២
ណាប៉ូឡេអុង បូណាផាត(Napoleon Bonaparte).............១១៦
កុសស្តាហ្វ ហ្លូប៊ឺត(Gustave Flaubert)............................១២៤
ស៊ិកម៉ាន់ដ៍ ហ្វ្រូឌ៍(Sigmun Freud).................................១២៦
អឺនែសត៍ ហែមិងវេយ៍(Ernest Hemingway)....................១៣០

**មេរៀនទី ៥**

**រៀនពូកែព្រោះតែឪពុក និងគ្រូបង្រៀនផ្ទាល់នៅផ្ទះ**

ព្រះបាទអាឡិចសាន់ឌ័រមហារាជ( Alexander the Great )...១៣៥

កាចូស ជូលៀស សេសារ៍( Gajus Julius Caezar ).............១៤០

ព្រះបាទហែនរីទី៨នៃរាជវង្សធ្យូឌ័រ( Henry VIII of tudor ).....១៤៤

ព្រះនាង ម៉ារី ស្ទួត នៃ ស្កុតឡែន ( Mary Stuart of Scotland ) ..........................................................................១៤៩

ព្រះបាទហ្វ្រេឌ័ររីខ មហារាជ នៃប្រ៉ុស្សៀ ( Frederick the Great ) ..........................................................................១៥២

វ៉ូលហ្វ៍កាង អាមេដៀស ម៉ូសាទ ( Wolfkang Amedeus Mozart ) ..........................................................................១៦០

**មេរៀនទី ៦**

**ទោះបីជាពុំសូវបានសិក្សារៀនសូត្រច្រើន ក៏ប៉ុន្តែតស៊ូព្យាយាមរហូតបានជោគជ័យ**

ថូម៉ាស់ អាលវ៉ា អេឌិសាន់( Thomas Alva Edison )............១៦៤

អាល់ហ្វ្រេត ណូបែល( Afred Nobel )...............................១៦៨

អាប្រាហាំ លីនខុន( Abraham Lincoin )...........................១៧២

ម៉ាក ធ្វេន( Mark Twain )..................................................១៧៦

ឆាលស៍ ឌិខែនស៍( Charles Dikens )...............................១៧៩

ហែនរីច ស្លីម៉ាន់ន៍ Henrich Schiemann )........................១៨៣

ចឺន-ចាកស៍រ៉ូហ្ស៊ូ( Jean-Jacques Rousseau )..................១៨៧

# មេរៀនទី ១

យើងអាចនិយាយបានថា លទ្ធផលនៃការរៀននៅសាលារបស់បុគ្គលម្នាក់ៗមិនអាចកាត់សេចក្ដីដោយដាច់ខាតបានទេថា បុគ្គលនោះនឹងទទួលបានជោគជ័យឬក៏បរាជ័យនៅក្នុងឆាកជីវិតនោះឡើយ មានភស្តុតាងយ៉ាងច្រើនដែលបង្ហាញឱ្យយើងឃើញថា អ្នកសិក្សាដែលមានលទ្ធផលនៃការសិក្សាអន់ខ្សោយនៅក្នុងសាលា អាចនឹងក្លាយជាមនុស្សអច្ឆរិយៈបាននៅថ្ងៃអនាគតរបស់ពួកគេ ដែលនៅក្នុងតួយ៉ាងទាំងនោះមានបុគ្គលម្នាក់ ក្នុងចំណោមបុគ្គលដែលមានឈ្មោះបោះសំឡេងបំផុតហើយជាអ្នកដែលបានសាងនូវស្មារតី និងជាអ្នកសាងនូវកម្លាំងចិត្តឱ្យដល់ពួកសិស្សដែលរៀនមិនពូកែទាំងឡាយដែលរៀនក្នុងថ្នាក់ជាមួយគ្នានោះក៏គឺ លោក អាល់បឺត អ៊ែនស្តែន ឬដូចដែលយើងបានស្គាល់ឈ្មោះជាភាសាអង់គ្លេសថា Albert Einstein នោះឯង។

កាលនៅវ័យកុមារ មិនទំនងអាចក្លាយជាអច្ឆរិយបុគ្គលបន្តិចសោះឡើយ ជាក្មេងដែលមានវិវឌ្ឍនាការយឺតយ៉ាវ មាតាបិតារបស់គាត់មានក្តីបារម្ភថាគាត់ជាក្មេងមិនគ្រប់លក្ខណៈ។

# អាលបឺត អ៊ែនស្តែន

( Albert Einstein, Germany ) គ.ស. ១៨៧៩ - ១៩៥៥

ការអប់រំមិនមែនជាការរៀនទៅតាមអ្វី
ដែលមានជាទូទៅតែចំពោះមុខយើងនោះឡើយ
តែវាជាការហ្វឹកហាត់ខួរក្បាលរបស់យើង
ឱ្យចេះគិតទៅវិញទេ



លទ្ធផលនៃការសិក្សារបស់ អ៊ែនស្តែន គឺពិតជាខ្សោយជាងមិត្តរួមថ្នាក់ពិតប្រាកដមែន ប៉ុន្តែអ្វីទាំងនេះមិនមែនមានន័យថា គាត់មានអៃឃ្យូ (IQ) ទាបឬខ្វះនូវភាពឈ្លាសវៃនោះឡើយ គាត់ក៏មានលក្ខណៈដូចអ្នកសិក្សាទូទៅក្នុងសកលលោកទាំងនៅក្នុងពេលអតីតកាល និងនាពេលបច្ចុប្បន្ននេះដែរ ប៉ុន្តែគាត់តែងតែគិតថា «ហេតុអ្វីគាត់ចាំបាច់ត្រូវរៀននូវអ្វីដែលគាត់មិនចាប់អារម្មណ៍ចង់ចេះចង់ដឹងនោះ»។

កាលនៅវ័យកុមារ អ៊ែនស្តែន ក្រៅអំពីមិនមានទំនោរបង្ហាញនូវភាពអច្ឆរិយៈណាមួយឱ្យប្រាកដហើយ គាត់ថែមទាំងជាក្មេងដែលមានវឌ្ឍនាការយ៉ាងយឺតយ៉ាវ គាត់ហាត់រៀននិយាយបានយឺតជាងក្មេងដទៃ មាតាបិតារបស់គាត់មានសេចក្តីព្រួយបារម្ភថា គាត់អាចនឹងក្លាយជាក្មេងមិនពេញលក្ខណៈ មានសតិសម្បជញ្ញៈមិនពេញបរិបូរ ហើយនៅពេល

ដែលគាត់អាចនិយាយបានតិចៗ គាត់និយាយចេញមកបានទាំងលំបាក គឺអាចនិយាយបានតែពាក់កណ្ដាលពាក្យប៉ុណ្ណោះ។ ក្រៅពីនេះ គាត់ជាមនុស្សចូលចិត្តនៅស្ងៀម មិនចូលចិត្តធ្វើសកម្មភាពរាងកាយដូចជាការរត់លេង និងការលោតដូចក្មេងៗដែលមានវ័យស្រករគ្នាចូលចិត្តធ្វើនោះឡើយ។

អ៊ែនស្តែន ត្រូវបានមាតាបិតាបញ្ជូនឲ្យទៅរៀននៅសាលាបឋមសិក្សាកាតូលិកមួយកន្លែងក្នុងក្រុង មូនិក ដែលនៅទីនោះគាត់ជាកុមារដែលមានឈាមជ័រជាជនជាតិ ជ្វីហ្វ តែម្នាក់គត់នៅក្នុងថ្នាក់រៀនរបស់គាត់។ តមកនៅពេលគាត់មានអាយុបាន ១១ ឆ្នាំគាត់បានបន្តការសិក្សាថ្នាក់មធ្យមសិក្សានៅសាលា លុយប៉ូល។ ទោះជាយ៉ាងណាក៏ដោយ គាត់តែងមានអារម្មណ៍ប្រតិកម្មជុយទៅនឹងប្រព័ន្ធគ្រប់គ្រងសាលា តាំងពីពេលដែលគាត់បានចូលរៀនដំបូងៗមកម្ល៉េះ ដូចដែលគាត់បានពោលក្នុងកាលជាខាងក្រោយទុកថា «ខ្ញុំមានអារម្មណ៍ថា បណ្ដាគ្រូបង្រៀនទាំងឡាយទាំងនៅថ្នាក់បឋមសិក្សា និងមធ្យមសិក្សា ពួកគាត់ធ្វើខ្លួនហាក់ដូចជាមេបញ្ជាការនៅជួរកងទ័ពអ៊ីចឹង»។

វិធីបង្រៀនដែលគ្រូក្នុងសម័យនោះចូលចិត្តប្រើ គឺការប្រើប្រាស់នូវការគំរាមកំហែង ប្រើប្រាស់កម្លាំងបាយ ធ្វើឲ្យសិស្សគ្មានអារម្មណ៍រៀនសូត្រ អ៊ែនស្តែន តែងតែរិះគន់នៅក្នុងចិត្តថា «ពួកគ្រូទាំងអស់នោះធ្វើឲ្យសេចក្ដីត្រេកអរក្នុងការសិក្សារៀនសូត្រនូវចំណេះវិជ្ជាផ្សេងៗ ដែលចង់ចេះចង់ដឹងត្រូវរលាយបាត់បង់អស់។

មនុស្សក្នុងសម័យនោះមានការយល់ច្រឡំជាខ្លាំងដូច្នេះថា ការបង្រៀនសិស្សដោយការប្រើវិន័យ និងបទបញ្ជាតឹងរ៉ឹងជាការបង្កើននូវបទដ្ឋានសិក្សាដ៏ល្អដល់សិស្សឡើងមកបាន សម្រាប់ខ្ញុំគិតថាសូម្បីពួកសត្វដែលស៊ីសាច់ស្រស់ទាំងឡាយ ក៏គង់នឹងគ្មានអារម្មណ៍ស៊ីនូវសាច់ស្រស់និងមានរស់ជាតិឆ្ងាញ់នោះដែរ ប្រសិនជាត្រូវដាក់កំហិត ឬបញ្ជាឲ្យស៊ីនូវអាហារដែលដាក់ជាគំនរនៅចំពីមុខដូច្នោះនុះ»។

អ៊ែនស្តែន រៀនបានពិន្ទុល្អជាលំដាប់លើមុខវិជ្ជាអក្សរសិល្ប៍ និងគណិតវិទ្យា ជាមុខវិជ្ជាដែលគាត់ចូលចិត្ត តែគាត់មិនចូលចិត្តមុខវិជ្ជាផ្នែកភាសា និងប្រវត្តិសាស្ត្រឡើយ។ ហេតុដូច្នេះហើយបានជាពិន្ទុរបស់គាត់ស្រុតធ្លាក់ចុះទៅតាមហ្នឹងដែរ តែគាត់ក៏មិនបានធ្វើព្រងើយកន្តើយ ឬបង្ហាញនូវឥរិយាបថណាមួយឲ្យគ្រូដឹងថា គាត់ស្អប់មុខវិជ្ជាទាំងអស់នុ៎ងដែរ។ ឥរិយាបថរបស់គាត់នៅក្នុងថ្នាក់រៀនបានធ្វើឲ្យគ្រូក្រពុលមុខយ៉ាងខ្លាំងរហូតមានគ្រូម្នាក់ធ្លាប់បាននិយាយជាមួយគាត់ថា«វាប្រហែលជាល្អបើអ្នកអាចចាកចេញឲ្យផុតពីទីនេះ» តែ អ៊ែនស្តែន ឆ្លើយតបទៅវិញថា «ខ្ញុំមិនបានធ្វើអ្វីខុសឯណា» ហើយគ្រូម្នាក់នោះបានគំរាមតបទៅវិញភ្លាមថា «វាគ្មានអ្វីដែលត្រូវបណ្តេញអ្នកឯងឲ្យចេញពីសាលាទេ តែក៏មិនប្រាកដដែរថា វានឹងមិនអាចកើតនៅថ្ងៃណាមួយបើអ្នកឯងនៅតែបន្តធ្វើឥរិយាបថព្រងើយកន្តើយឬអង្គុយស្រមើស្រមៃក្នុងខណៈដែលពួកខ្ញុំកំពុងតែបង្រៀនឲ្យអ្នកឯងទទួលបាននូវចំណេះដឹងខ្លះៗនោះ តើ

ឯងដឹងទេ ឥរិយាបថរបស់ឯងបានបំផ្លាញនូវការគោរពរាប់អាន ដែលសិស្សគ្រប់រូបគប្បីមានចំពោះគ្រូបាអាចារ្យ។

ពាក្យថា ការគោរពរាប់អានដែលគ្រូបាននិយាយនោះ ក្នុងខ្សែភ្នែករបស់ អ៊ែនស្តែន វាហាក់បីដូចជាការបិទសិទ្ធសេរីភាព ហើយគាត់តែងតែគិតថា ការបង្គាប់បញ្ជានិងការប្រើអំណាចនៅក្នុងសាលារៀនធ្វើឲ្យសិស្សបាត់បង់នូវភាពជាម្ចាស់ការលើខ្លួនឯង ហើយជាប្រព័ន្ធសាងនូវផ្នត់គំនិតមនុស្សបែបពាក់កណ្តាលទាសករ។

មុខវិជ្ជាដែល អ៊ែនស្តែន ស្អប់ជាងគេនោះគឺ មុខវិជ្ជាអត្តពលកម្ម ដែលគេត្រូវប្រើកម្លាំងរបស់ពួកទាហ៊ានមកបង្វឹកពួកសិស្ស ដែលធ្វើឲ្យគាត់មានទស្សនគតិជាអវិជ្ជមានចំពោះអ្វីៗគ្រប់យ៉ាង ដែលទាក់ទងនឹងទាហ៊ានដោយគាត់មិនបាននឹកឃើញសោះថាថ្ងៃណាមួយគាត់ក៏នឹងត្រូវចូលធ្វើជាទាហ៊ានដូចគេដែរ។

អ៊ែនស្តែន មានសេចក្តីរីករាយសប្បាយចិត្តយ៉ាងខ្លាំងនៅពេលដែលបានឮឪពុករបស់គាត់និយាយប្រាប់ថា «មុខជំនួញរបស់គ្រួសារយើងកំពុងរងការខាតបង់ហើយប្រឈមមុខនឹងការដួលរលំដូច្នេះហើយពួកយើងត្រូវផ្លាស់ទីលំនៅទៅរស់នៅឯក្រុង មិឡាន ទាំងគ្រួសារ»។

«ការផ្លាស់ទីលំនៅទៅរស់នៅឯបរទេស ជាឱកាសអាចជួយឲ្យគាត់បានចេញផុតពីសាលារៀនដែលគួរឲ្យធុញថប់ និងបានគេចផុតពីអ្វីដែលគាត់រឹតតែមិនចូលចិត្តនោះគឺការចូលធ្វើជាទាហ៊ាន» តែបន្ទាប់មក

អ៊ែនស្តែន ស្ទើរតែទន់ជង្គង់ពេលឪពុករបស់គាត់និយាយបន្តទៀតថា ការផ្លាស់ទីលំនៅទាំងគ្រួសារមិនមែនមានន័យថារួមទាំង អ៊ែនស្តែន ដែរនោះទេ គឺគេត្រូវស្នាក់នៅឯសាលារៀនទីនេះយ៉ាងហោចក៏មួយឆ្នាំទៀតដែរ រហូតទាល់តែគេរៀនចប់ថ្នាក់មធ្យមសិក្សា។

គាត់ត្រូវបានទុកចោលឲ្យនៅតែឯងក្នុងទីក្រុង ម្យូនិក ហើយត្រូវស៊ូទ្រាំគ្រាំចិត្តបន្តរៀននៅក្នុងសាលាដដែលអស់មួយរយៈ លុះក្រោយមក គាត់ក៏បាននឹកឃើញនូវផែនការអាក្រក់មួយគឺ គាត់បានសុំឲ្យមិត្តរបស់គាត់ម្នាក់ ដែលមានឪពុកជាគ្រូពេទ្យជួយចេញវេជ្ជបញ្ជាបញ្ជាក់ថា «គាត់មានជំងឺសរសៃប្រសាទមានសភាពយ៉ាងធ្ងន់ធ្ងរហើយតម្រូវឲ្យទៅសម្រាកព្យាបាលនៅឯប្រទេស អ៊ីតាលី យ៉ាងហោចណាស់ក៏កន្លះឆ្នាំដែរ» លោកនាយកសាលាក៏បានអនុញ្ញាតឲ្យគេសម្រាករៀនតាមបំណងដោយមិនបានដឹងថាជាល្បិចកលរបស់គេឡើយ។

ការសិក្សាតាមប្រព័ន្ធសាលារៀនរបស់គាត់ក៏ត្រូវបានបញ្ចប់មួយរយៈ ប៉ុន្តែគាត់ក៏មានលក្ខណសម្បត្តិល្មមគ្រប់គ្រាន់ដើម្បីស្នើសុំឲ្យគ្រូគណិតវិទ្យារបស់គាត់ ចេញលិខិតបញ្ជាក់ការសិក្សាផ្នែកគណិតវិទ្យាឲ្យមុនពេលគាត់ចាកចេញផងដែរ ដើម្បីងាយស្រួលក្នុងការទៅដាក់ពាក្យចូលរៀននៅតាមសាលាដែលមានបើកបង្រៀនផ្តោតសំខាន់លើ ជំនាញគណិតវិទ្យានិងវិទ្យាសាស្ត្រជាន់ខ្ពស់ក្នុងពេលខាងមុខទៀត។

បន្ទាប់ពីឈប់សម្រាកហើយ គាត់បានទៅស្នាក់នៅជាមួយក្រុមគ្រួសារនៅឯក្រុង មិឡាន បានមិនយូប៉ុន្មានបិតារបស់គាត់បានជំរុញឲ្យចូលរៀនបន្តនៅសាលា ប៉ូលីធិចនិច នៅក្នុងក្រុង ស៊ូរិក ដែលនៅក្នុងរវាងពេលនោះអាចនិយាយបានថា ជាសាលាផ្នែកបច្ចេកទេសជាន់ខ្ពស់ដ៏មានឈ្មោះបោះសំឡេងមួយនៅតំបន់អឺរ៉ុបកណ្ដាល ហើយអ្វីដែលពិសេសជាងនេះទៅទៀតនោះគឺ គាត់អាចចូលរៀនបន្តបានដោយមិនបាច់មានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិតែត្រូវប្រឡងចូលឲ្យជាប់ជាមុនសិន ហើយលទ្ធផលគឺគាត់បានប្រឡងធ្លាក់។ ទោះបីជាពិន្ទុគណិតវិទ្យារបស់គាត់បានខ្ពស់ជាងបេក្ខជនឯទៀតក៏ដោយ ប៉ុន្តែដោយគាត់ខ្សោយមុខវិជ្ជាផ្នែកភាសានិងមុខវិជ្ជាផ្សេងៗទៀត ទើបពិន្ទុរបស់គាត់ក៏បានទាបទៅតាមហ្នឹងដែរ គាត់បានពោលក្នុងកាលជាខាងក្រោយដូច្នេះថា «ការដែលខ្ញុំប្រឡងធ្លាក់ ខ្ញុំគិតថាវាសមគួរហើយ»។

លោកនាយកសាលា ប៉ូលីធិចនិច មានការពេញចិត្តយ៉ាងខ្លាំងចំពោះពិន្ទុគណិតវិទ្យាដ៏អស្ចារ្យរបស់គាត់ ហើយបានណែនាំឲ្យគាត់ទៅរៀនបន្ថែមមុខវិជ្ជាណាដែលខ្វះពិន្ទុនៅសាលារៀនមួយក្នុងក្រុង អារ៉ៅ។ នៅទីនោះហើយដែលគាត់បានពើបប្រទះនូវសាលារៀនដែលគាត់ប្រាថ្នាពីព្រោះជាសាលារៀនដែលមានប្រព័ន្ធអប់រំល្អ ផ្ដល់សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិដល់សិស្ស នេះហើយគឺជាអ្វីដែល អ៊ែនស្តែន មិនធ្លាប់បានជួបប្រទះកាលដែលគាត់នៅក្នុងប្រទេស អាល្លឺម៉ង់ នាពេលកន្លងមក។ ហេតុនេះហើយ ទើបធ្វើឲ្យគាត់ចូលរៀននៅទីនេះដោយភាពសប្បាយ

រីករាយ ហើយជាលទ្ធផលគាត់ក៏បានទទួលនូវសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ បន្ទាប់មកទើបគាត់អាចចូលរៀននៅសាលាប៉ូលីធិចនិច បានដូចបំណងប្រាថ្នា។

ព្រហ្មលិខិតចារវាសនាកំណត់ អ៊ែនស្តែន ប្រឡងចូលរៀននៅមហាវិទ្យាល័យមិនបានសម្រេចឡើយនៅពេលគាត់មានអាយុ ១៦ ឆ្នាំ។ ប៉ុន្តែគាត់បានក្លាយទៅជាសាស្ត្រាចារ្យនៅពេលគាត់មានអាយុ ៣៤ ឆ្នាំ ហើយនៅពេលដែលគាត់មានអាយុ ៤២ ឆ្នាំក៏បានទទួលជោគជ័យដ៏ធំធេងក្នុងឆាកជីវិតគឺ គាត់បានទទួលនូវពានរង្វាន់ណូបែល ផ្នែករូបវិទ្យា បន្ទាប់ពីគាត់បានស្រាវជ្រាវរកឃើញទ្រឹស្តីដ៏ល្បីល្បាញជាច្រើនបំផុតក្នុងសតវត្សរ៍ទី ២០។

# រីឆាត វ៉ាកណឺរ៍

( Rechard Wagner, Germany) គ.ស. ១៨១៣ - ១៨៨៣

ការច្រៀងចម្រៀងរបស់ វិលហ៊ែលមិន័រ ជ្រ័រឌ័រ-ដេវៀន បានជាកម្លាំងជំរុញទឹកចិត្តដ៏ខ្លាំងក្លា ដែលធ្វើឲ្យគាត់មានមហិច្ឆតា រហូតទទួលបានជោគជ័យ។



មូលហេតុដែលបណ្ដាលឲ្យបុគ្គលមួយចំនួនបានក្លាយខ្លួនទៅជាមនុស្សអច្ឆរិយៈមានលក្ខណៈផ្សេងៗពីគ្នាតាមប្រភេទនៃបុគ្គល សម្រាប់ រីឆាត វ៉ាកណឺរ៍ លោកជាមនុស្សដែលពោរពេញដោយមហិច្ឆតាដក់ជាប់ក្នុងចិត្តវិញ្ញាណតាំងពីពេលដែលគាត់បានប្រសូត្រនៅថ្ងៃទី ២២ ខែឧសភា ឆ្នាំ ១៨១៣ ក្នុងទីក្រុង ឡៃប៍ស៊ិក មកម្ល៉េះ។ គាត់ជាកូនទី ៩ នៃគ្រួសារនាយតម្រួតម្នាក់បម្រើការប្រចាំនៅតុលាការទីក្រុង ឡៃប៍ស៊ិក។

នៅក្នុងកំណត់ហេតុរបស់គាត់បានសរសេរថា "នៅពេលដែលខ្ញុំមានអាយុបានត្រឹមតែ ១១ ឆ្នាំ ខ្ញុំមានបំណងចង់ក្លាយជាកវីនិពន្ធដូចកវីនិពន្ធជនជាតិក្រិចសម័យបុរាណជាខ្លាំង ហើយខ្ញុំបានសរសេររឿងសោកនាដកម្មមួយដោយយកទម្រង់ ហ៊ែមឡែត និង យើងឡាយ មក

លាយបញ្ចូលគ្នា ហើយអ្វីដែលពិសេសបំផុតនៅក្នុងរឿងនោះគឺ ខ្ញុំបានកំណត់ឲ្យមានមនុស្សស្លាប់ចំនួន ៤២ នាក់ ហើយអ្នកស្លាប់ទាំងនោះ ខ្ញុំបានឲ្យក្លាយជាតួបិសាចបន្ទាប់ពីខ្ញុំរំឭកឃើញថា តួអង្គនៅក្នុងសាច់រឿងរបស់ខ្ញុំបានស្លាប់បាត់បង់ជីវិតស្ទើរតែទាំងអស់ទៅហើយ»។

រីឆាត ទើបតែមានអាយុបាន ៦ ខែប៉ុណ្ណោះ ឪពុករបស់គាត់ក៏បានទទួលអនិច្ចកម្មចោលទៅដោយជំងឺគ្រុនពោះវៀន។ ឪពុកចិញ្ចឹមរបស់គាត់ជាអ្នកសម្ដែងសិល្បៈដែលមានទាំងជំនាញច្រៀង គូរគំនូរនិងនិពន្ធ គាត់នេះហើយដែលជាអ្នកដឹកនាំឲ្យ រីឆាត ចាប់ផ្ដើមមានសម្ព័ន្ធជាមួយវិស័យសិល្បៈតាំងពីពេលដែលគាត់នៅវ័យក្មេងម្ល៉េះ ហើយគាត់បានដុះគំនិតចង់ក្លាយជាកវីនិពន្ធ ស្រាប់តែឪពុកចិញ្ចឹមរបស់គាត់បានទទួលអនិច្ចកម្មចោលគាត់ទៅម្នាក់ទៀត។ ពេលនោះក្រុមគ្រួសាររបស់គាត់បានផ្លាស់ទីលំនៅទៅរស់នៅឯក្រុង ទ្រេសឌែន ជាកន្លែងដែលគាត់បានចូលរៀនថ្នាក់ដំបូងនៅសាលា ខ្រយស៍ឈូឡ៊ី។

នាសម័យថ្ងៃមួយ គាត់មានឱកាសបានទៅទស្សនាល្ខោនរឿងហ្វ្រៃឈុត ដោយមាន ខាលម៉ារៀ ហ្វនវេបឺ ជាអ្នកសម្រួលតន្ត្រី។ គាត់មានការជក់ចិត្តជិតអារម្មណ៍យ៉ាងខ្លាំង ចាប់ពីពេលនោះមកគាត់ក៏ចាប់ផ្ដើមមានសេចក្ដីស្រមៃចង់ក្លាយជាអ្នកសម្រួលតន្ត្រីម្នាក់។ រីឆាត វ៉ាកណឺរៀននៅសាលា ទ្រេសឌែន បានរយៈពេល ៤ ឆ្នាំ ក្រុមគ្រួសាររបស់គាត់ក៏ត្រូវផ្លាស់ទីលំនៅទៅរស់នៅឯក្រុង ឡៃប៍ស៊ិក វិញ។ នៅពេលនោះគាត់ក៏បានចូលរៀននៅសាលា និខូឡៃឈូល័រ តែគាត់រៀនមិនបានល្អ

ទាល់តែសោះ ជាហេតុធ្វើឲ្យគាត់រៀនត្រួតថ្នាក់ជាញឹកញាប់ហើយគាត់ចាប់ផ្តើមមានអារម្មណ៍ធុញទ្រាន់នឹងការសិក្សារៀនសូត្រនៅក្នុងសាលា តែផ្ទុយទៅវិញ គាត់បែរជាផ្តោតអារម្មណ៍ និងយកចិត្តទុកដាក់មិនដែលបំភ្លេចទាល់តែសោះចំពោះផ្នែកតន្ត្រី។

នៅថ្ងៃមួយ គាត់មានឱកាសបានស្តាប់ចម្រៀង អ៊ែកម៉ែនត៍ របស់ ប៊ីថូហ្វិន ហើយគាត់មានអារម្មណ៍ជ្រោតជ្រាបពេញឱរ៉ាដោយអត្ថន័យដ៏ពីរោះនៃសូរសៀងសំនៀងតន្ត្រី រហូតធ្វើឲ្យគាត់បានសម្រេចចិត្តមួយរំពេចថា «គាត់នឹងក្លាយជាតន្ត្រីករដ៏មានឈ្មោះបោះសំឡេងឲ្យបាននៅថ្ងៃណាមួយ» ទោះបីជាគាត់មិនបានប្រាប់អំពីគោលគំនិតរបស់គាត់ទៅកាន់នរណាម្នាក់ក៏ដោយ តែគាត់ក៏បានចាប់ផ្តើមហាត់និពន្ធចម្រៀងជាបណ្តើរៗផងដែរ។

ថ្ងៃមួយ ចាត់បានថា ជាថ្ងៃដ៏មានសារៈសំខាន់បំផុតនៅក្នុងឆាកជីវិតរបស់គាត់បានឈានមកដល់គឺ គាត់បានទៅមើលល្ខោន ហ្វិដេលិអូ របស់ក្រុម ប៊ីថូហ្វិន ហើយបានស្តាប់ឮនូវសំនៀងដ៏ក្រអួនក្រអៅរបស់អ្នកចម្រៀងម្នាក់ដ៏មានសមត្ថភាព ដែលអាចច្រៀងចម្រៀងបានយ៉ាងពីរោះរណ្តំជ្រោតជ្រាបដក់ជាប់ក្នុងអារម្មណ៍បំផុតនោះគឺ វិលហ៊ែលមិន័រ ជ្រ័រឌ័រ-ដេប្រៀន ការច្រៀងរបស់តារាចម្រៀងម្នាក់នេះ បានធ្វើឲ្យគាត់មានអារម្មណ៍ជ្រោតជ្រាបស្ទើរទប់ចិត្តមិនបាន ហើយក្រោយមកគាត់ក៏បានសរសេរសំបុត្រមួយច្បាប់ បង្ហាញពីការស្ងើចសរសើរជូនចំពោះអ្នកចម្រៀងម្នាក់នោះ ដែលនៅក្នុងសំបុត្រនោះមានអត្ថន័យថា «ចាប់តាំង

ពីពេលនេះតទៅ ជីវិតរបស់ខ្ញុំពោរពេញដោយខ្លឹមសារប្រសិនបើថ្ងៃណាមួយ អ្នកបានឮឈ្មោះរបស់ខ្ញុំក្នុងពិភពសិល្បៈ សូមអ្នកចងចាំទុកចុះថាអ្នកហ្នឹងឯងដែលជាកម្លាំងជំរុញទឹកចិត្តរបស់ខ្ញុំ»។

បន្ទាប់ពីពេលនោះមក គាត់ក៏មិនបានគិតគូររៀនសូត្រនូវវិជ្ជាដទៃណានៅសាលារៀនទៀតឡើយ។ យុវជន វ៉ាកណឺ បានចាកចេញពីសាលារៀនក្នុងវ័យ ១៦ ឆ្នាំដោយគ្មានអ្វីជាដុំកំភួនឡើយ លុះកន្លះឆ្នាំក្រោយមក គាត់ក៏បានចូលរៀនសាជាថ្មីនៅសាលា ថូម៉ាស់ ស៊ូល័រ តែជាអកុសលត្រូវបានគេបណ្ដេញចេញពីសាលា ដោយទើបតែចូលរៀនបានត្រឹមតែ ៤ ខែតែប៉ុណ្ណោះ។ ចាប់តាំងពីពេលនោះមកជីវិតដែលត្រូវតស៊ូទាំងត្រដរដើម្បីកិត្តិយសកេរ្តិ៍ឈ្មោះត្រូវបានចាប់ផ្ដើមឡើង។

នៅទីបំផុត រីឆាត វ៉ាកណឺរ៍ បានក្លាយជាកំពូលអ្នកតែងនិពន្ធ, ម្ចាស់រោងភាពយន្ត និងឯកទេសខាងប្រើសង្គ្រាមពាក្យសម្ដី ដែលមានឥទ្ធិពលបំផុត។

# ហ្វ្រង់ ស៊ូបឺត

( Franz schubert, Austria ) គ.ស. ១៧៩៧ - ១៨២៨

ឪពុករបស់គាត់យល់ឃើញថា ការបង្គាប់ឲ្យកូនប្រុសធ្វើអ្វី ដែលមិនសមតាមបំណងរបស់គេ ជារឿងឥតប្រយោជន៍។



ប្រសិនបើមិនមានឥទ្ធិពលគាបសង្កត់ពីសំណាក់ឪពុក ដែលធ្វើជានាយកសាលាប្រចាំនៅក្នុងភូមិនោះទេ ហ្វ្រង់ ស៊ូបឺត ក៏ទំនងជាមិនបានរៀនសូត្រអ្វីឲ្យបានច្រើននោះដែរ។ ឪពុករបស់គាត់ចង់ឲ្យគាត់ធ្វើជាគ្រូបង្រៀនដូចខ្លួនគាត់ដែរ ទោះបីជាគាត់បានដឹងយ៉ាងច្បាស់ថា កូនរបស់គាត់មានទំនោរទៅខាងផ្នែកតូរតន្ត្រីក៏ដោយ ពីព្រោះនៅពេលគាត់បង្រៀនកូត វីយូឡុង និងលេងព្យាណូ ហ្វ្រង់ ស៊ូបឺត លេងបានយ៉ាងល្អ ហើយថែមទាំងអាចនិពន្ធភ្លេងបានទៀតផង។ ប៉ុន្តែការដែលគាត់មិនយកចិត្តទុកដាក់ក្នុងការរៀនអក្សរនោះ បានធ្វើឲ្យឪពុករបស់គាត់កើតទុក្ខមិនសុខចិត្តយ៉ាងខ្លាំង រហូតឪពុករបស់គាត់បានចេញបទបញ្ជាហាមមិនឲ្យប៉ះពាល់ឧបករណ៍តន្ត្រីជាដាច់ខាត ហើយមិនត្រឹមតែប៉ុណ្ណោះ ហ្វ្រង់ ស៊ូបឺត ត្រូវសន្យាជាមួយឪពុកទៀតថា «ត្រូវខិតខំព្យាយាមរៀន

សូត្រឲ្យបានច្រើន ហើយត្រូវទទួលការអប់រំដើម្បីឲ្យក្លាយជាគ្រូបង្រៀនដ៏ល្អទៀតផង»។ ទោះបីជាត្រូវបានឪពុកហាមដាច់ខាតមិនឲ្យប៉ះពាល់ឧបករណ៍តន្ត្រីយ៉ាងណាក៏ដោយ គាត់នៅតែឆ្លៀតលួចនិពន្ធបទភ្លេងយ៉ាងស្ងាត់ៗ។

លុះគាត់មានអាយុ ១៧ ឆ្នាំ គាត់បានប្រឡងជាប់ជាគ្រូបង្រៀន ហើយបានជួយបង្រៀននៅសាលាដែលឪពុករបស់គាត់ធ្វើជានាយកនៅទីនោះ ប៉ុន្តែគាត់មិនបានយកចិត្តទុកដាក់បំពេញតួនាទីជាគ្រូដ៏ល្អឡើយ នៅពេលគាត់កំពុងបង្រៀន ទោះបីជាពួកសិស្សនិយាយគ្នាឡូឡាឬបង្កភាពរញ៉េរញ៉ៃយ៉ាងណាក៏ដោយ ក៏គាត់មិនអើពើឬផ្តល់សេចក្តីណែនាំអ្វីសោះឡើយ ក្នុងខួក្បាលរបស់គាត់គិតតែរឿងតូរ្យតន្ត្រីប៉ុណ្ណោះ។ ទើបឪពុករបស់គាត់យល់កាន់តែច្បាស់អំពីនិស្ស័យនៃកូនគាត់ ហើយគាត់យល់ឃើញថា ការបង្គាប់បញ្ជាឬដាក់គំនាបទៅលើកូនប្រុសរបស់ខ្លួនឲ្យធ្វើអ្វីដែលមិនស្របតាមបំណងរបស់គេ ជារឿងដែលគ្មានប្រយោជន៍អ្វីទាល់តែសោះ។ ហេតុដូច្នេះហើយ ទើបគាត់អនុញ្ញាតឲ្យកូនប្រុសរបស់គាត់លាឈប់ពីការងាររយៈពេលមួយឆ្នាំ បន្ទាប់ពីនោះមក ហ្វ្រង់ ស៊ូបឺត ក៏មិនបានត្រឡប់មកចាប់អាជីពជាគ្រូបង្រៀនទៀតឡើយ។

ក្រោយពីបានឈប់ធ្វើជាគ្រូបង្រៀនមក គាត់មានជីវិតរស់នៅលើលោកយើងនេះបានតែរយៈពេល ១០ ឆ្នាំប៉ុណ្ណោះ ក្នុងអំឡុងពេល ១០ ឆ្នាំចុងក្រោយនៃឆាកជីវិតរបស់គាត់នេះហើយដែលគាត់បានសាងនិងបន្សល់ទុកនូវស្នាដៃដ៏សម្បូរបែបនិងសន្ធឹកសន្ធាប់។ នៅក្នុងចំណោម

ស្នាដៃដ៏អស្ចារ្យរបស់គាត់ទាំងនោះ មានស្នាដៃមួយដែលមានឈ្មោះថា ស៊ីមហ្វូនី លេខ ៨ (Die Unvollendete) ដ៏ពីរោះរណ្ដំបំផុត តែគួឲ្យស្ដាយក្រៃលែងដែលគាត់មិនបាននិពន្ធចប់នៅឡើយផងក៏អនិច្ចកម្មទៅ វាដូចនឹងអ្វីដែលគាត់ដាក់ចំណងជើងថា ស៊ីមហ្វូនី និងឆាកជីវិតដ៏សែនខ្លីរបស់គាត់នោះឯង។

# អាឌុហ្វ ហ៊ីត្លែ

( Adolf Hitler, Austria ) គ.ស. ១៨៨៩ - ១៩៤៥

គាត់បានប្រឡងធ្លាក់មុខវិជ្ជា
ភាសាអង់គ្លេស ភាសាបារាំង
និងគណិតវិទ្យា ចំណែកមុខវិជ្ជាខ្លះៗទៀត
ធ្វើបានពិន្ទុល្មមអាចជាប់
ហើយគាត់បានពិន្ទុល្អឥតខ្ចោះ
លើមុខវិជ្ជាគូរគំនូរនិងអត្តពលកម្ម។



បើយើងនិយាយដល់អ្នកសិក្សាដែលរៀនខ្សោយបំផុត ហើយបែរជាបានក្លាយខ្លួនជាបុគ្គលមានឈ្មោះល្បីល្បាញ នៅថ្ងៃអនាគតនោះ គឺត្រូវនឹកដល់បុគ្គលម្នាក់នេះគឺលោក អាឌុហ្វ ហ៊ីត្លែ។ គាត់កើតនៅថ្ងៃទី ២០ ខែមេសា ឆ្នាំ ១៨៨៩ ព្រហ្មលិខិតបានចារវាសនាឲ្យគាត់បានក្លាយជានាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋ អាល្លឺម៉ង់ និងបានជាកំពូលមេដឹកនាំចក្រពត្តិ អាល្លឺម៉ង់ ដ៏អង់អាចក្លាហាន។

នៅឯសាលារៀនមួយក្នុងភូមិ ហ្វិស្សលហាំ ក្បែរក្រុង ឡាំបាក នៃប្រទេស អសស្ត្រៀ។ ហ៊ីត្លែ គឺជាក្មេងតូចដែលមានសេចក្តីឧស្សាហ៍ព្យាយាម ធ្វើឲ្យឪពុកមានការរំភើបរីករាយ ហើយពួកគាត់បានតាំងចិត្ត

ថា «ថ្ងៃណាមួយនឹងបញ្ជូនកូនប្រុសរបស់គាត់ឲ្យចូលរៀននៅមហាវិទ្យាល័យឲ្យទាល់តែបានដើម្បីឲ្យក្លាយជាមន្ត្រីរាជការដូចគាត់ដែរ»។

ក្រុមគ្រួសាររបស់គាត់បានផ្លាស់ប្តូរទីលំនៅជាញឹកញាប់ជាហេតុធ្វើឲ្យ ហ៊ីត្លែ ត្រូវផ្លាស់ប្តូរសាលារៀនទៅតាមនោះដែរ។ ទោះជាយ៉ាងនេះក្តី គាត់នៅតែរៀនបានពូកែនៅគ្រប់សាលាដែលគាត់បានរៀនដដែល។ មិនត្រឹមតែប៉ុណ្ណោះ នៅពេលទំនេរគាត់បានឆ្លៀតទៅហាត់រៀនច្រៀងចម្រៀងហើយរៀនបានល្អទៀតផង។ នៅពេលមានអាយុ ១១ ឆ្នាំ គាត់បានរៀនបន្តថ្នាក់មធ្យមសិក្សានៅទីក្រុង ប៉ែកឡាំង នៅទីនេះហើយដែលគាត់ចាប់ផ្តើមខ្សោយទៅៗជាលំដាប់។ នៅក្នុងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិរបស់គាត់មានកំណត់ហេតុជាសម្គាល់ថា «គាត់មិនបានតាំងចិត្តរៀនសូត្រឲ្យបានដិតដល់ទេ និងបានប្រឡងធ្លាក់មុខវិជ្ជាគណិតវិទ្យាដែលជាហេតុធ្វើឱ្យគាត់មិនអាចឡើងថ្នាក់បាន។

អាឌុហ្វ ហ៊ីត្លែ បានសរសេរទុកក្នុងសៀវភៅរឿងរបស់គាត់ដែលមានចំណងជើងថា «ការតស៊ូរបស់ខ្ញុំ» មានសេចក្តីថា «ខ្ញុំនឹងរៀននូវអ្វីដែលខ្ញុំចូលចិត្តតែប៉ុណ្ណោះ ឯអ្វីដែលខ្ញុំគិតថាមិនគួរឲ្យចាប់អារម្មណ៍ឬគ្មានប្រយោជន៍ ខ្ញុំនឹងមិនរៀនឡើយ» ហើយមូលហេតុដែលធ្វើឲ្យគាត់បរាជ័យក្នុងការសិក្សានោះគាត់បានបញ្ជាក់នៅក្នុងសៀវភៅរបស់គាត់ថាវាកើតចេញពីចេតនារបស់គាត់ដែលគាត់បានតាំងចិត្តប្រឆាំងនឹងគោលបំណងរបស់ឪពុក «ជាលើកដំបូងនៅក្នុងឆាកជីវិតរបស់ខ្ញុំ ដែលរងនូវគំនាបយ៉ាងធ្ងន់ធ្ងរហួតធ្វើឲ្យខ្ញុំក្លាយជាគូបដិបក្ខជាមួយឪពុកបង្កើតខ្លួន

បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY

ឯង ព្រោះថាបើឪពុករបស់ខ្ញុំរឹតតែបង្ខំឲ្យធ្វើនូវអ្វីដែលខ្ញុំមិនចង់ធ្វើប៉ុនណា ខ្ញុំក៏រឹតតែមានអារម្មណ៍មិនចង់ធ្វើនូវអ្វីដែលគាត់រំពឹងទុកប៉ុណ្ណោះដែរ ខ្ញុំមិនចង់ធ្វើជាទាហ៊ានបន្តិចណាឡើយ ទោះបីជាឪពុកបានព្យាយាមគ្រប់មធ្យោបាយដើម្បីពន្យល់ណែនាំឲ្យខ្ញុំយល់ថា តើការធ្វើជាមន្ត្រីរាជការវាមានភាពអស្ចារ្យប៉ុនណា តែខ្ញុំនៅតែមិនយល់ស្របព្រោះខ្ញុំយល់ថាការធ្វើជាមន្ត្រីរាជការនឹងក្លាយជាមនុស្សគ្មានឥស្សរភាព មួយថ្ងៃៗអង្គុយតែទះមូសនៅក្នុងការិយាល័យ»។

អ្នកវិភាគខ្លះនិយាយថាអ្វីដែល ហ៊ីត្លែ បានពោលនោះវាគ្រាន់តែជាការបិទបាំងនូវភាពបរាជ័យរបស់ខ្លួនឯងប៉ុណ្ណោះ ព្រោះថាទោះបីជាគ្មាននរណាម្នាក់មកត្រួតត្រាលើជីវិតរបស់គេក៏ដោយ ក៏ការសិក្សារៀនសូត្ររបស់គេមិនបានល្អប្រសើរឡើយ។

ឪពុករបស់គាត់បានទទួលអនិច្ចកម្ម នៅពេលគាត់ទើបតែមានអាយុ ១៤ ឆ្នាំប៉ុណ្ណោះ ក្រុមអ្នកសិក្សាពីប្រវត្តិរបស់លោក ហ៊ីត្លែ ជាច្រើននាក់បានរកឃើញថាភាពបរាជ័យក្នុងការសិក្សារបស់ ហ៊ីត្លែ ក៏ព្រោះតែរូបគាត់ផ្ទាល់ ដែលតែងតែយល់ឃើញថាគ្រប់យ៉ាងដែលមានលក្ខណៈជាប្រព័ន្ធឬជារបៀបរបប គឺជាការបង្គាប់បញ្ជា ឬជាការកាន់កាប់ដោយអំណាច។ មួយទៀត សន្តានរបស់ ហ៊ីត្លែ អាចធ្វើបានល្អចំពោះតែរឿងណាដែលមិនសូវប្រើខួរក្បាលគិតប៉ុណ្ណោះ។

ក្រោយពេលឪពុករបស់គាត់ទទួលអនិច្ចកម្មទៅ គាត់នៅតែបន្តទៅរៀនអក្សរទាំងមិនពេញចិត្ត ហើយមុខវិជ្ជាដែលគាត់រៀនបានពិន្ទុទាបបំផុតនោះគឺភាសាបារាំង ដែលវាជាឧបសគ្គរាំងមិនឲ្យគាត់អាចឡើងថ្នាក់បានឡើយ លុះត្រាតែគាត់ប្រឡងសងលើមុខវិជ្ជានេះសាជាថ្មីទើបអាចឡើងថ្នាក់បាន ប៉ុន្តែត្រូវសន្យាជាមួយគ្រូថា ត្រូវតែទៅរៀននៅកន្លែងផ្សេង ហេតុដូច្នេះហើយបានជា ហ៊ីត្លែ ដែលមានវ័យ ១៥ ឆ្នាំត្រូវផ្លាស់ទៅរៀននៅសាលា រៀលស៊ូល័រ នៅក្នុងទីក្រុង ស្តាយយ័រ។

នៅទីក្រុង ស្តាយយ័រ គេបានស្នាក់នៅជាមួយគ្រួសារមន្ត្រីម្នាក់ដែលបម្រើការងារនៅតុលាការ ហើយភរិយារបស់មន្ត្រីរូបនោះបានមើលថែគាត់ដូចជាកូនបង្កើតរបស់នាងអ៊ីចឹងដែរ។ ហ៊ីត្លែ មានការពេញចិត្តចំពោះជីវភាពរស់នៅក្នុងអំឡុងពេលនោះយ៉ាងខ្លាំង គាត់បានសរសេរជាកំណត់ហេតុទុកថា «វាគឺជាពេលវេលាដ៏ស្រស់ត្រកាលគួរជាទីមនោរម្យនៃឆាកជីវិត ប្រសិនជាខ្ញុំមិនត្រូវខ្វល់ខ្វាយចំពោះការសិក្សារៀនសូត្រដ៏សែនលំបាកដែលប្រៀបបីដូចជាមានអន្ទាក់មកទាក់ក ជាពិសេសនៅពេលថ្ងៃប្រឡងជិតបានមកដល់»។

លទ្ធផលនៃការសិក្សារបស់គាត់នៅឯ ស្តាយយ័រ នៅតែមានភាពរន់ខ្សោយដូចដើម ក្រៅពីមុខវិជ្ជាគូរគំនូរនិងអត្តពលកម្ម ក្នុងសៀវភៅរបស់គាត់បានបង្ហាញពីលទ្ធផលនៃការសិក្សាគួរឲ្យព្រួយបារម្ភ ហើយថែមទាំងបានកើតហេតុការណ៍មួយដែលគាត់ត្រូវចងចាំក្នុងចិត្តជារៀងរហូតនោះគឺ នៅថ្ងៃវិស្សមកាលពួកសិស្សទាំងឡាយបានរៀបចំពិធីជប់លៀង

មួយឡើង ពេលនោះ ហ៊ីត្លែ បានផឹកស្រាអស់ជាច្រើនរហូតស្រវឹងភ្លេចភ្លាំងស្មារតី មិនដឹង និងមិនចាំបានថាមានរឿងអ្វីបានកើតឡើងឡើយ។

លុះព្រឹកថ្ងៃបន្ទាប់ មានស្ត្រីអ្នកកៀបទឹកដោះគោម្នាក់បានប្រទះឃើញគាត់ដេកលង់លក់មិនដឹងខ្លួននៅកណ្ដាលផ្លូវ ហើយស្ត្រីរូបនោះក៏បានដាស់ឲ្យក្រោកឡើង។ ហ៊ីត្លែ បានដើរត្រឡប់ទៅផ្ទះវិញទាំងដំណើរទ្រេតទ្រោតមិនទាន់ស្វាងស្រានៅឡើយ ឯស្ត្រីដែលជាភរិយារបស់មន្ត្រីជាម្ចាស់ផ្ទះដែលគាត់បានស្នាក់នៅជាមួយនោះ ស្ទើរគាំងបេះដូងពេលបានឃើញគាត់ធ្លាក់ក្នុងសភាពបែបនោះ ហើយបានសួរថាសៀវភៅនៅឯណា?

ហ៊ីត្លែ ហាក់ភ្ញាក់ស្មារតីហើយរកមើលសៀវភៅមិនឃើញដោយមិនដឹងថាខ្លួនបានភ្លេចនៅកន្លែងណាទេ ទើបគេម្នីម្នាត្រឡប់ទៅកាន់សាលាវិញដើម្បីសុំចម្លងសំណៅសៀវភៅថ្មី ប៉ុន្តែសៀវភៅរបស់គាត់ក៏មិនបានបាត់ទៅណាឡើយ គឺនៅពេលដែលគាត់ស្រវឹង គាត់បានយកវាទៅប្រើជំនួសក្រដាសជូតសម្អាតលាមកក្នុងបន្ទប់ទឹក រួចទុកនៅទីនោះ ហើយមានអ្នកប្រទះឃើញបានយកមកឲ្យគាត់វិញ។ បន្ទាប់ពីកើតហេតុការណ៍នោះមក ហ៊ីត្លែ បានស្បថថានឹងមិនប៉ះពាល់គ្រឿងស្រវឹងទៀតឡើយ។

លទ្ធផលនៃការសិក្សានៅក្នុងសៀវភៅបានបង្ហាញថា គាត់បានប្រឡងធ្លាក់មុខវិជ្ជាភាសាអាល្លឺម៉ង់, ភាសាបារាំង និងគណិតវិទ្យា ចំណែក

មុខវិជ្ជាមួយចំនួនទៀតគាត់រៀនបានពិន្ទុល្មមអាចជាប់បាន តែសម្រាប់មុខវិជ្ជាពីរគឺ គូរគំនូរ និងអត្តពលកម្ម គាត់រៀនបានពិន្ទុល្អគួរឲ្យស្ងើចសរសើរ។ រយៈពេលកន្លះឆ្នាំក្រោយមក គាត់ត្រូវបានឈប់ពីសាលារៀនដោយសារមានជំងឺហើមសួត ហើយជាមូលហេតុដែលធ្វើឲ្យគាត់មិនអាចអង្គុយធ្វើការក្នុងបន្ទប់តូចចង្អៀត មានខ្យល់អាកាសអាប់អួបានទើបគាត់បានសម្រេចចិត្តធ្វើជាវិចិត្រករ។

ទាំងនេះ ជាកញ្ចក់ឬជារឿងដែលគួរឲ្យសង្កេតថា អាឌុហ្វ ហ៊ីត្លែបានទម្លាក់កំហុសទាំងស្រុងទៅលើឪពុករបស់ខ្លួនថា គឺជាអ្នកដែលធ្វើឱ្យលទ្ធផលនៃការសិក្សារបស់គាត់មិនល្អ ដែលយើងស្តាប់ទៅហាក់បីដូចជាទាន់សម័យ ពីព្រោះនាពេលបច្ចុប្បន្ននេះ មនុស្សទូទៅតែងតែសម្លឹងឃើញពីភាពបរាជ័យរបស់ក្មេងថា នោះជាកំហុសរបស់ឪពុកម្តាយដែលមើលថែកូនមិនបានល្អ ឬការមើលថែអប់រំកូនដោយការបង្ខិតបង្ខំផ្លូវចិត្ត គំរាមកំហែង ដាក់សម្ពាធផ្លូវចិត្តហួសព្រំដែនពេក។

ការដែលកូនមានលទ្ធផលនៃការសិក្សាអន់ខ្សោយ អាចបណ្តាលមកពីឪពុកម្តាយមិនយកចិត្តទុកដាក់ចំពោះការសិក្សារបស់កូន ឬអាចបណ្តាលមកពីការគ្រប់គ្រងកូនតឹងតែងពេកព្រោះចង់ឲ្យកូនបានសម្រេចនូវអ្វីដែលខ្លួនប្រាថ្នាចង់បាន តែទោះជាយ៉ាងនេះក៏ដោយ ភាពបរាជ័យក៏អាចកើតឡើងចំពោះកូនស្របគ្នាដែរ។

# ហេនរី ឃិសស៊ិងចឺ

(Henry Kissinger, Federal Republic of Germany) គ.ស. ១៩២៣



ប្រសិនបើយើងប្រាថ្នាទទួលបានភាពជោគជ័យ យើងមិនអាចដំណើរជីវិតក្នុងលក្ខណៈធម្មតាៗបានឡើយ គឺយើងត្រូវព្យាយាមធ្វើគ្រប់យ៉ាងឲ្យបានល្អប្រសើរជាងអ្នកដទៃ។

ហែនរី ឃិសស៊ិងចឺ ឬដែលមានឈ្មោះជាភាសាអាល្លឺម៉ង់ ថា ហ៊ែន អាល់ហ្វ្រេត ឃិសស៊ិងចឺ ម្ចាស់ពានរង្វាន់ណូបែលផ្នែកសន្តិភាពនៅឆ្នាំ ១៩៧៣ គាត់កើតនៅថ្ងៃទី ២៧ ខែឧសភា គ្រិស្តសករាជឆ្នាំ ១៩២៣ នៅទីក្រុង ហ្វៀត ក្នុងត្រកូលជនជាតិ ជ្វីហ្វ ឪពុករបស់គាត់ជាគ្រូបង្រៀនថ្នាក់មធ្យមសិក្សាតែត្រូវបានគេបង្ខំឲ្យគាត់ចូលនិវត្តន៍មុនវ័យកំណត់នៅក្នុងឆ្នាំ ១៩៣៣ នៃគ្រិស្តសករាជ។ បន្ទាប់ពីនោះមកក្រុមគ្រួសាររបស់គាត់ត្រូវបង្ខំចិត្តផ្លាស់ទីលំនៅចេញពីប្រទេសអាល្លឺម៉ង់ នៅឆ្នាំ ១៩៣៨ ដើម្បីគេចពីភយន្តរាយដែលអាចនឹងកើតឡើងចំពោះក្រុមគ្រួសារ។

កុមារ ឃិសស៊ិងចឺ ជាសិស្សដែលរៀនពូកែជាមធ្យមដូចដែលគាត់បានពោលក្នុងកាលជាខាងក្រោយដូច្នេះថា«កាលគាត់នៅវ័យកុមារ

គាត់ចាប់អារម្មណ៍ចំពោះតែការលេងបាល់ទាត់តែប៉ុណ្ណោះ» ហើយគាត់អាចរៀនបានពិន្ទុល្អចំពោះតែមុខវិជ្ជាណាដែលទាក់ទងនឹងកីឡាប៉ុណ្ណោះ រីឯមុខវិជ្ជាដែលលំបាកបំផុតនោះគឺភាសាអង់គ្លេស។ នៅក្នុងសញ្ញាបត្រដែលទទួលបានពីសាលារៀននៅទីក្រុង ហ្វៀត ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៣៨ បញ្ជាក់ពីលទ្ធផលនៃការសិក្សារបស់គាត់ថា «សិស្សឈ្មោះ ហាញន៍ ឃិសស៊ិងចឺ ដែលបានមកចូលរៀនក្នុងសាលារៀនឯកជនជនជាតិ ជ្វីហ្វ រៀលស៊ូល័រ បានប្រឡងឡើងថ្នាក់ទី ៥ ជាប់ជាស្ថាពរ» គាត់បានពិន្ទុល្អក្នុងមុខវិជ្ជារូបវិទ្យានិងគីមីវិទ្យា ដោយសរុបរួមគ្រប់មុខវិជ្ជាទាំងអស់ពិន្ទុរបស់គាត់បានល្អគួរជាទីគាប់ចិត្ត។

ឃិសស៊ិងចឺ រៀនបានពិន្ទុល្អជាលំដាប់ក្នុងមុខវិជ្ជាប្រវត្តិសាស្ត្រ។ នៅទីបំផុត គាត់ក៏បានបញ្ចប់ការសិក្សាថ្នាក់បណ្ឌិតផ្នែកប្រវត្តិសាស្ត្រនៅសកលវិទ្យាល័យ ហាវ៍វើត ក្នុងឆ្នាំ ១៩៥៤។ បន្ទាប់ពីបានយល់ឃើញយ៉ាងច្បាស់ថា ការរស់នៅក្នុងសហរដ្ឋអាមេរិកប្រសិនបើយើងត្រូវការទទួលបាននូវភាពជោគជ័យនោះ យើងមិនអាចដំណើរជីវិតបែបធម្មតាៗបានឡើយ គឺត្រូវតែសង្វាតព្យាយាមធ្វើគ្រប់យ៉ាងឲ្យបានល្អប្រសើរជាងអ្នកដទៃ។ ហើយគាត់បានប្រកាន់ខ្ជាប់នូវគោលគំនិតបែបនេះក្នុងការដំណើរជីវិតជារៀងរហូតមក នៅទីបំផុតគាត់បានក្លាយជាអ្នកការទូតដ៏មានសមត្ថភាពបំផុតម្នាក់នៅក្នុងសតវត្សរ៍ទី២០។

# មេរៀនទី ២

«នៅក្នុងចិត្តស្អប់សាលារៀនរហូតក្លាយជាទីអស់សង្ឃឹម»

នៅក្នុងចំណោមអ្នកសិក្សាមួយចំនួនធំ ដែលក្លាយខ្លួនជាបុគ្គលអច្ឆរិយៈនាថ្ងៃអនាគតបាន មិនមែនមានត្រឹមតែអ្នកដែលសម្លឹងឃើញថា ការសិក្សាប្រៀបដូចជាថ្នាំដែលមានរស់ជាតិល្វីងនោះទេ គឺនៅមានអ្នកសិក្សាជាច្រើននាក់ទៀត ដែលស្ទើរតែទទួលយកមិនបានទាល់តែសោះនូវប្រព័ន្ធអប់រំរហូតក្លាយជាមានចិត្តស្អប់សាលារៀន។ ជាពិសេសពួកសិស្សដែលត្រូវស្នាក់នៅជាអចិន្ត្រៃយ៍ក្នុងអន្តេវាសិកដ្ឋាន ដែលត្រូវប្រើជីវិតប្រចាំថ្ងៃរួមគ្នា រស់នៅក្រោមបទបញ្ជានិងរបៀបវិន័យដ៏តឹងរ៉ឹង ហើយថែមទាំងមានគ្រូនៅចាំឃ្លាំមើលឥរិយាបថគ្រប់ពេលវេលា អ្វីៗទាំងនេះធ្វើឲ្យអ្នកសិក្សាខ្លះគិតថា សាលារៀនប្រៀបដូចជាមណ្ឌលកែប្រែដូច្នោះដែរ។

# វិនស្តុន ឆឺឈីល

( Vinston Churchill, England ) គ.ស. ១៨៧៤ - ១៩៦៥

ខ្ញុំទន្ទឹងរង់ចាំតែពេលវេលា
ដែលខ្ញុំត្រូវបានរួចផុតពីភាពជាទាសករ
ហើយបានវិលត្រឡប់ទៅផ្ទះ
«នោះក៏គឺថ្ងៃវិស្សមកាល»។



បទពិសោធជីវិតដ៏សែនលំបាក នៃអ្នកសិក្សាដូចដែលបានពោលមកខាងលើក៏ជាចំណែកមួយនៃជីវិតរបស់ ឆឺឈីល ផងដែរ ហើយវាគឺជាពេលវេលាដែលគាត់មិនអាចបំភ្លេចបានឡើយ។ នៅពេលគាត់មានវ័យ ៥០ ឆ្នាំប្លាយ គាត់បានសរសេរកំណត់ហេតុរំឭកដល់អតីតកាលនៃវ័យកុមាររបស់គាត់ថា«ពេលសម្លឹងមើលត្រឡប់ថយក្រោយទៅកាន់វ័យកុមារភាពរបស់ខ្ញុំ វាគឺជាពេលវេលាដ៏សែនឈឺចាប់និងគ្មានគុណតម្លៃអ្វីទាល់តែសោះក្នុងឆាកជីវិតរបស់ខ្ញុំ។ កាលនៅវ័យកុមារ ខ្ញុំគឺជាក្មេងដែលមានសេចក្ដីសុខ នៅពេលដែលខ្ញុំធំឡើងខ្ញុំមានអារម្មណ៍ថាខ្ញុំរឹតតែមានសេចក្ដីសុខទាំងផ្លូវកាយទាំងផ្លូវចិត្ត ប៉ុន្តែបើនិយាយពីជីវិតនៅក្នុងវ័យសិក្សារបស់ខ្ញុំវិញ វាប្រៀបបីដូចជាស្រមោលអន្ធការដ៏ខ្មៅងងឹតមកបិទបាំងរស្មីនៃជីវិតរបស់ខ្ញុំអ៊ីចឹង ពីព្រោះខ្ញុំត្រូវរងនូវសេចក្ដីទុក្ខវេទនាមួយ

ឆ្នាំហើយមួយឆ្នាំទៀត ថែមទាំងត្រូវប្រឈមមុខជាមួយការបង្ខិតបង្ខំ ការស្អប់ខ្ពើម បទបញ្ជា និងរបៀបវិន័យផ្សេងៗទាំងឥតប្រយោជន៍»។

វិនស្តុន ឆឺឈីល កើតនៅថ្ងៃទី ៣០ ខែវិច្ឆិកា គ្រិស្តសករាជ ១៨៧៤ នាប្រាសាទ ប្លែនហាំ ក្នុងមណ្ឌល អុកហ្វតឆៀរ៍ គាត់ប្រសូត្រក្នុងបន្ទប់របស់ម្តាយក្នុងខណៈដែលនាងកំពុងរៀបចំពិធីជប់លៀងស្រប ពេលដែលមានគភ៌គ្រប់ខែល្មមដល់ថ្ងៃប្រសូត្រតែម្តង។

វិស្តុន ឆឺឈីល ត្រូវបានបញ្ជូនឲ្យចូលរៀនក្នុងសាលារៀននៅជាអចិន្ត្រៃយ៍ពេលគាត់មានអាយុបានត្រឹមតែ ៧ ឆ្នាំដូចដែលគាត់ពោលថា «ការដែលស្នាក់នៅជាអចិន្ត្រៃយ៍នៅក្នុងសាលារៀន វាប្រៀបដូចជាឋាននរកដែលមានតែការវាយដោយខ្សែតី ធ្វើឲ្យរាងកាយវិនាសនិងនាំមកផ្តុំឲ្យរស់ឡើងវិញដើម្បីធ្វើទារុណកម្មបន្តទៀត» មធ្យោបាយដូចដែលបានពោលមកខាងលើ គឺជាវិធីអប់រំប្រៀនប្រដៅក្នុងប្រព័ន្ធសាលារៀនរបស់ប្រទេសអង់គ្លេសនៅក្នុងសម័យនោះ គេច្រើនប្រើមធ្យោបាយបែបនេះចំពោះកូនចៅពួកអ្នកមានទ្រព្យស្តុកស្តម្ភ។

ការប្រើវិធីបង្ខិតបង្ខំយ៉ាងធ្ងន់ធ្ងរដ៏គួរឲ្យភ័យខ្លាចបែបនេះ ពេលចូលរៀនដំបូងៗ ពួកសិស្សអាចមានអារម្មណ៍ថា រាងកាយនិងវិញ្ញាណរបស់ពួកគេកំពុងរងនូវការបែកធ្លាយ ប៉ុន្តែប្រសិនជាពួកគេអាចឆ្លងផុតដំណាក់កាលនេះបាន ពួកសិស្សទាំងនោះនឹងអង់អាចក្លាហាននិងអាចប្រឈមមុខនឹងសេចក្តីទុក្ខវេទនាគ្រប់យ៉ាងក្នុងឆាកជីវិតបាន។

សម្រាប់ ឆឺឈីល មិនមានការបង្ខិតបង្ខំឬការគំរាមកំហែងណាមួយដែលអាចឲ្យគាត់ធ្វើតាមអ្វីដែលគាត់មិនចូលចិត្តបានឡើយ ទោះជាបណ្ដាគ្រូទាំងឡាយព្យាយាមរិះរកគ្រប់មធ្យបាយ ដើម្បីធ្វើទារុណកម្មគាត់យ៉ាងណាក៏ដោយ ដូចដែលគាត់បានពោលបន្តទៀតថា «ប្រសិនជាខ្ញុំពុំមានចំណាប់អារម្មណ៍ក្នុងរឿងអ្វីមួយ ឬខ្ញុំយល់ឃើញថាកិច្ចការនោះជារឿងឥតប្រយោជន៍មិនអាចញ៉ាំងឲ្យ (កើតចិន្តនាការ) ដុះគំនិតអ្វីចេញមកបាននោះទេ ខ្ញុំមិនអាចរៀនយកនូវបំណិននោះៗបានឡើយ អស់រយៈពេល ១២ ឆ្នាំដែលខ្ញុំរៀនក្នុងសាលារៀន គ្មានគ្រូណាម្នាក់អាចបង្រៀនខ្ញុំឲ្យចេះសរសេរភាសាឡាតាំងបានត្រឹមត្រូវសូម្បីមួយប្រយោគសោះឡើយ»។

គាត់មានអារម្មណ៍ធុញទ្រាន់ចំពោះការរៀនភាសាឡាតាំង តាំងពីពេលដែលគាត់មានអាយុ ៧ ឆ្នាំមកម្ល៉េះ គឺពេលដែលគាត់បានចូលរៀននៅសាលា ហ្សិនត៍ជែមស៍។ សាលារៀន ហ្សិនត៍ជែមស៍ ជាសាលាដែលស្អាតបំផុត ថ្លៃបំផុត និងល្អបំផុតមួយនៅក្នុងប្រទេសអង់គ្លេសនាសម័យនោះ ជាសាលារៀនដែលប្រើប្រាស់រូបបែបដូចសាលារៀន អ៊ីតាន់ ដ៏ល្បីឈ្មោះដែរ ហើយក៏ជាសាលារៀនត្រៀមដើម្បីឲ្យសិស្សបានចូលរៀននៅសាលា អ៊ីតាន់ នាថ្ងៃអនាគតផងដែរ។

នៅក្នុងបន្ទប់រៀននីមួយៗ មានសិស្សត្រឹមតែដប់នាក់ប៉ុណ្ណោះ មានភ្លើងអគ្គិសនីប្រើប្រាស់ (ក្នុងសម័យនោះ វាមិនមែនជារឿងធម្មតាឡើយ) មានស្រះហែលទឹក មានទីលានបាល់ទាត់ មានកន្លែងលេង

កីឡាត្រីកឃីតដ៏ធំទូលាយហើយថែមទាំងមានដំណើរទស្សនកិច្ចសិក្សាពីរទៅបីដងក្នុងមួយឆមាស។ បណ្ដាគ្រូៗពាក់អាវធំ ពាក់មួក បារ៉ែតត៍ ហើយមានព្រះវិហារជារបស់សាលារៀនផ្ទាល់។ ពួកសិស្សមិនត្រូវបានអនុញ្ញាតឲ្យយកចំណីអាហារមកពីផ្ទះឡើយ គឺខាងសាលារៀនជាអ្នកទទួលខុសត្រូវទាំងអស់។

ឆឺឈើល ត្រូវបានម្ដាយជាអ្នកនាំទៅចូលរៀននៅសាលានេះ គាត់បានរំឭកដល់ហេតុការណ៍ក្នុងពេលនោះថា «ពួកយើងបានអង្គុយផឹកតែជាមួយលោកនាយកសាលា ហើយម្ដាយរបស់ខ្ញុំជជែកសន្ទនាជាមួយគាត់យ៉ាងជក់ចិត្ត តែខ្ញុំបែរជាមានអារម្មណ៍ភ័យខ្លាច ព្រោះធ្វើឱ្យកែវទឹកធ្លាក់បែក។ នេះជាការចាប់ផ្ដើមនៃប្រផ្នូលអាក្រក់សម្រាប់ខ្ញុំ ហើយបានគិតដដែលៗនៅក្នុងចិត្តប្រកបដោយភាពភ័យព្រួយថា តើខ្ញុំត្រូវទុកចោលឲ្យនៅម្នាក់ឯងក្នុងអគារដ៏ធំល្វឹងល្វើយ និងគួរឲ្យព្រឺសម្បុរជាមួយមនុស្សប្លែកមុខទាំងនេះមែនទេ ដោយខ្ញុំទើបតែមានអាយុ ៧ ឆ្នាំហ្នឹង»។

ពេលម្ដាយរបស់គាត់ចាកចេញទៅ លោកនាយកសាលាបាននាំគាត់ទៅជួបគ្រូប្រចាំថ្នាក់ម្នាក់ ហើយគ្រូរូបនោះនិយាយថា«ឯងមិនធ្លាប់បានរៀនភាសាឡាតាំងសោះឡើយ តើមែនទេ?» បន្ទាប់មកគ្រូក៏បានបង្រៀនអំពីវេយ្យាករណ៍ខ្លះៗដល់គាត់ ហើយគ្រូនិយាយថា «ឯងត្រូវទន្ទេញពាក្យគុណនាមរបស់តុឲ្យបានក្នុងរយៈពេលកន្លះម៉ោង» រួចចាកចេញទៅ លុះកន្លះម៉ោងក្រោយមកគ្រូបានចូលមកក្នុងថ្នាក់វិញហើយឲ្យឆឺឈើល សូត្រមេរៀនឲ្យស្ដាប់ ចំណែក ឆឺឈើល ក៏អាចសូត្របាន។

គាត់បានរំឭកដល់ហេតុការណ៍ក្នុងពេលនោះថា «ខ្ញុំបានសូត្រមេរៀនតាមដែលគ្រូបញ្ជា មើលទៅគ្រូហាក់ពេញចិត្តយ៉ាងខ្លាំង ទើបខ្ញុំកើតសេចក្ដីក្លាហានហាមាត់និយាយចេញមកសួរលោកគ្រូថា មេរៀនដែលលោកគ្រូដាក់ឲ្យខ្ញុំទន្ទេញគឺជាអ្វី? គ្រូក៏បានអធិប្បាយយ៉ាងច្រើនបែបច្រើនយ៉ាង រហូតមកដល់ប្រយោគចុងក្រោយគាត់បាននិយាយថា "ឯងនឹងត្រូវប្រើវាជាក់ជាមិនខាន បើសិនជាឯងនិយាយជាមួយតុ ខ្ញុំតបទៅកាន់គ្រូវិញភ្លាមថា ខ្ញុំគង់គ្មានថ្ងៃនិយាយជាមួយតុនោះទេ តែខ្ញុំនឹកចម្លែកក្នុងចិត្តយ៉ាងខ្លាំងពេលឮគ្រូតបមកវិញថា បើឯងនៅតែរបុិលរបុ៉ចរបៀបនេះ ថ្ងៃក្រោយត្រូវដាក់ទណ្ឌកម្មជាមិនខាន អញប្រាប់ឲ្យហើយនេះគឺជាចម្លើយចុងក្រោយរបស់គ្រូ»។

នេះគឺជាការចាប់ផ្ដើមមានប្រផ្នូលអាក្រក់ក្នុងថ្ងៃចូលរៀនដំបូងសម្រាប់ ឆឺឈីល។ គាត់រៀននៅក្នុងសាលារៀនដំបូងនៃឆាកជីវិតរបស់គាត់បានតិចតួចណាស់ តែគាត់អាចចងចាំនូវការធ្វើទារុណកម្មដែលតែងតែកើតឡើងជាញឹកញាប់ «ការដាក់ទណ្ឌកម្មដែលសាលារៀននេះបានធ្វើចំពោះសិស្សនោះ វាពិតជាធ្ងន់ធ្ងរជាងមណ្ឌលកែប្រែនានាក្នុងប្រទេសអង់គ្លេសទៅទៀត ពួកយើងទាំងអស់គ្នាត្រូវបាននាំចូលទៅឲ្យនៅរួមគ្នាក្នុងបណ្ណាល័យក្នុងមួយខែម្ដងទៅពីរដង ពួកសិស្សដែលមានកំហុសក៏ត្រូវបានចាប់ដាក់ឲ្យនៅក្នុងបន្ទប់ក្បែរៗគ្នា ហើយត្រូវបានវាយដោយសិស្សដែលមានមាឌធំជាងចំនួនពីរនាក់ រហូតហូរឈាមដាបខ្លួនក្នុងខណៈដែលពួកយើងអង្គុយស្ដាប់ឮនូវសំឡេងស្រែកទ្រហោយំ ដែល

លាន់ចេញពីបន្ទប់នោះទាំងខ្លួនប្រាណញ័រចំប្រប់»។ ឆឺឈឺល ក៏ត្រូវរង ទារុណកម្មបែបនោះញយៗដែរ ព្រោះគេមិនព្រមរៀននូវអ្វីដែលគួររៀន។

តែការដាក់ទណ្ឌកម្មចំពោះ ឆឺឈឺល មិនបានលទ្ធផលអ្វីឡើយ។ មានថ្ងៃមួយ គេបានយកមួកចំបើងរបស់នាយកសាលាមកជាន់ដោយជើងដើម្បីសម្តែងការមិនពេញចិត្ត ការធ្វើដូច្នោះរឹតតែញ៉ាំងស្ថានការណ៍ឲ្យអាក្រក់ឡើងថែមទៀត។ សេចក្តីស្អប់ខ្ពើមសាលារៀននិងសេចក្តីខ្លាចរអារឹតតែកើនឡើងទ្វេដង «ខ្ញុំសែនស្អប់ខ្ពើមសាលារៀននេះខ្លាំងណាស់ ការដែលខ្ញុំស្នាក់នៅ និងរៀនប្រកបដោយភាពភ័យខ្លាចអស់រយៈពេលពីរឆ្នាំកន្លងមកនេះ មិនបានទទួលលទ្ធផលអ្វីល្អប្រសើរឡើយ និងថែមទាំងមិនចូលចិត្តលេងកីឡាទៀត គឺខ្ញុំទន្ទឹងរង់ចាំតែថ្ងៃវិស្សមកាលមកដល់ជាពេលវេលាដែលត្រូវបានរួចផុតពីភាពជាទាសករ ហើយបានវិលត្រឡប់ទៅផ្ទះវិញ»។

ប៉ុន្តែក្រោយពេលវិស្សមកាល ឆឺឈឺល បានវិលត្រឡប់ទៅស្នាក់នៅឯផ្ទះ។ ឪពុកម្តាយរបស់គេមិនបានសង្កេត ឬចាប់អារម្មណ៍ចំពោះក្តីទុក្ខវេទនាដែលគាត់បានជួបប្រទះឡើយ នៅពេលដែលឪពុកម្តាយបញ្ជូនគេត្រឡប់ទៅកាន់សាលាដែលប្រៀបដូចជាឋាននរកនៅឯ ស៊ិនត៍ជែមត៍វិញ គេកើតទុក្ខយ៉ាងខ្លាំង។ គេចាប់ផ្តើមមានអាការៈខ្សោយទៅៗនិយាយតិចៗ (ខ្សាវៗ) និងនិយាយតដិតខ្លាំងឡើងៗ។ រយៈពេលពីរឆ្នាំកន្លងផុតទៅរាងកាយរបស់គេក៏មានសភាពទ្រុឌទ្រោមចុះខ្សោយមិនអាចធន់នឹងការវាយដំបាន ហើយបានដួលសន្លប់បាត់ស្មារតី ទើបឪពុកម្តាយរបស់

គេមកទទួលយកទៅនៅឯផ្ទះវិញ។ ទោះបានត្រឡប់ទៅផ្ទះវិញក៏ដោយ ប៉ុន្តែស្លាកស្នាមនៃការឈឺចាប់ ដោយការធ្វើទារុណកម្មបានដក់ជាប់ក្នុងចិត្តរបស់គេពិបាកនឹងបំភ្លេចបានណាស់។ ដោយសារឥទ្ធិពលនៃការធ្វើទារុណកម្ម ឆឺឈីល មិនអាចរៀនបានល្អឡើយ ហើយតែងតែប្រឡងធ្លាក់ម្តងហើយម្តងទៀត ប៉ុន្តែមានរឿងមួយដែលសាលារៀនបានឲ្យដល់គាត់និងបានក្លាយជាលទ្ធផលល្អនាថ្ងៃអនាគតនោះគឺ គាត់អាចអត់ធ្មត់ចំពោះសេចក្តីទុក្ខលំបាកដ៏ធ្ងន់ធ្ងរនឹងអំពើអយុត្តិធម៌បានមួយកម្រិត តែអ្វីដែលគួរឱ្យស្តាយអស់មួយជីវិតនោះគឺ គាត់មិនបានទទួលនូវការសិក្សាដូចដែលមនុស្សទូទៅបានទទួលឡើយ។

ភាពបរាជ័យក្នុងការសិក្សារបស់ ឆឺឈីល នៅមានមូលហេតុមួយទៀត ហើយនោះក៏តែងតែកើតឡើងចំពោះសិស្សានុសិស្សចំនួនមិនតិចឡើយក្នុងសម័យបច្ចុប្បន្ននេះគឺ គាត់មិនចាប់អារម្មណ៍ក្នុងការលេងកីឡា ហើយមុខវិជ្ជាណាដែលទាក់ទងនឹងកីឡាគាត់បរាជ័យទាំងអស់។ គាត់ស្អប់កីឡាគ្រីកឃីត និងភាសាឡាតាំងប្រហែលគ្នា ហើយមិនដែលមានចំណាប់អារម្មណ៍ចំពោះកីឡាបាល់ទាត់ដែលត្រូវគេចាត់ថា ជាប្រភេទកីឡាដ៏ពេញនិយមរបស់ប្រទេសអង់គ្លេស ហើយក៏មិនដែលលេងកីឡាថែននីសដែលជាប្រភេទកីឡារបស់ពួកអភិជនដែរ។ ប៉ុន្តែគាត់ចូលចិត្តហែលទឹកនិងជិះសេះ។

បញ្ហាមួយដែលគេតែងតែលើកជាសំណួរមកជជែកសួរ នោះគឺការលេងកីឡានៅតាមសាលារៀនទូទៅគួរចាត់ទុកថាជាផ្នែកមួយនៃការ

HUN SEN LIBRARY

សិក្សាយ៉ាងពិតប្រាកដឬគ្រាន់តែជាមធ្យោបាយដែលពួកសិស្សានុសិស្ស ប្រើសម្រាប់បន្ធូរបន្ថយនូវភាពតានតឹងបន្ទាប់ពីសិក្សា?

នៅក្នុងសម័យ ឆឺឈីល កីឡាជាវិជ្ជាមួយដែលសំខាន់ជាទីបំផុត ក្នុងប្រព័ន្ធអប់រំរបស់ប្រទេស អង់គ្លេស ប៉ុន្តែជាទស្សនៈផ្ទាល់ខ្លួនរបស់គាត់យល់ឃើញថា ការលេងកីឡាជាកំហុសដ៏ធំធេងរបស់សាលារៀន ក្នុងសម័យនោះទៅវិញ។

# ចច ប៊ីណាត សវ៍

( George Bernard Shaw, Ireland ) គ.ស. ១៨៥៦-១៩៥០

គ្រូដែលមកបង្រៀនសុទ្ធតែមិនបានរៀនសូត្រ កោសល្យឲ្យបានសក្តិសមជាគ្រូបង្រៀនឡើយ មកបង្រៀនដើម្បីដូរយកប្រាក់ប៉ុណ្ណោះ។



ចច ប៊ីណាត សវ៍ ក៏ជាបុគ្គលម្នាក់ដែលបានរិះគន់ប្រព័ន្ធអប់រំទាំងថ្នាក់វិទ្យាល័យ និងមហាវិទ្យាល័យនៃប្រទេសអង់គ្លេស យ៉ាងពេញទំហឹងដែរ បើទោះបីជាគាត់មិនធ្លាប់បានជួបប្រទះនូវបទពិសោធជីវិតដ៏អាក្រក់ដូចដែល ឆើឈីល បានជួបក៏ដោយ។ គាត់កើតនៅថ្ងៃទី ២៦ កក្កដា គ.ស. ១៨៥៦ នៅទីក្រុង ដាប់លិន។ គាត់បានទទួលការសិក្សាគ្រាដំបូងពីសំណាក់អ៊ំប្រុសខ្លួន ដែលជាអាចារ្យប្រចាំនៅវិហារកាតូលិក "ឆឺច អហ្វ អែងគ្លិកែន" បន្ទាប់ពីនោះមកគាត់បានចូលរៀននៅសាលាបានរយៈពេលតែ ៤ ឆ្នាំប៉ុណ្ណោះ។ ហើយនៅពេលដែលគាត់មានអាយុ ១៦ ឆ្នាំ គាត់យល់ឃើញដោយរួមថា «ប្រព័ន្ធនៃការអប់រំទាំងអស់គឺជាការបោកបញ្ឆោត ពីព្រោះថា បន្ទាប់ពីចំណាយពេលរៀនអស់រយៈពេល ១០ ឆ្នាំមនុស្សទាំងឡាយនៅតែមិនអាចប្រើប្រាស់សក្តានុពលរបស់ខ្លួនបានត្រឹមត្រូវឡើយ។ ភាពរឹងមាំ ភាពក្លាហានផ្នែករាងកាយពួកគេអាច

ទទួលបានមកពីវិស័យកីឡា ដែលបានបង្រៀននៅតាមសាលាក៏ពិតមែន តែសេចក្តីក្លាហានខាងផ្លូវចិត្តវិញ ត្រូវបានរសាត់ខ្ចាត់ខ្ចាយចេញពីចិត្តវិញ្ញាណអស់រលីងតែម្តង»។

សរ៍ បានចូលរៀននៅសាលា វេសលៀន ខននេកសិនណាល់ ជាជាលើកដំបូងក្នុងទីក្រុង ដាប់លិន គាត់រៀនភាសាឡាតាំងបានល្អប្រសើរជាងមិត្តរួមថ្នាក់ដទៃទៀត ដោយសារគាត់ធ្លាប់បានរៀនជាមួយអ៊ំប្រុសរបស់គាត់មុនពេលចូលរៀននៅសាលាបានច្រើនគួរសមដែរ។ ប៉ុន្តែគាត់មិនចូលចិត្តសាលារៀនឡើយ ព្រោះគាត់គិតថាសាលារៀនមិនល្អគ្រប់គ្រាន់សម្រាប់គាត់ទេ ដូចដែលគាត់បានពោលជាខាងក្រោយថា «បន្ទប់រៀនធំពេក ហើយគ្រូដែលមកបង្រៀនមិនបានទទួលការអប់រំពីវិធីបង្រៀនឲ្យបានសមរមជាគ្រូឡើយ មកបង្រៀនដើម្បីប្តូរយកតែប្រាក់មុននឹងបានត្រូវគេផ្លាស់ឲ្យទៅធ្វើជាអាចារ្យ»។

នៅក្នុងសាលា សរ៍ មិនបានរៀនអ្វីឡើយ គាត់ជាក្មេងខ្ជិលច្រអូសរហូតធ្វើឲ្យមុខវិជ្ជាភាសាឡាតាំងរបស់គាត់ខ្សោយជាងមិត្តរួមថ្នាក់។ នៅទីបំផុត គាត់ត្រូវបានបញ្ជូនឲ្យទៅរៀននៅសាលាឯកជនមួយកន្លែងដែលជាសាលារៀនបង្រៀនបែបអនុវត្តផ្ទាល់ឬបែបនិទស្សន៍ ដែលមានសុទ្ធតែសិស្សកាតូលិកទាំងអស់ ហើយគាត់ក៏មិនចូលចិត្តសាលារៀននេះទៀតដោយសារតែគាត់ជាប្រូតេស្តង់ (គ្រិស្ទៀននិកាយប្រូតេស្តង់) គាត់បានបន្តរៀននៅទីនោះមិនយូរប៉ុន្មាន ក៏ត្រូវបានផ្លាស់ឲ្យទៅរៀននៅសាលារដ្ឋម្តងទៀត។ គាត់បានរិះគន់សាលារៀនថ្មីរបស់គាត់ថា «ជាសាលារៀន

ដែលសក្តិសមសម្រាប់សិស្ស ដែលមានឪពុកម្តាយជាអ្នកក្រដូចរូបគាត់ ដែលគ្មានប្រាក់បញ្ជូនកូនទៅរៀននៅមហាវិទ្យាល័យទំនើបបាន ឪពុកម្តាយរបស់សិស្សពួកនេះមានបំណងឲ្យកូនបានរៀនត្រឹមតែបញ្ចប់ថ្នាក់ ហើយចេញមកអាចធ្វើជាអ្នកលក់ដូរបាន គឺមិនបានចង់ឲ្យក្លាយជាអ្នកប្រាជ្ញរាជបណ្ឌិតអ្វីនោះទេ»។

នៅក្នុងសំបុត្រនិងអត្តជីវប្រវត្តិរបស់ សរ៍ បានចារទុកថា «គាត់ជាក្មេងដែលពូកែអៀនខ្មាស និងតែងតែគេចមុខចេញពីហ្វូងមនុស្សជានិច្ច លុះដល់គាត់មានវ័យ ៨០ ឆ្នាំគាត់បានសរសេរបន្តទៀតថា «ខ្ញុំមិនធ្លាប់បាននឹកស្រមៃសោះឡើយថា ជីវិតរបស់ខ្ញុំត្រូវបានព្រះជាម្ចាស់ទ្រង់ប្រោសប្រទានកំណត់ឲ្យបានក្លាយជាមនុស្សល្បីល្បាញដូច្នេះ ដោយខ្ញុំធ្លាប់តែជាមនុស្សពូកែអៀនខ្មាសរកលេខដាក់គ្មាន» ហើយអ្វីដែលជាមូលហេតុធំធ្វើឲ្យគាត់ក្លាយជាមនុស្សដែលពូកែអៀនខ្មាសនោះគឺ គាត់ទម្លាក់កំហុសទៅលើឪពុកទាំងស្រុងថា ដោយសារតែឪពុករបស់គាត់ជាអ្នកប្រមឹកទើបធ្វើឱ្យគ្រួសាររបស់គាត់ត្រូវរស់នៅក្នុងភាពក្រីក្រនិងឯកា។

សរ៍ បានពោលទៀតថា «គាត់ចងចាំមិនបានទេថាតើកាលដែលគាត់នៅក្មេងធ្លាប់បានទៅសួរសុខទុក្ខសាច់ញាតិណាម្នាក់ដែរឬទេ ទម្រាំតែឪពុកអាចឈប់ផឹកស្រាបាន គឺយឺតពេលបាត់ទៅហើយដែលនឹងត្រូវស្តារជីវភាពក្នុងគ្រួសារឲ្យបានល្អប្រសើរឡើង»។ សរ៍ ធំដឹងក្តីឡើងមានមកជាមួយនឹងភាពអៀនខ្មាសជាអតិបរមា ហើយមិនដឹងថាត្រូវបដិបត្តិខ្លួនយ៉ាងដូចម្តេចនៅក្នុងសង្គមទើបត្រឹមត្រូវ។

គាត់បានសរសេរនៅក្នុងសំបុត្រមួយច្បាប់ក្នុងឆ្នាំ ១៩១២ ថា «ក្រៅពីជាមនុស្សដែលពូកែខ្លាសអៀនហើយ គាត់ជាមនុស្សកំសាកញីទៀតផង វាប្រហែលជាគ្មាននរណានឹកស្មានដល់ឡើយថា ខ្ញុំជាមនុស្សពូកែអៀន ហើយថែមទាំងជាមនុស្សកំសាកញីកម្រិតណានោះ»។

ប៉ុន្តែគាត់ក៏បានសរសេរកំណត់ហេតុនៃហេតុការណ៍មួយ ដែលបានជួបប្រទះនៅសាលារៀន ក្នុងនោះស្ទើរតែមិនអាចនិយាយបានទេថាគាត់ជាមនុស្សកំសាកញីឡើយ «មានសិស្សម្នាក់នៅក្នុងចំណោមពួកយើងបានធ្វើខុសវិន័យសាលា បណ្តាគ្រូៗក៏បានហៅពួកយើងឲ្យតម្រង់ជួរ ហើយសាកសួរម្នាក់ម្តងតាមលេខរៀងថាឯងជាអ្នកធ្វើខុសមែនទេ? បើឯងធ្វើខុសនឹងរកអ្នកផ្សេងឲ្យមកទទួលទោសជំនួស ខ្ញុំក៏បានបដិសេធមិនឆ្លើយនឹងសំណួរ ដោយគិតតាមហេតុផលថា គ្មានច្បាប់ឯណាយកអ្នកដទៃមកទទួលទោសជំនួសខ្លួនបាននោះទេ ហើយការសាកសួរនេះវាហាក់ដូចជាការដាក់អន្ទាក់បញ្ឆោតដល់សិស្សប៉ុណ្ណោះ បន្ទាប់មកគាត់ក៏ប្រាប់មិត្តភក្តិពីអន្ទាក់នេះ ទីបំផុតគ្មានសិស្សណាទទួលទោសទេ»។

កាលនៅវ័យកុមារ ចច ប៊ីណាត សវ៍ មិនអាចសម្របខ្លួនតាមប្រព័ន្ធអប់រំរបស់សាលាបានឡើយ លុះគាត់មានវ័យចម្រើនធំឡើងគាត់ក៏នៅតែជាមនុស្សខ្វះខាតនូវសញ្ជាតិញ្ញាណជាបុគ្គលដែលមានការប្រកួតប្រជែងខ្ពស់។ ពេលគាត់មានអាយុ ១៥ ឆ្នាំបានចូលធ្វើការក្នុងក្រុមហ៊ុនទិញលក់ដីមួយកន្លែង ប៉ុន្តែគាត់ត្រូវបរាជ័យក្នុងការងារទៀត គាត់បានពោលក្នុងកាលជាខាងក្រោយថា «ខ្ញុំពុំមានសញ្ជាតិញ្ញាណជាអ្នកប្រកួត

ប្រជែងសូម្បីបន្តិចឡើយ ខ្ញុំមិនធ្លាប់ប្រាថ្នាលាភសក្ការៈ យសស័ក្តិ ការសរសើរ ដូច្នេះហើយបានជាខ្ញុំមិនចាប់អារម្មណ៍ក្នុងការប្រកួតប្រជែងដណ្តើមយកឈ្នះចាញ់ជាមួយបុគ្គលដទៃណាឡើយ ក៏ប៉ុន្តែប្រសិនជាខ្ញុំឈ្នះ ខ្ញុំក៏មិនចង់ឃើញអ្នកដទៃអស់សង្ឃឹមដែរ តែបើសិនជាខ្ញុំចាញ់វិញនោះ ខ្ញុំក៏មិនអស់សង្ឃឹមដែរ»។

ទោះជាគាត់មិនបានទទួលការអប់រំនៅសាលារៀនច្រើនក៏ដោយ តែគាត់អាចសិក្សាស្វែងយល់ដោយខ្លួនឯងបានយ៉ាងល្អប្រពៃ។ គាត់អាចអភិវឌ្ឍទេពកោសល្យក្នុងការមើលពីខ្លឹមសារពិតរបស់មនុស្សជាតិ និងហេតុផលដែលនៅពីក្រោយព្រឹត្តិកម្មផ្សេងៗរបស់មនុស្ស និងអាចប្រឌិតចេញជាទ្រឹស្តីបានយ៉ាងច្រើននិងមានអត្ថន័យបែបស៊ីជម្រៅ។ នៅក្នុងវ័យប្រមាណជា ៥០ ឆ្នាំប្លាយ គាត់បានសរសេរកំណត់ហេតុទុកថា «គ្មាននរណាម្នាក់បានចាប់អារម្មណ៍ទេថា ខ្ញុំមានទេពកោសល្យអ្វី ហើយខ្ញុំនឹងក្លាយជាអ្វីនៅថ្ងៃអនាគត សូម្បីខ្លួនខ្ញុំផ្ទាល់ក៏មិនដឹងដែរថា តើខ្ញុំមានភាពខុសគ្នាពីអ្នកដទៃត្រង់ណា ហើយអ្វីដែលរឹតតែអាក្រក់ជាងនេះនោះគឺ ខ្ញុំគ្មានជំនឿលើខ្លួនឯងដូចដែលជនដទៃគេមានសូម្បីបន្តិចឡើយ។

# ហ្វ្រង់ ខាហ្វខា

( Franz Kafka, Czech Republic ) គ.ស. ១២៨៨៣ - ១៩២៤

បរិស្ថានជុំវិញខ្លួនរបស់យើង
មិនថាផ្ទះសម្បែងឬសាលារៀនទេ
សុទ្ធតែមានចំណែកធ្វើឲ្យទេពកោសល្យ
របស់មនុស្សសាបសូន្យបានទាំងអស់។



កាលនៅវ័យសិក្សា កវីល្បីឈ្មោះលោក ខាហ្វខា មានសេចក្តីភ័យខ្លាចដិតដាមជាប់ក្នុងអារម្មណ៍ខ្លួនជានិច្ច ជាមនុស្សពូកែខ្មាសអៀនទន់ជ្រាយ ពុំសូវមានទំនាក់ទំនងជាមួយអ្នកដទៃ ហើយជាមនុស្សដែលស្រឡាញ់ភាពយុត្តិធម៌ដក់ជាប់ក្នុងបេះដូងជានិរន្តរ៍។ គាត់កើតនៅថ្ងៃទី៣ កក្កដា គ.ស. ១៨៨៣ នាទីក្រុង ប្រាក ជាកូនរបស់អាជីវករម្នាក់ (អ្នកលក់គ្រឿងទេស) គាត់មានអាយុមិនទាន់នឹងបានគ្រប់ ៦ ឆ្នាំបរិបូរផង ឪពុករបស់គាត់បានបញ្ជូនឲ្យចូលរៀននៅសាលាក្នុងភូមិមួយ។ នៅពេលចូលរៀនដំបូងៗ ស្ត្រីចុងភៅដែលធ្វើការក្នុងផ្ទះរបស់គាត់ជាអ្នកជូនគាត់ទៅសាលាជារៀងរាល់ថ្ងៃ ខណៈដែលជូនគាត់ទៅរៀនម្តងៗនាងតែងតែបន្លាចគាត់ឲ្យខ្លាចរហូតព្រឺសម្បុរ។ ភាពភ័យខ្លាចដែលដិតដាមជាប់ក្នុងចិត្តរបស់ ខាហ្វខា នេះបានផុសចេញជាសាច់រឿងជាច្រើនតាមរយៈការនិពន្ធរបស់គាត់។

នៅក្នុងសំបុត្រមួយច្បាប់គាត់បានរំឭកដល់ហេតុការណ៍នេះថា «ពេលឈានជើងចេញផុតពីផ្ទះកាលណា នាងតែងតែប្រាប់ខ្ញុំថា នាងនឹងនិយាយប្រាប់គ្រូថា ពេលនៅផ្ទះខ្ញុំជាក្មេងកំហូចកម្រិតណា ជាក្មេងអាក្រក់ជួជាតិ ជារៀងរាល់ព្រឹកនាងតែងតែនិយាយដូច្នេះជាមួយខ្ញុំរហូតក្លាយជាការឈឺចាប់យ៉ាងក្រៃលែង កាលពីដំបូងឡើយខ្ញុំបានអង្គុយគិតពិចារណាថា ខ្ញុំមិនមែនជាក្មេងកំហូច និងមិនមែនជាក្មេងអាក្រក់ជួជាតិដូចដែលនាងបាននិយាយឯណា គ្រាន់តែនៅពេលខ្លះខ្ញុំអាចជាក្មេងឌឺឥតប្រយោជន៍ របិលរប៉ូច និងជាក្មេងក្រេវក្រោធ ប៉ុន្តែខ្ញុំគិតថាគ្រូអាចជួយអប់រំខ្ញុំឲ្យក្លាយជាក្មេងដែលមានចរិតល្អប្រសើរឡើងបាន ខ្ញុំប្រាកដក្នុងចិត្តដូច្នេះទើបខ្ញុំមិនខ្វល់នឹងសម្ដីគំរាមរបស់ស្ត្រីចុងភៅនោះ ប៉ុន្តែនៅក្នុងខណៈពេលកំពុងតែធ្វើដំណើរ ខ្ញុំតែងមានអារម្មណ៍ថាហេតុអ្វីផ្លូវទៅកាន់សាលារៀនឆ្ងាយយ៉ាងនេះ តើអាចនឹងមានរឿងអ្វីកើតឡើងចំពោះខ្ញុំដែរឬទេ ពេលធ្វើដំណើរកាន់តែជិតដល់សាលា ខ្ញុំក៏ចាប់ផ្ដើមត្រិះរិះថា ស្ត្រីចុងភៅម្នាក់នេះមើលទៅហាក់គួរឲ្យគោរពរាប់អាន ហើយគាត់គ្រាន់តែជាស្ត្រីធម្មតាម្នាក់ប៉ុណ្ណោះ គាត់នឹងមិននិយាយប្រាប់គ្រូដែលជាបុគ្គលជាទីគោរពដ៏ខ្ពង់ខ្ពស់របស់មនុស្សទូទៅក្នុងលោកនេះទេ»។

ពេលពួកគាត់កាន់តែចូលកៀកជិតដល់សាលា ភាពភ័យខ្លាចរបស់គាត់កាន់តែកើនឡើងទ្វេដង គាត់ប្រាប់បន្តទៀតថា «ពេលក្លោងទ្វាសាលាស្ថិតនៅចំពីមុខកាលណា ក្ដីភ័យខ្លាចនិងភាពរអាដោយសារតែពាក្យបន្លាចនោះ ក៏ចូលមកសង្កត់សង្កិនផ្លូវចិត្តរបស់ខ្ញុំឲ្យញាប់ញ័រដែរ។

ក្នុងខណៈនោះ សាលារៀនក៏ប្រែក្លាយទៅជាស្ថានទីដ៏គួរឲ្យខ្លាចសម្រាប់ខ្ញុំស្របពេលនោះដែរ ស្ត្រីជាចុងភៅក៏រឹតតែធ្វើឲ្យខ្ញុំភ័យខ្លាចកាន់តែខ្លាំងរហូត ខ្ញុំសុំអង្វរកនាងតែនាងមិនព្រមឈប់ ខ្ញុំបានបង្អង់ដំណើរហើយសុំអភ័យទោសនាង តែនាងនៅតែបន្តអូសខ្ញុំឲ្យដើរចូលក្នុងសាលា ខ្ញុំគំរាមនាងថា ខ្ញុំនឹងសងសឹកនាងវិញមិនខានទេ ដោយខ្ញុំនឹងនិយាយរឿងនេះប្រាប់ឪពុកម្តាយរបស់ខ្ញុំ តែនាងបែរជាសើចទៅវិញ (ក្នុងខណៈនោះខ្ញុំគិតថានាងមានអំណាចបំផុត) ខ្ញុំបានយកដៃចាប់តោងទ្វារតូបលក់អីវ៉ាន់ចាប់ហួយនិងតោងសំពត់របស់នាង ក្រាញមិនព្រមដើរទៅមុខឡើយបើសិនជានាងមិនព្រមអភ័យទោសដល់ខ្ញុំ តែនាងនៅតែបន្តចាប់អូសខ្ញុំឲ្យដើរទៅមុខព្រមទាំងនិយាយថា នឹងប្រាប់គ្រូនូវអ្វីដែលខ្ញុំបានធ្វើដាក់គាត់នាពេលនេះផងដែរ។

ពុទ្ធោ! ទោសកាន់តែបន្ថែម។ ខ្ញុំបានប្រទាញប្រទង់ជាមួយគាត់រហូតដល់ស្នូរជួងបានបន្លឺឡើងនាវេលាម៉ោង ៨ ព្រឹក ដែលជាពេលត្រូវចូលរៀន ហើយខ្ញុំនិងស្ត្រីចុងភៅនោះបានរត់យ៉ាងលឿនព្រោះខ្លាចចូលរៀនមិនទាន់ ពេលក្នុងខណៈដែលកំពុងរត់បណ្តើរខ្ញុំនឹកគិតបណ្តើរថាតើនាងនឹងនិយាយប្រាប់គ្រូនូវរឿងរ៉ាវទាំងអស់ ដូចដែលនាងបានគំរាមខ្ញុំដែរឬទេ? ការពិត នាងមិនបាននិយាយប្រាប់គ្រូនូវរឿងរ៉ាវដូចដែលនាងធ្លាប់បានគំរាមខ្ញុំនោះទេ ប៉ុន្តែនាងព្យាយាមធ្វើឥរិយាបថបែបនោះដាក់ខ្ញុំឲ្យខ្ញុំយល់ថាថ្ងៃណាមួយនាងនឹងនិយាយប្រាប់គ្រូជាមិនខាន»។

លោក ខាហ្វខា ជាសិស្សដែលរៀនពូកែម្នាក់ ទោះបីគេជាក្មេងដែលពូកែភ័យខ្លាចយ៉ាងណាក៏ដោយ គាត់មិនមែនមានភាពភ័យខ្លាចចំពោះតែពាក្យគំរាមរបស់ស្ត្រីចុងភៅតែម្យ៉ាងប៉ុណ្ណោះទេ គឺរាល់កិច្ចការដែលគាត់ត្រូវធ្វើក្នុងឆាកជីវិតរបស់គាត់ សុទ្ធតែប្រកបដោយភាពភ័យខ្លាចទាំងអស់ ហើយវាអាចមកពីការភ័យខ្លាចនេះឯង ដែលបណ្តាលឲ្យគាត់បានតាំងចិត្តរៀនសូត្របានយ៉ាងល្អប្រសើរ ប៉ុន្តែគាត់មិនចូលចិត្តសាលារៀនទេ គាត់មានអារម្មណ៍ប្រតិកម្មអវិជ្ជមាននឹងប្រព័ន្ធអប់រំរបស់សាលារៀនទាំងស្រុង។

ហ្វ្រង់ ខាហ្វខា រៀននៅសាលាបឋមសិក្សាប្រចាំនៅក្នុងភូមិអស់រយៈ ៤ ឆ្នាំ បន្ទាប់ពីនោះមកបានបន្តការសិក្សាថ្នាក់មធ្យមនៅសាលារដ្ឋអាល់ស្តេតធី នៃប្រទេស អាល្លឺម៉ង់។ គាត់រៀននៅទីនោះពូកែជាលំដាប់ធ្វើឲ្យបណ្តាគ្រូៗបាននាំគ្នាស្ងើចសរសើរដល់រូបគាត់ ទោះជាយ៉ាងនេះក៏ដោយ សេចក្តីភ័យខ្លាចក៏នៅតែគ្របសង្កត់ផ្លូវចិត្តរបស់គាត់គ្រប់ពេលវេលា គាត់មិនដែលមានអារម្មណ៍ទុកចិត្តលើខ្លួនឯងឡើយ ដូចដែលគាត់សេរសេរទុកថា «ខ្ញុំប្រហែលជាប្រឡងចូលរៀនថ្នាក់មធ្យមមិនជាប់ឡើយ ប៉ុន្តែបែរជាជាប់ទៅវិញ ហើយខ្ញុំបានគិតទៀតថា ខ្ញុំប្រហែលជាប្រឡងឡើងថ្នាក់មិនជាប់ទេ តែបែរជាប្រឡងជាប់ ហើយបានឡើងថ្នាក់តាមលំដាប់។ ដរាបណាខ្ញុំរៀនបានល្អកម្រិតណា ខ្ញុំត្រឡប់ជាគិតថាលទ្ធផលដែលត្រូវទទួលបានរឹតតែយ៉ាប់យ៉ឺនទ្វេដងជាងការគិតទុកទៅទៀត ព្រោះជាញឹកញាប់ ខ្ញុំតែងនឹកឃើញដល់ថ្ងៃមួយដែលពួកគ្រូទាំងឡាយពិភាក្សា

គ្នាដ៏គួរឲ្យខ្លាចអំពីរូបខ្ញុំថា អាក្មេងម្នាក់នេះគ្មានបញ្ញានិងគ្មានសមត្ថភាពអ្វីឡើយ ហេតុអ្វីវាអាចប្រឡងឡើងថ្នាក់បាន»។

ហ្វ្រង់ ខាហ្វខា មិនត្រឹមតែស្អប់សាលារៀននិងការប្រឡងដែលធ្វើឲ្យគាត់លោះព្រលឹងគ្រប់ពេលនោះទេ គាត់ថែមទាំងគិតថាសាលារៀនមិនបានផ្តល់ចំណេះដឹងដល់ពួកសិស្សឲ្យសមទៅនឹងពេលវេលា ដែលពួកគេបានចំណាយនៅក្នុងការសិក្សារៀនសូត្រឡើយ ហើយក្រៅតែពីនេះ ពួកលោកគ្រូអ្នកគ្រូទាំងឡាយពុំបានយកចិត្តទុកដាក់ជុំវិញពួកសិស្សដែលមានទេពកោសល្យពិសេស ឲ្យមានការរីកចម្រើនក្នុងវិស័យដែលពួកគេចូលចិត្តស្រឡាញ់និងស្ទាត់ជំនាញស្រាប់នោះទេ។ ថ្ងៃមួយ គាត់បានពោលថា «តាមបទពិសោធកន្លងមក ខ្ញុំយល់ថាបរិស្ថានជុំវិញខ្លួនរបស់យើងមិនថាផ្ទះសម្បែង ឬសាលារៀនទេសុទ្ធតែមានចំណែកធ្វើឲ្យទេពកោសល្យរបស់មនុស្សរលាយសាបសូន្យទៅបាន»។

# ឆាលស៍ បូដឺលែរ៍

( Charles Baudelaire, France ) គ.ស. ១៨២១ - ១៨៦៧

មិនព្រមឲ្យបទបញ្ជាណានីមួយមក
គ្រប់គ្រងលើគាត់បានឡើយ
ទើបគាត់ជួបបញ្ហាក្នុងការសម្របខ្លួន
ចូលក្នុងសង្គមមនុស្សឯសាលារៀនលុយស៍។



ឆាលស៍ បូដឺលែរ៍ ក៏បានសន្សំសេចក្ដីស្អប់ចំពោះសាលារៀនពេញបេះដូងដូចអច្ឆរិយបុគ្គលដូចនិយាយខាងលើដែរ។ គាត់កើតនៅថ្ងៃទី ៩ ខែមេសា គ.ស. ១៨២១ នាទីក្រុង ប៉ារីស នៅពេលគាត់មានអាយុ ១១ ឆ្នាំ បានចូលរៀននៅសាលាបឋមសិស្សានៅក្នុងទីក្រុង លីយ៉ុង ជាសាលារៀនដែលពួកសិស្សត្រូវស្នាក់នៅក្នុងសាលាជាអាចិន្ត្រៃយ៍។ នៅក្នុងកំណត់ហេតុខ្លីៗ ដែលទាក់ទងនឹងអត្តជីវប្រវត្តិរបស់គាត់បានបញ្ជាក់អំពីរឿងរ៉ាវនៃជីវិតនៅក្នុងសាលារៀនដូច្នេះថា «ក្រោយ គ.ស. ១៨៣០ នៅឯសាលារៀននាទីក្រុង លីយ៉ុង មានការឈ្លោះទាស់ទែងគ្នារហូតដល់វាយតប់គ្នាយ៉ាងសាហាវជាមួយគ្រូនិងមិត្តរួមថ្នាក់»។

មានគេនិយាយមកហូរហែអំពីដំណើរជីវិត បូដឺលែរ៍ ថាគេតែងតែព្យាយាមបង្ហាញចេញនូវលក្ខណៈផ្ទាល់ខ្លួនឲ្យសាធារណជនឃើញថា

«គាត់អាចធ្វើអ្វីៗទៅបាន» ទើបគាត់ក្លាយជាបច្ចេកជនដែលមិនព្រមឲ្យបទបញ្ជាណាមួយមកគ្រប់គ្រងលើខ្លួនបាន ដែលនេះជាហេតុឲ្យគាត់ជួបប្រទះបញ្ហាក្នុងការសម្របខ្លួនចូលក្នុងសង្គមមនុស្ស។ នៅពេលដែលគាត់បានទៅរៀនបន្តនៅសាលាមធ្យមសិក្សា លុយស៍ ឡឺក្រង់ដ៍ ដ៏ល្បីល្បាញនៃក្រុងបារីស គាត់បានឈ្លោះជាមួយនឹងបណ្ដាគ្រូបង្រៀនជាញឹកញាប់រហូតត្រូវគេបណ្ដេញចេញពីសាលានៅពេលគាត់មានអាយុត្រឹម ១៨ ឆ្នាំ ដោយមូលហេតុដែលគាត់បានប្រព្រឹត្តនូវអំពើមិនសមរម្យនៅក្នុងសាលា។ បន្ទាប់ពីនោះ គាត់បានរៀនបន្តនៅសាលាឯកជនមួយរហូតបានបញ្ចប់ការសិក្សាក្នុងរយៈមួយឆ្នាំក្រោយ។

បូដឺលែរ៍ មិនត្រឹមតែមានបញ្ហាក្នុងការសម្របខ្លួនសេពគប់មិត្តភក្តិនៅសាលាប៉ុណ្ណោះទេ ថែមទាំងត្រូវជួបប្រទះបញ្ហាជាច្រើននៅក្នុងជីវិតប្រចាំថ្ងៃដូចដែលបានពោលមកខាងលើទៀតផង។ នៅក្នុងកំណត់ហេតុមួយដែលគាត់បានសរសេរនាពេលដែលមានអាយុ ៣៣ ឆ្នាំដូច្នេះថា«ខ្ញុំជឿថាជីវិតរបស់ខ្ញុំប្រហែលត្រូវបណ្ដាសាតាំងពីកំណើត ហើយប្រហែលជានឹងត្រូវបណ្ដាសាជារៀងរហូតទៅ»។ គាត់មិនអាចអត់ទ្រាំចំពោះភាពឯកោបាន ទើបបានយកស្រាធ្វើជាមិត្ត «មនុស្សយើងគួររក្សាភាពស្រវឹងឲ្យបានជានិច្ចដើម្បីបំភ្លេចសេចក្ដីទុក្ខទាំងឡាយក្នុងជីវិត និងបំភ្លេចរាល់រឿងរ៉ាវទាំងអស់ដែលជាអម្រែកដ៏ធ្ងន់ហើយជាន់ពន្លិចវាទៅក្នុងព្រះធរណីឱ្យអស់ បើដូច្នោះចូរផឹកឲ្យអស់ដៃតែម្ដង!»។ ឆាលស៍ បូដឺលែរ៍ ជាអ្នកសរសេរប្រលោមលោកកំណាព្យ និងរឿងអប់រំកម្សាន្តខ្នាតខ្លីដ៏ល្បីឈ្មោះ និងមានឥទ្ធិពលក្នុងលោក។ រឿងដែលល្បីបំផុតក្នុងលោកគឺ The Flowers of Evil ផ្កាបិសាច។

# ហូណូរេ ដឺ បាល្ស័ក

(Honore' De Balzac, France) គ.ស. ១៧៩៩ - ១៨៥០



ទោះបីជាគាត់រៀនភាសាឡាតាំងខ្សោយយ៉ាងណាក៏ដោយ តែគាត់បានក្លាយជាអ្នកនិពន្ធដ៏ល្បីល្បាញ និងបានបន្សល់ទុកនូវស្នាដៃជាច្រើន។

ភាពស្រវឹងងប់ងុលសូម្បីនៅក្នុងវ័យសិក្សា ដើម្បីជាមធ្យោបាយដោះស្រាយបញ្ហាជីវិត វាក៏ជាផ្នែកមួយនៃជីវិតរបស់ ហូណូរេ ដឺ បាល្ស័ក ដែលជាកវីនិពន្ធជនជាតិបារាំងដ៏ល្បីល្បាញម្នាក់នេះដែរ។ ប៉ុន្តែសម្រាប់គាត់មិនមែនស្រវឹងងប់ងុលជាមួយនឹងសុរាឬគ្រឿងញៀនឡើយ គឺគាត់ស្រវឹងងប់ងុលក្នុងការអានសៀវភៅ។ នេះជាវិធីសាស្ត្រតែមួយគត់ ដែលបានជួយឲ្យគាត់រួចផុតចាកជីវិតដ៏សែនលំបាក នៅសាលារៀនតាមបែបសាសនាមួយកន្លែង។

នៅថ្ងៃមួយ សេចក្តីអត់ធន់ស៊ូទ្រាំក្នុងការលំបាករបស់គាត់ត្រូវបានបញ្ចប់នៅពេលគាត់សន្លប់បាត់ស្មារតី ដោយសារអាការៈតានតឹងក្នុងអារម្មណ៍ជាខ្លាំង ទើបឪពុកម្តាយរបស់គាត់បានមកទទួលយកគាត់ចេញពី «កន្លែងហាត់ពត់លត់ដំកុមារ» ដូចដែលគាត់បានពោលថា «វាពោរពេញទៅដោយសេចក្តីទុក្ខវេទនា និងការឈឺចាប់កើតឡើងមកលើរាងកាយ

និងផ្លូវចិត្ត»។ សេចក្តីទុក្ខវេទនារបស់គាត់មិនបានបញ្ចប់ត្រឹមតែប៉ុណ្ណោះនៅឡើយទេ គាត់បានពណ៌នារៀបរាប់ក្នុងកំណត់ហេតុមួយច្បាប់ផ្សេងទៀតថា «សេចក្តីទុក្ខវេទនាដ៏ធ្ងន់ធ្ងររបស់ខ្ញុំធ្វើឲ្យខ្ញុំក្លាយជាមនុស្សចាស់មុនអាយុ អ្នកប្រហែលជាមិនអាចនឹកស្មានដល់ឡើយថាខ្ញុំបានឆ្លងកាត់នូវអ្វីខ្លះក្នុងឆាកជីវិតកន្លងមករហូតដល់ខ្ញុំមានអាយុ ២២ ឆ្នាំ។

បល្ស៊ែក ជាកូនប្រុសនៃគ្រួសារអ្នកមានស្តុកស្តម្ភម្នាក់ គាត់កើតនៅថ្ងៃទី ២១ ឧសភា គ.ស. ១៧៩៩ ប៉ុន្តែគាត់មិនបានកើតមកដើម្បីសោយសុខក្នុងភាវៈជាបុគ្គលដែលបរិបូរដោយមាសប្រាក់ ទ្រព្យសម្បត្តិនិងបរិវារចាំបម្រើជុំជិតក្នុងត្រកូល បាល្ស៊ែក នោះទេ ម្តាយរបស់គាត់បានបញ្ជូនគាត់ទៅឲ្យមេដោះជាអ្នកចិញ្ចឹមបីបាច់រក្សាតាំងតែពីថ្ងៃកើតភ្លាមៗរហូតដល់អាយុ ៤ ឆ្នាំ ក្រោយមកក៏បានលើកឲ្យគ្រួសារមួយផ្សេងទៀតជាអ្នកមើលថែជំនួស ហើយត្រូវបានអនុញ្ញាតឲ្យមកលេងផ្ទះចំពោះថ្ងៃអាទិត្យប៉ុណ្ណោះ។ គាត់បានពោលក្នុងកាលជាខាងក្រោយថា«ខ្ញុំមិនធ្លាប់មានម្តាយទេ ព្រោះស្ត្រីម្នាក់នេះស្អប់ខ្ញុំតាំងពីពេលដែលខ្ញុំនៅក្នុងផ្ទៃម្ល៉េះ រូបគាត់នេះហើយជាមូលហេតុដែលធ្វើឲ្យវ័យកុមារភាពរបស់ខ្ញុំជួបក្តីទុក្ខវេទនាយ៉ាងក្រៃលែង ដែលស្ទើរតែគ្មានបុគ្គលណាម្នាក់ធ្លាប់បានជួបដូចឡើយ»។

ពេលគាត់មានអាយុ ៨ ឆ្នាំគាត់បានចូលរៀនឯសាលា អូរ៉ាថូរៀនក្នុងទីក្រុង វ៉ងដូម មាត់ទន្លេល្វ័រ។ ក្នុងរឿងប្រលោមលោករបស់គាត់មួយដែលមានចំណងជើងថា លុយស៍ ឡាមប៊ែរ៍ បានបរិយាយដោយលើកពី

ឆាកជីវិតពិតរបស់គាត់មករួមបញ្ចូលផង ទោះបីជាមានប្រើពាក្យពេចន៍ខ្លះតាមលំនាំនៃការនិពន្ធរឿងស្ដាប់ទៅហាក់បីដូចជាបំផ្លើសពីការពិត ក៏ដោយ ប៉ុន្តែវាគឺជាជីវប្រវត្តិរបស់គាត់ផ្ទាល់។

នៅក្នុងវគ្គដំបូងនៃរឿង គាត់បានបរិយាយរៀបរាប់អំពីក្លិនស្អុយដ៏អាក្រក់ដែលវិលវល់នៅតាមបន្ទប់រៀនថា «ក្លិនខ្លួននិងក្លិនញើសដែលសាយភាយមកតាមខ្យល់លាយឡំជាមួយក្លិនអាក្រក់ ដែលបណ្ដាលមកពីបន្ទប់រៀនហាប់ជិតឈឹងច្របល់ជាមួយក្លិនទឹកតែនិងនំប៉័ងផ្អូម ដែលគេបោះចោលពាសវាលពាសកាលអាចបណ្ដាលឲ្យពួកសត្វរុយធំក្លិន ហើយនាំគ្នាមកចោមរោមឆីជាអាហារ។ វាមិនត្រឹមតែមានខ្យល់អាកាសអាប់អួនិងមិនបរិសុទ្ធប៉ុណ្ណោះទេ នៅក្នុងបន្ទប់រៀននីមួយៗថែមទាំងមានទូដាក់អីវ៉ាន់តូចៗរបស់ពួកសិស្ស ដែលពួកគេប្រើប្រាស់សម្រាប់ទុកដាក់អីវ៉ាន់របស់ខ្លួនម្នាក់បន្តិចៗ នេះប្រៀបដូចជាសត្វព្រាបដែលគេហាន់ជាបន្ទះៗ ហើយប្រទ្បាក់គ្រឿងត្រៀមទុកសម្រាប់ពិធីជប់លៀង ឬអាហារដែលផ្អូមជូរ។ ជារៀងរាល់ព្រឹក ពួកយើងត្រូវតម្រង់ជួរលាងដៃនិងលាងមុខចំពោះមុខលោកគ្រូអ្នកគ្រូ បន្ទាប់មកពួកយើងនាំគ្នាមកអង្គុយនៅលើតុ ហើយមានស្ត្រីអ្នកបម្រើមកសិតសក់ផាត់មុខឲ្យពួកយើង។ បន្ទប់ដេកពួកយើងរប៉ាត់រប៉ាយនិងរញ៉េរញ៉ៃជានិច្ច ទោះបីមានបង្អួចធំៗជាច្រើនយ៉ាងណាក៏ដោយ ក៏មិនអាចបញ្ចេញចំហាយក្លិនស្អុយពីក្នុងបន្ទប់ដែលមានទាំងក្លិនលាមករបស់ពួកសិស្សដែលមានគ្នារហូតដល់ទៅ ៨០ នាក់បានបន្ទោបង់ជារៀងរាល់ថ្ងៃឲ្យអស់បានដែរ»។

ហើយអ្វីដែលអាក្រក់ជាងនេះទៅទៀតនោះគឺ ការដាក់ទណ្ឌកម្មដែលបណ្ដាគ្រូបង្រៀនទាំងឡាយប្រើប្រាស់ជាមធ្យោបាយបង្រៀនក្មេងៗឲ្យចងចាំនូវអ្វីដែលខ្លួនត្រូវរៀន «ក្នុងវិធីធ្វើទារុណកម្មរាងកាយទាំងអស់នោះគ្មានអ្វីដែលអាក្រក់ជាងការវាយបាតដៃដោយប្រើរំពាត់ស្បែក ដែលមានទំហំប៉ុនពីរធ្នាប់ដៃ ហើយគ្រូដែលជាអ្នកវាយនោះវាត់យ៉ាងខ្លាំងពេញទំហឹងលើបាតដៃដោយសេចក្ដីក្រោធខឹង។ ចំពោះសិស្សណាដែលបានធ្វើខុស ត្រូវអង្គុយលុតជង្គង់នៅចំកណ្ដាលចំណោមមិត្តរួមថ្នាក់ក្នុងបន្ទប់រៀនដែលកំពុងសម្លឹងមើលប្រកបដោយខ្សែភ្នែកចំអកឡកឡាយ។ គ្រាន់តែមើលឃើញរូបភាពនៃការវាយរបស់គ្រូ មកលើកូនសិស្សដែលបានធ្វើខុស សិស្សខ្លះកើតទុក្ខវេទនាផ្លូវចិត្តទ្វេដង អ្នកខ្លះទៀតស្រែកទ្រហោយំទឹកភ្នែកជោកប្រាណ អ្នកខ្លះខាំធ្មេញទប់អារម្មណ៍ខំអត់ធ្មត់មិនបង្ហាញភាពទន់ជ្រាយរបស់ខ្លួនឲ្យគេដឹង ប៉ុន្តែខ្សែភ្នែករបស់ពួកគេបានបង្ហាញចេញនូវអារម្មណ៍ឈឺចាប់យ៉ាងក្រៃលែង។

ប័ល្ស៊ែក ក៏ត្រូវរងនូវការវាយដំជាញឹកញាប់ដែរ ពួកគ្រូទាំងឡាយគិតថាគាត់ជាក្មេងមានចរិតឌឺដង ខ្ជិលច្រអូស និងជាក្មេងដែលចូលចិត្តអង្គុយអណ្ដែតអណ្ដូង មិនយកចិត្តដាក់រៀនភាសាឡាតាំង ទើបត្រូវគ្រូវាយដោយរំពាត់ដែកជារឿយៗ។ គាត់សន្សំចិត្តស្អប់គ្រូទាំងនោះយ៉ាងខ្លាំង នៅពេលដែលគ្រូជេរប្រទេចដល់រូបគាត់ សេចក្ដីស្អប់និងអារម្មណ៍ក្រេវក្រោធក៏ស្ដែងចេញមកតាមរយៈខ្សែភ្នែក ដែលសម្លឹងមើលទៅកាន់គ្រូទាំងនោះ ប្រៀបបីដូចជាផ្លេកបន្ទោរបញ្ចេញពន្លឺឆ្វាចមកកាន់ផែនដី

ហើយគ្រូធ្លាប់គំរាមគាត់ថា «បើឯងនៅតែប្រើខ្សែភ្នែកសម្លឹងមើលអញ បែបនេះទៀត ប្រយ័ត្នត្រូវរំពាត់ដែក»។

គាត់រៀនគណិតវិទ្យាមិនសូវពូកែប៉ុន្មានទេ ដូច្នេះហើយទើបគាត់ត្រូវរៀនបន្ថែមជាមួយបណ្ណារក្ស ដែលជាអ្នកបានអនុញ្ញាតឲ្យគាត់ចូលទៅរកសៀវភៅអានតាមត្រូវការ ហើយការអានសៀវភៅនេះឯងជាផ្នែកមួយដែលបានជួយសម្រាលទុក្ខខ្លះៗនៃជីវិតគាត់។ គាត់បានអានសៀវភៅជាច្រើនប្រភេទ មានដូចជាសៀវភៅទាក់ទងនឹងសាសនា ប្រវត្តិសាស្ត្រ ទស្សនវិជ្ជានិងវិទ្យាសាស្ត្រជាដើម។ ការបណ្ដុះនិស្ស័យឲ្យស្រឡាញ់ការអានកាន់តែខ្លាំង បានក្លាយជាយន្តការពង្រឹងមូលដ្ឋានគ្រឹះនៃចំណេះដឹងតាំងពីនៅវ័យក្មេងចំពោះគាត់ ដែលបង្កើតជាឧបនិស្ស័យនិងទេពកោសល្យក្នុងការសាងស្នាដៃផ្នែកអក្សរសិល្ប៍ដ៏សម្បូរបែបនិងអស្ចារ្យក្រៃលែង។

លទ្ធផលនៃការសិក្សារៀនសូត្ររបស់គាត់បែរជាខ្សោយទៅៗ ជាមូលហេតុធ្វើឲ្យគ្រូដាក់ទណ្ឌកម្មកាន់តែធ្ងន់ធ្ងរឡើងទ្វេដង របួសរាងកាយនិងផ្លូវចិត្តរបស់គាត់មិនអាចទ្រាំទ្របាន ហើយក្លាយជាការដួលសន្លប់បាត់បង់ស្មារតីទើបឪពុកម្ដាយបានមកទទួលយកត្រឡប់ទៅផ្ទះវិញ ហើយបញ្ជូនឲ្យទៅរៀននៅសាលាមួយផ្សេងទៀត ដូចបានពោលមកខាងលើ។

ហូណូរេ ដឺ បាល្សាក់ ពោលថា«សេចក្ដីទុក្ខវេទនានិងការឈឺចាប់ដែលខ្ញុំបានទទួលរងពីសំណាក់គ្រួសារ និងសាលារៀននៅតែមានដូចដើម វាគ្រាន់តែផ្លាស់ប្ដូររូបភាពខ្លះៗតែប៉ុណ្ណោះ។ ឪពុកម្ដាយរបស់ខ្ញុំមាន

សេចក្តីរីករាយដោយពួកគាត់គិតថាខ្ញុំមានអាហារញ៉ាំ មានខោអាវស្លៀកពាក់ បានរៀនភាសាឡាតាំង និងភាសាក្រិចនៅសាលាដែលខ្ញុំបានទៅស្នាក់នៅរៀនអស់រយៈពេលយ៉ាងយូរ ហើយបានស្គាល់មិត្តភក្តិជាច្រើន តែខ្ញុំពុំធ្លាប់បានជួបនរណាម្នាក់ ដែលមានឪពុកម្តាយមិនយកចិត្តទុកដាក់ចំពោះកូនដូចជាឪពុកម្តាយខ្ញុំឡើយ»។

បន្ទាប់ពីគាត់បានផ្លាស់ទៅរៀននៅសាលាមួយផ្សេងហើយ ក៏ត្រូវបរាជ័យក្នុងសិក្សាទៀត គាត់រស់នៅក្នុងអារម្មណ៍ឯកា ចំណែកការរៀនភាសាឡាតាំងនៅតែខ្សោយដូចដើម។ នៅក្នុងចំណោមសិស្សចំនួន ៣៥ នាក់ គាត់ប្រឡងភាសាឡាតាំងបានលំដាប់លេខ ៣៣ លុះម្តាយបានដំណឹងនោះ ក៏បានសរសេរសំបុត្រផ្ញើឲ្យគាត់មួយច្បាប់មានសេចក្តីថា «ម៉ែមិនអាចរកពាក្យពេចន៍ដទៃណា ដែលនឹងប្រាប់ឲ្យកូនយល់ពីអារម្មណ៍ឈឺចាប់របស់ម៉ែនៅពេលដែលម៉ែដឹងថា កូនប្រឡងធ្លាក់ ម៉ែពិតជាកើតទុក្ខក្រៀមក្រំយ៉ាងខ្លាំង ព្រោះម៉ែខំធ្វើអ្វីៗគ្រប់បែបយ៉ាងដើម្បីរកប្រាក់ឲ្យកូនបានរៀនសូត្រឲ្យបានពូកែ ប៉ុន្តែទីបំផុតលទ្ធផលគឺផ្ទុយស្រឡះ»។ ហើយគាត់បានដើរនិយាយប្រាប់គេហូរហែថា ម្តាយរបស់គាត់ជាមនុស្សមិនល្អ និងមានសន្តានព្រៃ។

ពេលខ្លះដល់ថ្នាក់និយាយថា ម្តាយគាត់ជាបិសាចដែលមានសន្តានសាហាវ គាត់ជាមនុស្សមានសារធាតុបិសាចក្នុងខ្លួន ខ្ញុំគិតថាម៉ែប្រហែលជាឡប់សតិហើយមើលទៅ ថ្ងៃមួយគាត់បានទៅរកគ្រូពេទ្យពិភាក្សាអំពីរឿងនេះ គ្រូពេទ្យបានប្រាប់គាត់ថា ម្តាយគាត់មិនមែនឆ្កួតឬឡប់សតិ

ដូចឯងគិតឯណា គាត់ជាមនុស្សដែលគិតតែពីខ្លួនឯងច្រើនជាងកូនតែប៉ុណ្ណឹងឯង»។

នៅទីបំផុត ហូណូរេ ដឺ បាល់ហ្សាក់ បានព្យាយាមសម្របខ្លួននិងកែប្រែចរិតអស្មិមានះចេញ ហើយខិតខំប្រឹងប្រែងរៀនសូត្ររហូតប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិបានជោគជ័យ។ អូណូរេ ដឺ បល្សាក់ ក្នុងវ័យ ១៧ ឆ្នាំបានចូលរៀនបន្តផ្នែកច្បាប់នៅមហាវិទ្យាល័យបារីស ទោះបីជាគាត់បានក្លាយជានិស្សិតហើយក៏ដោយ ក៏នៅតែរងនូវសម្ពាធគាបសង្កត់ពីសំណាក់ក្រុមគ្រួសារដដែល។ ឪពុករបស់គាត់គិតថា បល្សាក់ គួរតែរកការធ្វើបណ្ដើររៀនបណ្ដើរ ដូច្នឹងក៏បានដាក់ពាក្យធ្វើជាស្មៀនរបស់អ្នកច្បាប់ម្នាក់ លុះបីឆ្នាំក្រោយមក គាត់ក៏បានលាឈប់សម្រាកពីការងារដោយប្រកាសខ្លួនថា ចាប់ពីពេលនេះតទៅខ្ញុំនឹងខិតខំរៀនសូត្រតែម្យ៉ាង ពេលនោះហើយដែលជាចំណុចចាប់ផ្ដើមនៃភាពជាអ្នកនិពន្ធដ៏ល្បីល្បាញលំដាប់ពិភពលោករបស់គាត់។

# ហ្គតហ្វ្រែត ឃែលឡឺ

( Gottfried Keller, Switzerland ) គ.ស. ១៨១៩ - ១៨៩០



មូលហេតុដែលគាត់មិនបានបញ្ចប់ការសិក្សានោះ គឺដោយសារមានការដើរក្បួនបាតុកម្មប្រឆាំងគ្រូបង្រៀនម្នាក់ដែលត្រូវបានគេចោទប្រកាន់ថាជាបក្សពួកក្រុមអ្នកប្រឆាំងក្នុងឆាកនយោបាយ។

នៅក្នុងខណៈដែលបុគ្គលអច្ឆរិយៈជាច្រើននាក់ស្អប់សាលារៀន ដោយសារពួកគេត្រូវទៅរៀនក្នុងទីកន្លែងអចិន្ត្រៃយ៍ ឬមុខវិជ្ជាដែលមិនសមតាមបំណងប្រាថ្នារបស់ខ្លួនតែសម្រាប់លោក ហ្គតហ្វ្រែត ឃែលឡឺ បែរជាផ្ទុយគ្នាអំពីអ្នកទាំងនោះទៅវិញ។ គាត់ស្អប់សាលារៀនដោយសារគេមិនអនុញ្ញាតឲ្យនៅរៀនបន្ត ហើយត្រូវបានឲ្យចាកចេញពីសាលារៀននេះហើយជាឧបសគ្គរារាំងមិនឲ្យគាត់បានសិក្សាបន្ត។ ការខកខានមិនបានរៀនបន្តនេះ សម្រាប់រូបគាត់ហាក់បីដូចជាដាក់ទោសប្រហារជីវិតអ៊ីចឹងដែរ។ គាត់មិនអាចបំភ្លេចបាននូវហេតុការណ៍ទាំងនេះបានឡើយពេញមួយឆាកជីវិតរបស់គាត់ ទោះបីជាគាត់បានទទួលអាហារូបករណ៍ពីរដ្ឋាភិបាលនៅពេលមានវ័យជិត ៣០ ឆ្នាំ ដើម្បីចូលរៀនបន្តនៅមហាវិទ្យាល័យ ហៃឌែលប្រ៊ែក ក៏ឃើញពេលបាត់ទៅហើយដែរសម្រាប់គាត់។

កវីល្បីល្បាញជនជាតិ ស្វីស ម្នាក់នេះកើតនៅថ្ងៃទី ១៩ កក្កដា គ.ស. ១៨១៩ នៅក្នុងទីក្រុង ស៊ូរិក។ គាត់ជាក្មេងអភព្វ ឪពុករបស់គាត់បានធ្វើមរណកាលចោលទៅនៅពេលគាត់មានអាយុ ៥ ឆ្នាំ ហើយរយៈពេលមិនយូរប៉ុន្មានម្តាយក៏បានរៀបការជាមួយបុរសម្នាក់ទៀត។ អារម្មណ៍របស់ ឃែលឡឺ ក្នុងខណៈនោះក្រៅពីកើតទុក្ខចំពោះការបាត់បង់ឪពុកជាទីស្រឡាញ់ដែលធ្វើមរណភាពទាំងនៅវ័យក្មេងហើយ ត្រូវព្យាយាមសម្របខ្លួនរស់នៅជាមួយឪពុកចុងថែមទៀតផង។ ឃែលឡឺ គិតថាការបាត់បង់ឪពុកជាមូលហេតុធ្វើឲ្យគាត់ក្លាយជាក្មេងអភព្វ មូលហេតុមួយទៀតដែលធ្វើឲ្យគាត់រងនូវរបួសផ្លូវចិត្តនោះគឺ ការដែលគាត់ត្រូវបានគេបណ្តេញចេញពីសាលា។

ឃែលឡឺ ជាសិស្សដែលរៀនពូកែ ឧស្សាហ៍ព្យាយាម យកចិត្តទុក្ខដាក់ក្នុងការហ្វឹកហាត់ផ្នែកភាសា និងអក្សរសិល្ប៍ផ្សេងៗ ហើយជានិច្ចកាលគាត់រៀនបានពិន្ទុល្អជាលំដាប់ រហូតដល់ថ្ងៃដែលហេតុការណ៍មួយបានកើតឡើង ជាហេតុធ្វើឲ្យការសិក្សារបស់គាត់ក៏ត្រូវបានបញ្ចប់ពាក់កណ្តាលទីទាំងស្រុង នោះក៏គឺ មានការដើរក្បួនដង្ហែបាតុកម្មមួយដើម្បីប្រឆាំងតវ៉ានឹងគ្រូបង្រៀនម្នាក់ ដែលត្រូវបានគេចោទថាជាបក្សពួកក្រុមប្រឆាំងក្នុងឆាកនយោបាយ។ ក្បួនដង្ហែបានរៀបចំឡើងដោយក្រុមសិស្សដែលរៀនថ្នាក់លើគាត់មួយឆ្នាំ ដែលកំពុងធ្វើដំណើរឆ្ពោះទៅកាន់ផ្ទះគ្រូរូបនោះ។ នៅតាមផ្លូវ ក្មេងទាំងនោះបានឃើញ ឃែលឡឺ ហើយបបួលគាត់ឲ្យចូលរួមដើរដង្ហែក្បួនជាមួយគ្នា ទោះជាកាលនោះ ឃែឡឺ

ជាសិស្សរៀននៅថ្នាក់ក្រោមមួយថ្នាក់នៅឡើយក្តី និងគ្មានអ្វីពាក់ព័ន្ធនឹងសិស្សទាំងនោះក្តី ប៉ុន្តែពេលបានចូលដើរដង្ហែក្បួនគាត់ជាអ្នកប្រាប់និងរៀបចំឲ្យពួកសិស្សទាំងនោះដើរជាជួរៗឲ្យមានរបៀបរៀបរយ។

ហេតុដូច្នេះហើយ ពេលនាយកសាលាសាកសួររឿងរ៉ាវទាំងនោះ ឃែលឡឺ បែរជាត្រូវគេចោទថាជាមេខ្លោងទៅវិញ។ នៅពេលព្ធដូច្នោះគេស្នើរតែទន់ជង្គង់ ហាស៊្តីអ្វីពុំរួចឡើយ ហើយត្រូវបានគេហាមមិនឱ្យចូលរៀននៅសាលាណាទាំងអស់។ ជាច្រើនឆ្នាំក្រោយមក គាត់បានសរសេរកំណត់ហេតុរំឭកពីហេតុការណ៍នោះថា «រដ្ឋអំណាចអាងសិទ្ធិអ្វីក្នុងការកាត់សេចក្តីក្មេងតូចម្នាក់ ដែលមិនបានធ្វើនូវទង្វើអាក្រក់ ឬបង្កបញ្ហាក្នុងសង្គមអ្វីសោះ ឲ្យឈប់រៀន និងមិនឲ្យទទួលបាននូវការអប់រំនៅក្នុងសាលាសោះនោះ។ ធ្វើដូច្នេះវាហាក់ដូចជាសម្លាប់ក្មេងម្នាក់នោះទាំងរស់អ៊ីចឹងហើយធ្វើឲ្យការអភិវឌ្ឍគ្រប់យ៉ាងរបស់កុមារត្រូវបានបញ្ចប់ដែរ»។

ហេតុការណ៍ដែលកើតឡើងបានធ្វើឲ្យ ឃែលឡឺ ជួបទុក្ខលំបាកយ៉ាងខ្លាំង ដោយសារពុំមានប្រាក់ដើម្បីជួលគ្រូមកបង្រៀនផ្ទាល់នៅផ្ទះ ហើយគេក៏បានសម្រេចចិត្តទៅធ្វើការ និងហ្វឹកហាត់ផ្នែកគូរគំនូរជាមួយវិចិត្រករម្នាក់។ គាត់ចំណាយពេលអស់ជាច្រើនឆ្នាំទម្រាំតែអាចក្រោកឈរបានដោយខ្លួនឯង ហើយអាចរកប្រាក់ចំណូលចិញ្ចឹមជីវិតបានតាមរយៈការគូរគំនូរនិងការតែងនិពន្ធ។ លុះគាត់មានអាយុជាង ៤០ ឆ្នាំ រដ្ឋស៊ូរិក បានតាំងគាត់ឱ្យបានជាកិត្តិនាមសក្តិផ្នែកខាងការតែងនិពន្ធប្រចាំរដ្ឋដែលជាកិត្តិយសដ៏ឧត្តមឧត្តមក្រៃលែងក្នុងឆាកជីវិតរបស់គាត់។

# ហឺមែន ហ៊ែស្សេ

( Herrman Hesse, German Empire ) គ.ស. ១៨៧៧ - ១៩៦៣

គ្មានសាលារៀនណាស្វាគមន៍ខ្ញុំទេ
ខ្ញុំមិនអាចរៀនអ្វីបានឡើយ
សេចក្តីព្យាយាមដែលនឹងធ្វើឲ្យខ្ញុំក្លាយជា
មនុស្សមានប្រយោជន៍ត្រូវបានបរាជ័យ។



យុវជន ហឺមែន ហ៊ែស្សេ ជាសិស្សដែលរៀនពូកែហើយឧស្សាហ៍ព្យាយាមដូច ឃែលឡឺ ដែរ ប៉ុន្តែគេជួបនូវហេតុការណ៍ដែលធ្វើឲ្យគេត្រូវឈប់រៀនកណ្តាលទី ដោយសាររឿងដែលបង្កឡើងដោយខ្លួនគេផ្ទាល់។ សេចក្តីក្រោធនិងសេចក្តីស្អប់ខ្ពើម បានបណ្តាលឱ្យគេគិតខ្លីចង់សម្លាប់ខ្លួន ហើយបានរត់ចេញពីសាលារៀន ម៉ូលប្រនន៍ ធ្វើឲ្យឪពុកម្តាយនិងបណ្តាគ្រូរបស់គេចម្លែកចិត្តយ៉ាងខ្លាំង។

ហឺមែន ហ៊ែស្សេ ជាបុត្ររបស់សាសនទូត កើតនៅថ្ងៃទី ២ កក្កដា គ.ស. ១៨៧៧ ក្នុងទីក្រុង ខៅហ៍ ទឹកដី វិតថេនបឺក ឪពុករបស់គាត់ធ្វើការក្នុងរោងពុម្ពនិងជាអ្នកផ្សព្វផ្សាយសាសនា។ ហ៊ែស្សេ ពុំសូវពេញចិត្តក្នុងការសិក្សាថ្នាក់បឋមសិក្សារបស់គាត់ប៉ុន្មានទេ គាត់ពោលថា«អស់រយៈពេល ៨ ឆ្នាំដែលខ្ញុំរៀននៅថ្នាក់បឋមសិក្សា មានគ្រូតែម្នាក់ប៉ុណ្ណោះដែលខ្ញុំស្រឡាញ់និងនឹកឃើញដល់គុណូបការៈដែលបានបង្រៀនរូបខ្ញុំ»។

នៅពេលគាត់មានអាយុ ១២ ឆ្នាំ ត្រូវបានឪពុកម្ដាយបញ្ជូនឲ្យទៅរៀន ដើម្បីត្រៀមខ្លួនចូលប្រឡងវិញ្ញាសារបស់រដ្ឋ ដែលជាលក្ខខណ្ឌត្រូវបំពេញ មុនពេលចូលរៀននៅសាលា ម៉ូលប្រេនន៍។ ជាលទ្ធផលគាត់បានប្រឡង ជាប់ជាស្ថាពរ ហើយបានចូលរៀននៅសាលា ម៉ូលប្រេនន៍ ដូចបំណង ប្រាថ្នា។ ពេលចូលរៀនដំបូងគ្រប់យ៉ាងប្រព្រឹត្តទៅយ៉ាងរលូនហើយគាត់ បានសរសេរសំបុត្រមួយច្បាប់ផ្ញើជូនឪពុករបស់គាត់ថា «ខ្ញុំសប្បាយចិត្ត ណាស់ដែលបានរៀននៅទីនេះ។ ពិសេសគ្រូបង្រៀន និងសិស្សានុសិស្ស នៅទីនេះមានអធ្យាស្រ័យល្អ មានទំនាក់ទំនងល្អ មានភាពស្និទ្ធស្នាល រវាងគ្នានឹងគ្នា គ្រប់យ៉ាងនៅទីនេះគួរជាទីមនោរម្យក្រៃលែង ពុំមានការ គាបសង្កត់ឬគំរាមកំហែងអ្វីឡើយ»។

ស្នាមញញឹមរបស់គ្រួសារមិនទាន់បាត់ផង ក្នុងរយៈពេលត្រឹមតែ បីសប្ដាហ៍ក្រោយ ឪពុកបានទទួលសំបុត្ររន្ធត់មួយច្បាប់ គឺក្នុងចន្លោះ ពាក់កណ្ដាលខែមិនា គ.ស. ១៨៩២ ដោយក្រុមគ្រួសាររបស់គាត់បាន ទទួលទូរសារពីសាលារៀន ម៉ូលប្រេនន៍ មានអត្ថន័យថា «ហ៊ីមែន បាន បាត់ខ្លួនចេញពីសាលាតាំងពីវេលាម៉ោងពីររសៀលមកម្ល៉េះ សូមមេត្តាផ្ដល់ ដំណឹងមកខាងសាលារៀនផងថា តើគេនៅទីនោះដែរឬទេ?»។

ចំណែកក្រុមគ្រួសារមិនបានដឹងដំណឹងអ្វីពី ហ៊ីមែន ជាងគ្រូនៅ សាលានោះទេ។ បន្ទាប់ពីអាហារថ្ងៃត្រង់រួច ហ៊ីមែន បានបាត់ខ្លួនចេញ ពីសាលាដោយគ្មានហេតុផល ថែមទាំងគ្មានប្រាក់ និងអាវធំជាប់ជាមួយ នឹងខ្លួនឡើយ។ គ្រប់គ្នាបានព្យាយាមស្វែងរកគ្រប់ច្រកល្ហកក្បែរសាលា

រៀន ប៉ុន្តែរករូបគេមិនឃើញឡើយ លុះស្អែកឡើងគេក៏ត្រឡប់មកវិញ ដោយមានព្រានព្រៃម្នាក់ជាអ្នកនាំគេមក។

ក្រោយការបាត់ខ្លួនអស់រយៈពេល ២៣ ម៉ោងគត់ ហ៊ីមែន បានសរសេរសំបុត្រមួយច្បាប់ផ្ញើជូនឪពុករបស់គេថា «ខ្ញុំបានចំណាយពេលដើរក្នុងព្រៃពេញមួយយប់ គឺចាប់ពីម៉ោង ៨ ក្បាលព្រលប់ម្សិលមិញរហូតដល់ម៉ោង ៤ កន្លះវេលាជិតភ្លឺព្រឹកថ្ងៃនេះក្រោមអាកាសធាតុត្រជាក់ ១៧ អង្សា តែនៅគ្រាន់បើជាងការរៀន ហេតុដូច្នេះសូមប្រណីដល់រូបខ្ញុំផង កុំបង្ខំឲ្យខ្ញុំរៀនទៀតអី បើមិនដូច្នោះទេការសិក្សារបស់ខ្ញុំនៅទីនេះនឹងក្លាយជាឋាននរកមិនខាន។ សូមលោកឪពុកមេត្តាស្រឡាញ់រូបកូនដូចគ្រាមុនផង»។

ពី ... ហ៊ីមែន

នៅតែស្រឡាញ់លោកប៉ាអ្នកម៉ាក់ជានិច្ចនិរន្តរ៍

ក្នុងករណីដែលគេបាត់ខ្លួនទៅ គ្រូបានដាក់ទណ្ឌកម្មដោយការបង្ខាំងខ្លួនរយៈពេល ៨ ម៉ោង ហើយនៅក្នុងអំឡុងពេលដែលត្រូវគេឃុំខ្លួននោះ ហ៊ីមែន បានសេរសេរលិខិតផ្ញើជូនឪពុកម្ដាយរបស់គេថា «ខ្ញុំត្រូវអង្គុយទទួលទោសទណ្ឌនៅទីនេះ ដោយមានត្រឹមតែទឹក និងនំប៉័ងសម្រាប់បរិភោគប៉ុណ្ណោះ។ ខ្ញុំមានអារម្មណ៍អស់កម្លាំងល្វិតល្វៃជាខ្លាំង តែខណៈនេះកូនមិនអីទេ បានគ្រាន់បើបន្តិចហើយ»។ ជាបន្ត គេសរសេរទៀតថា«ខ្ញុំនឿយហត់អស់កម្លាំងខ្លាំងណាស់ មិនមែនមានន័យថាខ្ញុំឈឺ

ទេ ប៉ុន្តែមិនដឹងជាយ៉ាងម៉េចទេ វាចេះតែអស់កម្លាំងល្វិតល្វៃ ហើយជើងរបស់ខ្ញុំទាំងពីរត្រជាក់ដូចទឹកកក ចំណែកឯក្បាលរបស់ខ្ញុំវិញក្តៅដូចភ្លើងអ៊ុចឹង តែវាក៏នៅគ្រាន់បើជាងការរៀនវីយូឡុង»។

ហ៊ីម៉ែន តែងគេចវេះពីមនុស្សម្នាហើយព្យាយាមនៅស្ងៀមស្ងាត់ម្នាក់ឯង រីឯលទ្ធផលនៃការសិក្សារបស់គេវិញក៏ធ្លាក់ចុះជារឿយៗរហូតឪពុកម្តាយរបស់គេបានសម្រេចចិត្តមកទទួលយកគេត្រឡប់ទៅផ្ទះវិញ។ ទោះបីជា ហ៊ីម៉ែន បានត្រឡប់ទៅនៅឯផ្ទះជាមួយឪពុកម្តាយហើយក៏ដោយ អាការៈរោគរបស់គេនៅមិនបានល្អប្រសើរឡើយ គេបានក្លាយជាក្មេងមានសតិស្មារតីច្របូកច្របល់ និងមានលក្ខណៈហាក់ដូចជារោគសរសៃប្រសាទហើយតែងភ្លេចមុខភ្លេចក្រោយជានិច្ច។ គាត់បានសរសេរកំណត់ហេតុពីព្រឹត្តិការណ៍ក្នុងពេលនោះទុកថា «អ្វីៗដែលខ្ញុំខិតខំធ្វើរយៈពេល ១០ ឆ្នាំបានបរាជ័យទាំងអស់ ហើយពុំមានសាលារៀនណាមួយទទួលស្វាគមន៍រូបខ្ញុំទេ ខ្ញុំមិនអាចរៀនចំណេះវិជ្ជាផ្សេងៗបានឡើយ។ សេចក្តីព្យាយាមដែលថា នឹងអាចធ្វើឲ្យខ្លួនក្លាយជាមនុស្សមានប្រយោជន៍ទាំងអម្បាលម៉ានក៏ត្រូវបរាជ័យទាំងអស់ដែរ»។

គាត់បានចូលរៀនថ្នាក់មធ្យមសិក្សានៅ ខានស្តាត់ ជាអកុសលរៀនមិនចប់ឡើយ ហើយបានចូលហ្វឹកការងារជាអ្នកលក់សៀវភៅបានរយៈពេលត្រឹមតែ ៣ ថ្ងៃក៏លាឈប់ទៀត បន្ទាប់មកបានទៅរៀនផ្នែកជាងជួសជុលគ្រឿងចក្រប៉ុន្តែគ្មានបានលទ្ធផលអ្វីទាល់តែសោះ។ នៅទីបំផុតគាត់បានសម្រេចចិត្តចូលប្រឡូកក្នុងធុរកិច្ចលក់សៀវភៅ នៅពេលនោះ

ជីវិតរបស់គាត់ហាក់មានជោគវាសនាល្អឡើង។ គាត់បានពោលថា«ពេលនេះរូបខ្ញុំហាក់មានសេចក្ដីសុខខាងផ្លូវចិត្តបន្តិចម្ដងៗ ពេលវេលាដ៏អាក្រក់ដែលពោរពេញទៅដោយសេចក្ដីក្រេវក្រោធ និងសេចក្ដីស្អប់ខ្ពើមរួមទាំងគំនិតដែលធ្លាប់បានគិតថា នឹងធ្វើអត្តឃាតកន្លងមកហួសផុតអស់ទៅហើយ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយហេតុការណ៍ទាំងអស់នោះវាបានធ្វើឲ្យខ្ញុំមានភាពជាម្ចាស់ការលើខ្លួនឯង និងអាចប្រឈមមុខចំពោះព្យុះជីវិតដ៏កំណាចគ្រប់បែបយ៉ាងបានដោយងាយ»។

ចាប់តាំងពីពេលនោះមក រឿងដែលសំខាន់បំផុតក្នុងឆាកជីវិតរបស់ ហឺមែន ហ៊ែស្សេ នោះក៏គឺការអានសៀវភៅនិងការតែងនិពន្ធ ដែលធ្វើឱ្យគេស្គាល់ទូទាំងពិភពលោក។

# ថូម៉ាស់ ម៉ានន៍

( Thomas Mann, Germany ) គ.ស. ១៨៧៥ - ១៩៥៥

នៅពេលឪពុកអនិច្ចកម្មទៅក្រុមហ៊ុន ក៏ដួលរលំទៅតាមហ្នឹងដែរ ទើបគាត់ អាចធ្វើតាមសេចក្តីប្រាថ្នារបស់គាត់បាន។



ថូម៉ាស់ ម៉ានន៍ ក៏ជាអច្ឆរិយបុគ្គលមួយរូបទៀតដែលស្អប់សាលារៀនដែរ តែមិនធ្លាប់មានអារម្មណ៍អស់សង្ឃឹមឡើយ។ គាត់ជាកូនទីពីររបស់លោក យ៉ូហាន់ ហ៊ែនរីចម៉ានន៍ ដែលជាអ្នកជំនួញនិងជាសមាជិកព្រឹទ្ធសភានៃក្រុង លីប៊ែក កើតនៅថ្ងៃទី ៦ ខែមិថុនា គ.ស.១៨៧៥ ក្នុងក្រុង លីប៊ែក និងបានចូលរៀនថ្នាក់បឋមសិក្សានៅសាលា ខាថារីនេអ៊ុម ជាសាលារៀនដែលកសាងតាំងតែពីគ្រិស្តសតវត្សរ៍ទី ១៦។ អគារសាលាទាំងអស់កសាងពីឥដ្ឋដីដុតមានពណ៌ក្រហមព្រឿងៗ នេះធ្វើឲ្យយើងនឹកឃើញដល់បន្ទាយទាហាន ហើយបរិយាកាសនៃការសិក្សារៀនសូត្រនៅទីនោះក៏មានលក្ខណៈប្រហាក់ប្រហែលគ្នានឹងបន្ទាយទាហានដែរ។

ថូម៉ាស់ ម៉ានន៍ បានសរសេររៀបរាប់ពីសាលានោះថា «ពួកយើងដែលជាសិស្សត្រូវលេងប្រតែងប្រតោង និងក្រឡាប់ខ្លួនចុះឡើងជាមួយ

នឹងឧបករណ៍ហាត់ប្រាណក្នុងសាលហាត់ប្រាណដ៏គួរឲ្យស្លុតចិត្ត ដែលបានបន្សល់ទុកមកតាំងពីសម័យសង្គ្រាមណាប៉ូឡេអុង ពួកយើងត្រូវធ្វើលំហាត់ប្រាណដោយពាក់អាវដៃវែង និងមានទ្រនាប់ការពារដ៏រឹង ហើយមានគ្រូកីឡាអត្តពលកម្មប្រមឹកម្នាក់ពុកមាត់វែងស្រម៉ូម ចូលចិត្តស្រែកឮខ្លាំងៗដូចជាការបង្វឹកពួកទាហាននៅចាំមើលការខុសត្រូវពួកយើង»។

ថូម៉ាស់ ម៉ានន៍ មិនមែនជាសិស្សរៀនពូកែណាស់ណាទេ ហើយលទ្ធផលនៃការសិក្សារបស់គេក៏មិនអន់ប៉ុន្មានដែរ។ បើទោះបីជាមានម្តងនោះគេប្រឡងធ្លាក់ក៏ដោយ។ ក្នុងចំណោមលោកគ្រូអ្នកគ្រូទាំងអស់ គេស្រឡាញ់និងចូលចិត្តគ្រូបង្រៀនភាសាអាល្លឺម៉ង់ ខ្លាំងជាងគេព្រោះជាគ្រូប្រចាំថ្នាក់របស់គេផ្ទាល់ ហើយលោកគ្រូម្នាក់នោះឯងដែលជាអ្នកធ្វើឲ្យរូបគេជក់ចិត្តជិតអារម្មណ៍ក្នុងការអានសៀវភៅ។

ការពិត គោលបំណងរបស់ឪពុកគឺ ចង់ឲ្យគាត់បន្តវេនដំណើរការក្រុមហ៊ុនដូចជាបងប្រុសរបស់គាត់ដែរ។ ប៉ុន្តែជាអកុសលនៅពេលឪពុកធ្វើមរណកាលទៅក្រុមហ៊ុនរបស់គាត់ក៏ដួលរលំទៅផងដែរ។ ហេតុដូច្នោះទើបគាត់ងាកមកបំពេញសេចក្តីស្រមៃរបស់គាត់ នោះក៏គឺ ការចង់ក្លាយជាកវីនិពន្ធ។ បន្ទាប់ពីឪពុកបានស្លាប់ចោលទៅ ម្តាយរបស់គាត់បានសម្រេចចិត្តលក់ផ្ទះនៃត្រកូល ម៉ានន៍ ដ៏ស្កឹមស្កៃហើយទៅរស់នៅក្នុងផ្ទះតូចមួយដែលចំណាយប្រាក់ក្នុងការជួសជុលតុបតែងលម្អតិចជាងមុន។

ថូម៉ាស់ តាំងចិត្តថានឹងព្យាយាមប្រឡងបញ្ចប់ថ្នាក់មធ្យមសិក្សាឲ្យខានតែបាន តែគេបែរជាខ្ជិលច្រអូស ឌីដង និងលេងសើចបែបចំអកឡកឡឺយរឿងគ្រប់យ៉ាងដែលកើតឡើងក្នុងជីវិត និងប្រព្រឹត្តខ្លួនពាលាអាវ៉ាសែមិនយកចិត្តទុកដាក់រៀនសូត្ររយៈពេលមួយឆ្នាំពេញ ដូច្នឹងហើយទើបបានត្រូវគេបញ្ជូនឲ្យទៅធ្វើជាទាហានរយៈពេលមួយឆ្នាំ។

ក្រោយពីបានបញ្ចប់ការសិក្សាថ្នាក់មធ្យមសិក្សា គាត់បានចូលធ្វើការក្រៅម៉ោង ក្នុងក្រុមហ៊ុនធានារ៉ាប់រងអគ្គីភ័យមួយកន្លែងក្នុងទីក្រុងម្យូនិក និងបានបន្តការសិក្សានៅសកលវិទ្យាល័យ ម្យូនិក ផងដែរ។ ពីរឆ្នាំក្រោយមក គាត់បានធ្វើដំណើរទៅកាន់ទីក្រុង រ៉ូម ហើយបានចាប់ផ្ដើមនិពន្ធរឿងប្រលោមលោក ដែលមានបង្កប់នូវខ្លឹមសារជីវិតពិតនៃគ្រួសាររបស់គាត់ ហើយទទួលបានការពេញនិយមនិងល្បីល្បាញយ៉ាងខ្លាំងក្នុងរយៈខ្លីមិនគួរឲ្យជឿ។

# មេរៀនទី ៣

បុគ្គលដែលមានឈ្មោះបោះសំឡេងជាច្រើននាក់ ដែលបានក្លាយជាបុគ្គលអច្ឆរិយៈនាថ្ងៃអនាគតនោះ ក្នុងខណៈដែលពួកគេនៅជាសិស្សក៏គ្មានអ្វីដែលលេចធ្លោគួរឲ្យចាប់អារម្មណ៍ គ្មានអ្វីល្អឬអាក្រក់ ឬមានសមត្ថភាពពិសេសអ្វីមួយជាងមិត្តរួមថ្នាក់ ដែលអាចកំណត់ចំណាំបានថានឹងជាអច្ឆរិយបុគ្គលដែរ។ បុគ្គលទាំងនោះនឹងយកមកពណ៌នានៅក្នុងមេរៀនដូចតទៅ ៖

# ឆាលស៍ ដាវីន

( Charles Darwin, United Kingdom ) គ.ស. ១៨០៩ - ១៨៨២



ទស្សនៈវិទូដែលរកឃើញនូវទ្រឹស្តីវិវឌ្ឍនាការដ៏រន្ធឺជឿថាព្រះជាម្ចាស់ជាអ្នកបង្កើតពិភពលោកនិងមនុស្សតែនៅជឿថាមនុស្សមានបុព្វបុរសជាមួយសត្វស្វា។

ឆាលស៍ ដាវីន មានទំនាក់ទំនងពុំសូវជារលូនប៉ុន្មានទេជាមួយនឹងលោកឪពុករបស់គាត់ ដែលជាគ្រូពេទ្យល្បីឈ្មោះម្នាក់ មានជីវភាពធូរធា គាត់មានសេចក្តីសង្ឃឹមជឿជាក់យ៉ាងមុតមាំចំពោះកូនប្រុសខ្លួន។ ភាពជោគជ័យ និងភាពល្បីល្បាញរបស់ឪពុកជាគំនាបដល់ ដាវីន ជាខ្លាំង តែទោះបីជាយ៉ាងណាគាត់នៅគោរពដឹងគុណចំពោះឪពុកបង្កើតរបស់គាត់ដោយឥតល្មៀង។

ឆាលស៍ ដវីន ធ្លាប់បានសរសេរពីឪពុករបស់គាត់ទុកថា«ជាបុរសដែលមានរាងខ្ពស់បំផុត និងមានទម្ងន់ធ្ងន់បំផុត មើលទៅសង្ហាគ្រាន់បើដែរ គាត់មានកម្ពស់ ១.៨៨ សង់ទីម៉ែត្រនិងមានទម្ងន់ ១៥០ គីឡូក្រាម ហើយគាត់ឡើងគីឡូជាបន្តបន្ទាប់»។ លោកឪពុកធ្លាប់ស្តីជេរ និងថាឲ្យគាត់យ៉ាងធ្ងន់ៗ ធ្វើឲ្យគាត់មានអារម្មណ៍តូចចិត្តជាខ្លាំង «ឯង...អញមិនដែលឃើញឯងយកចិត្តទុកដាក់រឿងអ្វីក្រៅពីលេងបាញ់កាំភ្លើង លេង

ជាមួយឆ្កែនិងដេញចាប់សត្វកណ្ដុរមួយថ្ងៃៗឡើយ ប្រសិនបើឯងនៅតែបន្តធ្វើបែបនេះទៀត ឯងនឹងនាំមកនូវការអាប់ឱនកិត្តិយសដល់គ្រួសារនិងខ្លួនឯងផ្ទាល់»។

ឆាលស៍ ដារ៉ីន កើតនៅថ្ងៃទី ១២ ខែកុម្ភៈ គ.ស.១៨០៩ នៅទីក្រុង ឈ្រូបឺរី បានចូលរៀនក្នុងអាយុ ៨ ឆ្នាំ គាត់បានសរសេររឿងរ៉ាវនៃការសិក្សារៀនសូត្រក្នុងជីវប្រវត្តិរបស់គាត់ថា «នរណាៗក៏និយាយដែរថាខ្ញុំរៀនយឺតជាង ខែធើរីន ប្អូនស្រីរបស់ខ្ញុំ»។

ពេលរៀននៅថ្នាក់បឋមសិក្សាគាត់បង្ហាញពីទំនោរនៃអច្ឆរិយភាពទៅលើការស្រាវជ្រាវ ដូចដែលគាត់បានសរសេរទុកមកថា «កាលខ្ញុំរៀននៅថ្នាក់បឋមសិក្សា ខ្ញុំក៏ចាប់ផ្ដើមមានចំណាប់អារម្មណ៍ចំពោះធម្មជាតិហើយចូលចិត្តរក្សាទុកវត្ថុធាតុផ្សេងៗ ខ្ញុំបានព្យាយាមរកឈ្មោះនៃគ្រាប់ពូជនីមួយៗនិងបានសន្សំទុកនូវវត្ថុធាតុជាច្រើនមានដូចជា សម្បកខ្យងត្រាប្រថាប់ តែម កាក់ និងវត្ថុធាតុផ្សេងៗជាច្រើនប្រភេទ។ សេចក្ដីឈ្លក់វង្វេងក្នុងការសន្សំវត្ថុធាតុផ្សេងៗទាំងនេះហើយ ដែលជាមធ្យោបាយអូសទាញឲ្យគាត់ក្លាយជាអ្នកស្រាវជ្រាវដ៏ល្បីរន្ទឺមួយរូប...»។

មួយឆ្នាំបន្ទាប់មក គេផ្លាស់ទៅរៀននៅសាលាអចិន្ត្រៃយ៍ ដែលត្រូវស្នាក់នៅហូបចុកទីនោះរហូតដល់អាយុ ១៧ ឆ្នាំ។ សាលារៀននោះស្ថិតនៅមិនឆ្ងាយពីផ្ទះរបស់គេប៉ុន្មានទេ ដូច្នេះហើយគេតែងតែលួចទៅលេងផ្ទះជាញឹកញាប់ ដោយប្រើពេលវេលារត់ទៅផ្ទះនៅពេលល្ងាចនិង

វិលត្រឡប់មកផ្ទះវិញឲ្យបានមុនគេបើកទ្វារសាលារៀន។ ដាវីន មិនសូវចូលចិត្តសាលារៀននេះប៉ុន្មានទេ ពីព្រោះសាលារៀននេះបង្រៀនផ្តោតសំខាន់ទៅលើមុខវិជ្ជាមនុស្សសាស្ត្រ ដែលវាមិនស្របនឹងចំណង់ចំណូលចិត្តរបស់គាត់ គាត់ចូលចិត្តវិទ្យាសាស្ត្រ ហើយមិនមានទេពកោសល្យផ្នែកភាសាសូម្បីតែបន្តិចណាឡើយ តែក្នុងរយៈចុងក្រោយនៃការសិក្សានៅទីនោះគាត់ស្រាប់តែបានជួបនូវរឿងសប្បាយចិត្តយ៉ាងខ្លាំង ដែលគាត់បានសរសេរទុកថា «មុននឹងខ្ញុំចាកចេញពីសាលារៀននេះ ខ្ញុំក្លាយជាមនុស្សដែលជំនាញបាញ់សត្វ ហើយខ្ញុំគិតថាវាប្រហែលជាគ្មាននរណាម្នាក់ព្យាយាមហ្វឹកហាត់ធ្វើក្នុងរឿងនេះដូចខ្ញុំទេ»។

ក្រោយរៀនចប់ថ្នាក់មធ្យមសិក្សា គាត់មិនបានសាងកេរ្តិ៍ឈ្មោះជាសិស្សពូកែអ្វីឡើយ ហើយក៏គ្មាននរណាគិតថាគាត់នឹងមានអច្ឆរិយៈអ្វីដែរ សូម្បីឪពុកដែលជាបុគ្គលពោរពេញដោយចំណេះដឹងនោះផងដែរ។ ដាវីន ត្រូវឪពុកបញ្ជូនទៅសិក្សាវិជ្ជាពេទ្យនៅមហាវិទ្យាល័យ អេឌិនបឺក ទីនោះទៀតសោត មនុស្សទាំងឡាយគិតថាយុវនិស្សិតមានសមត្ថភាពជាមធ្យមម្នាក់នេះគ្មានអ្វីដែលលេចធ្លោឡើយ ការសិក្សាវិជ្ជាពេទ្យរបស់គេក៏គ្មានបានលទ្ធផលអ្វីដែរ។ សម្រាប់ ដាវីន មិនត្រឹមតែមានអារម្មណ៍ធុញទ្រាន់ចំពោះការចាក់ម្ជុលប៉ុណ្ណោះទេ ថែមទាំងត្រូវទ្រាំមើលសាកសពដែលគេយកមកវះកាត់ក្នុងការបង្រៀនទាំងវេទនាទៀតផង។

ក្រោយពីនោះមក គាត់បានប្តូរទៅរៀនផ្នែកទេវវិទ្យា ហើយគាត់ចាំបាច់ត្រូវរៀនភាសាក្រិចបុរាណបន្ថែមទៀត ព្រោះគាត់បានភ្លេចភាសា

ក្រិចអស់ទៅហើយ ប៉ុន្តែទោះបីជាគាត់ព្យាយាមរៀនផ្នែកទេវវិទ្យាយ៉ាង ក៏ដោយក៏មិនបានជោគជ័យឡើយ។ នៅក្នុងខណៈពេលគាត់កំពុងតែ តែលតោលចាប់នេះផុតចាប់នោះផុត ជាចៃដន្យ មានគេបបួលគាត់ឲ្យ ចូលរួមជាមួយក្រុមសិក្សាធម្មជាតិតាមកប៉ាល់ "ប៊ីហ្គើល" នៅពេលនោះ យុវជន ដាវីន មានឱកាសបានធ្វើដំណើរទស្សនាចរជុំវិញពិភពលោក អស់រយៈពេល ៥ ឆ្នាំ។

នេះហើយជាចំណុចចាប់ផ្តើម នៃការសិក្សាស្រាវជ្រាវលើជំនាញ ឯកទេសធម្មជាតិវិទ្យារបស់ ដាវីន។ ឆាលស៍ ដាវីន បានសិក្សាស្រាវជ្រាវ រកឃើញទ្រឹស្តីវិវឌ្ឍនាការដ៏ល្បីរន្ទឺ ដែលបានបណ្តុះជំនឿដល់ជនជាតិ អឺរ៉ុបក្នុងសម័យនោះ ដែលមានជំនឿថា ព្រះជាម្ចាស់ជាអ្នកបង្កើតលោក និងមនុស្សជាតិ ក៏ប៉ុន្តែគាត់មានជំនឿថាមនុស្សមានបុព្វបុរសជាមួយគ្នា នឹងសត្វស្វា ស្មើនឹងមនុស្សកើតពីសត្វស្វា ហើយបានក្លាយជាបញ្ហាដែល មនុស្សទាំងឡាយនៅតែនាំគ្នាជជែកវែកញែករកខុសរកត្រូវ រហូតមកដល់ ពេលបច្ចុប្បន្ននេះ។

# មហាត្មៈគន្ធី

( Mahatma Gandhi, India ) គ.ស. ១៨៦៩ - ១៩៤៨

បើទោះបីគាត់ជានិស្សិតផ្នែកច្បាប់ក៏ដោយ ក៏នៅតែជាប់សន្ដានអៀនខ្មាស ប៉ុន្តែគាត់បានក្លាយជាអ្នកនិយាយដ៏មានឥទ្ធិពល និងជាវីរបុរសរបស់ប្រជាជនឥណ្ឌា។



មហាត្មៈគន្ធី បុគ្គលដែលតស៊ូដើម្បីឯករាជនៃអាណាចក្រឥណ្ឌា គាត់បានឆ្លងកាត់ការសិក្សាគ្រប់កម្រិត តែគ្មានអ្វីលេចធ្លោគួរឲ្យកត់សម្គាល់ឡើយ។ ឈ្មោះដើមរបស់គាត់គឺ មហ័នដាស ខារាមច័ន្ទ កើតនៅថ្ងៃទី ២ ខែតុលា គ.ស. ១៨៦៩ ក្នុងទីក្រុង ផរ័ម៉ាន់ដា តាំងពីកុមាររហូតដល់ធំពេញវ័យបានចូលរៀននៅមហាវិទ្យាល័យហើយ ក៏នៅតែជាមនុស្សពូកែអៀនខ្មាសយ៉ាងខ្លាំងដូចដើម។

កាលរៀននៅថ្នាក់បឋមសិក្សា គាត់ជួបបញ្ហាខ្លះៗដូចជា ការធ្វើជីវប្រវត្តិសង្ខេបរបស់ខ្លួន ដូចដែលគាត់បានពោលទុកថា «ខ្ញុំជាសិស្សដែលរៀនបានពូកែជាមធ្យម» ប៉ុន្តែ គន្ធី ជាសិស្សមានការទទួលខុសត្រូវខ្ពស់និងជាមនុស្សស្លូតបូតទៀងត្រង់។

បញ្ហាដ៏ធំមួយដែល គន្ធី មានកាលនៅវ័យក្មេងគឺ ខ្លាចគេសើចចំអកឡកឡឺយ ជាពិសេសគឺគាត់មិនសូវចូលចិត្តនិយាយស្តីព្រោះគាត់មិនអាចនិយាយបានយ៉ាងស្ទាត់មាត់ និងមិនអាចនិយាយចេញឲ្យពេញប្រយោគបានឡើយ។ ពេលនិយាយម្តងៗបែបតដិតនិងរដាក់រដុបរកថាអ្វីមិនត្រូវ ករណីនេះហើយដែលធ្វើឲ្យគាត់មានសេចក្តីខ្មាសអៀនយ៉ាងខ្លាំង។ ពុំមាននរណាអាចដឹងមុនបានឡើយថា និស្សិតផ្នែកច្បាប់ដែលពូកែអៀនខ្មាសម្នាក់នេះ ក្លាយជាអ្នកដឹកនាំប្រកបដោយវោហារកោសល្យមានឥទ្ធិពលនិងជាបុគ្គលតស៊ូក្នុងឆាកនយោបាយដ៏ល្បីល្បាញបំផុតក្នុងសតវត្សរ៍ទី ២០ នៃប្រទេសឥណ្ឌា។

មហ៉ានដាស ខារាមច័ន្ទ ឬ មហាត្មៈគន្ធី ហ្នឹងឯងដែលជាអ្នកដឹកនាំចលនាតស៊ូប្រឆាំងជាមួយចក្រពត្តិអង់គ្លេស ដោយប្រើគោលការណ៍ធម៌អហិង្សា មិនប្រើកម្លាំងបាយ និងប្រកាន់ខ្ជាប់នូវធម៌ខន្តីតស៊ូអត់ធ្មត់រហូតបានទទួលរហស្សនាមថា «មហាត្មៈគន្ធី» ដែលមានន័យថាបុគ្គលដែលដឹងច្បាស់នូវសច្ចភាព ហើយបានបង្រៀនមនុស្សជាច្រើនលាននាក់ឲ្យដើរលើផ្លូវត្រូវ។ មហាត្មៈគន្ធី បានបង្រៀនថា អ្វីៗគ្រប់យ៉ាងត្រូវស្ថិតនៅលើមាគ៌ានៃសច្ចភាពនិងសីលធម៌ម្យ៉ាងគត់ ហើយអហិង្សាតែងតែឈ្នះហិង្សាជានិច្ច។

# ម៉ាទីន លូថឺរ៍

( Martin Luther, Germany ) គ.ស. ១៤៨៣ - ១៥៤៦

អាណាព្យាបាលគួរតែផ្តល់
ឱកាសឲ្យកូនបានរៀនសូត្រ។
យ៉ាងហោចណាស់ក្នុងមួយថ្ងៃ
១ ម៉ោងទៅ ២ ម៉ោងក៏ជាការល្អដែរ
ជាពិសេសពេលដែលក្មេងទំនេរពីការងារ
ស្រេចម្ការឬកិច្ចការផ្ទះផ្សេងៗ។



ម៉ាទីន លូថឺរ៍ កើតនៅថ្ងៃទី ១០ ខែវិច្ឆិកា គ.ស.១៤៨៣ ក្នុងទីក្រុង អែស៍លែបិន គាត់មិនមែនជាកូនកសិករក្រីក្រដូចដែលមានការពោលអះអាងក្នុងរឿងនិទានមួយចំនួននោះទេ ឪពុករបស់គាត់ជាម្ចាស់អាជីវកម្មត្បូងថ្មដែលទទួលបានភាពជោគជ័យយ៉ាងខ្លាំង នេះអាចសាងជីវភាពគ្រួសារឲ្យរស់នៅបានយ៉ាងសុខស្រួល។ ក្នុងនាមជាឪពុកតែងតែអប់រំទូន្មានប្រៀនប្រដៅកូនរបស់ខ្លួនយ៉ាងម៉ឺងម៉ាត់ ដោយបានជំរុញឲ្យម៉ាទីន លូថឺរ៍ ខិតខំប្រឹងប្រែងរៀនសូត្រឲ្យបានល្អបំផុតព្រោះមានគោលបំណងចង់ឲ្យ ម៉ាទីន លូថឺរ៍ ក្លាយជាគ្រូបង្រៀនផ្នែកច្បាប់នាថ្ងៃអនាគត។

នៅក្នុងឆ្នាំ ១៤៨៤ ក្រុមគ្រួសាររបស់គាត់ផ្លាស់ទីលំនៅទៅរស់នៅឯក្រុង ម៉ាន់ស៍ហ្វែត៍ ក្នុងពេលដែល ម៉ាទីន មានអាយុ ៥ ឆ្នាំ ឪពុកបានបញ្ជូនឲ្យចូលរៀននៅសាលា ឡាទីន គាត់រៀននៅទីនោះអស់រយៈពេល ១៤ ឆ្នាំទើបបានប្តូរទៅរៀននៅសាលារៀនសាសនាប្រចាំទីក្រុងម៉ាក់ឌៃហ្វ៊ក។ បន្ទាប់ពីនោះ ត្រឹមតែមួយឆ្នាំប៉ុណ្ណោះក្រុមគ្រួសាររបស់គាត់ក៏បានផ្លាស់ទៅរស់នៅឯក្រុង អែស៊ែនណ៉ាក ហើយ ម៉ាទីន ក៏បានផ្លាស់ទៅរៀននៅឯសាលាសាសនាមួយកន្លែងទៀតនៃ ស៊ិនត៍ក៍រអកែន។

ម៉ាទីន លូធឺរ៍ បានបន្តការសិក្សានៅមហាវិទ្យាល័យ អែហ្វឺត ផ្នែកសិល្បៈនិងបានបញ្ចប់ការសិក្សានៅឆ្នាំ ១៥០៥ បន្ទាប់ពីនោះទើបគាត់បានរៀនបន្តផ្នែកច្បាប់ ប៉ុន្តែជាអកុសលគាត់ទើបតែចូលរៀនបានពីរខែប៉ុណ្ណោះស្រាប់តែមានរឿងហេតុកើតឡើងមិនគួរឲ្យជឿគឺ គាត់ស្ទើរតែត្រូវរន្ទះបាញ់ស្លាប់នៅក្បែរទីក្រុង អែហ្វឺត ដោយហេតុការណ៍នេះក៏បានឈប់រៀន ហើយបានបួសជាបព្វជិតសាសនាគ្រិស្តនៅទីក្រុង អែហ្វឺត។

យើងពុំមានឯកសារស្តីពីការសិក្សារបស់ ម៉ាទីន លូធឺរ៍ ឲ្យបានច្រើនជាងនេះនោះទេ ប៉ុន្តែគាត់ប្រហែលមិនមែនជាសិស្សដែលព្រងើយកន្តើយចំពោះការសិក្សារៀនសូត្រ ឬក៏ជាសិស្សដែលរៀនសូត្រមិនបានដិតដល់នោះដែរ ពីព្រោះបិតារបស់គាត់ជាមនុស្សដែលពោរពេញដោយមហិច្ឆតាប្រាថ្នាចង់ឲ្យកូនមានចំណេះដឹង ហើយតែងតែមើលថែនិងផ្តល់ឱកាសសិក្សារៀនសូត្រដល់កូនដោយយកចិត្តទុកដាក់ (ក្នុងសម័យនោះបង្ខំកូនឲ្យរៀនដោយការវាយដោយរំពាត់)។

មានកំណត់ហេតុបង្ហាញថា ម៉ាទីន លូថឺរ៍ កាលនៅក្នុងវ័យសិក្សា ពុំសូវមានសេចក្តីសុខឡើយ ហើយគាត់ថែមទាំងស្អប់វិធីបង្ហាត់បង្រៀនក្នុងសម័យនោះទៀតផង។ គាត់បានរំឭកពីបទពិសោធក្នុងសាលារៀនដែលគាត់បានឆ្លងកាត់ដូច្នេះថា «ឋាននរកនិងអណ្តាតភ្លើងបានដុតកម្តៅបាបនៅកន្លែងដែលពួកយើងត្រូវគេធ្វើទារុណកម្ម យើងមិនអាចរៀនអ្វីបានឡើយដោយសារការវាយដំបែបនោះ យើងបានត្រឹមតែញ័រចំប្រប់សព្វខ្លួនប្រាណដោយការភ័យខ្លាចនិងសេចក្តីទុក្ខដ៏ធ្ងន់ធ្ងរ»។

ពីបទពិសោធដ៏ល្វីងជូចត់ ដែលគាត់បានជួបប្រទះក្នុងវ័យសិក្សានោះឯង ជាបុព្វហេតុធ្វើឲ្យគាត់ជំរុញនិងគាំទ្រឲ្យមានការផ្លាស់ប្តូរប្រព័ន្ធអប់រំនៅតាមសាលារៀន ចាប់តាំងពីថ្នាក់បឋមសិក្សារហូតដល់ថ្នាក់មហាវិទ្យាល័យ កុំប្រើប្រាស់មធ្យោបាយបង្ខិតបង្ខំគំរាមកំហែងនិងគាបសង្កត់សិស្សានុសិស្ស។ បណ្តាលោកគ្រូអ្នកគ្រូទាំងឡាយគួរគប្បីប្រើតែមនោសញ្ចេតនា សេចក្តីស្រឡាញ់ និងយល់អធ្យាស្រ័យក្នុងការបង្ហាត់បង្រៀនកូនសិស្សវិញ។ អ្វីដែល ម៉ាទីន លូថឺរ៍ ខ្វល់ខ្វាយយ៉ាងខ្លាំងនោះគឺសាលារៀនមានគុណភាពខ្សោយទៅៗ ព្រោះតែខ្វះអ្នកមកទទួលខុសត្រូវពិតប្រាកដនិងបញ្ហាកង្វះខាតថវិកាសម្រាប់ឧបត្ថម្ភគាំទ្រ។

នៅក្នុងឆ្នាំ ១៥២៤ គាត់បានសរសេរសំបុត្រផ្ញើទៅកាន់ភាគីនយោបាយគ្រប់ខេត្តក្រុង និងអំពាវនាវឲ្យបង្កើតសាលារៀនសាសនាគ្រិស្តឡើង ដែលមានហេតុផលស្តាប់ទៅហាក់បីដូចជានៅទាន់សម័យនៅឡើយ ថ្វីត្បិតថារឿងរ៉ាវទាំងអស់នេះបានកើតឡើងជាង ៤០០ ឆ្នាំ

កន្លងទៅហើយក៏ដោយ។ នៅក្នុងសំបុត្រនោះគាត់បានសរសេររៀបរាប់ថា «ពួកយើងបានជួបប្រទះដោយផ្ទាល់មកហើយថា ក្នុងរដ្ឋទាំងឡាយនៃប្រទេសអាល្លឺម៉ង់ មានការបណ្តែតបណ្តោយចំពោះសាលារៀនយ៉ាងណាខ្លះ។ សាលាដែលរាល់គ្នាគិតថា ផ្តល់ការសិក្សាលំដាប់ខ្ពស់ក៏ខ្សោយទៅៗ អារាមនៃសាសនាគ្រិស្តទាំងឡាយក៏បាត់បង់ទៅបន្តិចម្តងៗ គ្មាននរណាចាប់អារម្មណ៍ និងអើពើពីបញ្ហាដែលកំពុងតែកើតឡើងទាំងនេះឡើយថានឹងនាំមកនូវហាយនភាពដល់សង្គមកម្រិតណា។ គ្មាននរណាចាប់អារម្មណ៍សង្កេតឡើយថា កំពុងមានរឿងអ្វីកើតឡើងនៅក្នុងសង្គមហើយបែរមករកការប្រឹក្សាយោបល់គ្នា ដើម្បីរិះរកមធ្យោបាយទប់ស្កាត់និងស្តារឡើងវិញឡើយ ដោយពួកយើងរវល់តែភ័យខ្លាចនឹងជនជាតិទួរគី សង្គ្រាម និងបញ្ហាក្រពះព្រោះយើងបានយល់ច្បាស់អំពីប្រយោជន៍ឬការខូចខាតនៃរឿងទាំងអស់នោះ។ ប៉ុន្តែគ្មាននរណាយល់ពីគុណតម្លៃនៃការសិក្សាដែលជារឿងសំខាន់បំផុតសម្រាប់សង្គមជាតិ។ វាប្រហែលជាមធ្យោបាយសមរម្យនិងសន្សំសំចៃមួយ ប្រសិនយើងហ៊ានលះបង់ថវិកាម្នាក់មួយកាក់មួយសេន ដើម្បីជួយឧបត្ថម្ភក្នុងការធ្វើសង្គ្រាមប្រឆាំងនឹងពួក ទួរគី ក៏ប៉ុន្តែសម្រាប់ខ្ញុំគិតថាប្រហែលជាល្អប្រសើរដូចគ្នាប្រសិនជាយើងហ៊ានលះបង់ថវិកាក្នុងម្នាក់មួយកាក់មួយសេន ដើម្បីជួយឧបត្ថម្ភក្នុងការផ្តល់ការសិក្សាអប់រំដល់យុវជនជំនាន់ក្រោយ ដើម្បីឲ្យពួកគេមានអនាគតល្អ និងក្លាយជាគ្រិស្ទៀនដ៏ល្អនាថ្ងៃអនាគតខាងមុខ ដូច្នឹងហើយទើបខ្ញុំមានបំណងសំណូមពរដល់បណ្តាអស់លោកទាំងឡាយ មេត្តាយល់ដល់ព្រះជាម្ចាស់ និងគិតដល់យុវជនជំនាន់ក្រោយដ៏គួរឲ្យអាណិតរបស់

យើង សូមមេត្តាកុំបណ្ដែតបណ្ដោយក្នុងរឿងនេះឡើយព្រោះបញ្ហានេះជាបញ្ហាដ៏ធំយ៉ាងពិតប្រាកដ ជារឿងដែលព្រះអង្គម្ចាស់ព្រះយេស៊ូគ្រិស្ដទ្រង់កង្វល់ ហើយមនុស្សក្នុងលោកគិតខ្វល់ខ្វាយយ៉ាងខ្លាំងថាតើគួរជួយសង្គ្រោះនិងផ្ដល់យោបល់ដល់យុវជនរបស់យើងយ៉ាងណា។ បើសិនជាយើងជួយពួកគេទាំងនោះបាន វាក៏បីដូចជាពួកយើងបានជួយខ្លួនយើងអ៊ីចឹងដែរ។ អស់លោកជាទីគោរពស្រឡាញ់ទាំងឡាយ ពួកយើងបានចាយវាយលុយកាក់ប្រាក់កាសអស់ច្រើនណាស់ហើយ ក្នុងការទិញអាវុធកសាងផ្លូវថ្នល់ កសាងទំនប់ទឹក (អាងរក្សាទឹកទុក) និងបញ្ហាក្រពះ ឬសេចក្ដីសុខសុវត្ថិភាពផ្សេងៗ ដើម្បីឲ្យប្រទេសយើងមាននូវសេចក្ដីសុខសន្តិភាព ហេតុអ្វីបានជាយើងមិនចាយវាយប្រាក់ឲ្យច្រើនជាងនេះបន្តិចឬក៏ប៉ុនគ្នានេះដើម្បីជួយយុវជនរបស់យើងដែលកំពុងតែខ្វះខាត ដើម្បីឲ្យពួកគេបានជាអ្នកចេះដឹងនិងជាបញ្ញវន្តប្រកបដោយសមត្ថភាព អាចជួយសង្គ្រោះសង្គមជាតិយើងបាននាថ្ងៃអនាគតតទៅ»។

ម៉ាទីន លូថឺរ៍ យល់ឃើញថាសាលារៀនជាស្ថាប័នដែលសំខាន់បំផុត ពីព្រោះថាបណ្ដាអាណាព្យាបាលរបស់ក្មេងៗមិនអាចអប់រំបង្ហាត់បង្រៀនកូនខ្លួនឯងបាន គាត់បានពោលថា «ឪពុកម្ដាយរបស់ក្មេងៗជាច្រើនមិនដឹងថា គួរតែអប់រំឬផ្ដល់ចំណេះដឹងដល់កូនប្រុសស្រីរបស់ខ្លួនយ៉ាងណានោះទេ ពីព្រោះថាពួកគេក៏មិនបានឆ្លងកាត់ការសិក្សាអ្វីឡើយក្រៅពីការរកស៊ីចិញ្ចឹមក្រពះពីមួយថ្ងៃទៅមួយថ្ងៃ»។ ក្រៅពីនេះនៅមានមនុស្សជាច្រើននាក់បានសួរគាត់ថា តើវាសមគួរដែរឬទេដែលយើងត្រូវ

រៀនភាសា ឡាទីន ភាសាក្រិចបុរាណ និងភាសាហ៊ីប្រ៊ូ (Hebrew) ព្រោះយើងក៏អាចបង្រៀនសិស្សឲ្យសិក្សាពីគម្ពីរប៊ីប ជាភាសាអាល្លឺម៉ង់បានដែរតើ។

លោក ម៉ាទីន លូធើរ៍ ឆ្លើយតបនឹងសំណួរទាំងនោះដោយផ្ដល់ជាគំនិតថា «មែនហើយ ខ្ញុំដឹងយ៉ាងច្បាស់គួរសមដែរថា ពួកយើងជនជាតិអាល្លឺម៉ង់ ជាសត្វព្រៃ ហើយវានឹងនៅជាសត្វព្រៃដូច្នេះតទៅក្នុងខ្សែភ្នែករបស់ប្រទេសជិតខាង។ ដោយឡែក ខ្ញុំចម្លែកក្នុងចិត្តថាហេតុអ្វីបានជាពួកយើងពុំដែលនិយាយឡើយសូម្បីតែម្ដងថា ពួកប្រភេទទំនិញដែលមកពីក្រៅប្រទេសដូចជាកំណាត់សូត្រ ស្រា ឬគ្រឿងឧបភោគបរិភោគ វាគ្មានសារៈសំខាន់អ្វីចំពោះជីវិតពួកយើងទៅ តែពួកយើងនៅតែប្រាថ្នាចង់បានវត្ថុទាំងអស់នោះអ្វីម្ល៉េះ ស្របពេលដែលផែនដីនៃប្រទេសអាល្លឺម៉ង់របស់យើងក៏សម្បូរហូរហៀរទៅដោយស្រាក្នុងតំបន់ គ្រាប់ពូជធញ្ញជាតិគ្រប់ប្រភេទ កំណាត់ធ្វើពីរោមសត្វ ឈើ និងថ្មដែលយើងអាចនឹងប្រើប្រាស់ដោយមិនបាច់បារម្ភពីអ្វីឡើយ។ ប៉ុណ្ណឹងហើយក៏ដោយ ក៏ពួកយើងនៅតែមិនអាចខ្វះអីវ៉ាន់មកពីក្រៅប្រទេសទាំងនោះឡើយ។ បើយើងនិយាយពីចំណេះដឹង ជំនាញ ឬភាសាបរទេសដែលនឹងញ៉ាំងប្រយោជន៍ឲ្យកើតសតិបញ្ញាដល់ពួកយើងនោះ ពួកយើងបែរជាគេចវេះឬធ្វើព្រងើយកន្តើយមិនយកចិត្តទុកដាក់ក្នុងរឿងទាំងអស់នេះទៅវិញ តើនេះមិនមែនមានន័យថាពួកយើងដូចជាជនជាតិនៃមនុស្សព្រៃ ឬជាប្រភេទពួកឡប់សតិទៅហើយឬយ៉ាងណា?»។

នៅតាមបណ្ដាសាលារៀនទាំងឡាយ ដែលមានបង្ហាត់បង្រៀនភាសាបរទេសគួរតែអភិវឌ្ឍឲ្យបានល្អប្រសើរជាងនេះ មិនមែននៅតែបន្តប្រើវិធីវាយសំឡុតតែម្យ៉ាង ដោយមិនបានបង្ហាត់បង្រៀនអ្វីដល់ពួកកូនសិស្សឲ្យប្រាកដប្រជានោះឡើយ។ ម៉ាទីន លូធើរ៍ ហៅសាលារៀនទាំងនោះថា «ជាសាលារៀននរក...! មែនហើយ... អ្វីដែលមនុស្សម្នានាំគ្នារៀននៅតាមសាលានិងនៅតាមអារាមសាសនាគ្រិស្តផ្សេងៗនោះ ក៏គឺរៀនដើម្បីក្លាយជាសត្វលាល្ងង់ខ្លៅ។ យើងនាំគ្នារៀន ២០ ឆ្នាំឬ ៤០ ឆ្នាំក៏នៅតែមិនអាចធ្វើអ្វីបានសូម្បីតែជួយខ្លួនឯង។ ខ្ញុំសូមមិននិយាយដល់ជីវិតដ៏សែនអាក្រក់ និងពោរពេញទៅដោយបាបកម្មនៃបណ្ដាកូនអ្នកមានទាំងឡាយដែលបានក្លាយជាជនពាលអាវ៉ាសែ ទាំងអស់នេះត្រូវបន្ទោសសាលារៀនទាំងនោះ ដែលមិនបានបង្ហាត់បង្រៀនក្មេងៗទាំងនោះឲ្យមានចំណេះដឹងនិងវិធីនៃការដំណើរជីវិតបានយ៉ាងត្រឹមត្រូវសមរម្យ។ ខ្ញុំមានបំណងចង់ឃើញសាលាទាំងនោះ ប្រែក្លាយទៅជាសាលារៀនគ្រិស្ទៀនដ៏សមរម្យ បើមិនដូច្នោះទេសូមធរណីស្រូបសាលារៀននរកទាំងនេះទៅផងចុះ»។

ក្នុងសំបុត្រដែលគាត់បានសរសេរផ្ញើទៅកាន់ក្រុមអ្នកនយោបាយនៅតាមខេត្តក្រុងនានានោះ គាត់បានភ្ជាប់ព័ត៌មានលម្អិតស្ដីពីបញ្ហារបស់សិស្សដែលពាក់ព័ន្ធនឹងឪពុកម្ដាយអាណាព្យាបាលផងដែរ។ ក្នុងសម័យនោះឪពុកម្ដាយ ឬអាណាព្យាបាលភាគច្រើនមិនចង់ឲ្យកូនទៅសាលារៀនទេ ព្រោះពួកគេត្រូវការប្រើកូនៗរបស់ពួកគេឲ្យធ្វើកិច្ចការផ្ទះ ឬធ្វើស្រែ

ចម្ការ។ មានអ្នកខ្លះធ្លាប់និយាយទៅកាន់ ម៉ាទីន លូធើរ៍ ទាំងងើល និងគឃ្លើនថា «មែនហើយ... លោកឯងពូកែតែមាត់ប៉ុណ្ណោះ... មានឪពុកម្ដាយឯណាដែលមិនចង់ឲ្យកូនជួយធ្វើការងារជំនួសឱ្យកូនទៅរៀននោះ»។

ម៉ាទីន លូធើរ៍ ឆ្លើយតបទៅវិញថា «ខ្ញុំគិតថាពួកយើងគួរតែផ្ដល់ឱកាសដល់ក្មេងៗបានសិក្សារៀនសូត្រ យ៉ាងហោចណាស់មួយថ្ងៃមួយម៉ោងឬពីរម៉ោងក៏ជាការល្អដែរ។ ជាពិសេស ក្នុងចន្លោះពេលដែលក្មេងទំនេរពីកិច្ចការងារផ្ទះឬការងារស្រែចម្ការ។ ឪពុកម្ដាយគ្រប់រូបគួរតែផ្ដល់ឱកាសដល់កូនៗបានសិក្សារៀនសូត្រផង ជួយធ្វើកិច្ចការងារផងប្រសើរជាងបណ្ដោយកូនរបស់អស់លោកចំណាយពេលវេលាឥតប្រយោជន៍ទៅលេងបាល់ រត់លេងឬវាយតប់គ្នាដែលគ្មានបានផលប្រយោជន៍ខាងផ្នែកសតិបញ្ញាស្មារតីអ្វីសោះឡើយ។ ចំណែកកូនស្រីគួរតែឲ្យនាងបានទៅរៀនមួយថ្ងៃមួយម៉ោងក៏ជាការល្អដែរ ហើយពួកនាងក៏អាចធ្វើការងារផ្ទះបានយ៉ាងមានរបៀបរៀបរយទៀតផង វាប្រសើរជាងបណ្ដោយឲ្យពួកនាងដេកខ្ជិលអេះពោះនៅផ្ទះ ឬក៏ទៅដើរលេងរាំរែកឥតប្រយោជន៍ ឬថាទៅប្រព្រឹត្តអំពើផ្ដេសផ្ដាសដែលមិនគួរធ្វើ។ ពួកក្មេងៗទាំងនេះនៅថ្ងៃអនាគតនឹងក្លាយជាបុគ្គលដ៏មានគុណតម្លៃចំពោះសង្គមជាតិដូចជា គ្រូបាអាចារ្យអ្នកទេសនា (សាសនាគ្រិស្ត) ឬធ្វើការងារផ្សេងៗទៀតដែលអាចញ៉ាំងប្រយោជន៍ដល់សង្គម ជាតិ សាសនាបាន»។

ក្រៅពីនេះ ម៉ាទីន លូថឺរ៍ ក៏បានអំពាវនាវដល់បណ្ដាមន្ត្រីរាជការទាំងអស់ ឱ្យយកចិត្តទុកដាក់ និងបង្កើតជាបណ្ណាល័យសម្រាប់យុវជន។ នៅទីបញ្ចប់នៃសេចក្ដីសំបុត្រនោះ គាត់បានសរសេរថា «វាគួរឲ្យស្ដាយខ្លាំងណាស់ ដែលពួកយើងលិចលង់នៅក្នុងភាពអន្ធការជាយូរយារណាស់មកហើយ»។

# ជេមស៍ ចយស៍

(James Joyece, Ireland) គ.ស. ១៨៨២ - ១៩៤១

គាត់ត្រូវបានគ្រូវាយបាតដៃយ៉ាងខ្លាំង ដោយចោទថាគាត់ខ្ជិលធ្វើលំហាត់ ប៉ុន្តែតាមការពិតគាត់បានធ្វើឲ្យវ៉ែនតារបស់គាត់ធ្លាក់បែកទើបមិនអាចធ្វើលំហាត់នៅផ្ទះបាន។



សម្រាប់លោក ជេមស៍ ចយស៍ វិញសាលារៀនប្រៀបបីដូចជាភ្នំគិរីវង្គតអ៊ីចឹងដែរ។ គាត់កើតនៅថ្ងៃទី ២ ខែកុម្ភៈ គ.ស. ១៨៨២ ក្នុងទីក្រុង ដាប់ឡាំង ប្រទេសអៀរឡង់។ នៅពេលគាត់មានអាយុ ៦ ឆ្នាំជាពេលវេលាមួយដែលត្រូវធ្វើដំណើរឆ្លងកាត់ក្លោងទ្វារដ៏ធំមហិមា ដើម្បីចូលទៅកាន់សាលារៀន ក្លូនកូវូឌ ដែលគ្រប់គ្រងដោយគណាចារ្យនៃសាសនាគ្រិស្ត។ នៅក្នុងភាពយុវវ័យ ចយស៍ បានពិពណ៌នារៀបរាប់អំពីរឿងរ៉ាវដែលគាត់បានជួបប្រទះនៅក្នុងសាលារៀននោះដូចតទៅ ៖

ថ្ងៃមួយ គាត់បានធ្វើឲ្យវ៉ែនតារបស់គាត់ធ្លាក់បែក ហើយគាត់ក៏មិនអាចរៀនឬធ្វើលំហាត់បានឡើយ។ ប៉ុន្តែគ្មាននរណាម្នាក់ជឿគាត់ទេ គ្រូគិតថាគាត់រកលេសដោះសាដូចដែលសិស្សដទៃធ្លាប់ធ្វើកន្លងមក។

សម្ដីគ្រូ «ឯង...អាក្មេងខ្ទង់វែង...កម្ជិលផេះ...ហុចដៃមកឥឡូវនេះភ្លាម» គ្រូបានប្រើរំពាត់វាយលើបាតដៃដ៏ក្រហមរបស់គាត់ជាច្រើនដងរហូតដល់ទឹកភ្នែកហូរជោកថ្ពាល់ ផ្ទៃមុខរបស់គេឡើងក្រហមប្រកបដោយភាពខ្មាសអៀន សេចក្ដីភ័យខ្លាច និងការឈឺចាប់ឥតឧបមា។

នៅតាមបណ្ដាសាលារៀននានាក្នុងប្រទេសអង់គ្លេស នាសម័យបច្ចុប្បន្ននេះ នៅតែប្រើវិធីដាក់ទោសទណ្ឌចំពោះកូនសិស្សបែបនេះនៅឡើយ។ ទោះជាមានលោកគ្រូអ្នកគ្រូមួយចំនួនធំបានព្យាយាមអំពាវនាវដើម្បីឲ្យបញ្ឈប់នូវការប្រើប្រាស់វិធីដាក់ទោសទណ្ឌកម្មសិស្ស ដោយការវាយដំបែបនេះតទៅទៀតក៏នៅតែគ្មានប្រសិទ្ធិភាពនៅឡើយ គឺមានការកែប្រែចំពោះសាលារៀនខ្លះៗតែប៉ុណ្ណោះ។ ជេមស៍ ចយស៍ អាចឆ្លងផុតដំណាក់កាលជីវិតដ៏សែនលំបាកលំបិននេះបានក៏ពិតមែន ប៉ុន្តែគាត់រស់ក្នុងភាពកណ្ដោចកណ្ដែង ឯកា និងពុំសូវមានមិត្តភក្ដិឡើយ។ ទោះបីជាគាត់មិនមែនជាសិស្សដែលមានសមត្ថភាពលេចធ្លោក៏ដោយ គាត់ក៏បានព្យាយាមស្វែងរកចំណេះដឹង និងបទពិសោធពីសង្គមដោយផ្ទាល់ រហូតបានក្លាយជាកវីនិពន្ធដ៏ល្បីល្បាញម្នាក់នៅក្នុងពិភពលោក។

# ខាល ម៉ាក្ស

(Karl Marx, German Confederation) គ.ស. ១៨១៨ - ១៨៨៣

កាលអាយុ ១៧ ឆ្នាំ គាត់បានសរសេរតែងសេចក្ដីមួយដែលមានសេចក្ដីថា«ប្រវត្តិសាស្ត្របានប្រាប់យើងថាបុគ្គលដែលមានសេចក្ដីសុខបំផុតគឺបុគ្គលដែលបានធ្វើឲ្យមនុស្សភាគច្រើនមានសេចក្ដីសុខ»។



KARL MARX

ខាល ម៉ាក្ស ក៏ជាបុគ្គលម្នាក់នៅក្នុងចំណោមសិស្សដែលមិនមានទេពកោសល្យអ្វីជាពិសេសឡើយ។ គាត់កើតនៅថ្ងៃទី ៥ ខែឧសភា គ.ស. ១៨១៨ នៅក្នុងទីក្រុង ត្រៀរ៍ ជាកូនរបស់អ្នកច្បាប់ម្នាក់ដែលដើមឡើយជាជនជាតិ ជ្វីហ្វ។ ប៉ុន្តែក្រោយមកបានប្ដូរមកកាន់សាសនាគ្រិស្តព្រមទាំងបាននាំ ខាល ដែលទើបតែមានអាយុ ៦ ឆ្នាំចូលកាន់សីលបែបសាសនាគ្រិស្តផងដែរ។ ខាល ចូលរៀននៅសាលា ហ្វ្រីតរីច វិលហែមរយៈ ៥ ឆ្នាំ។ គាត់បានបញ្ចប់ការសិក្សាថ្នាក់មធ្យមសិក្សានៅពេលគាត់មានអាយុ ១៧ ឆ្នាំ ហើយនៅក្នុងសញ្ញាបត្ររបស់គាត់បញ្ជាក់ថាលទ្ធផលនៃការសិក្សារបស់គាត់ល្អប្រសើរលើមុខវិជ្ជាភាសាបុរាណ ភាសាអាល្លឺម៉ង់និងប្រវត្តិសាស្ត្រ ហើយបានពិន្ទុល្អគួរជាទីពេញចិត្តលើមុខវិជ្ជាគណិតវិទ្យាភាសាបារាំងនិងបានពិន្ទុល្អបង្គួរលើមុខវិជ្ជាសាសនា ចំណែករូបវិទ្យាវិញ

បានពិន្ទុមធ្យម ហើយគាត់អាចតែងសេចក្តីជាភាសាអាល្លឺម៉ង់បានយ៉ាងល្អឥតខ្ចោះ។ គាត់បកប្រែសេចក្តីពីភាសាក្រិចបុរាណ និងភាសាឡាទីនមកជាភាសាអាល្លឺម៉ង់បានយ៉ាងល្អឥតខ្ចោះផងដែរ។

កាលនៅវ័យកុមារ ខាល ម៉ាក្ស ជាជនឧត្តមគតិនិយម ពេលមានអាយុ ១៧ ឆ្នាំគាត់បានសរសេរតែងសេចក្តីអំពី «ផ្នត់គំនិតរបស់យុវជនទាក់ទងទៅនឹងការជ្រើសរើសអាជីពរបស់គេ»។ នៅក្នុងអត្ថបទសំណេរតែងសេចក្តីនោះ គាត់បានសង្កត់ធ្ងន់ថា យើងមិនគួរជ្រើសអាជីពដោយប្រាថ្នាតែផលប្រយោជន៍ កិត្តិយសកេរ្តិ៍ឈ្មោះដល់ខ្លួនឡើយ យើងគប្បីពិចារណាថា អាជីពនោះអាចញ៉ាំងនូវគុណប្រយោជន៍ដល់សាធារណជនទូទៅដែរឬទេ។ ប្រសិនជាបុគ្គលណាម្នាក់ធ្វើការដើម្បីតែផលប្រយោជន៍ផ្ទាល់ខ្លួនម្យ៉ាង បុគ្គលនោះអាចក្លាយជាអ្នកប្រាជ្ញរាជបណ្ឌិត និងជាអ្នកពោរពេញដោយចំណេះដឹងឬជាកវីឯកបាន។ ក៏ប៉ុន្តែគេមិនអាចក្លាយជាមនុស្សអស្ចារ្យដ៏ពិតប្រាកដបាននោះទេ នៅក្នុងទំព័រប្រវត្តិសាស្ត្រលោកពោលលើកសរសើរចំពោះតែបុគ្គលណា ដែលមិនគិតតែប្រយោជន៍ផ្ទាល់ខ្លួនហើយបានបូជាកាយឧទ្ទិសខ្លួនដើម្បីផលប្រយោជន៍រួមតែប៉ុណ្ណោះ។ បទពិសោធក្នុងប្រវត្តិសាស្ត្របានប្រាប់យើងថាអ្នកដែលមានសេចក្តីសុខបំផុតគឺ បុគ្គលដែលបានធ្វើឲ្យមនុស្សភាគច្រើនមានសេចក្តីសុខ។ ព្រះសាសនាបានបង្រៀនពួកយើងថា គោលការណ៍ដែលមនុស្សគ្រប់រូបគួររំ [illegible]ិងបដិបត្តិគឺ យើងគួរតែរៀនលះបង់ផលប្រយោជន៍ខ្លួនឯងដើម្បីសេចក្តីសុខនៃមនុស្សទូទៅក្នុងលោក តើអ្នកណានឹងហ៊ានប្រព្រឹត្តល្មើស

នឹងពាក្យប្រដៅរបស់ព្រះយេស៊ូគ្រិស្តជាម្ចាស់នោះ។ ប្រសិនយើងប្រកាន់ខ្ជាប់នូវគោលការណ៍ដែលព្រះអង្គបានបង្រៀននេះ នោះយើងនឹងមិនរួញរាចិត្តក្នុងការបំពេញភារកិច្ចការងារផ្សេងៗឡើយ ហើយយើងក៏នឹងបានទទួលសេចក្តីសុខដែលប្រាសចាកមន្ទិល ព្រោះការមើលឃើញតែប្រយោជន៍ខ្លួន និងការចង្អៀតចង្អល់ចិត្តនោះនឹងនាំមកនូវវិបត្តិយ៉ាងច្រើនប្រការ។ សេចក្តីសុខរបស់យើង គឺជាសេចក្តីសុខរបស់មនុស្សរាប់សែនលាននាក់ នេះជាបុព្វហេតុដែលនាំឱ្យមនុស្សទាំងឡាយចងចាំនូវវីរភាពរបស់យើងជារៀងរហូតទៅ ហើយមុនស្សទាំងឡាយនោះនឹងសម្រក់ទឹកភ្នែក...។

ទោះបីជា ខាល ម៉ាក្ស សិក្សារៀនសូត្រនៅសាលាពូកែជាមធ្យម ដូចដែលមានការបញ្ជាក់ក្នុងសញ្ញាបត្ររបស់គាត់ក៏ដោយ ប៉ុន្តែគាត់មានកម្រិតចំណេះដឹង និងភាពស្ទាត់ជំនាញខ្ពស់ជាងនោះយ៉ាងពិតប្រាកដ ដូចដែលយើងបានដឹងហើយថា កាលនៅវ័យសិក្សាគាត់បានអានស្នាដៃរបស់កវីនិពន្ធជនជាតិបារាំង កវីនិពន្ធជនជាតិក្រិចបុរាណនិងរឿងរបស់សេកស្ពៀរ៍ជាដើម។ នេះសបញ្ជាក់ឲ្យឃើញថា គាត់ព្យាយាមប្រឹងប្រែងសន្សំចំណេះដឹងតាមរយៈការសិក្សាស្វែងយល់ដោយខ្លួនឯង។ សូម្បីក្នុងពេលដែលគាត់កំពុងសិក្សាផ្នែកច្បាប់នៅមហាវិទ្យាល័យរយៈពេល ៦ ឆ្នាំ គាត់តែងឆ្លៀតសិក្សាស្វែងយល់ដោយខ្លួនឯង ជាពិសេសប្រវត្តិសាស្ត្រ និងទស្សនវិជ្ជា។ នៅទីបំផុត គាត់ក៏បញ្ចប់ការសិក្សាថ្នាក់បណ្ឌិតដោយជោគជ័យនៅពេលមានអាយុ ៣៣ ឆ្នាំ។

# មេរៀនទី ៤

« រៀនសូត្របានពេញលេញ ពោរពេញដោយភាពស្ទាត់ជំនាញ »

ក្នុងចំណោមអច្ឆរិយបុគ្គលទាំងឡាយ ដែលបានចារឹកទុកក្នុងទំព័រប្រវត្តិសាស្ត្រពិភពលោកនោះមានចំនួនមិនតិចនាក់ទេ ដែលខិតខំប្រឹងប្រែងសិក្សារៀនសូត្ររហូតបានក្លាយជាសិស្សពូកែ។ ដូច្នេះត្រូវតែទទួលស្គាល់ថា បុគ្គលទាំងនេះបានបង្ហាញនូវអច្ឆរិយភាពតាំងពីនៅវ័យក្មេងមកម្ល៉េះ។ បុគ្គលទាំងនោះបានសាងនូវសេចក្ដីសុខ សេចក្ដីសប្បាយរីករាយចិត្តដល់ឪពុកម្ដាយ គ្រូបាអាចារ្យ ដែលបានចិញ្ចឹមបីបាច់ថែរក្សា និងអប់រំទូន្មានប្រៀនប្រដៅយ៉ាងយកចិត្តទុកដាក់បំផុត។ អច្ឆរិយបុគ្គលទាំងនោះបានដល់ ៖

# អ៊ិមម៉ានុអ៊ែល ខានត៍

(Immanuel Kant, Königsberg, Prussia [now Kaliningrad, Russia]) គ.ស. ១៧២៤ - ១៨០៤

មានទំនោរអច្ឆរិយៈតាំងពីនៅកុមារ គេបានគ្រងតំណែងលេខ ១ ប្រចាំថ្នាក់ រយៈពេលឆ្នាំ ៨ ឆ្នាំជាប់គ្នា។



ទស្សនវិទូ អ៊ិមម៉ានុអ៊ែល ខានត៍ បុគ្គលដែលបានសាងស្នាដៃកក្រើកពិភពលោករូបនេះកើតនៅថ្ងៃទី ២២ ខែមេសា គ.ស. ១៧២៤ ក្នុងទីក្រុង ខូនិកស៍ប៊ឺក នៃទឹកដី ប្រាស់សៀ ខាងកើត (ក្នុងសម័យនោះ) ជាកូនទី ៤ ក្នុងចំណោមបងប្អូន ១១ នាក់ នៃគ្រួសារជាងធ្វើស្បែក (យកស្បែកឆៅមកប្រឡាក់ហាលថ្ងៃ ដើម្បីកែច្នៃធ្វើជារបស់ប្រើប្រាស់ផ្សេងៗ)។ ក្រោយពីសិក្សាថ្នាក់បឋមសិក្សារយៈពេលពីរឆ្នាំ គេបានចូលរៀនបន្តនៅឯសាលា ខលេកជៀម ហ្វ្រីដឺរីសៀណ៍ម (Colllegium Fridericianum) ជាសាលារៀនដែលទាន់សម័យនិងល្បីល្បាញនៃក្រុងខូនិកស៍ប៊ឺក។ នៅទីនេះឯងដែលគាត់គ្រងតំណែងលេខមួយប្រចាំថ្នាក់រយៈពេល ៨ ឆ្នាំជាប់គ្នា។

នៅសាលា ខល្លេចជៀម ហ្វ្រីដឺរីសៀណ៍ម បង្រៀនផ្ដោតសំខាន់ទៅលើភាសាបុរាណ ហើយ ខានត៍ អាចអាន និងសរសេរភាសាឡាទីន

បានយ៉ាងស្ទាត់ជំនាញ។ ស្នាដៃនិពន្ធរបស់គាត់មួយចំនួនក៏បានសរសេរជាភាសាឡាទីនដែរ។ កាលនៅវ័យកុមារគាត់ធ្លាប់មានក្ដីស្រមៃចង់ក្លាយជាកវីនិពន្ធដូចកវីជនជាតិក្រិចសម័យបុរាណ ទើបគាត់បានខិតខំប្រឹងប្រែងសង្វាតព្យាយាមអានសៀវភៅ ដែលជាស្នាដៃនិពន្ធរបស់អ្នកប្រាជ្ញសម័យបុរាណ ហើយគាត់ចងចាំសាច់រឿងទាំងនោះបានស្ទើរតែទាំងអស់ មិនត្រឹមប៉ុណ្ណោះគាត់អាចលើកយកចំណុចសំខាន់ៗនៃសាច់រឿងទាំងនោះមកនិទាន និងពន្យល់ដល់សិស្សដែលជាមិត្តភក្ដិបានទៀតផងដោយអំណាចនៃការចងចាំអច្ឆរិយៈរបស់គាត់នោះឯង។ តែបើនិយាយពីរឿងសុខភាពវិញ សុខភាពគាត់មិនសូវជាល្អទេ ព្រោះមានបញ្ហាផ្លូវដង្ហើមនិងជំងឺបេះដូងតាំងពីក្មេងមកម្ល៉េះ។

បើទោះបីជាគាត់ជាសិស្សគំរូប្រចាំសាលារៀនក៏ដោយ ក៏គាត់មិនសូវជាពេញចិត្តចំពោះវិធីបង្ហាត់បង្រៀនរបស់សាលាដែរ។ បញ្ហាដែលធ្វើឲ្យគាត់ចង្អៀតចង្អល់ក្នុងចិត្ត នោះគឺការដាក់កម្រិតឲ្យធ្វើសាសនកិច្ចនិងតម្រូវឲ្យសូត្រមន្តរៀងរាល់លើក មុននិងក្រោយពេលរៀននូវមេរៀននីមួយៗ។ សូម្បីនៅពេលពួកកូនសិស្សវិលត្រឡប់ទៅផ្ទះហើយក៏ដោយអាណាព្យាបាលត្រូវចាំសង្កេតឃ្លាំមើល និងបង្គាប់ឲ្យបុត្រធីតារបស់ខ្លួនសូត្រមន្តជារៀងរាល់ថ្ងៃ។ បទពិសោធទាំងអស់នេះហើយ ដែលធ្វើឲ្យខានត៍ ស្អប់ការសូត្រមន្តគ្រប់រូបភាពនិងជាអនុស្សាវរីយ៍ដ៏ល្វីងជូរចត់នៅក្នុងវ័យសិក្សារបស់គាត់។

# វ៉ុលធៀរ៍

( Voltaire, France ) គ.ស. ១៦៩៤ - ១៧៧៨

រិះរកគ្រប់មធ្យោបាយដើម្បីប្រាក់រង្វាន់
ទីបំផុតក៏ជោគជ័យដោយទទួលបាន
ប្រាក់រង្វាន់មហាសាល ហើយបានយក
ប្រាក់ទាំងនោះទៅវិនិយោគ
ក្នុងវិស័យធុរកិច្ចជាច្រើនប្រភេទ។



អ្នកប្រាជ្ញដ៏ល្បីល្បាញ វ៉ុលធៀរ៍ រូបនេះតែងរំឭកនឹកដល់គុណសាលារៀនជានិច្ច។ គាត់កើតនៅថ្ងៃទី ២១ ខែវិច្ឆិកា គ.ស. ១៦៩៤ នៅទីក្រុងបារីស ឈ្មោះពិតប្រាកដគឺ ( Francois-Marie Arouet )។ ឪពុកមានបំណងចង់ឲ្យគាត់ក្លាយជាអ្នកច្បាប់ ហើយបានបញ្ជូនទៅរៀននៅសាលាមធ្យមសិក្សា លីសេ លុយស៍-ឡឺ-ក្រង ដ៏ល្បីល្បាញ។ កាលនៅក្មេង វ៉ុលធៀរ៍ គឺជាមនុស្សមានកិរិយាមារយាទគួរឲ្យស្រឡាញ់រាប់អានស្គាល់កាលៈទេសៈ ស្គាល់ទាបស្គាល់ខ្ពស់ គ្រូបង្រៀននិងមិត្តរួមថ្នាក់ទាំងឡាយស្រឡាញ់ចូលចិត្តរូបគេយ៉ាងខ្លាំង មិនត្រឹមប៉ុណ្ណោះវ៉ុលធៀរ៍ជាសិស្សដែលឧស្សាហ៍ព្យាយាមរៀនសូត្រយ៉ាងហ្មត់ចត់ ហើយរៀនពូកែទៀតផង។

ទោះបីជានៅពេលក្រោយមក គាត់បានវាយប្រហារចំពោះអ្នកបួសក្នុងសាសនាគ្រិស្តយ៉ាងធ្ងន់ធ្ងរ ប៉ុន្តែគាត់មិនដែលនិយាយប៉ះពាល់បែបរមិលគុណចំពោះគ្រូបាអាចារ្យសូម្បីម្តងណាឡើយ។ វ៉ុលធៀរ៍ បានសរសេរក្នុងកំណត់ហេតុថា «រយៈពេល ៧ ឆ្នាំដែលរូបខ្ញុំបានទទួលការអប់រំ ទូន្មាន ប្រៀនប្រដៅពីសំណាក់បុរសទាំងនេះ។ ពួកគាត់មិនដែលនឿយណាយចំពោះការអប់រំចិត្តចំពោះយុវជនឡើយ។ ប្រសិនជាមានបុគ្គលណាម្នាក់សួរខ្ញុំថា តើអ្នកធ្លាប់បានប្រទះឃើញអ្វីខ្លះនៅក្នុងអំឡុងដែលរៀននៅសាលារបស់ពួកអ្នកបួសនិកាយអ៊ិតនេះ?

ខ្ញុំប្រាកដជាឆ្លើយថា ខ្ញុំបានឃើញការដំណើរជីវិតបែបសាមញ្ញយកចិត្តទុកដាក់ចំពោះតួនាទីការងារ លោកគ្រូរបស់ខ្ញុំបែងចែកពេលវេលាមួយផ្នែកសម្រាប់បង្ហាត់បង្រៀនពួកខ្ញុំ មួយផ្នែកទៀតទុកសម្រាប់បដិបត្តិសាសនកិច្ចយ៉ាងតឹងរ៉ឹងតាមច្បាប់នៃគ្រិស្តសាសនានិកាយអ៊ិត។

វ៉ុលធៀរ៍ ជាបុគ្គលដែលបានផ្តួចផ្តើមគំនិតរៀបចំផែនការបដិវត្តក្នុងប្រទេសបារាំង មានខ្សែជីវិតផ្ទុយពីគំនិតនៃមនុស្សទូទៅដែលជឿថាពេលគេធំឡើងនឹងមិនប៉ិនប្រសប់ក្នុងការប្រើជីវិតទេ។ វ៉ុលធៀរ៍ ត្រូវបានរត់គេចពីការតាមចាប់ខ្លួនពីសំណាក់មន្ត្រីរដ្ឋាភិបាល ហើយក៏ត្រូវបានគេចាប់ដាក់ពន្ធនាគារជាច្រើនលើកផងដែរ ពេលខ្លះត្រូវបាននិរទេសចេញពីប្រទេសទៀតផង។ វ៉ុលធៀរ៍ ជាមនុស្សដែលមានឋានៈល្អ ដោយសារគាត់បានរិះរកឃើញពីវិធីរកប្រាក់ និងវិធីធ្វើឲ្យប្រាក់នោះកើនឡើងជាបន្តបន្ទាប់។ មូលហេតុដែលគាត់បានក្លាយជាអ្នកមាននោះគឺ គាត់ត្រូវឆ្នោត

រង្វាន់ទឹកប្រាក់ដ៏ច្រើនមហាសាល ប៉ុន្តែមិនមែនជារឿងចៃដន្យនោះទេ វាកើតចេញពីភាពឆ្លាតវៃរបស់គាត់។ នៅពេលគាត់មើលឃើញពីចន្លោះប្រហោងរបស់គណៈកម្មការឆ្នោតហើយ គាត់បានរួមដៃគ្នាជាមួយនឹងមិត្តភក្តិដែលជាអ្នកជំនាញផ្នែកគណិតវិទ្យាគឺលោក កង ដាមីន ក្នុងការគណនារកចំណុចដែលអាចទៅរួច (អាចដឹងមុនថាឆ្នោតនឹងចេញលេខអ្វី) ហើយអ្នកទាំងពីរក៏បានសម្រេចដូចបំណងដោយទទួលបានប្រាក់រង្វាន់យ៉ាងច្រើនសន្ធឹកសន្ធាប់។

គាត់បានយកប្រាក់ទាំងនោះទៅរកស៊ីជាច្រើនផ្នែកដូចជា បើករកស៊ីផ្តល់សេវានាវាកម្សាន្តជាដើម ហើយទទួលបានប្រាក់ចំណេញកើនឡើងជាលំដាប់។ គាត់ជាបុគ្គលអច្ឆរិយៈដែលអាចសាងគុណលាងទោស និងបានសាងកិត្តិយស និងកេរ្តិ៍ឈ្មោះក្លាយជាអ្នកប្រាជ្ញដ៏ល្បីល្បាញពេញពិភពលោក។

# រេណេ ខែសកាតស៍

( Rene Descartes, France ) គ.ស. ១៥៩៦ - ១៦៥០

គាត់បានសិក្សាស្រាវជ្រាវរកឃើញ
នូវរបបគំហើញថ្មីបំផុត
ផ្នែករូបវិទ្យានិងតារាសាស្ត្រ។



អតីតសិស្សគំរូ រេណេ ខែសកាតស៍ មិនសូវជាមានលុយកាក់ប្រាក់កាសប៉ុន្មានទេបើប្រៀបធៀបជាមួយលោក វ៉ុលធៀរ៍ បើទោះបីជាគាត់ពូកែគណិតវិទ្យាជាង វ៉ុលធៀរ៍ ក៏ដោយ។ ខែលកាតស៍ កើតថ្ងៃទី ៣១ ខែមិនា គ.ស. ១៥៩៦ នៅ ទូរ៉ែន ប្រទេសបារាំង មានឪពុកជាមេធាវី និងបានឆ្លងកាត់ការអប់រំទូន្មានប្រៀនប្រដៅពីសំណាក់គណាចារ្យសាសនាយេស៊ូនិកាយអ៊ិត ដូច វ៉ុលធៀរ៍ ដែរ។ គាត់បានរៀននៅសាលាខល្លេចរ៉ូយ៉ាល់ ជាសាលារៀនល្អបំផុតមួយក្នុងតំបន់អឺរ៉ុប អស់រយៈពេល ៨ ឆ្នាំ។ មានរឿងតំណាលតៗគ្នាមកថា ខែសកាតស៍ រៀនពូកែផ្នែកខាងគណិតវិទ្យារហូតធ្វើឲ្យបណ្ដាគ្រូទាំងឡាយកើតសេចក្ដីភ្ញាក់ផ្អើល និងងឿងឆ្ងល់ពីសមត្ថភាពរបស់គេយ៉ាងខ្លាំង។ អ្នកប្រាជ្ញរូបនេះបានបង្កើតទ្រឹស្ដីផ្នែកទស្សនៈវិជ្ជាដែលជាឫសគល់នៃគណិតសាស្ត្រ និងវិទ្យាសាស្ត្រថ្មីៗជាច្រើន។

នៅដើមសតវត្សរ៍ទី ១៧ សាលារៀនដែលបង្កើត និងគ្រប់គ្រងដោយគណាចារ្យសាសនាយេស៊ូនិកាយអ៊ិត ជាសាលាដែលទាន់សម័យបំផុតក្នុងសម័យនោះ។ យុវជន ឌេសកាតស៍ មិនត្រឹមតែបានសិក្សាអំពីវិធីនិយាយក្នុងទីសាធារណៈនិងវិជ្ជាភាសាបុរាណប៉ុណ្ណោះទេ ថែមទាំងបានស្រាវជ្រាវរកឃើញរបបគំហើញថ្មីបំផុតផ្នែករូបវិទ្យា និងតារាសាស្ត្រទៀតផង។

កាលដែល រេណេ ឌេសកាតស៍ ទើបមកចូលរៀននៅសាលានេះ សុខភាពពុំសូវជារឹងមាំប៉ុន្មានទេ ហេតុដូច្នោះហើយទើបគាត់បានទទួលសិទ្ធិពិសេសអនុញ្ញាតឲ្យស្នាក់នៅបន្ទប់មួយតែម្នាក់ឯង ហើយនៅពេលព្រឹក ក៏មិនត្រូវបានគេដាស់ឲ្យក្រោកពីព្រលឹមដូចជាសិស្សដទៃទៀតដែរ (ហេតុផលដែល ឌេសកាតស៍ បានសិទ្ធិពិសេសដូចបានពោលមកខាងលើ អាចមកពីដោយសារគ្រូម្នាក់ក្នុងសាលារៀននោះជាអ៊ំរបស់គាត់)។ បើទោះបីជា ឌេសកាតស៍ បានក្លាយខ្លួនជាបុគ្គលដែលមានកេរ្តិ៍ឈ្មោះបោះសំឡេងល្បីខ្ចរខ្ចាយពេញពិភពលោក ដែលមានមនុស្សមួយចំនួនមានមន្ទិលសង្ស័យចំពោះអ្វីៗគ្រប់យ៉ាង ដែលបានកើតឡើងជុំវិញខ្លួនគាត់ក៏ដោយ ក៏គាត់តែងតែរំឭកនឹកគុណដល់បណ្ដាបព្វជិតសាសនាគ្រិស្តដែលជាគ្រូបាអាចារ្យរបស់គាត់អស់មួយជីវិត ទាំងអស់នេះក៏ព្រោះតែបណ្ដាគ្រូទាំងនោះបានឧបត្ថម្ភជ្រោមជ្រែងរូបគាត់ ឲ្យបានរៀនសូត្រកាន់តែច្រើនឡើងតាមរយៈការផ្ដល់ជាសៀវភៅអានផ្សេងៗ (ដែលសៀវភៅទាំងអស់នោះជាប្រភេទសៀវភៅដែលត្រូវបានគេហាមប្រាមដាច់ខាត ព្រោះជាផ្ទុត

គំនិតបែបថ្មី ដែលប្រាសចាកពីពាក្យប្រៀនប្រដៅរបស់គ្រិស្តសាសនា) ដោយសារតែមូលហេតុដែលគាត់បានអានសៀវភៅទាំងអស់នេះហើយ ទើបធ្វើឲ្យរូបគាត់ក្លាយជាអ្នកប្រាជ្ញប្រកបដោយគោលគំនិតដ៏ស៊ីជម្រៅ។

# ម៉ុក្ស៊ីមីលៀន ឌឺ រ៉ូបែសពីអ៊ែរេ

( Maximillian De Robesbierre, Franch ) គ.ស. ១៧៥៨ - ១៧៩៤



គាត់បានចូលរួមសម្រេចសេចក្តីកាត់ទោសប្រហារជីវិតព្រះបាទលុយស៍ទី ១៦ និងព្រះនាង ម៉ារី អង់ធ័រនែតថ៍ លុះរូបគាត់មានអាយុ ៣៦ ឆ្នាំក៏ត្រូវបានកាត់ក្តីប្រហារជីវិតដោយ Guillotin ( ម៉ាស៊ីនកាត់ក ) ដូចគ្នាដែរ។

ម៉ុក្ស៊ីមីលៀន ឌឺ រ៉ូបែសពីអ៊ែរេ មានរហស្សនាមក្នុងប្រវត្តិសាស្ត្រថា «បុគ្គលមិនធ្លាប់ឆបោក» ហើយរូបគាត់នេះឯងដែលបានធ្វើឲ្យជនជាតិបារាំងស្លាប់រាប់ពាន់អ្នកដោយ Guillotin នៅក្នុងអំឡុងពេលដែលបារាំងស្ថិតនៅក្រោមការគ្រប់គ្រងរបស់ពួកចាខូបែង។ គាត់ជាមនុស្សមានគំនិតវក់ឆ្កួតក្នុងច្បាប់និងវិន័យហួសហេតុ។ ក្រុមអ្នកចិត្តវិទ្យាដែលសិក្សាពីប្រវត្តិរបស់គាត់បានពោលថា គាត់មិនអាចជាអ្វីផ្សេងបានទេក្រៅពីជាបុគ្គលដែលវក់ឆ្កួតក្នុងច្បាប់និងវិន័យហួសហេតុនោះ ហើយអ្វីដែលធ្វើឲ្យគាត់ប្រែក្លាយជាបែបនេះ ក៏ដោយសារតែឥទ្ធិពលនៃឪពុករបស់គាត់ដែរ។

ម៉ុក្ស៊ីមីលៀន ឌឺ រ៉ូប៉ែសពីអ៊ែរ កើតថ្ងៃទី ៦ ខែឧសភា ឆ្នាំ ១៧៥៨ នៅទីក្រុង អារ៉ាស ប្រទេសបារាំង គាត់បានបាត់បង់ម្ដាយតាំងពី ៦ ឆ្នាំមកម្ល៉េះ។ បន្ទាប់ពីនោះ ៦ ឆ្នាំ ឪពុករបស់គាត់ដែលជាមេធាវីដ៏ជោគជ័យបានបោះបង់រូបគាត់និងប្អូនៗពីរនាក់ចោលទៀត។ ដូច្នេះគាត់និងប្អូនៗត្រូវរស់ជាមួយនឹងជីដូននិងជីតា។ ម៉ុក្ស៊ីមីលៀន ឌឺ រ៉ូប៉ែសពីអ៊ែរ មិនអាចអត់ឱន ឬអភ័យទោសចំពោះឪពុកដែលបោះបង់គាត់និងប្អូនៗចោលនោះឡើយ ហើយគាត់ត្រូវធ្វើតួនាទីដូចជាឪពុកម្ដាយចិញ្ចឹមបីបាច់ថែរក្សាប្អូនៗ។ ព្រោះតែដូច្នឹងហើយ ទើបគាត់ព្យាយាមរៀបចំវិន័យនៅក្នុងក្រុមគ្រួសាររបស់គាត់ឲ្យរៀបរយនិងមានសណ្ដាប់ធ្នាប់ល្អ។

នៅក្នុងកំណាត់ហេតុអនុស្សាវរីយ៍របស់ ឆាឡែត ជាប្អូនស្រីរបស់គាត់ នាងបានពោលថា «គាត់បានផ្លាស់ប្ដូរពីបាតដៃទៅជាខ្នងដៃកាលដើមឡើយ គាត់មានចរិតឫកពាដូចក្មេងៗដែលមានវ័យស្រករគ្នាដែរ។ ប៉ុន្តែក្រោយមក ពេលដែលគាត់ដឹងថាគាត់ត្រូវទទួលបន្ទុកចិញ្ចឹមប្អូនៗ និងជាបង្គោលនៅក្នុងគ្រួសារទាំងមូល គាត់ក៏ប្រែក្លាយជាមនុស្សដែលប្រកបដោយហេតុផល មានរបៀបរៀបរយ និងមហិច្ឆតាខ្ពស់។ គាត់និយាយជាមួយពួកខ្ញុំដូចមនុស្សចាស់និយាយជាមួយក្មេងៗ ប្រសិនបើនៅពេលខ្លះគាត់លេងជាមួយពួកខ្ញុំ ព្រោះគាត់ចង់គ្រប់គ្រងការលេងឲ្យដូចអ្វីដែលគាត់ត្រូវការ គាត់ស្រឡាញ់និងយកចិត្តទុកដាក់មើលថែថ្នាក់ថ្នមពួកខ្ញុំដូជាឪពុកអ៊ីចឹង»។

តាមពិតទៅ ឌី រ៉ូប៊ែសពីអ៊ែរ ជាមនុស្សប្រកបដោយមហិច្ឆតា និង មិនដែលបណ្ដែតបណ្ដោយខ្លួនឲ្យសប្បាយភ្លើតភ្លើនសូម្បីម្ដងណាឡើយ គាត់មិនដូចជាក្មេងដទៃទៀតទេ។ នៅពេលមានអាយុ ៨ ឆ្នាំគាត់បានចូលរៀននៅ ខល្លែច ឌី អារ៉ាស់ ដែលបង្ហាត់បង្រៀនដោយបណ្ដាគ្រូបាអាចារ្យជាបព្វជិតសាសនាគ្រិស្ដ។ ឌី រ៉ូប៊ែសពីអ៊ែរ គឺជាសិស្សល្អមានរបៀបរៀបរយ ឧស្សាហ៍ព្យាយាម មិនសេពគប់មិត្តភក្តិ និងមិនលេងសើចជាមួយនឹងនរណាងាយៗឡើយ។ គាត់ជាសិស្សដែលមានសេចក្ដីឧស្សាព្យាមរៀនសូត្ររហូតធ្វើឲ្យលោក ប៊ិឆបនៃអារ៉ាស បានរកប្រាក់មកឧបត្ថម្ភឲ្យរៀនបន្តនៅសាលា លុយស៍ ឡឺ ក្រង់ដ៍ ល្បីល្បាញ។ ឌី រ៉ូប៊ែសពីអ៊ែរ សិក្សានៅទីនោះអស់រយៈពេល ១២ ឆ្នាំប្រកបសេចក្ដីព្យាយាមប្រឹងប្រែងយ៉ាងខ្ជាប់ខ្ជួន។ ឃើញដូច្នោះលោកនាយកសាលាក៏បានសរសេរកំណត់ហេតុក្នុងសៀវភៅរបស់គាត់ថា «គេលះបង់នូវអ្វីៗគ្រប់យ៉ាងដើម្បីរៀនសូត្រឲ្យបានល្អបំផុត គេមិនដែលរួញរាក្នុងការស្វែងរកចំណេះដឹង និងបង្កើនសតិបញ្ញាស្មារតីឡើយ រហូតគេអាចភ្លេចទៅហើយថាគេក៏ជាមនុស្សធម្មតាដែលត្រូវការសេចក្ដីសប្បាយខ្លះនោះ»។

ឌី រ៉ូប៊ែសពីអ៊ែរ ខិតខំប្រឹងប្រែងសិក្សារៀនសូត្រយ៉ាងម៉ឺងម៉ាត់ មិនមែនដើម្បីត្រឹមតែសាងសតិបញ្ញា ដូចដែលនាយកសាលាបានសរសេរទុកក្នុងសៀវភៅនោះឡើយ គឺអាចដើម្បីគោលបំណងផ្សេងដែលសំខាន់សម្រាប់គាត់។ យុវជន ឌី រ៉ូប៊ែសពីអ៊ែរ ដ៏កំសត់ កំព្រាឪពុកម្ដាយម្នាក់នេះមានគោលបំណងចង់បានការទទួលស្គាល់ សេចក្ដីស្រឡាញ់រាប់អាន

ពីមនុស្សទូទៅ ព្រោះហេតុនេះហើយបានជាគាត់ប្រឹងប្រែងរៀនសូត្រយ៉ាងម៉ត់ចត់បំផុត។ នៅក្នុងឆ្នាំ ១៧៧២-១៧៧៤ និងឆ្នាំ ១៧៧៥ គាត់រៀនបានចំណាត់ថ្នាក់លេខមួយប្រចាំថ្នាក់ ហើយលទ្ធផលទាំងអស់នេះឯងហើយ ដែលជួយសម្រួលដល់ជីវភាពរស់នៅក្នុងសង្គមនិងជួយលើកមុខលើកមាត់គាត់នៅក្នុងថ្នាក់រៀន ដែលសុទ្ធតែជាកូនចៅអ្នកធំនិងអ្នកមានស្តុកស្តម្ភរៀនជាមួយ។ នៅពេលដែលគាត់មានអាយុ ២០ ឆ្នាំលោកប៊ិឆបនៃអារ៉ាស ដែលជាអ្នកមានគុណឧបត្ថម្ភប្រាក់ដល់រូបគាត់ឲ្យរៀនបានផ្លាស់ទៅធ្វើជំនួញនៅទីក្រុងបារីស។ គាត់មិនអាចទៅជួបអ្នកមានឧបការគុណរូបនេះទេ ដោយសារពុំមានខោអាវស្លៀកពាក់ឲ្យសមរម្យដើម្បីទៅជួបគាត់ គាត់បានសម្រេចចិត្តសរសេរលិខិតមួយច្បាប់ផ្ញើជូនចៅអាវាសវត្តសាសនាគ្រិស្តមួយកន្លែង ដែលធ្លាប់បានជួយទំនុកបម្រុងរូបគាត់ដូចគ្នាថា «ខ្ញុំបានជ្រាបថាលោកម្ចាស់ ប៊ិឆបនៃអារ៉ាស បានទៅរស់នៅនាទីក្រុងបារីស ខ្ញុំចង់ជួបគាត់ខ្លាំងណាស់ ប៉ុន្តែខ្ញុំពុំមានខោអាវស្លៀកពាក់ឲ្យសមរម្យដើម្បីទៅជួបគាត់ និងខ្វះខាតវត្ថុជាច្រើនយ៉ាងទៀតដែលមិនអាចធ្វើឲ្យខ្ញុំចេញទៅក្រៅជួបនឹងរូបគាត់បាន។ ខ្ញុំបាទសង្ឃឹមយ៉ាងមុតមាំថាលោកម្ចាស់នឹងជម្រាបដល់លោកម្ចាស់ ប៊ិឆបនៃអារ៉ាសឲ្យបានជ្រាបពីរឿងរ៉ាវរបស់ខ្ញុំ ដើម្បីឲ្យគាត់បានជួយសម្រួលនូវអ្វីដែលខ្ញុំកំពុងខ្វះខាតហើយខ្ញុំអាចធ្វើដំណើរទៅជួបគាត់បាន។

ដោយសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

ឌី រ៉ូប៊ែសពីអែរ

ពេលដែលព្រះបាទលុយស៍ទី ១៦ និងព្រះនាង ម៉ារី អង់ធ្វនែតត៍ បានឡើងគ្រងរាជសម្បត្តិក្លាយជាព្រះរាជា និងរាជនីនៃប្រទេសបារាំង នោះ សាលារៀន លុយស៍-ឡឺ-ក្រង់ដ៍ បានជ្រើសយក ឌឺ រ៉ូប៊ែសពីអ៊ែរ ដែលជាសិស្សល្អបំផុតប្រចាំសាលា និងធ្លាប់ទទួលរង្វាន់សិស្សឆ្នើមញឹកញាប់បំផុតឲ្យធ្វើដំណើរទៅពោលថ្វាយព្រះពរចំពោះអង្គព្រះប្រមុខទាំងពីរក្នុងនាមតំណាងឲ្យសាលារៀន លុះ ៦ ឆ្នាំក្រោយមក គាត់ក៏បានបញ្ចប់ការសិក្សាផ្នែកច្បាប់ ហើយបានក្លាយជាមេធាវី។ ក្រោយពីនោះមិនយូរប៉ុន្មាន គាត់បានក្លាយបេក្ខភាពមួយរូបដែលបានចូលរួមកាត់ក្ដីប្រហារជីវិតព្រះបាទលុយស៍ទី ១៦ និងព្រះនាង ម៉ារី អង់ធ្វនែតត៍ លុះមានអាយុ ៣៦ ឆ្នាំខ្លួនគាត់ផ្ទាល់ត្រូវប្រហារជីវិតដោយ Guillotin ដូចគ្នានេះដែរ។

# ចច វិលហែម ហ្វ្រីដរីច ហេហ្គេល

( Georg Wilhelm Fridrich Hegel, Germany ) គ.ស. ១៧៧០ - ១៨៣១



គាត់បានទទួលរង្វាន់ល្អគ្រប់លំដាប់
ចាប់តាំងពីគាត់មានអាយុ១០
ឆ្នាំដល់អាយុ ១៨ ឆ្នាំគ្រងតំណែងលេខ១ រហូត។

«បុគ្គលដែលមានចិត្តខ្ជាប់ខ្ជួន និងមានរបៀបវិន័យដ៏តឹងរ៉ឹង មិនមែនសុទ្ធតែត្រូវបញ្ចប់ជីវិតនៅកន្លែងពិឃាតទាំងអស់នោះទេ»។ ចំពោះហេហ្គេល វិញគាត់ជាបិតានៃការសិក្សាទស្សនវិជ្ជានៃប្រទេសអាល្លឺម៉ង់ ហើយគាត់បានធ្វើឲ្យមុខវិជ្ជានេះមានអត្ថន័យទូលំទូលាយជាទីបំផុត និងមានរបៀបវិន័យនៃការសិក្សាតឹងរ៉ឹងជាទីបំផុត ហើយគាត់ក៏ជាមនុស្សជំពាក់ចិត្តជិតអារម្មណ៍ក្នុងរបៀបវិន័យដែរ។ គោលគំនិតទាំងអស់របស់គាត់សំដៅទៅរកការរៀបចំឲ្យមានច្បាប់ទម្លាប់ ឬបង្កើតនូវច្បាប់ទម្លាប់ថ្មីឡើងមក។ ក្រៅតែពីការងារ គាត់ក៏បានព្យាយាមចាត់របៀបក្នុងការរស់នៅប្រចាំថ្ងៃរបស់ខ្លួនផងដែរ។ គាត់ខិតខំចិញ្ចឹមបីបាច់ថែរក្សាកូនក្រៅផ្លូវការ (កូនឥតខាន់ស្លា) និងភរិយាដែលមានអាយុតិចជាងគាត់រហូតដល់ទៅ ២០ ឆ្នាំ ព្រមទាំងកូនៗនិងភរិយាដែលធំពេញវ័យរបស់គាត់បានយ៉ាងល្អ។ ប៉ុន្តែកូនដើមរបស់គាត់ក្លាយជាក្មេងមានបញ្ញាតូចចិត្តតូចថ្លើម

ដោយគិតថា «ឪពុកមិនស្រឡាញ់រូបគេដូចកូនប្រពន្ធក្រោយ» ជាហេតុធ្វើឲ្យគេរៀនអន់យ៉ាងខ្លាំង ហ៊ើហ្គេល ក៏បានសម្រេចចិត្តយកកូនចេញពីសាលា។ ហ៊ើហ្គេល ឈឺចិត្តយ៉ាងខ្លាំងពេលឃើញកូនរបស់ខ្លួនរៀនមិនពូកែដូចរូបគាត់កាលនៅរៀន។

ចច វិលហ៊ែម ហ្វ្រីដរីច ហ៊ើហ្គេល កើតថ្ងៃទី ២៧ ខែសីហា គ.ស. ១៧៧០ នៅក្នុងទីក្រុង ស្ទូកាត ប្រទេស អាល្លឺម៉ង់។ គាត់ជាកូនប្រុសសំណព្វចិត្តរបស់ឪពុកម្ដាយ ដោយសារគាត់ជាក្មេងដែលរៀនពូកែ និងឧស្សាហ៍ព្យាយាម។ គាត់ត្រូវបានបញ្ជូនឲ្យចូលសាលារៀនតាំងពីអាយុ ៣ ឆ្នាំ ហើយគាត់ក៏បានរៀនអាន សរសេរ និងគណនា។ លុះមានអាយុ ៥ ឆ្នាំ គាត់ក៏បានចូលរៀននៅសាលាឡាទីន និងបានផ្លាស់ទៅរៀននៅសាលាមធ្យមសិក្សា ឥល្លុសស្ទ័រ នាទីក្រុង ស្ទូកាត។ ប្អូនស្រីរបស់គាត់នៅចាំបានថា «គាត់បានទទួលរង្វាន់សិស្សពូកែក្នុងការសិក្សាគ្រប់កម្រិត ព្រោះគាត់រៀនបានពិន្ទុល្អឥតខ្ចោះទីមួយ ក្នុងចំណោមសិស្សទាំងឡាយនៃថ្នាក់រៀនតាំងពីគាត់មានអាយុ ១០ ឆ្នាំរហូតដល់ ១៨ ឆ្នាំគាត់បានគ្រងតំណែងជាប់លេខមួយរហូត»។

នៅពេល ហ៊ើហ្គេល មានអាយុ ១៥ ឆ្នាំ គាត់ចាប់ផ្តើមសរសេរកំណត់ហេតុប្រចាំថ្ងៃ ក្នុងនោះមានចំណែកខ្លះសរសេរជាភាសាឡាទីន ហើយបានសរសេរទុកយ៉ាងលម្អិតថា «ពីមួយថ្ងៃទៅមួយថ្ងៃ គាត់បានអាន បានរៀន និងបានធ្វើកិច្ចការផ្សេងៗក្នុងសាលារៀន ព្រមទាំងមានរឿងរ៉ាវខ្លះៗបានកើតឡើង» និងមានកំណត់ហេតុមួយគាត់បានបញ្ជាក់

ថា «នៅថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ១៧៨៥ គាត់បានប្រាកដខ្លួនចំពោះមុខទីប្រជុំរបស់គណាចារ្យ ក្នុងឋានៈជាសិស្សជាប់លេខមួយប្រចាំថ្នាក់ និងជាតំណាងឲ្យសិស្សផងដែរ។ ក្នុងកំណត់ហេតុនោះបញ្ជាក់ឲ្យឃើញថា បណ្ដាសិស្សានុសិស្សវ័យជំទង់ៗក្នុងសម័យនោះ មិនមែនសុទ្ធតែប្រព្រឹត្តខ្លួនល្អទាំងអស់ទេ ពួកគ្រូបាអាចារ្យទាំងឡាយបានអប់រំពួកយើងនិងឲ្យពួកយើងជួយដាស់តឿនមិត្តភក្តិ កុំរវល់តែនាំគ្នាលេងសើចឥតប្រយោជន៍ ឬប្រព្រឹត្តអំពើពាលាអាវាសែនៅតាមក្រុម (ជំរំ) ផ្សេងៗដែលបានរស់នៅពពាក់ពពូនគ្នាក្នុងខណៈនោះ។ ក្រុមទាំងអស់នេះរួមមាន យុវជនអាយុ ១៧ ទៅ ១៨ ឆ្នាំ និងពួកក្មេងស្រីៗអាយុត្រឹមតែ ១១ ទៅ ១២ ឆ្នាំប៉ុណ្ណោះ ពួកក្មេងប្រុសៗទាំងឡាយតែងនាំក្មេងស្រីព្រហ្មចារិនីទាំងនោះចេញទៅដើរលេងហើយប្រព្រឹត្តអនាចារគួរឲ្យខ្មាសអៀនយ៉ាងខ្លាំង»។

នៅក្នុងពិធីទទួលសញ្ញាបត្របញ្ចប់ការសិក្សាថ្នាក់មធ្យមសិក្សា ហ៊ែហ្គេល បានឡើងថ្លែងសុន្ទរកថាចំពោះមុខលោកគ្រូអ្នកគ្រូ និងសិស្សានុសិស្សមិត្តរួមជំនាន់ទាំងឡាយ ក្នុងន័យកោតសរសើរចំពោះការបង្ហាត់បង្រៀនរបស់លោកគ្រូអ្នកគ្រូ និងបានថ្លែងនូវអំណរគុណចំពោះលោកគ្រូអ្នកគ្រូទាំងឡាយដែលបានលះបង់កម្លាំងកាយចិត្ត និងពេលវេលាដ៏មានតម្លៃបង្ហាត់បង្រៀនឲ្យរូបគាត់បានក្លាយជាមនុស្ស ដែលមានទាំងចំណេះដឹងនិងចរិយាធម៌ដ៏សមរម្យ ព្រមទាំងបានថ្លែងលើកតម្កើង និងកោតសរសើរចំពោះរដ្ឋាភិបាលអាល្លឺម៉ង់ ដែលបានផ្ដល់នូវការឧបត្ថម្ភជ្រោមជ្រែងចំពោះវិស័យអប់រំជារៀងដរាបមក។ ក្នុងការថ្លែងសុន្ទរកថា

របស់គាត់ មិនត្រឹមតែប្រកបទៅដោយពាក្យពេចន៍សុភាពរាបសា ផ្អែមល្ហែមនិងបង្កប់ទៅដោយអត្ថន័យខ្លឹមសារប៉ុណ្ណោះទេ ថែមទាំងបង្កប់នូវវត្ថុបំណងស្នើសុំអាហារូបករណ៍ ដើម្បីសិក្សាបន្តនៅឯមហាវិទ្យាល័យ ធីបិងងែន ទៀតផង។ ហើយនៅក្នុងសុន្ទរកថានោះគាត់បានពោលថា «ខ្ញុំបាទសូមសច្ចាថា នឹងខិតខំប្រឹងប្រែងរៀនសូត្រដោយយកចិត្តទុកដាក់បំផុត ហើយអនាគតតទៅ ខ្ញុំនឹងមិនប្រកបអាជីពដទៃណាក្រៅតែពីការឧទ្ទិសខ្លួនចំពោះព្រះសាសនាតែប៉ុណ្ណោះ»។ ការស្នើសុំរបស់គាត់បានសម្រេច ទីបំផុតក៏បានបន្តការសិក្សានៅមហាវិទ្យាល័យ ធីបិងងែន ដូចបំណងប្រាថ្នា។

លទ្ធផលនៃការសិក្សារបស់ ហ៊ើហ្គេល ក្នុងមួយឆមាសៗមានភាពល្អប្រសើរដែលបង្ហាញឲ្យឃើញពីការតាំងចិត្តសិក្សារៀនសូត្រយ៉ាងខ្ជាប់ខ្ជួន។ ប៉ុន្តែចំពោះព្រឹត្តិកម្មផ្សេងៗត្រូវបានគេរិះគន់ញឹកញាប់ ព្រោះគាត់មិនចូលចិត្តបទបញ្ជាផ្ទៃក្នុងដ៏តឹងតែង ក្នុងការស្នាក់ក្នុងអន្តេវាសិកដ្ឋាននោះទេ។ ជានិច្ចកាល គាត់តែងតែត្រឡប់មកកាន់បន្ទប់ស្នាក់នៅយប់ជ្រៅនិងក្រោកពីដំណេកយឺតយ៉ាវ និងខកខានមិនបានសូត្រមន្តពេលព្រឹកជាញឹកញាប់។ ហ៊ើហ្គេលបញ្ចប់ការសិក្សានៅអាយុ ២៣ ឆ្នាំ ប៉ុន្តែគាត់មិនចង់ក្លាយជាអ្នកទេវវិទ្យាតាមឯកទេសដែលបានរៀនឡើយ គាត់បានធ្វើជាគ្រូពិសេស (គ្រូបង្រៀនតាមផ្ទះ) បណ្ណាធិការនិងនៅទីបំផុតក៏បានក្លាយជាគ្រូបង្រៀននៅមហាវិទ្យាល័យ។ នៅពេលដែលគាត់បានក្លាយជាបុគ្គលដែលមានឈ្មោះល្បីល្បាញ បណ្ដាមិត្តភក្តិរួមជំនាន់របស់

គាត់បាននាំគ្នាពោលថា «ពួកយើងមិននឹកស្មានដល់ថា ហ៊ែហ្គេល ក្លាយជាបុគ្គលអច្ឆរិយៈ និងជាបិតាទស្សនវិជ្ជារបស់អាល្លឺម៉ង់ ដូច្នេះបានសោះ»។ នៅក្នុងខ្សែភ្នែករបស់មិត្តភក្តិគិតថា ចច វិលហែម ហ្វ្រីដរីច ហ៊ែហ្គេល បណ្តែតបណ្តោយខ្លួនឱ្យទៅតាមសម័យសប្បាយហួសហេតុពេក រហូតជាមនុស្សកែលែងឡើងទៅហើយ។

# វ្លាឌិមៀរ៍ អ៊ិលជ្សិតឆ៍ ឡេនីន

( Wladimir Iljitsch Lenin, Rusia ) គ.ស. ១៨៧០ - ១៩២៤

ឡេនីនមានខួរក្បាលចងចាំដ៏អច្ឆរិយៈ
ប្រឡងបានពិន្ទុខ្ពស់គ្រប់មុខវិជ្ជា
ធ្វើកិច្ចការងារគ្រប់យ៉ាងបានរហ័សរហួន
ហើយជាមនុស្សមានសមាធិខ្ជាប់ខ្ជួន។



ឡេនីន កាលនៅវ័យកុមារ និងវ័យសិក្សាជាមនុស្សពោរពេញដោយសេចក្តីសុខ មានឈ្មោះពិតថា វ្លាឌិមៀរ៍ អ៊ិលជ្សិតឆ៍ អ៊ូល្យាណហ្វ កើតនៅថ្ងៃទី ២២ ខែមេសា គ.ស. ១៨៧០ នាទីក្រុង ស៊ីមប៊ៀក៍ មានឪពុកជាគ្រូបង្រៀនគណិតវិទ្យានិងរូបវិទ្យានៅសាលាមធ្យមសិក្សា ហើយក្រោយមកក៏បានទទួលតំណែងជាអនុរក្ស។

ឡេនីន កាលនៅវ័យកុមាររៀនដើរបានយឺតយ៉ាវណាស់ រហូតដល់អាយុ ៣ ឆ្នាំទើបចេះដើរតតេះតតះ បងស្រីរបស់គាត់ឈ្មោះអាណាធ្លាប់បាននិទានពីរឿង ឡេនីន កាលពីនៅតូចថាគេតែងតែដើរដួលចំតិតចំតួងជានិច្ច។ នាងនិយាយថា «ប្រហែលជាខួរក្បាលរបស់គេមានខ្លាញ់ច្រើនពេក ទើបវាធ្ងន់ជាងរាងកាយផ្នែកផ្សេងៗក៏អាចថាបាន» ក៏ប៉ុន្តែនៅពេលចេះដើរស្ទាត់គាត់មិនដែលនៅស្ងៀមឡើយ។

បងប្រុសរបស់គាត់ឈ្មោះ អាឡិចសាន់ឌ័រ ដែលមានឈ្មោះហៅក្រៅថា សច្ឆា ជាបុគ្គលគំរូដែល ឡេនីន ចង់ធ្វើតាមឲ្យដូចគ្រប់យ៉ាងដូចជាគាត់ចង់ញ៉ាំស៊ុបដែលបងប្រុសតែងញ៉ាំ ចង់ស្លៀកឈុតឯកសណ្ឋានសិស្សសាលាថ្នាក់មធ្យមដូចដែលបងប្រុសស្លៀក និងចង់គេងនៅលើគ្រែដូចដែ សច្ឆា ធ្លាប់ដេក។ ប៉ុន្តែជាអកុសល សច្ឆា ត្រូវបានកាត់ទោសប្រហារជីវិត ដោយសារតែពាក់ព័ន្ធនឹងគម្រោងការលបធ្វើឃាតស្ដេចសាអាឡិចសាន់ឌ័រទី៣។ ចាប់តាំងពីពេលនោះមក ឡេនីន ដែលធ្លាប់តែពោរពេញដោយសេចក្ដីសុខ ព្រោះមានបងប្រុសជាទីស្រឡាញ់ក៏ត្រូវបានរលាយបាត់បង់អស់។

ឡេនីនចេះអានអក្សរនៅពេលមានអាយុ ៥ ឆ្នាំនិងចេះលេងអុកយ៉ាងស្ទាត់ជំនាញនៅអាយុ ៨ ឆ្នាំ គាត់ចាប់ផ្ដើមរៀនភាសាបរទេសនិងព្យាណូតាំងតែពីនៅតូចៗ។ មានគ្រូម្នាក់ដែលក្រុមគ្រួសាររបស់គាត់បានជួលមកបង្រៀននៅផ្ទះបានសម្លឹងឃើញ ឡេនីន ថាជាក្មេងដែលឆ្លាតហួសប្រមាណគួរឲ្យបារម្ភ។ គាត់បានចូលរៀននៅសាលាមធ្យមសិក្សានៃក្រុង ស៊ីមប៊ៀក៍ នៅពេលគាត់មានអាយុ ៩ ឆ្នាំ។ បើទោះបីជាក្មេងៗក្នុងត្រកូល អ៊ូល្យាណាហ្វ សុទ្ធតែរៀនពូកែគ្រប់គ្នាក៏ដោយតែ ឡេនីន បែរជាលេចធ្លោជាងអ្នកណាទាំងអស់ ព្រោះគាត់មានខួរក្បាលចងចាំដ៏អច្ឆរិយៈ។ គាត់បានពិន្ទុល្អឥតខ្ចោះលើគ្រប់មុខវិជ្ជាដែលបានប្រឡង គាត់អាចធ្វើកិច្ចការងារគ្រប់បែបយ៉ាងបានយ៉ាងរហ័សរហួន និងប្រកបដោយភាពនឹងន។ ចំពោះការសរសេរតែងសេចក្ដីវិញ គាត់មិនចាំបាច់សរសេរ

សេរសេចក្ដីព្រាងជាមុនឡើយ ហើយពេលសម្រាកពីរៀនចេញមកដល់ផ្ទះ គាត់តែងតែមានវិធីធ្វើលំហាត់ប្រាណសម្រួលសរសៃប្លែកៗ ដោយការរត់ទៅរត់មកនៅក្នុងផ្ទះ។ ពេលខ្លះគាត់រត់ដោយប្រើដៃជំនួសជើង (ច្រត់ដៃចុះក្រោមផ្ទាល់នឹងផ្ទៃដីហើយលើកជើងទាំងគូរឡើងលើ)។

បើទោះបី ឡេនីន ជាសិស្សដែលរៀនពូកែអស្ចារ្យពោរពេញទៅដោយភាពប៉ិនប្រសប់និងភាពស្ទាត់ជំនាញផ្នែកតួរ្យតន្ត្រី និងមានថ្វីមាត់ពូកែយ៉ាងណាក៏ដោយ ប៉ុន្តែគេមិនមែនជាមនុស្សឆ្មើងឆ្មៃក្រអឺតក្រទមនោះទេ គាត់ជាមនុស្សទន់ភ្លន់សុភាពរាបសា ចេះបន្ទាបបន្ទន់ខ្លួនគួរជាទីរាប់អាន។ លោកគ្រូម្នាក់បានសរសេរនៅក្នុងសៀវភៅរបស់ ឡេនីន ថា «គេជាក្មេងមានរបៀបរៀបរយ មិនថាក្នុងកាលៈទេសៈណាក៏ដោយ គេមិនធ្លាប់អួតអាងយកមុខយកមាត់ឡើយ។ គេឆ្លើយសំណួរប្រកបដោយភាពឈ្លាសវៃ និងស្របទៅនឹងរាល់ប្រធានបទដែលគ្រូបានចោទសួរ»។

នាង យ៉ុបស្កាយា ត្រូវជាភរិយារបស់ ឡេនីន ធ្លាប់បាននិយាយថានៅពេលដែល ឡេនីន នៅក្មេងគាត់ជាក្មេងដែលសុភាពរាបសាមានរបៀបរៀបរយនិងប្រព្រឹត្តិល្អជានិច្ច។ បងស្រីរបស់គាត់និយាយថាកាលដែលលោកឪពុកមានជីវិតរស់នៅនៅឡើយ គាត់បានអប់រំទូន្មានប្រៀនប្រដៅកូនៗឲ្យចេះគោរពពេលវេលា និងស្ដាប់បង្គាប់ឪពុកម្ដាយចាស់ទុំយ៉ាងខ្ជាប់ខ្ជួន។ នាងបាននិយាយបន្តទៀតថាកាលនៅពីក្មេង ឡេនីន មិនដែលនិយាយកុហកឡើយ «ប្រសិនជាគេមិនចង់និយាយអ្វី គេនឹងនៅស្ងៀមស្ងាត់» ប៉ុន្តែមានម្ដងនោះគេនិយាយពាក្យមិនពិត គឺពេលគេ

ទៅសួរសុខទុក្ខអ៊ំស្រី ហើយបានធ្វើឲ្យកែវទឹកធ្លាក់បែក ហើយគេបែរជាប្រាប់ថា «វាបែកដោយឯកឯង» ការនិយាយពាក្យកុហកដោយមិនបានតាំងចិត្តក្នុងពេលនោះ ធ្វើឲ្យគេពិបាកចិត្តយ៉ាងខ្លាំង ហើយបានរត់ទាំងទ្រហោយំទៅរកម្ដាយ លុះរយៈពេល ៣ ខែកន្លងផុតទៅទើបគេប្រាប់ការពិតនៃរឿងនោះដល់ម្ដាយឲ្យបានជ្រាប។ ឡេនីន ក៏ធ្លាប់ពោលក្នុងកាលជាខាងក្រោយដែរថា «រឿងដែលថោកទាបបំផុតសម្រាប់រូបខ្ញុំគឺការកុហកនិងភាពកំសាកញី»។ បងប្រុសរបស់ ឡេនីន ដែលបានធ្វើមរណកាលចាកលោកទៅក៏មានលក្ខណៈនិស្ស័យដូចគ្នាដែរ គឺពេលគាត់ត្រូវយកជីវិតត្រូវសងដោយជីវិត គាត់មិនព្រមបដិសេធកុហកថាគាត់មិនបានពាក់ព័ន្ធនឹងការរៀបចំគម្រោងធ្វើឃាតព្រះបាទ សារ៍ នោះ។

នៅពេល សច្ឆា ត្រូវបានប្រហារជីវិតនោះ ឡេនីន មានអាយុ ១៧ ឆ្នាំ និងកំពុងតែសិក្សានៅថ្នាក់មធ្យមសិក្សានៅឡើយ បើទោះបីជាគាត់សោកសៅ និងខ្សឹកខ្សួលចំពោះការចាកចោលទៅរបស់បងប្រុសសំណព្វចិត្តយ៉ាងណាក៏ដោយ គាត់នៅតែរៀនបានពិន្ទុល្អឥតខ្ចោះ និងបានទទួលនូវរង្វាន់មេដាយមាសសិស្សពូកែទៀតផង។ គាត់ក្លាយជាអ្នកបដិវត្តនៅពេលដែលគាត់កំពុងរៀននៅមហាវិទ្យាល័យ ខាសាន ហើយត្រូវបានគេចាប់ខ្លួន ដោយសារតែចូលរួមដើរដង្ហែក្បួនបាតុកម្មរបស់ពួកនិស្សិតនិងត្រូវបានបណ្ដេញចេញពីមហាវិទ្យាល័យ។

ក្រោយមក គេត្រឡប់មកចូលរៀនផ្នែកច្បាប់ម្ដងទៀតនៅមហាវិទ្យាល័យ ស៊ិនត៍ភីតធីរ៍ស្បឺក រហូតបានបញ្ចប់ការសិក្សាដោយជោគជ័យ

ព្រមទាំងទទួលបានកិត្តិនិយមលំដាប់លេខមួយ ហើយបានធ្វើការជាជំនួយការមេធាវីម្នាក់។

ក្រោយការបដិវត្តរុស្ស៊ី វ្លាឌិមៀរ៍ អ៊ិលជ្យិតឆ៍ ឡេនីន បានក្លាយជាប្រមុខនៃគណៈរដ្ឋាភិបាល បលហ្សេវិគ ដរាបដល់ថ្ងៃអវសានជីវិត។

# ចូសែហ្វ ស្តាលីន

( Joseph Stalin, Rusia ) គ.ស. ១៨៧៩ - ១៩៥៣



ជាសិស្សមានទេពកោសល្យខ្ពស់
ឧស្សាហ៍ព្យាយាម និងមាន
សេចក្តីភ្ញាក់រឭកចំពោះការសិក្សាជានិច្ច
ប៉ុន្តែត្រូវបានគេបណ្តេញចេញពីសាលារៀនទៅវិញ។

ដូចគ្នានឹង ឡេនីន ដែរ។ ស្តាលីន ជាសិស្សដ៏គំរូម្នាក់ រៀនពូកែ និងប្រកបដោយសមត្ថភាពខ្ពស់។ គាត់កើតនៅថ្ងៃទី ២១ ខែធ្នូ គ.ស. ១៨៧៩ ក្នុងទីក្រុង ករី សាធារណរដ្ឋ ចជៀរ៍ បច្ចុប្បន្ន មានឪពុកជាជាងធ្វើស្បែកជើង។ ម្តាយរបស់គាត់មានបំណងចង់ឲ្យរូបគាត់បានក្លាយជាបព្វជិតសាសនាគ្រិស្ត ដូច្នឹងហើយនាងក៏បានបញ្ជូនរូបគាត់ឲ្យទៅរៀននៅសាលាសាសនានៅពេល ស្តាលីន មានអាយុ ៩ ឆ្នាំហើយគាត់ក៏បានរៀននៅទីនោះអស់រយៈពេល ៤ ឆ្នាំ។

គាត់ជាសិស្សម្នាក់ក្នុងចំណោមសិស្សដែលរៀនពូកែបំផុត។ ទោះបីមានជួបបញ្ហាខ្លះៗក្នុងការសិក្សារៀនសូត្រ ដោយសារនៅសាលាដែលគាត់រៀននោះប្រើប្រាស់ភាសារុស្សី ក្នុងការបង្ហាត់បង្រៀនដែលគាត់មិនសូវជាថ្នឹកប៉ុន្មាន (នៅក្នុងក្រុមគ្រួសាររបស់គាត់និយាយតែភាសាចជៀរ៍

ប៉ុណ្ណោះ) ប៉ុន្តែក្មេងប្រុសតូច ស្តាលីន នៅតែអាចសិក្សារៀនសូត្រឆាប់យល់និងឆាប់ចេះបានយ៉ាងរហ័ស។ មិនយូរប៉ុន្មាន បណ្តាគ្រូនិងមិត្តរួមថ្នាក់របស់គាត់ក៏នាំគ្នាស្រឡាំងកាំងចំពោះការចងចាំដ៏អស្ចារ្យរបស់គាត់។ ស្តាលីនមានឥរិយាបថខុសគ្នាពី ឡេនីន ដែលតែងតែបន្ទាបខ្លួនជានិច្ច តែចំពោះ ស្តាលីន វិញតែងតម្កើងឫកខ្ពស់ជាងមិត្តរួមថ្នាក់ ហើយបញ្ជាឲ្យអ្នកដទៃធ្វើនូវអ្វីដែលខ្លួនត្រូវការ។

ឪពុកបានចូលអនិច្ចកម្មចោលទៅនៅពេល ស្តាលីន មានអាយុ ១៤ ឆ្នាំ។ អំណើះអត់ពីឪពុកទៅ ម្តាយរបស់គាត់ត្រូវរែកអម្រែកគ្រួសារតែម្នាក់ឯង ដោយការស៊ីឈ្នួលបោកគក់ខោអាវឲ្យគេ ដើម្បីចិញ្ចឹមជីវិតនិងចិញ្ចឹមកូនប្រុសជាទីស្រឡាញ់។

ស្តាលីនបានទទួលទុនការសិក្សានៅសាលារៀនអ្នកបួសសាសនាគ្រិស្តនៃធិហ្វលីស ជាសាលារៀនដ៏ល្បីល្បាញនៃប្រទេសចៀហ្ស៍។ ស្តាលីនស្នាក់នៅរៀនទីនោះ ប្រៀបដូចជារស់នៅក្នុងបន្ទាយទាហានផងនិងនៅក្នុងវត្តផង ពីព្រោះទីនោះមានបទបញ្ជានិងវិន័យដ៏តឹងរឹង ហើយមិនត្រូវបានអនុញ្ញាតឲ្យចេញទៅខាងក្រៅសាលាឡើយ។ ទោះជាយ៉ាងណាក៏ដោយយុវជនស្តាលីន នៅតែជាបុគ្គលដែលពោរពេញទៅដោយទេពកោសល្យខ្ពស់ប្រកបដោយភាពឧស្សាហ៍ព្យាយាម និងភ្ញាក់រឭកចំពោះការសិក្សារៀនសូត្រជានិច្ច។ ស្តាលីនមិនមែនជាក្មេងទន់ជ្រាយ ព្រមធ្វើអ្វីៗគ្រប់យ៉ាងតាមកតិការរបស់ពួកបព្វជិតផ្តាច់ការទាំងនោះឡើយ គេតែងលបលួចធ្វើនូវទង្វើដែលផ្ទុយពីបទបញ្ជាផ្សេងៗដូចជា លួចទាក់ទង

ជាមួយមនុស្សនៅខាងក្រៅ ហើយនាំយកបទកំណាព្យដែលគេបានតែងនិពន្ធ (ដោយប្រើឈ្មោះក្លែងក្លាយ) ទៅបោះពុម្ពឬបើមិនដូច្នោះទេគាត់ខ្ចីសៀវភៅ ដែលត្រូវបានគេហាមប្រាមពីបណ្ណាល័យយកមកអាន ដូចជាសៀវភៅរបស់លោក វិចទ័រ ហ៊ូកូ ជាដើម។ ទង្វើទាំងអស់ដូចដែលបានរៀបរាប់ខាងលើហ្នឹងហើយ ដែលជាហេតុធ្វើឲ្យរូបគាត់ត្រូវបានគេដាក់ទោសទណ្ឌកម្មដោយការបង្ខាំងខ្លួនរយៈពេលយូរ ក៏ប៉ុន្តែការដាក់ទោសទណ្ឌកម្មនេះមិនបានធ្វើឲ្យ ស្តាលីន រាងចាល ឬខ្សោយការចងចាំនោះឡើយ។ មិត្តរួមថ្នាក់ម្នាក់ធ្លាប់បាននិយាយពីគាត់ថា «ចូសើហ្វ ស្តាលីន មិនដែលឃ្លាតឆ្ងាយពីសៀវភៅម្តងណាឡើយ សូម្បីនៅពេលទទួលទានអាហារក៏គាត់អានសៀវភៅដែរ»។

នៅពេលដែលគាត់មានអាយុ ១៩ ឆ្នាំក៏បានចូលរួមជាមួយក្រុមសង្គមនិយម ធិហ្វលីស ដោយលាក់កំបាំងយ៉ាងស្ងាត់ៗ ហើយមានបព្វជិតពីររូបបានចូលរួមក្នុងចលនានោះដែរ។ ចូសើហ្វ ស្តាលីន បានពោលថា «ខ្ញុំក្លាយខ្លួនជាពួក ម៉ាក៌ស៊ីស ពីព្រោះឪពុករបស់ខ្ញុំជាកម្មកររោងចក្រស្បែកជើងចំណែកឯម្តាយរបស់ខ្ញុំក៏ជាកម្មករដូចគ្នាដែរ ខ្ញុំត្រូវបង្ខំឲ្យធ្វើដំណើរលើវិថីនេះដោយការខ្វះខន្តីធម៌យ៉ាងធ្ងន់ធ្ងរ និងរបៀបរបបដ៏ឆ្គងតឹងប៉ង់ុលរបស់ពួកសាសនាយេស៊ូនិកាយអ៊ិត។ បរិយាកាសដែលខ្ញុំបានជួបប្រទះកាលនៅក្នុងសាលារៀន ជាកន្លែងដែលខ្ញុំធ្លាប់បានរស់នៅបានបណ្តុះគំនិតស្អប់ខ្ពើមចំពោះរបបទុរយសផ្តាច់ការ នៃព្រះបាទសារ៍នៅក្នុងចិត្តកាន់តែខ្លាំងឡើងៗរហូតមិនអាចអត់ទ្រាំបាន»។

គាត់ព្យាយាមអានសៀវភៅ ម៉ារ័ស៊ីស កាន់តែច្រើន ទើបធ្វើឲ្យគាត់មានគំនិតកុម្មុយនិស្តកាន់តែខ្លាំងឡើង ទោះជាយ៉ាងនេះក្តី ចូស៊ើហ្វស្តាលីន នៅតែជាសិស្សពូកែលំដាប់កំពូលនោះឯង ប៉ុន្តែនៅទីបំផុតក៏ត្រូវបានគេបណ្តេញចេញពីសាលា ដោយមូលហេតុមិនបានប្រឡងមុខវិជ្ជាមួយចំនួន។ បន្ទាប់ពីនោះមក គាត់មិនបានចូលរៀននៅសាលាដទៃណាទៀតឡើយ។

បើទោះបីជាមិនបានរៀនច្រើន តែបានក្លាយជាមេដឹកនាំដ៏មានឥទ្ធិពលក្នុងលោក។

# ម៉ារី ឃុរី

(Marie Curie, Poland) គ.ស. ១៨៦៧ - ១៩៣៤



សេចក្តីប្រាថ្នាកាលនៅកុមារនោះគឺ ការសិក្សារៀនសូត្រទោះបីជាមានអាយុតិចជាងគេក៏ដោយតែនាងរៀនបានពិន្ទុលំដាប់ទីមួយគ្រប់មុខវិជ្ជាដែលរៀន។

ម៉ារៀ សះខ្លូដូហ្វស្កា ស្ត្រីជនជាតិប៉ូឡូញ ដែលប្រវត្តិសាស្ត្របានចារឹកឈ្មោះនាងថា ម៉ារី ឃូរី នោះបានទទួលរង្វាន់ណូបែលចំនួនពីរលើក។ លើកទី ១ នៅក្នុងឆ្នាំ ១៩០៣ នាងបានទទួលរង្វាន់ផ្នែករូបវិទ្យារួមជាមួយស្វាមីរបស់នាង ដោយអ្នកទាំងពីរមានសមត្ថភាពអាចញែកនូវវិទ្យុសកម្មចេញរ៉ែ ប៉ូឡូញ៉ូម (Polonium) និង រ៉ាឌីញ៉ូម (Radium) បានជោគជ័យ និងលើកទីពីរនៅក្នុងឆ្នាំ ១៩១១ ផ្នែកគីមីវិទ្យា។

នាងកើតនៅថ្ងៃទី ៧ ខែវិច្ឆិកា គ.ស. ១៨៦៧ នាទីក្រុង វ៉ារស៉ ជាធីតារបស់គ្រូបង្រៀនថ្នាក់មធ្យមសិក្សាម្នាក់។ ផ្ទះនាងមានលក្ខណៈដូចសាលារៀនពាក់កណ្តាលស្រាប់ទៅហើយ កាលនៅតូចនាងបានគូរគំនូរនិងសរសេរទុកថា ពិភពលោកទាំងមូលគឺជាសាលារៀនដ៏ធំមហិមា។ នៅពេលនាងមានអាយុ ៤ ឆ្នាំនាងចេះអានអក្សរបានមុនពេលចូលរៀន

នៅសាលាទៅទៀត។ ពេលបងស្រីរបស់នាងឈ្មោះ ប្រូនៀរ៍ នាំនាងទៅសាលាជាមួយ នាងបែរជាយល់យ៉ាងឆាប់រហ័សជាង ប្រូនៀរ៍ ទៅទៀត។

នៅពេលដែល ម៉ារៀរ៍ ចូលរៀននៅសាលា នាងរៀនបានពិន្ទុលំដាប់លេខមួយគ្រប់មុខវិជ្ជា បើទោះបីជានាងមានអាយុតិចជាងគេនៅក្នុងថ្នាក់រៀនក៏ដោយ។ បំណងប្រាថ្នាតែម្យ៉ាងកាលនៅតូចគឺ ការសិក្សា ហើយវាគឺជារឿងដែលងាយស្រួលបំផុតសម្រាប់នាង ពីព្រោះនាងមានការចងចាំដ៏អច្ឆរិយៈ។ នាងអាចចងចាំកំណាព្យកាព្យឃ្លោងដ៏វែងបានយ៉ាងស្ទាត់ ហើយអាចសូត្របានដោយមិនមានកំហុសសូម្បីមួយពាក្យឡើយ ក្រោយពីនាងបានអាននូវកំណាព្យនោះត្រឹមតែពីរចប់ប៉ុណ្ណោះ។ ក្រៅពីនេះ នាងជាមនុស្សមានសមាធិនឹងន ដូចដែលកូនស្រីរបស់នាងឈ្មោះ អ៊ីហ្វ បានសរសេរក្នុងជីវប្រវត្តិរបស់នាងថា «ការដែលគាត់មានសមាធិនឹងន គឺជារឿងដែលរកបានដោយកម្រសម្រាប់មនុស្សនៅវ័យក្មេងបែបនេះ ហើយក្លាយជារឿងសប្បាយសម្រាប់បងស្រីរបស់គាត់និងមិត្តភក្តិក្នុងសាលារៀន មិនថានរណាស្រែកថ្ង និងឡូឡាខ្លាំងប៉ុនណាក៏ដោយ ក៏មិនអាចដាស់អារម្មណ៍ម្តាយរបស់ខ្ញុំឲ្យភ្ញាក់ងាកចេញពីការអានសៀវភៅបានឡើយសូម្បីតែមួយដង្ហើម»។

នាងអានសៀវភៅគ្រប់បែបយ៉ាង មិនថានោះជាសៀវភៅមេរៀន សៀវភៅកំណាព្យកាព្យឃ្លោង ប្រលោមលោក រឿងរ៉ាវផ្សងព្រេងឬសូម្បីតែសៀវភៅអ្នកជំនាញរបស់ឪពុកនាង។ នៅពេលដែលនាងបានអានសៀវភៅ នាងនឹងភ្លេចនូវទុក្ខកង្វល់ទាំងឡាយក្នុងឆាកជីវិតពីរឿងម្តាយ

របស់នាងកំពុងមានជំងឺ ឪពុករបស់នាងជួបបញ្ហាការងារបានលាឈប់ពីគ្រូបង្រៀននៅសាលា ហើយបើកបង្រៀននៅផ្ទះដែលអាចរកប្រាក់បានបន្តិចបន្តួចៗ ចំណែកនៅសាលារៀននាងពុំមានសេចក្ដីសុខ និងសេចក្ដីសប្បាយផ្លូវចិត្តជារៀងរហូតនោះដែរ។ នាងមិនសូវចូលចិត្តគ្រូជនជាតិរុស្ស៊ី ហើយគ្រូខ្លះទៀតក៏និយាយថានាងជាក្មេងឆ្មើងកន្ត្រើង ក៏ប៉ុន្តែក្រៅពីរឿងរ៉ាវទាំងអស់នេះ នាងក៏ពេញចិត្តពេញថ្លើមចំពោះការសិក្សារៀនសូត្រយ៉ាងខ្លាំង។ នាងធ្លាប់បានសរសេរសំបុត្រមួយច្បាប់ផ្ញើឲ្យមិត្តរបស់នាងថា «តើឯងដឹងឬទេ កាសៀ ទោះបីជាយ៉ាងណាក៏ដោយ ខ្ញុំនៅតែស្រឡាញ់និងចូលចិត្តសាលារៀនដូចដើម។ ជួនកាល ឯងអាចនឹងសើចចំអកខ្ញុំក្នុងរឿងនេះ ក៏ប៉ុន្តែខ្ញុំត្រូវប្រាប់ឯងថា ខ្ញុំស្រឡាញ់និងចូលចិត្តសាលារៀនខ្លាំងណាស់...រយៈពេលពីរឆ្នាំទៀតតែប៉ុណ្ណោះ ខ្ញុំក៏នឹងបានចាកចេញពីទីនោះហើយ...ពេលវេលាពិតជាលឿនមែនទែន»។

ម៉ារៀ បញ្ចប់ថ្នាក់មធ្យមសិក្សានៅអាយុ ១៦ ឆ្នាំ ព្រមទាំងបានទទួលមេដាយមាសផ្នែកសិស្សពូកែទៀតផង។ នាងបានចំណាយពេលធ្វើដំណើរកម្សាន្តទៅកាន់ទីកន្លែងផ្សេងៗក្នុងប្រទេសអស់រយៈពេលមួយឆ្នាំ ក្រោយមកបានធ្វើការជាជំនួយការគ្រូបង្រៀន ហើយក្រោយមកទៀតបានធ្វើជាគ្រូបង្រៀនក្រៅម៉ោង ហើយក៏បានទៅបន្តការសិក្សានៅមហាវិទ្យាល័យនាទីក្រុង បារីស បើទោះបីជានាងពុំសូវជាមានប្រាក់កាសក៏ដោយ។ នៅថ្នាក់មហាវិទ្យាល័យ ម៉ារៀ ឃូរី រៀនបានលំដាប់លេខមួយរៀងរាល់ឆ្នាំ ដែលជាហេតុធ្វើឲ្យនាងបានទទួលនូវអាហារូបករណ៍ដែល

អាចជួយសម្រួលបញ្ហាលុយកាក់បានមួយកម្រិត ហើយនៅមហាវិទ្យាល័យនាទីក្រុងបារីសនេះឯង ដែលនាងបានជួបគ្នាជាមួយនឹងលោក ពីយេ ឃូរី អនាគតស្វាមីរបស់នាង ដែលមានអាយុច្រើនជាងរូបនាងរហូតដល់ទៅ ៨ ឆ្នាំ។

# ណាប៉ូឡេអុង បូណាផាត

( Napoleon Bonaparte, Franch ) គ.ស.១៧៦៩ - ១៨២១



ពូកែវិជ្ជាកាប់ដាវ
គណិតវិទ្យា ភូមិវិទ្យា និងប្រវត្តិសាស្ត្រលោក
បានក្លាយជាអ្នកចម្បាំងដ៏អស្ចារ្យនៅក្នុងលោក។

សាលារៀនផ្នែកទាហាន និងយុទ្ធវិទ្យាក្នុងតំបន់អឺរ៉ុបជាច្រើនប្រទេស ដែលបានផលិតចេញនូវឧត្តមសេនីយ៍ដ៏មានឈ្មោះល្បីល្បាញជាច្រើននាក់ចាប់តាំងពីសតវត្សរ៍ទី ១៩ មកម៉្លេះ។ សាលារៀនទាំងនោះប្រហែលជានឹងមិនបានបង្កើតឡើងឡើយ បើមិនមានការបដិវត្តិបារាំង និងសង្គ្រាម ណាប៉ូឡេអុង កើតឡើង។ ណាប៉ូឡេអុង បានក្លាយជាគំរូសម្រាប់ពួកទាហានជំនាន់ក្រោយ បានសិក្សារៀនសូត្រពីប្រវត្តិសាស្ត្រផ្នត់គំនិត យុទ្ធវិធីក្នុងការធ្វើចម្បាំងដ៏ស្វាហាប់ និងដាច់ខាត់បំផុតរបស់គាត់។ ចំពោះរូបគាត់ផ្ទាល់ កាលនៅសិក្សាក៏ជាសិស្សដែលរៀនឆ្លាតមិនចាញ់សិស្សដទៃឡើយ ក៏ប៉ុន្តែគាត់មិនមែនពូកែរហូតឬពូកែគ្រប់មុខវិជ្ជាទាំងអស់នោះទេ។

ណាប៉ូឡេអុង បូណាផាត កើតថ្ងៃទី ១៥ ខែសីហា គ.ស. ១៧៦៩ ក្នុងទីក្រុង អាច័កសុិអូ នៅលើកោះ ខរ័សុិកា ក្នុងខណៈដែលម្ដាយទើបតែមានអាយុត្រឹមតែ ១៩ ឆ្នាំ។ ម្ដាយរបស់ ណាប៉ូឡេអុង ជាស្ត្រីឆ្លាតក្នុងការចិញ្ចឹមបីបាច់ថែរក្សាអប់រំទូន្មានកូនប្រកបដោយវិធីដែលទាន់សម័យ។ នាងបានរៀបចំបន្ទប់ធំមួយសម្រាប់កូនៗរបស់នាងលេងនៅពេលដែលមានភ្លៀងធ្លាក់មិនអាចចេញទៅរត់លេងខាងក្រៅផ្ទះបាន។ នាងឲ្យកូនៗលេងគ្រប់យ៉ាង មិនថា ការគូររូបផាត់ពណ៌នៅលើជញ្ជាំងបានទាំងអស់តាមចិត្តប្រាថ្នា ប៉ុន្តែនាងក៏មិនបណ្ដោយឲ្យកូនៗក្លាយជាក្មេងទម្រើសឡើយ។ នាងធ្លាប់បានពោលថា «ម្ដាយក្មេកនិងស្វាមីរបស់ខ្ញុំក៏យកចិត្តទុកដាក់ចំពោះកូនចៅណាស់ដែរ ហើយពួកគាត់និងរត់មករកកូនភ្លាមប្រសិនឮសំឡេងកូនយំតែបន្តិច ដើម្បីនឹងប្រឡោមលួងលោមពួកគេ ចំណែករូបខ្ញុំវិញក្រៅពីមើលថែកូនដោយយកចិត្តទុកដាក់ហើយនៅពិចារណាមើលទៀតថា តើគួរតែធ្វើយ៉ាងណាចំពោះពួកគេទើបសមតាមទេពកោសល្យរបស់គេ»។

ឪពុកម្ដាយរបស់ ណាប៉ូឡេអុង មានគំនិតដូចគ្នាគឺត្រូវឲ្យកូនៗរៀនឲ្យបានល្អជាទីបំផុត។ អ្នកទាំងទ្វេគិតថា អាវុធដែលអាចប្រើដើម្បីតស៊ូពុះពារចំពោះឧបសគ្គនៅក្នុងឆាកជីវិតក្រៅអំពីសេចក្ដីអត់ធន់ នោះក៏គឺចំណេះវិជ្ជា។ នៅក្នុងអំឡុងពេលដែល ណាប៉ូឡេអុង បានមកចាប់កំណើតនោះ ឪពុករបស់គាត់កំពុងបន្តការសិក្សាថ្នាក់បណ្ឌិតផ្នែកច្បាប់នៅឡើយ។ ចំណែកឯ ណាប៉ូឡេអុង វិញគឺជាសិស្សដែលស្រេកឃ្លាន

ចំពោះការសិក្សារៀនសូត្រយ៉ាងខ្លាំងក្លា ហើយតែងតែរៀនសូត្របានល្អជានិច្ច ជាពិសេសមុខវិជ្ជាគណិតវិទ្យា។

នៅពេលដែលគាត់មានអាយុ ៥ ឆ្នាំ ឪពុកបានបញ្ជូនទៅនៅសាលាមតេយ្យសម្រាប់ពួកកុមារី។ ណាប៉ូឡេអុង បានពោលរំឭកថា កាលនោះ គាត់បានលង់ស្នេហ៍ជាមួយនឹងក្មេងស្រីដ៏គួរឲ្យស្រឡាញ់ម្នាក់ នាងមានឈ្មោះថា ជៀកកូមមិនែតា ប៉ុន្តែស្រីតូចម្នាក់នោះមិនបានចាប់អារម្មណ៍ចំពោះរូបគាត់ឡើយ ពីព្រោះតែស្រោមជើងរបស់គាត់តែងតែរបូតធ្លាក់ទៅនៅនឹងភ្នែកគោ។ ក្រោយពីនោះមិនយូរប៉ុន្មាន រូបគាត់និងបងប្រុសឈ្មោះ ចូសែហ្វ បានផ្លាស់ទៅរៀនសិល្បៈការអាន ការសរសេរ និងរៀនគណនាលេខជាមួយនឹងបព្វជិតនៃសាសនាគ្រិស្តមួយរូប ដែលណាប៉ូឡេអុង បានបញ្ជាក់ឈ្មោះក្នុងពាក្យបណ្តាំមុនពេលធ្វើមរណៈភាពថា «ឲ្យលោកគ្រូជាទីស្រឡាញ់របស់ខ្ញុំម្នាក់នេះបានទទួលប្រាក់ចំនួនពីរម៉ឺនហ្វ្រង់ដ៏ផង»។

លោកឪពុករបស់ ណាប៉ូឡេអុង ត្រូវបានជ្រើសតាំងជាសមាជិកសភា និងជាតំណាងរាស្ត្រមកពីកោះ ខស៊ិកា ទៅប្រចាំការនៅទីក្រុងបារីស ហើយគាត់បានឆ្លៀតឱកាសក្រាបបង្គំទូលព្រះរាជា សូមព្រះរាជទានអាហារូបករណ៍ដល់កូនរបស់ខ្លួនម្នាក់ ដើម្បីបានទៅសិក្សាបន្តនៅសាលាទាហានសម្រាប់ពួកអភិជនបារាំងសែស។ ទីបំផុត ណាប៉ូឡេអុង បានទទួលអាហារូបករណ៍ ប៉ុន្តែគាត់ត្រូវទៅរៀននៅសាលា អូតឹង ដើម្បីហ្វឹកហាត់ភាសាបារាំងឲ្យស្ទាត់ជំនាញជាមុនសិន គឺនៅឯស្រុកកំណើត

របស់គាត់នាកោះ ខរ័ស៊ិកា គឺប្រើប្រាស់តែភាសាក្នុងតំបន់គឺភាសាអ៊ីតាលី។ ក្រោយពីនោះរយៈពេល ៥ ខែទើបអាចចូលទៅរៀននៅសាលាកិច្ចការយោធា ( Military Academy ) បាន ហើយបន្តរៀននៅទីនោះអស់រយៈពេល ៥ ឆ្នាំ។

ដោយធ្លាប់រស់នៅកោះ ខរ័ស៊ិកា ប្រកបដោយបរិយាកាសដែលពោរពេញដោយឥស្សរភាពនិងសេរីភាព នៅពេលផ្លាស់មករៀនសាលាយោធានោះ ណាប៉ូឡេអុង មានអារម្មណ៍ហាក់បីដូចជាជាប់គុកអ៊ីចឹង។ ការអប់រំនៅសាលារៀនប្រព្រឹត្តទៅយ៉ាងតឹងរ៉ឹងបំផុត ពួកសិស្សទាំងឡាយមិនសូវជាបានអនុញ្ញាតឲ្យចេញទៅខាងក្រៅបរិវេនសាលាទេ ហើយត្រូវរៀនដោយមិនមានពេលវិស្សមកាលទៀតផង។ ពួកសិស្សអាហារូបករណ៍បានទទួលប្រាក់ពីព្រះរាជាសម្រាប់ចាយវាយចំនួនតិចតួចប៉ុណ្ណោះ និងមិនអនុញ្ញាតឲ្យទទួលយកអំណោយ កាដូ ឬសូម្បីតែសៀវភៅពីបុគ្គលខាងក្រៅឡើយ។

ណាប៉ូឡេអុង មានអារម្មណ៍ចង្អៀតចង្អល់ចិត្តយ៉ាងខ្លាំង ដែលត្រូវមករៀនក្នុងសភាពដូច្នេះ។ ក្នុងចំណោមពួកសិស្សទាំងនោះគាត់មានរាងទាបជាងគេ ហើយពួកសិស្សទាំងនោះចូលចិត្តនិយាយចំអកចំអន់ធ្វើត្រាប់តាមចំពោះការនិយាយភាសាបារាំង ប៉ែឡាំៗរបស់គេ។ ភាគច្រើនគាត់ចូលចិត្តនៅតែម្នាក់ឯង ធ្វើលំហាត់ អានសៀវភៅ ឬអង្គុយលេងក្នុងសួនតូចរបស់គេ (សិស្សសាលាយោធាក្នុងប្រទេសបារាំងសម័យនោះគេប្រគល់ដីមួយកន្លែងឲ្យសម្រាប់ដាំបន្លែឬដាំផ្កាផ្សេងៗក៏បាន)។

គាត់រៀនបានពិន្ទុល្អឥតខ្ចោះចំពោះមុខវិជ្ជាគណិតវិទ្យា ហើយមុខវិជ្ជាមួយចំនួនផ្សេងទៀត រៀនបានពិន្ទុល្អជាមធ្យមនិងមានខ្លះទៀតខ្សោយតែម្តង។ ចំណែកការសរសេរអក្សររបស់គាត់វិញ មិនស្អាតឡើយ ហើយច្រើនតែប្រើពាក្យពេចន៍ខុសខ្លះត្រូវខ្លះ រីឯភាសាបារាំងរបស់គាត់ស្តាប់ទៅហាក់បីដូចជាមនុស្សព្រៃនិយាយគ្នា។ គាត់រៀនពូកែចំពោះតែអ្វីដែលគាត់ចាប់អារម្មណ៍តែប៉ុណ្ណោះដូចជា គណិតវិទ្យា ភូមិវិទ្យា និងប្រវត្តិសាស្ត្រជាដើម។

ណាប៉ូឡេអុង បានក្លាយជាសិស្សនាយទាហានពេញលក្ខណៈនៅអាយុ ១៥ ឆ្នាំ ហើយបានប្តូរទៅរៀនសាលាយោធានៅទីក្រុងបារីស ប៉ុន្តែគាត់នៅតែខ្សោយភាសាបារាំងដូចដើម។ គាត់សរសេរដូចដែលគាត់បានស្តាប់ឮ (ភាសានិយាយ, ភាសាបារាំងត្រូវសរសេរតាមវេយ្យាករណ៍ មានការតភ្ជាប់ពាក្យ បើមិនដូច្នោះទេនឹងខុសបានដោយងាយ)។ គាត់ចូលចិត្តបរិយាកាសនៅទីក្រុងជាង។ សាលាដែលត្រូវមករៀនតនេះគឺជាសាលាសាងសង់ថ្មី តែសម្រាប់គាត់គឺអស្ចារ្យខ្លាំងណាស់ ក្នុងបន្ទប់រៀនក្រាលដោយកម្រាលព្រំពណ៌ផ្ទៃមេឃដ៏ស្រស់ស្អាត ហើយប្រដាប់ដោយផ្កាលីលីពណ៌មាសនៅតាមបង្អួច និងទ្វារតុបតែងទៅដោយវាំងននយ៉ាងស្អាត បន្ទប់កក់ក្តៅដោយមានជើងក្រានកម្តៅស៊េរីថ្មី។

ក្រៅអំពីនេះ ឈុតឯកសណ្ឋានសិស្សរបស់សាលារៀននេះមើលទៅស្អាតត្រូវចិត្ត ណាប៉ូឡេអុង ម៉ាច់តែម្តង ហើយអាហារក៏មានរស់ជាតិឆ្ងាញ់ ឯគ្រូបង្រៀនវិញសុទ្ធតែជាអ្នកឯកទេសស្ទាត់ជំនាញផ្នែកកិច្ចការ

យោធា។ ណាប៉ូឡេអុង រៀននៅថ្នាក់នាយទាហានផ្នែកកាំភ្លើងធំហើយ ផ្នែកនេះត្រូវការប្រើប្រាស់គំនិតក្នុងការគណនាយ៉ាងចាំបាច់ ទើបក្លាយជាទីពេញចិត្តពេញថ្លើមគាត់យ៉ាងខ្លាំង ព្រោះគាត់ចូលចិត្តមុខវិជ្ជាគណិតវិទ្យា ភូមិវិទ្យា និងប្រវត្តិសាស្ត្រដែលមានក្នុងកម្មវិធីសិក្សានោះផងដែរ។ ទោះជាមុខវិជ្ជានេះ ពួកសិស្សទូទៅតែងតែរអ៊ូរទាំថា លំបាកខ្លាំងណាស់ តែគាត់អាចរៀនបានល្អជាមធ្យមខាងវិជ្ជាយុទ្ធសាស្ត្ររៀបចំបន្ទាយ ឯភាសាអាល្លឺម៉ង់រៀនបានល្មមប្រើការបាន។ គាត់រៀនបានកំពូលក្នុងមុខវិជ្ជាកាប់ដាវ ប៉ុន្តែការរៀនរបាំកាយវិការបែរជាបរាជ័យទៅវិញ។

តាមការពិតទៅ គាត់រៀនមុខវិជ្ជាទាំងឡាយប្រហាក់ប្រហែលគ្នាកាលពីមុនដែរ។ ប៉ុន្តែនៅទីនេះគាត់បានបង្កើនសេចក្តីឧស្សាហ៍ព្យាយាមកាន់តែខ្លាំងឡើង ព្រោះឪពុករបស់គាត់បានធ្វើមរណកាលទៅក្នុងអំឡុងពេលនេះដែរ ទើបគាត់ខំប្រឹងរៀនឲ្យចប់ដើម្បីឆាប់បានចេញធ្វើការងារនឹងអាលបានជួយសម្រាលភារកិច្ចរបស់ម្តាយជាទីគោរពស្រឡាញ់របស់គាត់។ ណាប៉ូឡេអុង បានព្យាយាមប្រឡងមុខវិជ្ជាផ្សេងៗរហូតបានបញ្ចប់ការសិក្សាក្នុងរយៈពេលត្រឹមតែមួយឆ្នាំ ដែលជាទូទៅគឺត្រូវរៀនរយៈពេលពីរឆ្នាំពេញទើបអាចបញ្ចប់គ្រប់មុខវិជ្ជាបាន ហើយព្រះបាទលុយស៍ទី ១៦ បានប្រោសព្រះរាជទានឡាយព្រះហស្តលេខាផ្ទាល់ព្រះអង្គនៅក្នុងសញ្ញាបត្ររបស់គាត់។ ក្នុងខណៈនោះគាត់មានអាយុ ១៦ ឆ្នាំ ហើយក្លាយជាយុវជនដែលគ្មានសេចក្តីសុខនិងរស់នៅក្នុងភាពឯកោ។

គាត់មានអារម្មណ៍ស្អប់សង្គម ដែលគាត់បានជួបប្រទះក្នុងសម័យនោះ។ មានគ្រាមួយ គាត់ធ្លាប់គិតចង់សម្លាប់ខ្លួនទៀតផង គាត់បានសរសេររៀបរាប់អំពីអារម្មណ៍ក្នុងអំឡុងពេលនោះថា «ខ្ញុំមានអារម្មណ៍កណ្តោចកណ្តែងសូម្បីតែនៅកណ្តាលចំណោមនៃហ្វូងមនុស្សម្នា ពេលណាដែលមានអារម្មណ៍បែបនេះ ខ្ញុំតែងបង្ខាំងខ្លួនឯងនៅក្នុងបន្ទប់ស្ថិតនៅក្នុងសភាពពិបាកចិត្តនិងសេចក្តីខ្លាចព្រឺព្រួច អារម្មណ៍អាក្រក់ដែលលងបន្លាចរូបខ្ញុំនេះនឹងនាំរូបខ្ញុំទៅទីណា ... នាំទៅរកសេចក្តីស្លាប់មែនទេ...? ទេ... អ្វីដែលរុញច្រានឲ្យខ្ញុំឈានទៅរកវិថីនៃការបំផ្លាញខ្លួនឯងដូច្នេះ...? ខ្ញុំមិនដឹងថា ខ្ញុំចាប់ផ្តើមជីវិតនៅក្នុងលោកនេះយ៉ាងណា ... ទោះយ៉ាងណាក៏គង់តែនឹងស្លាប់ ... អ៊ីចឹងច្របាច់កខ្លួនឯងឲ្យស្លាប់តែម្តងទៅវាល្អជាជាង...? ជីវិតខ្ញុំនេះពោរពេញទៅដោយសេចក្តីទុក្ខលំបាក ខ្ញុំពុំដែលបានជួបសេចក្តីសុខកាយសប្បាយចិត្តម្តងណាឡើយ មានតែការឈឺចាប់ពើតផ្សារ ដោយខ្ញុំត្រូវត្រដររស់នៅជាមួយមនុស្សម្នាទាំងឡាយទាំងក្នុងពេលនេះ និងពេលអនាគតតដែលមានលក្ខណៈខុសគ្នាដាច់ស្រឡះពីរូបខ្ញុំ ប្រៀបដូចជាព្រះចន្ទនិងព្រះអាទិត្យអ៊ីចឹង»។

ក្រោយមកមិនយូរប៉ុន្មាន គាត់បានក្លាយជានិមិត្តរូបនៃយុវជនជំនាន់ក្រោយទូទាំងទ្វីបអឺរ៉ុប ដែលតាំងចិត្តចង់ឃើញទ្វីបអឺរ៉ុបកែប្រែមុខមាត់ដែលទាន់សម័យ និងប្រកបដោយបរិយាកាសនៃសេចក្តីសុខសន្តិភាពសេរីភាព។ ជាពិសេសពួកបញ្ញាជនទាំងឡាយក្នុងប្រទេសអាល្លឺម៉ង់មានសេចក្តីពេញចិត្តចំពោះរូបគាត់យ៉ាងក្រៃលែង។ គីថេ ធ្លាប់បាននិយាយពី

ណាប៉ូឡេអុងថា «គាត់ជាបុរសដែលមានប្រាជ្ញា ដឹងច្បាស់ និងធ្វើការសម្រេចចិត្តបានយ៉ាងត្រឹមត្រូវសមស្របគ្រប់ស្ថានការណ៍ ប្រកបដោយកម្លាំងពលំនិងឥទ្ធិពលដ៏លើសលុប»។ គ្រីលផារ័ហ្ស៊ឺរ៍ ព្រមទទួលស្គាល់ថា ណាប៉ូឡេអុង ទាក់ទាញគាត់ដូចជារាយមន្តសណ្តំអ៊ីចឹង «គាត់បានរាយមន្តដាក់ខ្ញុំដូចពស់រឹតកូនបក្សីតូចអ៊ីចឹង»។ ចំណែក ហ៊ែនរីច ហ៊ែនន័របានពោលថា «ណាប៉ូឡេអុង មិនមែនសាងមកពីឈើដែលមនុស្សអាចយកមកឆ្លាក់ធ្វើក្បត្របាននោះទេ ប៉ុន្តែគាត់គឺត្រូវបានគេសាងឡើងពីថ្មកែវដែលបដិមាករ (ជាងចម្លាក់) ដែឯកបានឆ្លាក់ជាអទិទេពយ៉ាងពិតប្រាកដ»។

# គុសស្តាហ្វ ហ្លូបឺត

(Gustave Flaubert, Franch) គ.ស. ១៨២១ - ១៨៨០

នៅកុមារនរណាៗក៏និយាយ
ថាគាត់ជាក្មេងបញ្ញាខ្សោយ
ប៉ុន្តែនៅពេលមានអាយុ ៩
ឆ្នាំគាត់អាចនិពន្ធរឿងបាន។



កាលនៅក្នុងវ័យសិក្សា ហ្លូបឺត មានការជឿជាក់លើភាពអស្ចារ្យរបស់ខ្លួនឯងយ៉ាងមោះមុត ប៉ុន្តែស្របពេលជាមួយគ្នានោះដែរ គាត់ជាក្មេងពូកែអៀនគ្មានលេខដាក់ និងតែងតែមានអារម្មណ៍ថា «នៅសាលាមធ្យមសិក្សានាទីក្រុង រួង ពុំមាននរណាយល់ចិត្តរូបគាត់ឱ្យពិតប្រាកដឡើយ ហើយពួកគេចូលចិត្តចំអែចំអន់គាត់ទៀតផង។

គុសស្តាហ្វ ហ្លូបឺត កើតថ្ងៃទី ១២ ខែធ្នូ គ.ស. ១៨២១ នៅទីក្រុង រួង មានឪពុកជាគ្រូពេទ្យ។ កាលទើបនឹងប្រសូត្រនរណាក៏គិតថាគាត់ជាក្មេងបញ្ញាខ្សោយ (មិនគ្រប់ទឹក) ក៏ប៉ុន្តែពេល ហ្លូបឺត មានអាយុ ៩ ឆ្នាំស្រាប់តែអាចនិពន្ធរឿងបាន។ គាត់ចូលរៀននៅកម្រិតថ្នាក់ ៦ នៅសាលាមធ្យមសិក្សានៃទីក្រុង រួង។ នៅពេលគាត់មានអាយុ ១១ ឆ្នាំ បើទោះបីជាគាត់មានអារម្មណ៍ថា ខ្លួនគាត់មានចំណុចខ្សោយ មិនដែល

ស្រឡះពីចិត្តរបស់គាត់ម្តងណាឡើយក៏ដោយ ប៉ុន្តែគាត់ក៏អាចពិសោធខ្លួនឯងបានដែរថា គាត់ជាសិស្សដែលរៀនពូកែអស្ចារ្យហួសពីការស្មាន។ មុខវិជ្ជាដែលទាក់ទាញចិត្តដ៏មានឥទ្ធិពលបំផុតចំពោះគាត់គឺ អក្សរសិល្ប៍ និងប្រវត្តិសាស្ត្រ ហើយថែមទាំងធ្លាប់បានទទួលរង្វាន់សិស្សពូកែផ្នែកប្រវត្តិសាស្ត្រផងដែរ។ ហ្លូបឺត បានបញ្ចប់ការសិក្សាថ្នាក់មធ្យមនៅអាយុ ១៩ ឆ្នាំ ហើយសំណេរនិពន្ធបិទបញ្ចប់ថ្នាក់មធ្យមរបស់គាត់ មានកម្រិតខ្ពស់អាចប្រៀបធៀបជាមួយស្នាដៃនិពន្ធកម្រិតថ្នាក់អនុបណ្ឌិតបាន។

កុសស្តាហ្វ ហ្លូបឺត មិនបានរៀនបញ្ចប់ថ្នាក់មហាវិទ្យាល័យទេ គឺនៅពេលដែលគាត់ចូលរៀនផ្នែកច្បាប់នៅមហាវិទ្យាល័យ ក៏ស្រាប់ឈប់ពាក់កណ្តាលទី ព្រោះគាត់ត្រូវការលះបង់ពេលវេលាទាំងអស់សម្រាប់តែការសរសេរនិពន្ធប៉ុណ្ណោះ។

ទីបំផុត បុរសដែលមិនបានរៀនអ្វីច្រើនផង ស្រាប់តែក្លាយជាអ្នកនិពន្ធជាតិបារាំងដ៏មានឥទ្ធិពលបំផុត និងជាអ្នកនិពន្ធប្រលោមលោកដ៏អស្ចារ្យម្នាក់ស្ទើរតែរកគូប្រៀបពុំបាន។

# ស៊ិកម៉ាន់ដ៍ ហ្វ្រូដ

(Sigmund Frued, Austrian Empire) គ.ស. ១៨៥៦ - ១៩៣៩

ខ្ញុំមិនចង់ក្លាយជាពេទ្យណាស់ណាទេ ខ្ញុំចូលចិត្តសិក្សាពីអ្វីដែលទាក់ទិននឹងទំនាក់ទំនងនៃមនុស្សជាងការសិក្សាពីវត្ថុដែលពាល់ត្រូវបាន។



ស៊ិកម៉ាន់ដ៍ ហ្វ្រូដ ជាបុគ្គលដែលពិភពលោកបានស្គាល់ថា គឺជាអ្នករៀនដែលអាចនិយាយបានថា គាត់មានការជឿជាក់លើខ្លួនឯងជាងអូសស្កា វៀលដ៍ ហើយជាអ្នកវិភាគផ្លូវចិត្តដែលបានសាងនូវទ្រឹស្តីដ៏គួរឲ្យភ្ញាក់ផ្អើលក្នុងចំណោមអ្នកសិក្សាផ្នែកចិត្តវិទ្យាទាំងឡាយទាំងពួង។ ប៉ុន្តែដោយសារគាត់ជាជនជាតិជ្វីហ្វ ទើបជីវិតក្នុងការសិក្សារបស់គាត់មិនសូវជារលូនប៉ុន្មានទេ។ គាត់កើតថ្ងៃទី ៦ ឧសភា គ.ស. ១៨៥៦ នៅទីក្រុងហ្វ្រាយប៊ឺក ក្នុងដែនដី ម៉ូរ៉ាវៀ ដែលខណៈនោះជាផ្នែកមួយនៃចក្រពត្តិអស្ត្រៀ-ហុងគ្រី (បច្ចុប្បន្នស្ថិតក្នុងសាធារណរដ្ឋឆេក)។ តែជាសំណាងអាក្រក់ដែលនៅក្នុងអំឡុងពេលនោះ មានការបំផុសបំផុលបង្កើតឡើងនូវបណ្តាញប្រឆាំងនិងរើសអើងជនជាតិជ្វីស នៅទូទាំងទ្វីបអឺរ៉ុប រួមទាំង

ចក្រពត្តិអស្ត្រៀ-ហុងគ្រីផងដែរ។ សម្រាប់ ហ្វ្រូដ មានមោទនភាពដែលបានកើតមកជាជនជាតិជ្វីហ្វ ហើយត្រូវតស៊ូដើម្បីការពារអត្តសញ្ញាណជាតិខ្លួន ដែលផ្ទុយគ្នាពីឪពុកគាត់ដែលជាអ្នកលក់កំណាត់រោមសត្វ។ ឪពុកគាត់ធ្លាប់និទានឲ្យស្តាប់ថា «ថ្ងៃមួយគាត់កំពុងតែដើរនៅតាមថ្នល់ស្រាប់តែមានបុរសម្នាក់ស្ទុះមករករូបគាត់ហើយចាប់កញ្ឆក់មួករោមសត្វចេញពីក្បាលរបស់គាត់ ហើយបោះចោលព្រមទាំងស្រែកជេរថា «អ្នែង! អាពួក ជ្វីហ្វ ចង្រៃ អ្នែង! ឆាប់ចេញឲ្យផុតពីផ្លូវនេះភ្លាម» ឮដូច្នោះគាត់ក៏សួរទៅកាន់ឪពុកថាចុះពុកឯងធ្វើយ៉ាងម៉េច? ឪពុកបែរជាឆ្លើយប្រាប់ថា ពុកដើរទៅរើសមួកហើយដើរចាកចេញទៅដោយមិនតបតអ្វីឡើយ។ ចម្លើយរបស់ឪពុកធ្វើឲ្យ ហ្វ្រូដ អស់សង្ឃឹមយ៉ាងខ្លាំង។

គាត់បានចូលរៀននៅសាលាមធ្យមសិក្សា ស្ប៉ីល នៅក្នុងទីក្រុងវៀនណា ហើយបានបង្ហាញនូវភាពអច្ឆរិយៈឲ្យប្រាកដតាំងពីពេលនោះមក។ គាត់ប្រឡងជាប់លេខមួយស្ទើរតែរាល់ឆ្នាំ ដែលនោះមិនមែនមកពីគាត់ឧស្សាហ៍ និងជឿជាក់លើខ្លួនឯងខ្ពស់នោះទេ តែមកពី ហ្វ្រូដ ជាបុគ្គលស្រេកឃ្លានចំណេះដឹងគ្រប់ពេលវេលា ហើយតែងសិក្សាស្រាវជ្រាវនូវចំណេះដឹងផ្សេងៗក្រៅពីមុខវិជ្ជាដែលរៀននៅសាលាជានិច្ច។ ក្រៅពីនេះ ហ្វ្រូដ ជាក្មេងអច្ឆរិយៈផ្នែកភាសា គាត់សិក្សានិងស្វែងយល់ភាសាឡាតាំង ភាសាក្រិចបុរាណ អាចនិយាយភាសាបារាំង និងភាសាអង់គ្លេសបានយ៉ាងស៊ីជម្រៅនិងស្ទាត់ជំនាញ។ គាត់រៀនភាសាអ៊ីតាលី និងភាសាអេសប៉ាញដោយខ្លួនឯង។ មិនត្រឹមប៉ុណ្ណោះគាត់អាចប្រើប្រាស់ភាសា

ហ៊ីប្រ៊ូ (Hebrew) បានយ៉ាងល្អទៀតផង។ គាត់រៀនចប់ថ្នាក់មធ្យមសិក្សាប្រកបដោយជោគជ័យ និងមានពិន្ទុខ្ពស់បំផុត ហើយទទួលបាននូវប័ណ្ណសរសើរជាសិស្សឆ្នើមទៀតផង។

ក្រោយពេលបញ្ចប់ការសិក្សាថ្នាក់មធ្យមសិក្សា គាត់បានសម្រេចចិត្តរៀនបន្តផ្នែកវិជ្ជាពេទ្យ។ គាត់បានផ្តល់នូវហេតុផលក្នុងកាលជាខាងក្រោយថា «លោកឪពុកគាត់ឲ្យខ្ញុំសម្រេចចិត្តខ្លួនឯងថាខ្ញុំគួររៀនជំនាញអ្វី ឬគួរប្រកបអាជីពអ្វីឲ្យពិតប្រាកដនៅថ្ងៃអនាគត ហើយខ្ញុំក៏ពុំសូវចូលចិត្តវិជ្ជាពេទ្យណាស់ណាដែរ ខ្ញុំចូលចិត្តសិក្សាទាក់ទិននឹងទំនាក់ទំនងនៃមនុស្សជាងការសិក្សាអំពីវត្ថុដែលពាល់ត្រូវបាន។ ក្រៅពីនេះ រឿងរ៉ាវក្នុងព្រះគម្ពីរប៊ីប ក៏មានឥទ្ធិពលចំពោះការសម្រេចចិត្តរបស់ខ្ញុំមិនតិចជាងទ្រឹស្តីដែលទាក់ទងនឹងវិវឌ្ឍនាការវត្ថុនិងសភាវៈមានជីវិតរបស់ ដារ៉វិនប៉ុន្មានដែរ។

ហ្វ្រូដចូលរៀនពេទ្យនៅមហាវិទ្យាល័យ វៀនណា នៅពេលគាត់មានអាយុ ១៧ ឆ្នាំ។ ការដំណើរជីវិតក្នុងឋានៈជាគ្រូពេទ្យ និងជាអ្នកស្រាវជ្រាវពិសោធពិតជាជួបផលលំបាកខ្លាំង ជាងកាលគាត់នៅរៀនទៅទៀត។ គាត់ត្រូវប្រឈមមុខជាមួយការប្រឆាំងជំទាស់របស់ពួកអ្នកចិត្តវិទ្យាបុរាណនិយម ដែលមិនព្រមទទួលស្គាល់ទ្រឹស្តីនៃ«អឌ្ឍសម្បជញ្ញៈ» របស់គាត់យ៉ាងដាច់ខាត។

ក្រោយពីការតស៊ូក្នុងអាជីពអស់រយៈពេលដ៏យូរអង្វែង គាត់ក៏បានក្លាយជាសាស្ត្រាចារ្យនៅពេលគាត់មាន ៤៦ ឆ្នាំ ប៉ុន្តែការតស៊ូរបស់គាត់មិនត្រូវបានបញ្ចប់ត្រឹមតែប៉ុណ្ណោះឡើយ។ គាត់ត្រូវជួបជាមួយនឹងគូសត្រូវនិងគូបដិបក្ខដែលជាអ្នកជំនាញការពេញមួយជីវិត។

បច្ចុប្បន្ននេះ គាត់ត្រូវបានគេស្គាល់ថាជាបិតានៃអ្នកវិភាគពីអាថ៌កំបាំងផ្នែកខាងចិត្តវិទ្យា ( Father of Psychoanalysis )។

# អឺនែសត៍ ហេមិងវេយ៍

( Ernest Hemingway, U.S ) គ.ស. ១៨៩៩ - ១៩៦១



គាត់ចាប់អារម្មណ៍ចំពោះ មុខវិជ្ជាអក្សរសិល្ប៍ និងបានព្យាយាមហ្វឹកហាត់ ជំនាញសរសេរយ៉ាងស្វាត់។ នៅពេលបានក្លាយជា អ្នកកាសែតគាត់បានរិះរកវិធី សរសេរជាទម្រង់ប្រយោគខ្លីៗ ត្រឹមត្រូវតាមប្រធាបទ និងប្រកបដោយអត្ថន័យ ទូលំទូលាយគ្រប់គ្រាន់។

ក្នុងចំណោមអ្នកសិក្សាអច្ឆរិយៈ ដែលមានភាពជឿជាក់លើខ្លួនខ្ពស់នោះ គឺត្រូវតែរាប់បញ្ចូល អឺនែសត៍ ហេមិងវេយ៍ ផងដែរ។ អ្នកនិពន្ធជនជាតិ អាមេរិក ដែលបានទទួលរង្វាន់ណូបែលផ្នែកវណ្ណកម្មម្នាក់នេះ កើតថ្ងៃទី ២១ កក្កដា គ.ស. ១៨៩៩ នៅ អូកផាក រដ្ឋអ៊ីលីណយស៍ សហរដ្ឋអាមេរិក ឪពុករបស់គាត់ជាគ្រូពេទ្យ។ គាត់បាននិពន្ធទាំងរឿងខ្លីៗ និងប្រលោមលោកដែលបង្ហាញឲ្យឃើញដល់ «សម័យកាលនៃមនុស្សជំនាន់ ( បាត់បង់ ) វិនាសកម្ម» នោះគឺយុវជនដែលរស់នៅក្រោយសម័យសង្គ្រាមលោកលើកទីមួយ ហើយរូបគាត់ក៏បានក្លាយជាសំឡេង

រគាំងដាស់សតិមនុស្សម្នាក្នុងសម័យនោះ។ បើទោះបីជាមានរឿងដែលបាននិយាយតៗគ្នាមកថា គាត់ជាក្មេងក្បាលរឹងដែលតែងមានរឿងរ៉ាវទាំងនៅផ្ទះនិងនៅសាលារៀន តាមការពិតទៅគាត់ធ្លាប់រត់ចេញពីផ្ទះចំនួនពីរដងមែន ប៉ុន្តែក៏ប្រញាប់ប្រញាល់វិលត្រឡប់មករកភាពកក់ក្តៅរបស់ក្រុមគ្រួសារភ្លាមៗវិញដែរ។ គាត់អាចជាក្មេងចូលចិត្តការធ្វើដំណើរផ្សងព្រេង ប៉ុន្តែមិនមែនជាក្មេងដែលក្បាលរឹង ឬជាក្មេងមានបញ្ហានោះទេ។

ជីវិតនៅសាលារៀន ហេមិងវេយ៍ ជាសិស្សដែលរៀនពូកែហើយបានទទួលឈ្មោះថា «អ្នកឆ្លាតដ៏មុតស្រួចបំផុត» ដូចដែលមាននៅក្នុងសៀវភៅកម្រងអនុស្សាវរីយ៍ជំនាន់របស់គាត់។ មហិច្ឆតាមានចំណែករុញច្រានឲ្យគាត់ក្លាយជាអ្នកជាប់លំដាប់លេខមួយគ្រប់មុខវិជ្ជា សូម្បីតែក្នុងវិស័យកីឡាក៏គាត់មានសមត្ថភាពដែរ។ ដូចជា ការហែលទឹក ហាត់ប្រដាល់ និងបាល់ទាត់ បណ្តាមិត្តភក្តិទាំងឡាយស្ងើចសរសើររូបគាត់យ៉ាងខ្លាំង។ គាត់មានចំណាប់អារម្មណ៍ចំពោះវិជ្ជាអក្សរសិល្ប៍យ៉ាងខ្លាំងតាំងពីដំបូងឡើយ ហើយបានព្យាយាមហ្វឹកហាត់ជំនាញសរសេរឲ្យមានភាពរីកចម្រើនជារឿយៗ ដោយមានលោកគ្រូពីររូបចាំជួយជ្រោមជ្រែងគាត់។ គាត់និពន្ធកំណាព្យកាព្យឃ្លោង រឿងខ្លីៗហើយកាត់ធ្វើជាឯកសារសម្រាប់ពួកសិស្សនិស្សិតផងដែរ។ ក្រៅពីនេះ គាត់ត្រូវបានគេជ្រើសតាំងឱ្យជាអ្នកនាំពាក្យប្រចាំថ្នាក់រៀនទៀតផង។ បណ្តាគ្រូនិងសិស្សានុសិស្សទាំងឡាយទទួលស្គាល់នូវសមត្ថភាពរបស់គាត់ ជាហេតុធ្វើឲ្យគាត់រៀន

នៅទីនោះប្រកបដោយសេចក្ដីសុខជាពន់ពេក។ ទោះជាយ៉ាងនេះក្ដីនៅពេលសហរដ្ឋអាមេរិកចូលរួមធ្វើសង្គ្រាមលោកលើកទីមួយនាឆ្នាំ ១៩១៧ អឺនែសត៍ មានបំណងលាឈប់ពីសាលារៀនភ្លាមៗដើម្បីចូលបម្រើក្នុងជួរកងទ័ព ក៏ប៉ុន្តែឪពុកមិនយល់ព្រមឲ្យឈប់រៀនពាក់កណ្ដាលទី ដូច្នេះហើយទើបគាត់បានរៀនបន្តរហូតដល់ចប់ថ្នាក់មធ្យមសិក្សា។

ក្រោយពីនោះ អឺនែសត៍ ហេមិងវេយ៍ បានចាកចេញពីផ្ទះដើម្បីទៅធ្វើជាអ្នកកាសែតនៅក្រុង ខែនសាស់ ស៊ីធី។ ក្នុងអំឡុងពេលនោះឯងដែលគាត់បានសិក្សាស្វែងយល់ពីវិធីសាស្ត្រនៃការយកព័ត៌មាន ដោយប្រើបច្ចេកទេសក្នុងការសរសេរជាទម្រង់ប្រយោគខ្លីៗ និងស្របតាមប្រធានបទ (ហេតុការណ៍) មានអត្ថន័យច្បាស់លាស់ ជៀសវាងការប្រើប្រាស់ពាក្យពេចន៍ដែលមិនចាំបាច់។ ទាំងនេះហើយដែលជាលក្ខណៈពិសេសក្នុងការសរសេរវណ្ណកម្មផ្ទាល់ខ្លួនរបស់គាត់ រហូតបានទទួលពានរង្វាន់ណូបែលផ្នែកវណ្ណកម្ម។

ទីបំផុត អឺនែសត៍ ហេមិងវេយ៍ បានក្លាយជាអ្នកកាសែតនិងអ្នកសរសេរជាតិអាមេរិកដ៏អច្ឆរិយៈ ហើយស្ទីលនៃការសរសេររបស់គាត់បានក្លាយជាស្នាដៃដ៏មានឥទ្ធិពលប្រចាំសតវត្សរ៍ទី២០ ដ៏គួរឱ្យសរសើរ។

# មេរៀនទី ៥

រៀនពូកែព្រោះតែឪពុក និងគ្រូបង្រៀនផ្ទាល់នៅផ្ទះ

យើងបានឃើញគំរូជាច្រើន ហើយអ្វីដែលបានរៀបរាប់នៅខាងលើមកនេះអាចយកជាគំរូបានចំនួនមិនតិចទេ។ អ្នករៀនអច្ឆរិយៈ និងមិនអច្ឆរិយៈមើលឃើញសាលារៀនប្រៀបដូចទៅនឹងកន្លែងឃុំឃាំង ដែលបង្គាប់ឲ្យពួកសិស្សធ្វើនេះធ្វើនោះ ហើយធ្វើឲ្យអ្នករៀនបាត់បង់សេរីភាពដោយប្រការផ្សេងៗ។ ពាក្យថា សាលារៀននៅក្នុងអម្បូរភាសាអឺរ៉ុបមួយចំនួនធំក្លាយមកពីភាសាក្រិចបុរាណគឺ "Schole" ដែលមានអត្ថន័យច្បាស់លាស់ថា «ជាឥស្សរភាពចាកភារកិច្ចទាំងពួង» ដែលកាលនោះជនជាតិក្រិចនឹងសិក្សាស្វែងរកចំណេះវិជ្ជាដោយឥស្សរភាព។ បន្ទាប់មកពាក្យនេះបានវិវត្តអត្ថន័យក្លាយមកជាទីកន្លែងដែលមនុស្សម្នាទាំងឡាយមករួមគ្នាជាក្រុមដើម្បីរៀនស្តាប់ និងជជែកវែកញែកផ្លាស់ប្តូរយោបល់គ្នាទៅវិញទៅមកទៅវិញ។

ដូច្នេះ ការស្វែងរកចំណេះវិជ្ជា គឺប្រព្រឹត្តទៅដោយការស្ម័គ្រចិត្ត និងសេរីភាពជាកត្តាសំខាន់ នោះក៏គឺត្រូវទំនេរពីភារកិច្ចការងារផ្សេងៗ។ ការស្វែងរកចំណេះដឹង គឺជារឿងដែលមានតែពួកអភិជនប៉ុណ្ណោះដែលមានពេលវេលាទំនេរអាចធ្វើបាន ជនជាតិអឺរ៉ុបយុគសម័យបុរាណបានបដិបត្តិដូច្នេះរៀងមក។

តាំងពីសម័យក្រិច រ៉ូម៉ាំងបុរាណ រហូតដល់សម័យកណ្តាលមាន បណ្តាពួកអាចារ្យ និងបព្វជិតសាសនាគ្រិស្តទាំងឡាយស្វែងរកចំណេះដឹង និងអភិរក្សរក្សានូវគម្ពីរក្បួនច្បាប់ផ្សេងៗ ហើយផ្សព្វផ្សាយតាមរយៈការ បង្ហាត់បង្រៀនមនុស្សគ្រប់ស្រទាប់វណ្ណៈ។ ដូច្នឹងហើយ វិហារនិងអារាម នានាក្នុងសាសនាគ្រិស្ត ជាប្រភពនៃការសិក្សាសិល្បៈវិជ្ជាការទាំងឡាយ ទាំងពួងអស់រយៈកាលរាប់រយរាប់ពាន់ឆ្នាំមកហើយ។ បន្ទាប់មកទៀត ពាណិជ្ជកម្មការជួញដូរ មានភាពរីកចម្រើនរុងរឿងក្នុងអំឡុងគ្រិស្តសតវត្សរ៍ ទី ១៣។ មនុស្សវណ្ណៈកណ្តាលចាប់ផ្តើមមានលុយ និងមានអំណាច កាន់តែច្រើនឡើងនៅក្នុងសង្គម បាននាំគ្នាឧបត្ថម្ភជ្រោមជ្រែងឲ្យបង្កើត ឡើងនូវគ្រឹះស្ថានអប់រំបំបែកខ្លួនចេញពីវត្តអារាម និងមានកម្មវិធីសិក្សា ដែលទាក់ទងខាងផ្លូវលោកកាន់តែច្រើនឡើង។ គ្រូបាអាចារ្យទាំងឡាយ ក៏ចាប់ផ្តើមពីពួកបព្វជិតមកជាយរាវាសដែលប្រកបដោយចំណេះកាន់តែ ច្រើនឡើងៗជាលំដាប់។

ប៉ុន្តែតាំងពីសម័យបុរាណជាដើមរៀងមក មានបុគ្គលចំនួនមិន តិចទេដែលសិក្សារៀនសូត្រនៅក្នុងក្រុមគ្រួសារ ដែលមានឪពុកម្តាយ ជាអ្នកបង្រៀនផ្ទាល់ បើមិនដូច្នោះទេក៏ជួលគ្រូពិសេសមកបង្រៀនដល់ ផ្ទះតែម្តង។ បុគ្គលទាំងនោះក៏មានចំណេះដឹងនិងពោរពេញដោយជំនាញ មិនចាញ់ពួកបុគ្គលអច្ឆរិយៈទាំងឡាយដែលរៀននៅសាលារៀនឡើយ។ យើងនឹងបានស្គាល់ពីប្រវត្តិរបស់បុគ្គលទាំងនេះ តាំងពីអតីតកាលរហូត ដល់បច្ចុប្បន្នកាលសព្វថ្ងៃនេះដូចតទៅ ៖

# ព្រះបាទ អាឡិចសាន់ឌ័រ មហារាជ

( Alexander the Great, Greek ) ៣៥៦ -៣២៣ ឆ្នាំមុនគ្រិស្តសករាជ

កំពូលអ្នកប្រាជ្ញដ៏ល្បីលប្បាញ
អារីស្តូតគឺជាគ្រូបង្រៀនព្រះបាទ
អាឡិចសាន់ឌ័រ មហារាជ
ហើយអារីស្តូតនេះឯងជាអ្នកជំរុញ
ឲ្យព្រះអង្គទ្រង់ធ្វើសង្គ្រាម
ដើម្បីគ្រប់គ្រងពិភពលោកទាំងមូល។



វិធីសិក្សារបស់ព្រះមហាក្សត្រដ៏មានព្រះកិត្តិនាមល្បីរន្ទឺអង្គនេះ និងគ្រូបង្រៀនព្រះអង្គ គឺកំពូលអ្នកប្រាជ្ញដ៏ល្បីល្បាញបំផុតនៅក្នុងពិភពលោកគឺ អារីស្តូត បានក្លាយជាបែបផែន (និមិត្តរូប) នៃការសិក្សានិងការបង្ហាត់បង្រៀនរបស់អឺរ៉ុបរហូតមកទល់នឹងសតវត្សរ៍ទី ១៩ ហើយជាចំណែកមួយនៃវប្បធម៌អឺរ៉ុប ដែលបាបបន្សល់ទុកអស់រយៈពេលដ៏យូរលង់បំផុត។ ព្រះបាទ អាឡិចសាន់ឌ័រ មានព្រះជន្ម ១៤ ព្រះវស្សា ព្រះបិតារបស់ព្រះអង្គ គឺព្រះបាទ ហ្វីលិបស៍ទី២ នៃម៉ាសុីដូនៀ ទ្រង់បានអញ្ជើញ អារីស្តូត មកធ្វើជាគ្រូបង្រៀនព្រះរាជឱរសរបស់ព្រះអង្គនៅព្រះរាជសំណាក់នាក្រុងភែលា។ ខណៈនោះ អារីស្តូត ក្នុងវ័យ ៤០ ឆ្នាំបាន

ឈានដល់ចំណុចកំពូលនៃជីវិត ហើយបានអភិវឌ្ឍប្រព័ន្ធផ្នត់គំនិតផ្នែកទស្សនវិជ្ជារបស់គាត់ឲ្យរីកចម្រើនជាងអ្នកប្រាជ្ញ ផ្លេតូ ដែលជាគ្រូរបស់គាត់ទៅទៀត។ ការសិក្សាវិភាគបែបគំនិតច្នៃប្រឌិតឬដែលហៅថា «ការផ្តល់ហេតុផលបែបបរមត្ថន័យ» ត្រូវបានយកមកប្រើប្រាស់រហូតដល់ពេលបច្ចុប្បន្ននេះ។ តាមសេចក្តីសន្និដ្ឋានចំណេះវិជ្ជាដែល អារីស្តូត បាននាំយកមកអប់រំដល់ព្រះរាជបុត្រដ៏ឆ្លាតវៃ (អាឡិចសាន់ឌ័រ) និងបណ្តាពួកកូនៗរបស់មន្ត្រីនៃក្រុង ម៉ាសុីដូនៀ ទាំងឡាយនោះក្រៅពីទស្សនវិជ្ជានៅមានទាំងសត្វសាស្ត្រ រុក្ខសាស្ត្រ កាយសិក្សា (សិក្សាអំពីរាងកាយ) តារាសាស្ត្រ រូបវិទ្យា បរមត្ថវិជ្ជា ចរិយាសាស្ត្រ ជំនាញការប្រើប្រាស់ហេតុផលនិងការតែងនិពន្ធ។

អ្នកប្រវត្តិសាស្ត្រទាំងឡាយយល់ឃើញផ្សេងៗខុសពីគ្នា នៃការសិក្សារបស់ព្រះបាទ អាឡិចសាន់ឌ័រ អ្នកខ្លះយល់ឃើញថាព្រះអង្គកើតនៅក្នុងទឹកដី ម៉ាសុីដូនៀ ដែលជនជាតិក្រិចប្រកាន់ថាជាទឹកដីព្រៃផ្សៃនោះព្រះអង្គទ្រង់មានសំណាងល្អយ៉ាងក្រៃលែង ដែលបានជួបគ្រូដូចជាអារីស្តូតមកបង្រៀនថ្វាយ តែអ្នកខ្លះទៀតបែរជាគិតថា ព្រោះការបង្ហាត់បង្រៀនរបស់ អារីស្តូត ដែលជាជនជាតិក្រិច ទើបធ្វើឲ្យព្រះអង្គទទួលឥទ្ធិពលលោកទស្សនៈបែបក្រិច ដែលយល់ឃើញថា ជនជាតិដទៃណាដែលមិនជាប្រជាជនក្រិចជាជនជាតិព្រៃផ្សៃ។ ដូច្នឹងហើយគួរតែស្ថិតនៅក្រោមការគ្រប់គ្រងរបស់ជនជាតិក្រិច ហើយអរិយធម៌របស់ជនជាតិក្រិចគួរតែបានផ្សព្វផ្សាយទៅកាន់ពិភពលោកទាំងមូល ឬអាចនិយាយក្នុង

ន័យម្យ៉ាងទៀតបានថា អារីស្តូត នេះហើយជាអ្នកជំរុញ (អាចដោយមិនបានតាំងចិត្ត) ឲ្យព្រះអង្គទ្រង់ធ្វើសង្គ្រាមវាទីដើម្បីគ្រប់គ្រងពិភពលោកទាំងមូល ហើយគាត់គួរតែជាអ្នកទទួលខុសត្រូវចំពោះសេចក្តីទុក្ខវេទនាដែលព្រះអង្គបានបង្កចំពោះប្រជាជននៅក្នុងដែនដីជាច្រើននានា។

ឥទ្ធិពលរបស់អារីស្តូត ដែលមានចំពោះព្រះបាទអាឡិចសាន់ឌ័រ ក៏បានឃើញប្រាកដជាក់ស្តែង នៅគ្រប់គ្រាដែលព្រះអង្គទ្រង់ប្រថាប់ត្រាលើផែនការអ្វីមួយ មិនចំពោះតែនៅក្នុងទឹកដីក្រិចដែលព្រះអង្គទ្រង់គ្រប់គ្រងទាំងស្រុងហើយនោះទេ សូម្បីតំបន់បូព៌ាប្រទេស ស៊ីរី អេហ្ស៊ីប បាប៊ីឡូនៀ រួមទាំងឥណ្ឌាផងដែរនោះ ព្រះអង្គមិនត្រឹមតែនាំទ័ពក្លាហាន ឬបណ្តាអ្នកជំនាញផ្នែកអាវុធយុទ្ធភណ្ឌ វិស្វករ ពេទ្យ អ្នកគ្រប់គ្រងមើលការខុសត្រូវ និងស្មៀនព្រះរាជសម្ងាត់ ឬអ្នកសង្កេតការណ៍ប៉ុណ្ណោះទេ ថែមទាំងមានទាំងកវី ប្រាជ្ញព្រឹត្តិបណ្ឌិត បញ្ញវ័ន្ត ទៅជាប់ជាមួយនឹងព្រះអង្គផងដែរ។ នោះគឺដើម្បីវិភាគនិងកត់ត្រានូវព្រះរាជករណីកិច្ចដែលព្រះអង្គទ្រង់បានបំពេញ។

តឹកតាងមួយទៀត បង្ហាញពីឥទ្ធិពលរបស់ អារីស្តូត ដែលមានមកលើ អាឡិចសាន់ឌ័រ ជាសិស្សដ៏ឆ្លាតវាងវៃអង្គនេះនោះគឺព្រះអង្គបាននាំក្មួយប្រុសរបស់ អារីស្តូត ដែលមានឈ្មោះថា ខាលីសថេនីស នៃក្រុងអូលីន ទៅធ្វើតួនាទីស្រដៀងនឹងអ្នកកាសែតយោធា (អ្នកយកព័ត៌មានក្នុងពេលមានសង្គ្រាម) និងជាអ្នកឃោសនាបញ្ចុះបញ្ចូលហើយរូបគាត់នេះឯងជាបុគ្គលទីមួយ ដែលបានកត់ត្រានូវប្រវត្តិសាស្ត្ររបស់ព្រះបាទ

អាឡិចសាន់ឌ័រមហារាជ។ ក្រៅអំពីនេះព្រះអង្គទ្រង់តែងតែបានសរសេរព្រះរាជសារទាក់ទងគ្នាជាមួយលោកគ្រូជាទីគោរពរបស់ព្រះអង្គគឺ អារីស្តូត ជារឿយៗពុំដែលខកខានអស់មួយព្រះជន្មព្រះអង្គ។

កាក់ខ្មៅមួយចំហៀងទៀតដែល អារីស្តូត ព្យាយាមពន្យល់ចង្អុលបង្ហាញ អាឡិចសាន់ឌ័រ ដែលជាហេតុនាំឱ្យមានការខ្វែងគំនិតគ្នារវាងគ្រូនិងសិស្សនោះ ព្រោះ អារីស្តូត មានទស្សនៈយល់ឃើញថាពួកជនជាតិផ្សេងៗទៀតជាជនព្រៃផ្សៃ ដែលជនជាតក្រិចគួរនាំយកមកធ្វើជាទាសករ ប៉ុន្តែ អាឡិចសាន់ឌ័រ បែរជាមានគំនិតរួបរួមលោកខាងលិចនិងលោកខាងកើតឱ្យចូលគ្នាជាចក្រភពតែមួយដោយមានព្រះអង្គជាអ្នកត្រួតត្រា។

ព្រះបាទអាឡិចសាន់ឌ័រ ទ្រង់បានរៀបអភិសេកជាមួយក្សត្រីនៃដែនដី បាក់ត្រៀន ហើយទ្រង់បានចាត់ឲ្យមានការរៀបការជាក្រុមរវាងទាហាន ម៉ាស៊ីដូនៀ របស់ព្រះអង្គនឹងស្ត្រីជនជាតិផ្សេងៗដែលទ្រង់ត្រួតត្រាលើជាច្រើនគូ។ ជាអកុសល ក្រោយពីនោះរយៈពេល ២ ឆ្នាំព្រះអង្គក៏ទ្រង់យាងសោយទិវង្គតក្នុងព្រះជន្មាយុ ៣៣ ព្រះវស្សា។ ឯ អារីស្តូត ក៏ទទួលមរណភាពនៅឆ្នាំបន្ទាប់ក្រោយពេលដែលបានបង្កើតសាលារៀនទស្សនវិជ្ជានាឧទ្យានព្រៃស័ក្តិសិទ្ធដែលមានឈ្មោះថា លីខៀន (Lyk eion) ដែលពាក្យនេះបានក្លាយជាប្រភព និងជាឫសគល់នៃពាក្យថាសាលារៀនមធ្យមសិក្សាក្នុងភាសាអឺរ៉ុបជាច្រើនភាសា ដូចជាពាក្យថា Lycee ក្នុងភាសាបារាំងជាដើម។

បិតាទស្សនវិទូ អារីស្តូត និងព្រះបាទ អាឡិចសាន់ឌ័រ មហារាជ ជាអ្នកផ្សព្វផ្សាយនូវអរិយធម៌ក្រិច និងវិធីសិក្សារៀនសូត្របែបក្រិចទៅទូទាំងតំបន់អឺរ៉ុបនិងបូព៌ាប្រទេស។ ដូច្នឹងហើយ ទើបជនជាតិអឺរ៉ុបបាននាំគ្នាសិក្សារៀនសូត្រតាមលំនាំរបស់កវី និងអ្នកប្រាជ្ញជនជាតិក្រិចជារៀងរហូតអស់រយៈកាលជាង ២០០០ ឆ្នាំមកហើយ ហើយអាចនិយាយបានថាជាគំរូដំបូងនៃអរិយធម៌លោកខាងលិច រហូតមកដល់បច្ចុប្បន្នសម័យនេះ។

# កាចូស ជូលៀស សែសារ៍

(Gajus Julius Caesar, Rome) ១០០ - ៤៤ ឆ្នាំមុនគ្រិស្តសករាជ

សែសារ៍ រៀនពូកែទាំងភាសាឡាទីន និងភាសាក្រិច ហើយអាចប្រើប្រាស់បានយ៉ាងស្ទាត់ជំនាញ និងច្បាស់លាស់។ អច្ឆរិយភាពរបស់គាត់គឺស្នាដៃនិពន្ធទាំង ៧ ភាគ។



កាចូស ជូលៀស សែសារ៍ កើតនៅថ្ងៃទី ១៣ ខែកក្កដា មុនគ្រិស្តសករាជ ១០០ ឆ្នាំ។ ដូចព្រះបាទ អាឡិចសាន់ឌ័រ ដែរ គាត់ជាអ្នកចម្បាំង និងជារដ្ឋបុរសដ៏អង់អាចក្លាហានគ្មានបុគ្គលណាអាចប្រៀបផ្ទឹមបាន។ គាត់សិក្សារៀនសូត្រយ៉ាងល្អឥតខ្ចោះ តាំងតែពីអាយុ ១០ ឆ្នាំ គ្រូរបស់គាត់គឺ ម៉ារ៍ឃុស អាន់ថូនីអុស កនីហ្វូ ជាអ្នកមានប្រាជ្ញាឈ្លាសវៃលើជំនាញផ្នែកភាសា អក្សរសិល្ប៍ក្រិច និងឡាទីន យ៉ាងច្បាស់លាស់។ ដូច្នឹងហើយទើប សែសារ៍ បានទទួលនូវការសិក្សាលើជំនាញអាន និងសរសេរភាសាទាំងពីរយ៉ាងស្ទាត់ជំនាញ។ អច្ឆរិយភាពក្នុងការនិពន្ធមានប្រាកដនៅក្នុងស្នាដៃនិពន្ធទាំង ៧ ភាគរបស់គាត់ ដែលទាក់ទងទៅនឹងចម្បាំងក្នុងដែនកូល (De bello Gallico) និង ៣ ភាគទៀតពិពណ៌នា

ពីសង្គ្រាមផ្ទារីក (សង្គ្រាមកណ្ដាលទីក្រុង) រវាងខ្លួនគាត់ផ្ទាល់ជាមួយនឹង ប៉មប៉េយ៍ (De bello Civile)។

សេសារ៍ជាយុវជនកំព្រាឪពុកតាំងពីអាយុ ១៦ ឆ្នាំ ចូលចិត្តចូលរួមសន្និបាតជាប្រចាំដើម្បីស្ដាប់វាគ្មិនល្បីៗ មិនត្រឹមតែប៉ុណ្ណោះគាត់តែងតែតាមដានការអត្ថាធិប្បាយនយោបាយជានិច្ច។ ដោយវិធីនេះឯងហើយដែលគាត់បានសិក្សាស្វែងយល់ពីសិល្បៈនៃការនិយាយ និងការអភិប្រាយក្នុងលំដាប់ខ្ពស់ជាអតិបរមា និងជាកត្តាសំខាន់ក្នុងការអភិវឌ្ឍខ្លួនជាអ្នកនយោបាយដ៏ល្អនៅថ្ងៃអនាគត។ ដើម្បីបានរៀនជំនាញនិយាយឲ្យបានស៊ីជម្រៅ គាត់បានសម្រេចចិត្តធ្វើដំណើរទៅរៀននៅសាលារៀនដែលមានបង្រៀនឯកទេសសិល្បៈនៃការនិយាយដ៏ល្បីឈ្មោះមួយកន្លែង នៅកោះ រ៉ូហ៍ស្តូស។ ក្នុងអំឡុងពេលធ្វើដំណើរទៅកាន់ទីនោះ ពួកចោរនៅតំបន់ក្បែរសមុទ្រ មេឌិទែរេណេ បានចាប់ខ្លួនគាត់ហើយគំរាមទាមទារតម្លៃលោះខ្លួនជាទឹកប្រាក់ចំនួន ២០ ថាឡែនថ៍ (ប្រមាណ ៥ ម៉ឺនដុល្លារសហរដ្ឋអាមេរិកបើប្រៀបធៀបនឹងតម្លៃសាច់ប្រាក់បច្ចុប្បន្ន) ពី សេសារ៍។

ប៉ុន្តែយុវជន សេសារ៍ អ្នកដែលមិនធ្លាប់គិតថា ខ្លួនមានចំណុចខ្សោយណាទៀយក្នុងឆាកជីវិត បែរជាសើចចំអកឲ្យពួកចោរទាំងនោះព្រមទាំងពោលថា «ពួកឯង...មិនដឹងទេថា...តើនរណាគេកំពុងតែឈរនៅចំពោះមុខពួកឯង!»។ បន្ទាប់មក សេសារ៍ ប្រាប់ពួកចោរឲ្យតំឡើងថ្លៃលោះខ្លួនរបស់គេទ្វេមួយជាពីរ ទៅជាចំនួន ៥០ ថាឡែនថ៍ ពួកចោរទាំងនោះក៏យល់ព្រមទាំងងឿងឆ្ងល់។ ពួកចោរទាំងនោះក៏បានទទួលនូវ

តម្លៃខ្លួនតាមដែល សែសារ៍ បានណែនាំ ប៉ុន្តែប្រាក់ទាំងនោះមិនមែន គ្រួសាររបស់ សែសារ៍ ជាអ្នកបង់ខាតនោះទេ គឺខាងរដ្ឋការទីក្រុង រ៉ូម ទេ ជាអ្នកទទួលខុសត្រូវទាំងអស់។

ចំណេះដឹងទាំងឡាយដែល សែសារ៍ បានទទួលការអប់រំ និង ហ្វឹកហាត់យ៉ាងចំណាន ជាពិសេសការផ្តោតសំខាន់លើការសិក្សាផ្នែក កំណាព្យកាព្យឃ្លោង ការនិព្វន្ធ និងអក្សរសិល្ប៍ក្រិចនោះ ត្រូវបានបន្ត វេនរហូតដល់សម័យចក្រពត្តិ រ៉ូម៉ាំង ហើយស្តេចចក្រពត្តិគ្រប់ៗព្រះអង្គ សុទ្ធតែបានសិក្សារៀនសូត្រយ៉ាងល្អឥតខ្ចោះ។ ក្នុងពេលជាក្រោយមក បើទោះជាការសិក្សាយកមូលដ្ឋានគ្រឹះតាមក្បួនច្បាប់ដើម ជាភាសាក្រិច បានធ្លាក់ចុះក៏ដោយ ក៏នៅតែមានការសិក្សារៀនសូត្រយកតាមបែបភាសា ឡាទីន ដែលបានបកប្រែពីច្បាប់ដើមដែលជាភាសាក្រិចដដែល។

នៅពេលចក្រពត្តិ រ៉ូម៉ាំង ដួលរលំក្នុងឆ្នាំ ៤៧៦ នៃគ្រិស្តសករាជ ខាងគ្រិស្តចក្រនិកាយ កាតូលិក ជាអ្នកថែរក្សាទុកគម្ពីរក្បួនច្បាប់ និង ចំណេះដឹងផ្សេងៗនៃអរិយធម៌ក្រិចនិងរ៉ូម៉ាំងបុរាណ។ បើទោះបីជាមាន ការបំផ្លាញចោលខ្លះៗក៏ដោយ (ដោយសារតែផ្ទុយពីគោលការណ៍នៃ ពាក្យប្រៀនប្រដៅរបស់សាសនា)។ ការសិក្សាតាមបែបក្រិច និងរ៉ូម៉ាំង បានត្រឡប់មកកាន់ភាពរុងរឿងសាជាថ្មីម្តងទៀត គឺនៅពេលដែលអឺរ៉ុប បានឈានចូលយុគសម័យស្តារ និងអភិវឌ្ឍលើវិស័យអប់រំ សិល្បវិទ្យា ឬដូចដែលយើងស្គាល់តាមរយៈឈ្មោះមួយទៀតថាយុគ រ៉េនែសហ្សង់។

ជាសរុប កាចូស ជូលៀស សេសារ៍ ក៏ជាមនុស្សម្នាក់ដែលរៀនពីគ្រូមួយទល់មួយដែរ។ ប៉ុន្តែ ដោយសារតែសេចក្ដីតស៊ូប្រឹងប្រែង ទីបំផុតគាត់បានក្លាយជាឧត្ដមសេនីយ៍រ៉ូម៉ាំង ជារដ្ឋបុរស និងជាអ្នកនិពន្ធដ៏មានឥទ្ធិពល។ គាត់ដើរតួជាបុគ្គលយ៉ាងសំខាន់ក្នុងការធ្វើឱ្យកើតមានឡើងនូវចក្រពត្តិរ៉ូម។

# ព្រះបាទហ៊ែនរីទី៨ នៃរាជវង្សធ្យូឌ័រ

( Henry VIII of Tudor, England ) គ.ស. ១៤៩១ - ១៥៤៧

ព្រះអង្គជាអ្នកសិក្សាដែលឧស្សាហ៍ព្យាយាម ហើយទ្រង់បត់បែនតាមកាលៈទេសៈ បានដោយល្អឥតទាស់។



ព្រះអច្ឆរិយភាពរបស់ព្រះបាទ ហ៊ែនរីទី៨ នៃរាជវង្សធ្យូឌ័រ ក្នុងការប្រើប្រាស់ភាសាឡាទីន ទាំងការអាន ការសរសេរ និងការនិយាយគឺល្អឥតខ្ចោះ សូម្បីកាលព្រះអង្គនៅមានព្រះជន្មាយុត្រឹមតែ ៩ ព្រះវស្សានៅឡើយ។ ព្រះអង្គបានធ្វើឲ្យអ្នកប្រាជ្ញល្បីឈ្មោះក្នុងយុគសម័យនៃរ៉េនែសហ្សង់ ទាំងឡាយមានសេចក្តីពេញចិត្តពេញថ្លើមយ៉ាងខ្លាំង ដូចជាលោក អ៊ីរ៉ាសម៉ុន ឬសូម្បីតែលោក ហ្សីថូម៉ាស់មរ៍ ក៏មានសេចក្តីពេញចិត្តពេញថ្លើម ចំពោះភាពឈ្លាសវៃរបស់ព្រះរាជបុត្រតូចអង្គនេះយ៉ាងខ្លាំងដែរ។

ព្រះអង្គប្រសូត្រនៅថ្ងៃទី ២៨ ខែមិថុនា គ.ស. ១៤៩១ នៅព្រះរាជវាំង គ្រីននីច ជាព្រះឱរសទី២ របស់ព្រះបាទហ៊ែនរីទី៧ នៃចក្រភពអង់គ្លេស។ តាមប្រពៃណីការបន្តវេនឡើងគ្រងរាជបល្ល័ង្ករបស់អង់គ្លេសនោះ រាជសម្បត្តិគួរតែជារបស់ព្រះរាជបុត្រ អាថឺរ៍ ព្រះជេដ្ឋារបស់ព្រះ

អង្គ។ ចំណែកឯព្រះអង្គក៏គួរតែកាន់តំណែងធំដុំខាងសាសនា ក៏ប៉ុន្តែជាអកុសល ព្រះរាជបុត្រ អាថ៌ ចូរ៍ បានសោយទិវង្គតនៅពេលដែល ហ៊ែនរី មានព្រះជន្មាយុបានត្រឹមតែ ១១ ព្រះវស្សា ជាហេតុធ្វើឲ្យព្រះអង្គក្លាយជារាជទាយាទបន្តរាជបល្ល័ង្កជំនួសព្រះជេដ្ឋា។

ព្រះអង្គបានទទួលការអប់រំ ដើម្បីត្រៀមព្រះកាយក្លាយជាស្តេចផែនដីដោយមានគណាចារ្យល្បីកំពូលៗ មកពីគ្រប់បណ្តាមហាវិទ្យាល័យក្នុងប្រទេសអង់គ្លេសមកបង្រៀនថ្វាយ មានទាំងប្រវត្តិវិទូ អ្នកជំនាញផ្នែកភាសា។ ជាពិសេសគឺលោក ចន ស្កែលតុន កវីល្បីឈ្មោះក្នុងសម័យនោះជាគ្រូបង្ហាត់បង្រៀនឲ្យព្រះអង្គអាចប្រើប្រាស់ភាសាឡាទីន និងភាសាអង់គ្លេសបានយ៉ាងស្ទាត់ជំនាញ។ មិនត្រឹមតែប៉ុណ្ណោះព្រះអង្គបានសិក្សាភាសាបារាំង និងភាសាអ៊ីតាលី ហើយអាចមានព្រះរាជឱង្ការជាភាសាទាំងពីរនេះបានល្អទៀតផង។ ព្រះអង្គបានបន្តការសិក្សាបែបនេះជារៀងរហូត បើទោះបីជាព្រះអង្គមិនបានស្ថិតនៅក្នុងភេទជាអ្នកបួស (សាសនាគ្រិស្ត) បន្តទៀតក៏ដោយ។

មនុស្សនៅក្នុងសម័យបច្ចុប្បន្ននេះ ច្រើនតែសម្លឹងមើលឃើញព្រះបាទហ៊ែនរីទី៨ ថាជាក្សត្រដែលពោរពេញទៅដោយល្បិចកល កាចសាហាវនិងសោយព្រះក្រយាច្រើនដូចជាបាវ។ កាលព្រះអង្គនៅវ័យជំទង់ព្រះអង្គទ្រង់ជាអ្នករៀន ដែលប្រកបដោយវីរិយៈសេចក្តីព្យាយាមយ៉ាងខ្ជាប់ខ្ជួន ហើយជាមនុស្សចេះបត់បែនតាមកាលៈទេសៈបានយ៉ាងងាយបណ្តាគ្រូបាអាចារ្យទាំងឡាយមានបីតិសោមនស្សយ៉ាងខ្លាំង ដែលបាន

បង្រៀនថ្វាយទ្រង់ ហើយបានព្យាយាមបណ្តុះផ្នត់គំនិតជាតិនិយមតាមបែប អើនែសហ្សង់ ដល់ព្រះអង្គឲ្យទ្រង់បានព្រះទ័យបើកទូលាយទាំងផ្លូវលោកនិងផ្លូវធម៌ព្រោះមើលឃើញថា ព្រះអង្គមានបញ្ញាឈ្លាសវៃមោះមុតអាចព្រះតម្រិះ បែងចែកនូវគ្រប់រឿងរ៉ាវប្រកបដោយហេតុផល។ ក្រៅពីនេះ គ្រូបាអាចារ្យទាំងឡាយមានការសង្ឃឹមជឿជាក់យ៉ាងមុតមាំថា ព្រះអង្គទ្រង់នឹងឧបត្ថម្ភជ្រោមជ្រែងសិល្បៈវិទ្យាការ វិស័យអប់រំ និងមហាវិទ្យាល័យក្នុងថ្ងៃអនាគតទៅមុខ។ ព្រះអង្គគឺជាក្តីសង្ឃឹមនៃបណ្តាអ្នកប្រាជ្ញទាំងឡាយក្នុងប្រទេសអង់គ្លេស នៅពេលដែលព្រះអង្គទ្រង់ឡើងគ្រងរាជ្យនៅក្នុងព្រះជន្ម ១៨ ព្រះវស្សា។

លោក ហ្សឺ ថូម៉ាស់មរ៍ បានសរសេរលិខិតមួយច្បាប់ទៅកាន់លោក អ៊ីរ៉ាសមុ័ន ថា«ខ្ញុំមានបំណងចង់ឲ្យលោកបានអញ្ជើញមកឃើញដោយផ្ទាល់នឹងភ្នែកនូវប្រជានុរាស្ត្រ ដែលបន្លឺសំឡេងទទួលស្វាគមន៍នូវយុវក្សត្រអង្គថ្មី ថាតើវាអធិកអធមដល់កម្រិតណា!»។ យុវក្សត្រដែលជាទីគោរពស្រឡាញ់របស់ប្រជារាស្ត្រទាំងឡាយក្រៅពីទ្រង់ជាយុវជន ដែលដ៏ឈ្លាសវៃ គួរឲ្យស្រឡាញ់ និងពោរពេញទៅដោយជំនាញផ្នែកតូរតន្ត្រីហើយថែមទាំងចេះលេងអុក ខ្លុយ និងព្យាណូបានយ៉ាងពីរោះរណ្តំហើយថែមទាំងអាចនិពន្ធបទភ្លេងបានទៀតផង (បទភ្លេងខ្លះនៅលេងរហូតបច្ចុប្បន្ននេះ) ផ្នែកកីឡាដូចជា ជិះសេះ ទូកក្តោង ថេនីស និងយុទ្ធគុនក៏រកបុគ្គលណាមកធៀបស្មើនឹងព្រះអង្គពុំបានឡើយ។

ប៉ុន្តែ ព្រះអង្គបែរជាធ្វើឲ្យជនានុជនទាំងឡាយដែលបាននាំគ្នាផ្ញើសេចក្ដីសង្ឃឹមទុកចិត្តចំពោះព្រះអង្គខកបំណងជាខ្លាំង ដោយព្រះអង្គបានក្លាយជាអ្នកអភិរក្សនិយមយ៉ាងដាច់ខាតនិងងប់ងុល ហើយព្រះអង្គបានព្យាយាមរក្សាទុកគ្រប់បែបយ៉ាងដែលធ្លាប់មានតាំងពីអតីតមក ជាពិសេសព្រះរាជអំណាចគ្មានទីបំផុតរបស់ព្រះអង្គផ្ទាល់។

នៅពេលដែលលោក ម៉ាទីន លូធឺរ៍ បានផ្សព្វផ្សាយលិខិតប្រឆាំងព្រឹត្តិកម្មរបស់គ្រិស្តចក្រកាតូលិកចំនួន ៩៥ ចំណុចនិងបានបំផុសបំផុលកំណែទម្រង់សាសនាទូទាំងអឺរ៉ុបនោះ ព្រះបាទ ហ៊ែនរីទី៨ ទ្រង់ពិរោធចំពោះទង្វើរបស់ ម៉ាទីន លូធឺរ៍ យ៉ាងខ្លាំង ហើយព្រះអង្គក៏បានសរសេរជាព្រះរាជសារដើម្បីសម្ដែងប្រតិកម្មតបតចំពោះ ម៉ាទីន លូធឺរ៍ ជាភាសាឡាទីនភ្លាមៗយ៉ាងក្ដៅគគុក។ ទង្វើរបស់ព្រះអង្គធ្វើឲ្យពួកគ្រិស្តចក្ររ៉ូម៉ាំងកាតូលិកពេញចិត្តយ៉ាងខ្លាំង សម្ដេចសន្តប៉ាប៉ា ពោលសរសើរព្រះអង្គថាជា «រាជាដែលការពារនូវជំនឿបានយ៉ាងល្អ» ដែលក្សត្រអង់គ្លេសគ្រប់អង្គសុទ្ធតែត្រូវបានទទួលងារដូច្នេះរហូតមកដល់ពេលបច្ចុប្បន្ននេះ។

ចំណុចដែលគួរឲ្យកត់សម្គាល់ នៅក្នុងព្រះរាជសារតបតចំពោះ ម៉ាទីន លូធឺរ៍ របស់ព្រះអង្គនោះគឺព្រះអង្គទ្រង់មានព្រះរាជបំណងការពារនូវពាក្យប្រៀនប្រដៅ (សាសនាគ្រិស្ត) ដែលទាក់ទងទៅនឹងការរៀបអាពាហ៍ពិពាហ៍ហើយទ្រង់សរសេរជាប្រធានបទទីមួយទៀតផង។ ព្រះអង្គទ្រង់បានសរសេរទុកថា «មនុស្សកុំអាលអួតអាងហ៊ានបែងចែកនូវអ្វីដែលព្រះជាម្ចាស់ទ្រង់បាននាំមក និងរួបរួមទុក (បានដល់អពាហ៍ពិពាហ៍

របស់គ្រិស្តបរិស័ទនិកាយរ៉ូម៉ាំងកាតូលិក ធ្វើឡើងចំពោះព្រះភក្ត្រព្រះជាម្ចាស់នៅក្នុងនៅក្នុងវិហារ ដែលថាការលែងលះគ្នាជារឿងដែលមិនគួរកើតឡើងជាដាច់ខាត) ដោយព្រះអង្គផ្ទាល់ប្រហែលជាមិនជ្រាបជាមុនឡើយថា ខ្លួនព្រះអង្គផ្ទាល់បានប្រព្រឹត្តល្មើសច្បាប់ខាងលើ រហូតដល់ចំនួន ៦ លើក។ ព្រះអង្គបានរៀបអភិសេក ៦ លើក លែងលះចំនួនពីរលើក ហើយទ្រង់បានបញ្ជាឲ្យប្រហារជីវិតព្រះមហេសីចំនួនពីរព្រះអង្គទៀតផង។ ជីវិតផ្ទាល់ព្រះអង្គព្រមទាំងរឿងរ៉ាវផ្សេងៗជាច្រើនបានធ្វើឲ្យព្រះអង្គក្លាយជាក្សត្រដែលសាហាវឃោរឃៅគ្មានមេត្តាធម៌ ចូលចិត្តប្រើប្រាស់កម្លាំងបាយ និងគិតតែពីផលប្រយោជន៍ផ្ទាល់ខ្លួន។

# ព្រះនាង ម៉ារី ស្ទួត នៃស្កុតឡែន

(Mary Stuart of Scotland) គ.ស. ១៥៤២ - ១៥៨៧

ព្រះនាងមានព្រះសិរីរូបឆោមលោមពណ៌ស្រស់សោភា និងមានសតិបញ្ញាឈ្លាសវៃដ៏អច្ឆរិយៈ ប៉ុន្តែព្រះនាងខ្វះវិចារណញ្ញាណទើបត្រូវបានបាត់បង់រាជបល្ល័ង្កនិងត្រូវប្រហារជីវិត។



ព្រះនាង ម៉ារី ស្ទួត នៃប្រទេសស្កុតឡែន គឺជាបុគ្គលដែលប្រវត្តិសាស្ត្របានចារឹកព្រះនាមក្នុងឋានៈជាព្រះរាជនីមួយអង្គ ដែលត្រូវបានប្រហារជីវិតដោយព្រះរាជនីមួយអង្គទៀត គឺព្រះនាង អេលីស្សាបែត ទី១។ ព្រះនាងប្រសូត្រនៅថ្ងៃទី ៨ ខែធ្នូ គ.ស. ១៥៤២ នៅក្នុងប្រទេសស្កុតឡែន ក៏ប៉ុន្តែទ្រង់ចម្រើនវ័យវឌ្ឍនាការនៅប្រទេសបារាំង ពីព្រោះព្រះនាងត្រូវរៀបអភិសេកជាមួយនឹងព្រះអង្គម្ចាស់ ហ្វ្រង់ស៊ីសទី២ នៅក្នុងព្រះជន្មាយុ ១៥ ព្រះវស្សា។ ក្រោយពីបានរៀបអភិសេករយៈពេល ៣ ឆ្នាំ ព្រះស្វាមីក៏យាងចូលទិវង្គតចោលទៅ ទើបព្រះនាងស្តេចយាងត្រឡប់មកកាន់ស្កុតឡែនវិញ។ កាលពីនៅវ័យជំទង់ ព្រះនាងទ្រង់មានសតិបញ្ញាឆ្លាតវាងវៃ មនុស្សម្នាទាំងឡាយនាំគ្នាពោលសរសើរថាព្រះនាងជាក្មេងមហាអច្ឆរិយៈ ព្រោះមានសមត្ថភាព និងមានភាពស្ទាត់ជំនាញ

ខ្ពស់គ្រប់ផ្នែក។ ព្រះនាងសិក្សាអ្វីៗគ្រប់យ៉ាងបានឆាប់រហ័ស ព្រះនាងអាចមានព្រះរាជឱង្ការជាភាសាបារាំង អ៊ីតាលី អេសប៉ាញ យ៉ាងស្ទាត់ជំនាញរួមទាំងភាសាអង់គ្លេសផងដែរ។ ក្រៅពីនេះ ព្រះនាងទ្រង់ជាកំពូលក្នុងផ្នែកភាសាបុរាណដូចជាភាសាក្រិច និងភាសាឡាទីនជាដើម។

ស្ថិតនៅពេលមានព្រះជន្មាយុ ១៣ ព្រះវស្សាព្រះនាងបានថ្លែងសុន្ទរកថាជាភាសាឡាទីន ដែលព្រះនាងទ្រង់បានសរសេរនិពន្ធដោយផ្ទាល់ព្រះហស្ត។ ព្រះនាងមានព្រះរាជតម្រិះយល់ឃើញថាស្ត្រីនិងបុរសគួរតែអាចធ្វើការងារផ្នែកសិល្បៈវិជ្ជាការបានដោយស្មើភាពគ្នា ព្រះនាងផ្ទាល់ក៏ពុំសូវជាពេញព្រះទ័យចំពោះការចំលង ឬធ្វើតាមស្នាដៃសិល្បៈដែលបុគ្គលដទៃបានបង្កើតឡើងនោះទេ ទ្រង់មានបំណងប្រាថ្នាសាងស្នាព្រះហស្តថ្មីផ្ទាល់ព្រះអង្គ។ ព្រះនាងបាននិពន្ធកំណាព្យកាព្យឃ្លោងផ្សេងៗជាច្រើន ដែលប្រកបដោយអត្ថន័យខ្លឹមសារដ៏ពីរោះពិសា។ ព្រះនាងទ្រង់ជ្រោតជ្រាបក្នុងផ្នែកអក្សរសិល្ប៍ ទស្សនវិជ្ជា និងប្រវត្តិសាស្ត្រយ៉ាងល្អិតល្អន់ ហើយទ្រង់បានចំណាយរាជទ្រព្យផ្ទាល់ព្រះអង្គអស់យ៉ាងច្រើនដើម្បីអភិរក្ស រក្សាសៀវភៅ គម្ពីរក្បួនច្បាប់ដើមដ៏មានគុណតម្លៃ ព្រះនាងទ្រង់មានព្រះសិរីឆោមលោមពណ៌ដ៏ស្រស់សោភា មានកម្ពស់ខ្ពស់ស្រឡះសក្តិសមសួន ហើយទ្រង់បានប្រកួតរាំរបាំទទួលបានពានរង្វាន់រាប់មិនអស់ និងអាចរកបុគ្គលដទៃណាមកប្រៀបបានដោយកម្រ។

ព្រះនាងទ្រង់សពព្រះរាជហឫទ័យចំពោះកីឡាដូចជា ការជិះសេះ ហើយជិះបានយ៉ាងស្ទាត់ជំនាញជាងបុរសមួយចំនួនទៀតផង ហើ

ព្រះនាងក៏ទ្រង់សពព្រះរាជហឫទ័យ ក្នុងការប្រពាតព្រៃបរបាញ់សត្វផង ដែរ។ ថ្វីត្បិតថាព្រះនាងទ្រង់មានព្រះសិរីឆោមលោមពណ៌ស្រស់សោភា និងប្រកបដោយសតិបញ្ញាឈ្លាសវៃ ក៏មិនអាចជួយឲ្យព្រះនាងទ្រង់មាន វិចារណញ្ញាណក្នុងការគ្រប់គ្រងកិច្ចការនយោបាយ ឬផ្នែកចិត្តវិទ្យាមនុស្ស ដែរ ទើបធ្វើឲ្យព្រះនាងជួបនូវភាពបរាជ័យទាំងការគ្រប់គ្រង់រដ្ឋ និងជីវិត ផ្ទាល់ព្រះអង្គរហូតដល់បាត់បង់ទាំងរាជបល្ល័ង្ក។ សូម្បីនៅពេលដែលព្រះ នាងភៀសព្រះកាយទៅគង់នៅក្នុងព្រះទេសអង់គ្លេសហើយក៏ដោយ ក៏ បានទៅពាក់ព័ន្ធជាមួយគម្រោងការក្បត់ចំពោះព្រះនាង អេលីស្សាបែត ទី១ ជាច្រើនលើកច្រើនគ្នា រហូតដល់ទីបំផុតព្រះនាងក៏ត្រូវបានប្រហារ ជីវិត។ ព្រះរាជជីវប្រវត្តិដ៏សោកសៅរបស់ព្រះនាងបានសបញ្ជាក់ឲ្យឃើញ ពីរឿងរ៉ាវនៃអច្ឆរិយបុគ្គលដ៏សៃនឆ្លាត ដែលនរណាៗក៏លាន់មាត់ពោល សរសើរថាជាក្មេងមហាស្ចារ្យ ប៉ុន្តែបែរជាខ្វះខាតនូវវិចារណញ្ញាណដែល ត្រឹមត្រូវទើបធ្វើឲ្យគ្រប់យ៉ាងបញ្ចប់ទៅដោយការប្រហារជីវិតបែបនេះ។ នេះសមនឹងពាក្យបុរាណខ្មែរថា «ចេះដប់មិនស្មើប្រសប់មួយ»។

# ព្រះបាទ ហ្វ្រេឌ័ររីខ មហារាជ នៃប្រ័សសៀ

( Frederick the Great, Prussia ) គ.ស. ១៧១២ - ១៧៨៦

ព្រះអង្គទ្រង់បានសន្សំសៀវភៅ
ទុកក្នុងបន្ទប់ការិយាល័យផ្ទាល់ព្រះអង្គ
ដ៏ច្រើនចំនួន ៤០០០ ក្បាល
ជាសៀវភៅគ្រប់បំណិននៃចំណេះដឹងទាំងអស់
ព្រះអង្គជាមហាក្សត្រដែលប្រកបដោយធម៌។



មានលោកឪពុកចំនួនមិនតិចនាក់ទេ ដែលខិតខំតម្រែតម្រង់ដោយបង្គាប់បញ្ជាដាច់អហង្ការ ប្រាថ្នាដើម្បីឲ្យបុត្រធីតារបស់ខ្លួនក្លាយជាអច្ឆរិយៈបានក្នុងថ្ងៃអនាគត បើទោះជាមធ្យោបាយរបស់លោកឪពុកទាំងនេះ មើលទៅហាក់ដូចជាកាចសាហាវបន្តិចក៏ដោយចុះ។ ព្រះបាទ ហ្វ្រេឌ័ររីខ វិលហែម បិតារបស់ ហ្វ្រេឌ័ររីខទី២ ក៏បានប្រើប្រាស់វិធីទាំងនោះដែរ។ ព្រះបាទ ហ្វ្រេឌ័ររីខទី២ ឬហ្វ្រេឌ័ររីខ នៃប្រ័សសៀ ប្រសូត្រនៅថ្ងៃទី ២៤ ខែមករា គ.ស. ១៧១២ នាទីក្រុង ប៊ែកឡាំង។ ព្រះបិតារបស់ព្រះអង្គផ្ទាល់ ជាអ្នករៀបចំកម្មវិធីសិក្សាអប់រំចំពោះរាជឱរសយ៉ាងល្អិតល្អន់ ដោយទ្រង់កំណត់ព្រះរាជករណីយកិច្ចទាំងអស់របស់ព្រះរាជបុត្រដែលជារាជទាយាទយ៉ាងតឹងរ៉ឹងនិងខ្ជាប់ខ្ជួនបំផុត។ ព្រះអង្គទ្រង់ជឿ

ជាក់ចំពោះលទ្ធផល នៃការសិក្សាស្រាវជ្រាវខាងវេជ្ជសាស្ត្រក្នុងសម័យនោះថា ការបណ្តោយឲ្យក្មេងគេងច្រើនហួសប្រមាណជាហេតុនាំឲ្យប៉ះពាល់ដល់សុខភាពរបស់ក្មេង ដូច្នឹងហើយទើបព្រះអង្គទ្រង់ដាក់ចេញនូវរាជបញ្ជាចំពោះគ្រូឲ្យអនុវត្តចំពោះរាជកុមារតូចដូច្នេះគឺ៖

«រៀងរាល់ថ្ងៃអាទិត្យ ហ្វ្រេឌ័ររីខ ត្រូវក្រោកពីផ្ទំនៅវេលាម៉ោង ៨ ព្រឹក ពេលពាក់ស្បែកជើងរួចហើយត្រូវលុតជង្គង់សូត្រធម៌ (សាសនាគ្រិស្ត) ដោយសំឡេងខ្លាំងៗ ឲ្យអ្នកនៅក្នុងបន្ទប់ដែលផ្ទំបានឮគ្រប់គ្នា។ ក្រោយសូត្រធម៌ចប់ហើយ ព្រះអង្គត្រូវប្រញាប់ទ្រង់គ្រឿង ស្រង់សុគន្ធវារីជម្រះព្រះកាយឲ្យស្អាតបាតភ្លាមៗ ហើយសម្អិតសម្អាងកាយា សិតព្រះកេសា ផាត់ព្រះភក្ត្រនិងទ្រង់គ្រឿងសព្វគ្រប់ប្រការហើយ ត្រូវសូត្រធម៌ម្តងទៀតឲ្យចប់ក្នុងរយៈពេល ១៥ នាទី។ នៅវេលាម៉ោង ៨.១៥ នាទីព្រឹកព្រះរាជបុត្រត្រូវសូត្រធម៌ម្តងទៀតនៅចំពោះមុខគ្រូបាអាចារ្យ (គ្រូបង្រៀន ឬបព្វជិតក្នុងសាសនាគ្រិស្ត) និងគ្រូបង្រៀនផ្ទាល់ព្រះអង្គ។ បន្ទាប់មក ឲ្យគណាចារ្យអានព្រះគម្ពីរប៊ីបថ្វាយរាជកុមារទ្រង់ព្រះសណ្តាប់ និងតម្រូវឲ្យរាជកុមារច្រៀងចម្រៀងអរគុណព្រះជាម្ចាស់។ ក្រោយពីពួកគណាចារ្យ (បព្វជិតសាសនាគ្រិស្ត) ចាកចេញវិលត្រឡប់ទៅវិហារវិញនៅវេលា ៨.៤៥ នាទី គណាចារ្យលើកយកនូវមេរៀនក្នុងព្រះគម្ពីរមកបង្រៀនដល់ព្រះរាជបុត្រ ព្រមទាំងទូលព្រះរាជបុត្រថា ពាក្យប្រៀនប្រដៅក្នុងព្រះគម្ពីរទាំងអស់មានសារៈសំខាន់ចំពោះគ្រិស្តបរិស័ទជាខ្លាំង រហូតដល់វេលាម៉ោង ៩.០០ នាទី។ បន្ទាប់ពីនោះត្រូវនាំរាជកុមារមករកយើង

ដើម្បីចូលក្នុងព្រះវិហារ និងសោយក្រយាពេលព្រឹកជាមួយគ្នា ក្រោយពីនោះបណ្តោយឲ្យរាជកុមារទ្រង់ធ្វើកិច្ចបដិបត្តិតាមព្រះទ័យប្រាថ្នា លុះដល់វេលាល្ងាចត្រូវនាំរាជកុមារមករកយើងម្តងទៀត ដើម្បីនិយាយពាក្យរាត្រីសួស្តី (លាគ្នាមុនចូលក្រឡាបន្ទំ) ជាមួយយើង រួចហើយនាំរាជកុមារទៅកាន់បន្ទប់ផ្ទំ ហើយត្រូវដោះគ្រឿងអលង្ការចេញ រួចហើយត្រូវលាងព្រះហស្ត បន្ទាប់មករាជកុមារត្រូវលុតជង្គង់សូត្រព្រះធម៌ម្តងទៀតដោយគណាចារ្យជាអ្នកនាំសូត្រ និងត្រូវច្រៀងចម្រៀងសរសើរព្រះជាម្ចាស់ចំពោះមុខគណាចារ្យទាំងឡាយ។ ព្រះរាជបុត្ររបស់យើងត្រូវចូលផ្ទំនៅវេលាម៉ោង ១០.៣០ នាទីយប់»។

នេះជាព្រះរាជកិច្ចដែលព្រះរាជបុត្រតូចត្រូវបដិបត្តិ ជារៀងរាល់ថ្ងៃអាទិត្យ ជាថ្ងៃដែលមនុស្សទូទៅគួរបានឈប់សម្រាកកាយ។ នៅក្នុងថ្ងៃធម្មតាព្រះរាជកុមារត្រូវតើនពីផ្ទំនៅវេលាម៉ោង ៦ ព្រឹកជារៀងរាល់ថ្ងៃ ហើយត្រូវបដិបត្តិរាជកិច្ចផ្សេងដូចថ្ងៃអាទិត្យដែរ ប៉ុន្តែបន្ថែមកាលវិភាគសិក្សាផ្សេងៗ ដូចជា ប្រវត្តិសាស្ត្រ ភូមិវិទ្យា ការគ្រប់គ្រង ការសរសេរ ការអាន ការនិយាយភាសាជាដើម ។ល។ ព្រះអង្គត្រូវបានអនុញ្ញាតសម្រាកនៅវេលាម៉ោង ៥ ល្ងាច តែត្រូវទៅសម្រាកដោយការជិះសេះនៅកណ្តាលវាលដើម្បីស្រូបយកខ្យល់អាកាសបរិសុទ្ធ ហើយហាមលួចផ្ទំ (Take a nap) ជាដាច់ខាត។ នៅរៀងរាល់ថ្ងៃសៅរ៍ គឺជាថ្ងៃដែលត្រូវសាកល្បងចំណេះដឹងថាក្នុងសប្តាហ៍កន្លងទៅ តើព្រះអង្គរៀនចេះអ្វីខ្លះ ប្រសិនបើអាចឆ្លងផុតការសាកល្បងចំណេះដឹងបាន ព្រះអង្គនឹងត្រូវបានអនុញ្ញាត

ឲ្យធ្វើនូវកិច្ចដែលតាមសេចក្តីប្រាថ្នានៅពេលរសៀល។ ក៏ប៉ុន្តែបើឆ្លងមិនផុតទេ នោះព្រះរាជកុមារនឹងត្រូវទន្ទេញមេរៀនសាជាថ្មី តាំងពីវេលាម៉ោង ២ រសៀលរហូតដល់ម៉ោង ៦ ល្ងាច។

សម្រាប់ព្រះរាជកុមារតូច ដែលទើបតែមានព្រះជន្មាយុ ៦ ព្រះវស្សានោះ រាប់ថា ជាតារាងភារកិច្ចដ៏ធ្ងន់ធ្ងរស្ទើរតែមិនអាចទទួលយកបាន។ រឿងដែលគួរឲ្យសង្កេតនោះគឺព្រះអង្គត្រូវលាងព្រះហស្តក្នុងមួយថ្ងៃជាច្រើនដងតាមបញ្ជារបស់ព្រះបិតា។ ព្រះបាទ ហ្វ្រេឌ័រីខ វិលហែមទ្រង់យកព្រះទ័យទុកដាក់យ៉ាងខ្លាំងចំពោះអនាម័យព្រះវរកាយ (ព្រោះជារឿងដែលមិនសូវប្រក្រតីក្នុងសម័យនោះ) ក្សត្រនៃ ប្រ៊ុសសៀ អង្គនេះត្រូវបានគេបញ្ចើចបញ្ចើទូទាំងអឺរ៉ុប ព្រោះទ្រង់ស្រង់សុគន្ធវារីញឹកញាប់ពេកក្នុងមួយថ្ងៃៗ។ មនុស្សម្នាទាំងឡាយនាំគ្នានិន្ទាព្រះអង្គថា ព្រះអង្គមានវិកលភាពផ្លូវចិត្ត ដោយសារតែព្រះអង្គទ្រង់ផ្លាស់សម្លៀកបំពាក់ជារៀងរាល់ថ្ងៃ ព្រោះមនុស្សភាគច្រើនក្នុងសម័យនោះស្លៀកពាក់ខោអាវដដែលៗយ៉ាងតិចមួយសប្តាហ៍ទើបប្តូរម្តង ដោយគេចាត់ទុកថា នេះគឺវាប្រណីតពេកណាស់ទៅហើយ។ ព្រះអង្គក៏ត្រាស់បញ្ជាដល់ភីលៀង អ្នកមើលថែរាជកុមារឲ្យយកចិត្តទុកដាក់ចំពោះរឿងដូចខាងលើ ដោយមិនអាចបណ្តែតបណ្តោយបានជាដាច់ខាត «អ្នកត្រូវតែមើលថែរាជកុមារឲ្យចេះស្លៀកពាក់ និងដោះចេញឲ្យបានត្រឹមត្រូវ ហើយត្រូវផ្ចិតផ្ចង់ចំពោះអនាម័យកុំឲ្យកខ្វក់សូម្បីតែបន្តិចណាឡើយ»។

ព្រះរាជកុមារត្រូវបានអប់រំបង្ហាត់និស្ស័យ ឲ្យក្លាយជាបុរសរឹងមាំ តាំងពីនៅវ័យក្មេងមកម្ល៉េះ។ ព្រះអង្គទ្រង់មិនចូលចិត្តការសោយបារីរបស់ព្រះបិតាជាខ្លាំង ពេលខ្លះហាក់អស់ព្រះជន្មដោយសារឈ្លក់ក្លិនបារី និងមានអាការៈក្អកយ៉ាងខ្លាំង ព្រះបិតាបែរជារិះគន់ឱរសក្នុងការដែលទ្រង់មិនចូលចិត្តជក់បារី និងសោយសុរាទៅវិញ។ ព្រះរាជបុត្រចូលចិត្តតុបតែងព្រះកាយដូចអ្នកបង្ហាញម៉ូដបារាំង និងចូលចិត្តតន្ត្រីដែលបិតាយល់ឃើញថាជារឿងឥតប្រយោជន៍ ហើយជាកិច្ចការដែលមិនសក្តិសមនឹងមនុស្សប្រុស។

មុខវាំងនន ព្រះរាជបុត្រទ្រង់ធ្វើជាសព្វព្រះរាជហឫទ័យចំពោះអ្វីដែលព្រះបិតាហាមយ៉ាងដាច់ខាត។ តែក្រោយវាំងននវិញ ព្រះរាជបុត្រតែងធ្វើអ្វីដែលទ្រង់សព្វព្រះរាជហឫទ័យ ដូចជា ការរៀនភាសាឡាតាំងដោយព្រះអង្គបានលួចគ្រូឲ្យបង្រៀនដល់ព្រះអង្គ ប៉ុន្តែពេលបិតាទ្រង់ជ្រាប ទ្រង់ខ្ញាល់ចំពោះព្រះឱរសយ៉ាងខ្លាំង និងបានបណ្តេញគ្រូរូបនោះចេញពីតំណែងភ្លាមៗទៀតផង។ ហេតុដូច្នោះទើបព្រះរាជាតូចដែលត្រូវបដិបត្តិខ្លួនតាមបញ្ជារបស់ព្រះបិតាគ្រប់យ៉ាង ក្លាយទៅជាមនុស្សខ្ជិលច្រអូសក្នុងការរៀនសូត្រ ពេលជិះសេះក៏ខ្ជិលច្រអូស មិនលាងព្រះហស្ថតាមបញ្ជា មិនស្រង់ទឹក (បើមានឱកាស) ហើយអ្វីដែលធ្វើឲ្យបិតាស្ទើរតែខ្យល់ចាប់ក៏គឺទ្រង់ចូលចិត្តមួលព្រះកេសាព្រះអង្គឯងលេង។ ទោះបីយ៉ាងណាក៏ដោយ ព្រះអង្គក៏មិនមានបំណងប្រឆាំងនឹងបញ្ជាបិតាដោយចំហឡើយ គឺនៅចំពោះព្រះភក្ត្របិតា ព្រះអង្គបដិបត្តិតាមរាជបំណង

របស់បិតាទាំងអស់ ប៉ុន្តែពេលនៅក្រោយខ្នង ព្រះអង្គក៏សម្រេចព្រះទ័យធ្វើអ្វីតាមដែលទ្រង់ត្រូវការដោយលួចលាក់បំផុត។

ព្រះរាជាអង្គតូចដែលមានព្រះជន្មាយុ ១៥ ព្រះវស្សាបានខ្ចីប្រាក់ពីមន្ត្រីធនាគារម្នាក់នៅទីក្រុង ប៊ែកឡាំង ចំនួន ៤០០០ ថាឡែន ហើយព្រះអង្គបានទិញផ្ទះមួយកន្លែងនៅក្នុងទីក្រុង គឺទុកសម្រាប់ដោះគ្រឿងអាភរណៈឈុតទាហាន ដែលត្រូវបញ្ជាឲ្យពាក់គ្រប់ពេលវេលា (ព្រះអង្គហៅឈុតទាហាននោះថាកំណាត់រុំសព)។ ចំណែកប្រាក់ដែលនៅសល់ព្រះអង្គទ្រង់បានចំណាយ ដើម្បីទិញសៀវភៅគ្រប់ប្រភេទដែលទ្រង់សព្វព្រះទ័យអានដោយមានគ្រូបង្រៀនព្រះអង្គចាំជួយដោយស្ងាត់ៗ។

គ្រិស្តសករាជ ១៧៣០ ព្រះបិតាបានជ្រាបពីអាថ៌កំបាំងទាំងអស់នោះ ក្នុងពេលនោះព្រះរាជឱរស ហ្វ្រីឌ័រីខ បានសន្សំសៀវភៅទុកក្នុងបណ្ណាល័យផ្ទាល់ព្រះអង្គចំនួនដល់ទៅ ៤០០០ ក្បាល ក្នុងនោះសុទ្ធតែជាសៀវភៅដែលសំខាន់ៗ ដូចជា វចនានុក្រមភាសាអង់គ្លេស បារាំង អេសប៉ាញ អ៊ីតាលី បទានុក្រម សៀវភៅរឿងនិទានផ្សេងៗ សៀវភៅរៀនតែងកំណាព្យកាព្យឃ្លោង សៀវភៅបែបសន្ទនា បែបហ្វឹកហាត់សរសេរនិពន្ធ ស្នាដៃនិពន្ធរបស់អ្នកប្រាជ្ញក្នុងសម័យបុរាណដែលប្រែជាភាសាបារាំង សៀវភៅប្រវត្តិសាស្ត្រ កម្រងអនុស្សាវរីយ៍ សៀវភៅទេសចរណ៍ ផែនទីពិភពលោក សៀវភៅដែលជាស្នាដៃនិពន្ធរបស់អ្នកប្រាជ្ញបារាំងតាំងពីសម័យលោក ប៊ីលែស រហូតមកដល់លោក វ៉លធៀរ៍ សៀវភៅគណិតវិទ្យា រូបវិទ្យា វិទ្យាសាស្ត្រ សៀវភៅនយោបាយរបស់

លោក ម៉ាឃីអាវែលី និងលោក ថូម៉ាស់ ម៉រ៍ ស្នាដៃនិពន្ធរបស់ ខែសកាតស៍ និងលោក ចន ឡក់ និងមានទាំងទស្សនាវដ្តីជាភាសាបារាំង និងភាសាអង់គ្លេសជាច្រើនក្បាលទៀត។ល។

ក្រោយពេល ដែលបិតាទ្រង់ជ្រាបពីជីវិតអាថ៌កំបាំងរបស់រាជបុត្រ ព្រះអង្គទ្រង់ពិរោធយ៉ាងខ្លាំង ពេលនោះរាជបុត្រ ហ្វ្រីឌ័រីខ បានរត់គេចព្រះកាយចេញពីរាជវាំងជាមួយមិត្តម្នាក់ទៀត ប៉ុន្តែអ្នកទាំងទ្វេត្រូវបានចាប់ខ្លួនដោយពួកទាហានវាំង ហើយមិត្តសំឡាញ់របស់ព្រះអង្គត្រូវបានប្រហារជីវិត ចំណែកព្រះអង្គត្រូវបានឃុំឃាំងព្រះកាយអស់មួយរយៈធំ។

ពីបរិបទខាងលើព្រះរាជបុត្រ ហ្វ្រីឌ័រីខ ត្រូវបានបិតាគាបសង្កត់យ៉ាងខ្លាំងក្លា ត្រូវទទួលទោសទណ្ឌកម្មជាញឹកញាប់ ប៉ុន្តែព្រះអង្គរកវិធីគេចវេះពីការពិតដ៏កាចសាហាវ ទៅលាក់ខ្លួនពួនអាត្មាផ្សារភ្ជាប់និស្ស័យក្នុងការអានសៀវភៅដ៏មានគុណតម្លៃ។ ប្រសិនបើជាយុវជនក្នុងសម័យបច្ចុប្បន្ននេះខ្លះវិញ ប្រហែលជានឹងដោះស្រាយដោយវិធីផ្សេងពីនេះដែលមានឥទ្ធិពលអាក្រក់ចំពោះខ្លួនដូចជា ការសេពគ្រឿងញៀន លេងហ្គេមលេងល្បែងផ្ទាល់ផ្សេងៗជាដើម។

បើទោះបីជាព្រះអង្គក្រោធខឹងនឹងបិតាយ៉ាងណាក៏ដោយ តែការអប់រំបែបទាហានដ៏ម៉ឺងម៉ាត់ ដែលទ្រង់បានទទួលការហ្វឹកហាត់បានធ្វើឲ្យព្រះអង្គក្លាយជាទាហានដ៏អង់អាចក្លាហានមួយរូប និងមានឥទ្ធិពលបំផុតក្នុងសតវត្សរ៍ទី ១៨ ដោយសារតែព្រះអង្គជាបុគ្គលដែលស្រឡាញ់

ពេញចិត្តការសិក្សាស្រាវជ្រាវ ធ្វើឲ្យព្រះអង្គក្លាយជាព្រះមហាក្សត្រដែលប្រកបដោយធម៌ សមដូចព្រះនាមថា «មហារាជា» ក្នុងសម័យដ៏ភ្លឺស្វាងរបស់អឺរ៉ុបនោះឯង។

# វ៉ុលហ្វ៍ហ្គាង អាមេឌៀស ម៉ូសាទ

(Wolfgang Amadeus Mosart, Austria) គ.ស. ១៧៥៦ - ១៧៩១



ម៉ូសាទ រៀនវិធីការអានណោតភ្លេង លេងព្យាណូ វីយូឡុង រួមទាំងការអាន ការសរសេរ និងការគណនាពីឪពុកទាំងស្រុង។

វ៉ុលហ្វ៍ហ្គាង អាមេឌៀស ម៉ូសាទ ជាអច្ឆរិយបុគ្គលដែលមិនធ្លាប់បានចូលរៀននៅសាលារៀនឡើយ។ អច្ឆរិយភាពរបស់គាត់កើតចេញពីទេពកោសល្យពិសេសផ្ទាល់ខ្លួន។ យោងតាមប្រវត្តិការពិត គាត់មិនត្រឹមតែមាននូវអច្ឆរិយភាពប៉ុណ្ណោះទេ គាត់គឺជាមនុស្សមហាស្ចារ្យក្រៃលែង។ ឡេអូប៉ូល ម៉ូសាទ ដែលមានឪពុកជាតន្ត្រីករក្នុងព្រះវិហារសាសនាគ្រិស្ត បានសង្កេតឃើញពីទេពកោសល្យរបស់កូនប្រុសតាំងពី ម៉ូសាទ មានអាយុបាន ៥ ឆ្នាំ ដោយ ម៉ូសាទ ចាប់ផ្តើមចេះនិពន្ធបទភ្លេងបានខ្លះៗបានហើយ។ នៅពេលកុមារតូច ម៉ូសាទ មានអាយុ ៣ ឆ្នាំគាត់បានស្តាប់លោកឪពុកបង្រៀនតន្ត្រីដល់បងស្រី តែរូបគាត់ចាប់យកនិងចងចាំបានលឿនជាងបងស្រី ដែលបងស្រីគាត់ក៏មានទេពកោសល្យមិនចាញ់គាត់ដែរ។ ឪពុករបស់គាត់មានជំនឿថាព្រះជាម្ចាស់បានប្រទានទេពកោសល្យ

ដ៏អស្ចារ្យដល់កូនៗគាត់ ដូច្នឹងហើយទើបគាត់សុខចិត្តលះបង់ពេលវេលាដើម្បីបង្ហាត់បង្រៀនផ្នែកតូរ្យតន្ត្រីដល់កូនៗគាត់ដោយផ្ទាល់។

លោកឪពុករបស់ ម៉ូសាទ ជាអ្នកកំណត់កាលវិភាគក្នុងការបង្ហាត់បង្រៀនអប់រំកូនៗ។ គាត់បាននាំកូនទាំងអស់ចេញមកប្រគំតន្ត្រីអស់រយៈពេល ១៥ ឆ្នាំ ជាហេតុធ្វើឲ្យ ម៉ូសាទ តូចគ្មានពេលវេលាដើម្បីបានចូលរៀននៅសាលារៀនដូចគេឡើយ។ លុះ ម៉ូសាទ មានអាយុ ២៥ ឆ្នាំទើបគ្រួសារអាចសាងគ្រឹះទីលំនៅច្បាស់លាស់នៅក្នុទីក្រុង វៀនណា។ ពេលនោះ ម៉ូសាទ តូចមានឱកាសបានរៀនអានណោតភ្លេង លេងវីយូឡុងដេញព្យាណូ និងរៀនពីវិធីអាន ការសរសេរអក្សរ និងលេខនព្វន្តអំពីសំណាក់ឪពុករបស់ខ្លួនទាំងស្រុង។ ម៉ូសាទ គាត់រៀនឆាប់ចេះឆាប់ចាំដ៏អច្ឆរិយៈ ចំណែកឯភាសាបរទេសដែលប្រើប្រាស់សម្រាប់ការនិពន្ធបទចម្រៀងនោះ គឺគាត់រៀនតាមរយៈការធ្វើដំណើរទៅកាន់ទីកន្លែងផ្សេងៗស្ទើរទូទាំងទ្វីបអឺរ៉ុបអស់រយៈពេលជាច្រើនឆ្នាំ។

ម៉ូសាទ កើតថ្ងៃទី ២៧ ខែមករា គ.ស. ១៧៥៦ នៅទីក្រុងសាល់បឺក ប្រទេស អូសត្រៀ។ នៅពេលគាត់មានអាយុ ៦ ឆ្នាំឪពុកបាននាំចេញទៅប្រគំតន្ត្រីនៅទីក្រុង ម្យូនីក និងទីក្រុង វៀនណា ដោយកាលនោះ ម៉ូសាទ ចេះលេងព្យាណូយ៉ាងស្ទាត់ជំនាញធ្វើឲ្យទស្សនិកជនភ្ញាក់ផ្អើលយ៉ាងខ្លាំង។ បន្ទាប់មកទៀតគាត់មានឱកាសបានធ្វើទៅកាន់ទីក្រុងបារីស ទីក្រុង ឡុងដ៍ និង ប្រ៊ុសសែលស៍ និងបន្តដំណើរទៅកាន់ប្រទេសស្វីស ត្រឡប់មកកាន់ប្រទេសបារាំងសាជាថ្មីម្តងទៀត។ នៅពេលមាន

អាយុ ១៣ ឆ្នាំឪពុកបាននាំទៅប្រគំតន្ត្រីទេសចរណ៍ទូទាំងអ៊ីតាលី អស់រយៈពេលដ៏យូរ យុវជន ម៉ូសាទ បានស្គាល់ស្ទើរគ្រប់ទីកន្លែងនៅអឺរ៉ុបជាពិសេសនៅតាមរាជសំណាក់ផ្សេងៗ។ សម័យថ្ងៃមួយ កាលដែលគាត់មានអាយុមិនទាន់ទាំងគ្រប់ ៧ ឆ្នាំពេញបរិបូរផង ឪពុករបស់គាត់បាននាំទៅទីក្រុង វៀនណា ហើយមានឱកាសបានចូលគាល់ស្ដេចចក្រពត្តិនីម៉ារៀថីរេសា ទៀតផង ហើយឪពុករបស់គាត់បានសរសេរសំបុត្រផ្ញើទៅកាន់ក្រុមគ្រួសារដែលកំពុងស្នាក់នៅផ្ទះ និយាយអំពីរឿងនេះដោយសោមនស្សរីករាយថា «នៅពេលលេចព្រត៌មានថាពួកយើងបានមកដល់ទីក្រុង វៀនណា ស្រាប់តែមានព្រះរាជបញ្ជាឲ្យពួកយើងចូលគាល់ភ្លាមៗ ខ្ញុំមិនចង់ជឿសោះថាពួកយើងបានទទួលនូវព្រះមហាករុណាទិគុណពីសំណាក់ស្ដេចចក្រពត្តិដូច្នោះឡើយ ... បើនិយាយទៅតិចថាខ្ញុំកុហក ...នៅពេល វ៉ូហ្វ៍ហ្គែរ៍ (ឈ្មោះហៅក្រៅរបស់ម៉ូសាទ) ឡើងអង្គុយលើភ្លៅស្ដេច ព្រះអង្គទ្រង់បានថើបគេពេញដោយក្ដីស្រឡាញ់តែម្ដង ... ពួកយើងគាល់ស្ដេចតាំងពីវេលាម៉ោង ២ សៀលរហូតដល់ម៉ោង ៦ ល្ងាច»។

ជាការសរុបត្រួសៗនៃស្នាដៃរបស់គាត់មានប្រមាណជា ៦០០ ស្នាដៃ ដែលភាគច្រើនទាក់ទងនឹងតន្ត្រី ដែលធ្វើឱ្យគាត់ក្លាយជាបុគ្គលដ៏មានឥទ្ធិពលនាលោកខាងលិច។

# មេរៀនទី ៦

មានបុគ្គលមួយចំនួនធំនៅក្នុងលោកនេះ បើទោះបីជាពុំសូវបានសិក្សារៀនសូត្រ ក៏ប៉ុន្តែតស៊ូពុះពាររហូតបានជោគជ័យ។ ជាបន្តនិងជាមេរៀនបញ្ចប់នេះនឹងលើកយកនូវតួយ៉ាងស្ដីអំពីបុគ្គលទាំនោះរួមមាន៖

# ថូម៉ាស់ អាល់វា អេឌីសាន់

(Thomas Alva Edison, U.S) គ.ស. ១៨៤៧ - ១៩៣១

គាត់ត្រូវបានគ្រូជេរប្រមាថថា «អាក្មេងអត់ខួរ»ចំពោះមុខមិត្តរួមថ្នាក់ ទើបគាត់មិនទៅសាលារៀនទៀតឡើយ តើគាត់អាចក្លាយជាអ្នកច្នៃប្រឌិត (Inventor) ដ៏ល្បីល្បាញបានយ៉ាងដូចម្ដេច?



គាត់មិនសូវជាចូលចិត្តសាលារៀនតាំងពីដំបូងឡើយមកម្ល៉េះ ដូចអ្វីដែលគាត់បានពោលក្នុងកាលជាខាងក្រោយថា «ខ្ញុំនៅចងចាំថាខ្ញុំមានអារម្មណ៍មិនសូវជាស៊ីខ្សែគ្នាជាមួយសាលារៀនទេ ខ្ញុំតែងតែជាសិស្សចុងក្រោយគេដែលចូលថ្នាក់រៀន (ទៅរៀនយឺតពេល) ខ្ញុំមានអារម្មណ៍ថាគ្រូមិនសូវចូលចិត្តខ្ញុំទេ ហើយឪពុកខ្ញុំក៏តែងតែគិតថា ខ្ញុំជាក្មេងល្ងង់ខ្លៅរកលេខដាក់គ្មានដែរ»។

ជីវិតនៅក្នុងសាលារៀនរបស់គាត់បានរយៈពេលដ៏ខ្លី គឺបានត្រឹមតែ ៣ ខែប៉ុណ្ណោះត្រូវគ្រូម្នាក់បានជេរប្រមាថថា «អាក្មេងអត់ខួរ» ចំពោះមុខមិត្តរួមថ្នាក់ ពាក្យសម្ដីរបស់គ្រូម្នាក់នោះបានចាក់ទម្លុះដល់បេះរបស់

កុមារតូច អេឌីសាន់ ក្នុងវ័យ ៨ ឲ្យឈើចុកចាប់ក្រៃលែងទ្រាំពុំបាន គេបានស្ទុះរត់ចេញពីសាលារៀនភ្លាមៗ ហើយរត់ទៅរកម្តាយព្រមទាំងប្តេជ្ញាចិត្តថា រូបគេនឹងមិនត្រឡប់ទៅរៀនទៀតឡើយ។ ចាប់តាំពីពេលនោះមក គាត់មិនដែលបានទទួលការសិក្សានៅសាលារៀនណាទៀតឡើយ ប៉ុន្តែគាត់បែរជាជោគជ័យដោយបានក្លាយខ្លួនជាអ្នកប្រឌិត (Inventor) ដ៏ល្បីល្បាញដែលគេនិយាយច្រើនបំផុតនៅក្នុងពិភពលោក។

លោក អេឌីសាន់ បានចុះបញ្ជីកម្មសិទ្ធិបញ្ញាវត្ថុប្រឌិតរបស់គាត់មានចំនួនរហូតដល់ ២៥០០ ប្រភេទ។ គាត់គឺជាអ្នកបង្កើតម៉ៃក្រូហ្វូន ដែលក្រោយមកទៀត អាឡិចសាន់ឌ័រ គ្រេហ៊ែម ប៊ែល បានយករូបមន្តនោះមកច្នៃចេញជាទូរសព្ទបានសម្រេច។ អេឌីសាន់ បានស្រាវជ្រាវរកឃើញនូវប្រភពភ្លើងអគ្គិសនី និងគ្រឿងអគ្គិសនីដែលតភ្ជាប់ជាមួយនឹងគ្រឿងចក្រចំហាយឧស្ម័ន ដោយបានដាក់បង្ហាញក្នុងពិធីតាំងពិពណ៌អន្តរជាតិនាទីក្រុងបារីស នៅឆ្នាំ ១៨៨១ បន្ទាប់មកទីក្រុងញូយ៉ក បាននាំយករូបមន្ត និងស្នាដៃរបស់គាត់មកបង្កើតជាកន្លែងផលិតចែកចាយអគ្គិសនីដំបូងគេនៅលើពិភពលោកនៅក្នុងឆ្នាំ ១៨៨២។

ក្នុងវិស័យធុរកិច្ចខ្សែភាពយន្ត ក៏ជាគុណបំណាច់របស់គាត់ដែរ ព្រោះរូបគាត់នេះឯងជាអ្នករកឃើញការបង្កើតម៉ាស៊ីនថតភាពយន្ត និងកែច្នៃថ្មឲ្យប្រើប្រាស់បានយូរ និងមានប្រសិទ្ធភាពខ្ពស់ឡើង។ ទាំងអស់នេះ គ្រាន់តែជាឧទាហរណ៍ខ្លះៗដើម្បីបង្ហាញឲ្យឃើញពីអច្ឆរិយភាពរបស់លោក អេឌីសាន់ តែប៉ុណ្ណោះ។

ថូម៉ាស់ អាល់វ៉ា អេឌីសាន់ កើតនៅថ្ងៃទី ១១ ខែកុម្ភៈ គ.ស. ១៨៤៧ នៅទីក្រុង មិឡាន រដ្ឋអូហៃយ៉ូ សហរដ្ឋអាមេរិក។ គាត់អាចឈប់រៀននៅក្នុងសាលាបានតាមការតាំងចិត្តរបស់ខ្លួន ដោយសារក្នុងកាលនោះមិនទាន់មានច្បាប់គ្រប់គ្រងការសិក្សានៅឡើយ។ ក្រោយអំពីគាត់បានត្រឡប់មកពីសាលាដល់ផ្ទះ ដោយសេចក្ដីក្រៀវក្រោធចំពោះគ្រូយ៉ាងខ្លាំងនោះ ម្ដាយរបស់គាត់បានសន្យាថានឹងបង្ហាត់បង្រៀនដោយខ្លួនគាត់ផ្ទាល់។ ចំណែកលោកឪពុករបស់គាត់ក៏យល់ស្របតាមនោះដែរ ព្រោះគាត់យល់ថា វានឹងសន្សំសំចៃលុយខ្លះៗ ដោយមិនបាច់ចំណាយដើម្បីឲ្យកូនទៅរៀននៅសាលា។ អេឌីសាន់ បានពោលក្នុងកាលជាខាងក្រោយថា «ម្ដាយរបស់ខ្ញុំជាអ្នកតម្រង់ទិសខ្ញុំឲ្យបានសម្រេចនូវអ្វីៗគ្រប់យ៉ាងដូចសព្វថ្ងៃនេះ គាត់ស្រឡាញ់និងយល់ចិត្តខ្ញុំ ហើយបណ្ដោយឲ្យខ្ញុំធ្វើនូវអ្វីដែលខ្ញុំចូលចិត្ត»។

ម្ដាយគាត់បានបង្ហាត់បង្រៀនឲ្យគាត់ចេះអាន ចេះសរសេរ និងចេះគណនាលេខនព្វន្តបាន។ ម្ដាយរបស់គាត់បានឲ្យគាត់អានសៀវភៅ «ប្រវត្តិសាស្ត្រក្នុងអន្តរកាលនៃការចុះខ្សោយ និងការដួលរលំនៃចក្រពត្តិរ៉ូម៉ាំង» របស់លោក គិបបនស៍ និង «ប្រវត្តិសាស្ត្រអង់គ្លេស» របស់លោក ហ៊ូម ប្រវត្តិសាស្ត្រពិភពលោករបស់លោក ហ្សៀរ៍ ហើយគាត់បានអានស្នាដៃនិពន្ធបែបទំនើបរបស់ សេកស្ពៀរ៍ និង ឌិហ្គែនស៍ ទៀតផង។

គាត់បានស្វែងយល់គ្រប់យ៉ាងដែលម្ដាយបានណែនាំឲ្យគាត់អាន ក៏ប៉ុន្តែអ្វីដែលធ្វើឲ្យគាត់បានត្រេកអរស្ញើរទប់អារម្មណ៍ពុំបាននោះគឺ នៅ

ពេលដែលគាត់បានអាន «សៀវភៅទស្សនវិជ្ជាធម្មជាតិ» អេឌីសាន់បានចាប់ផ្តើមអនុវត្តតាមទ្រឹស្តីនៅក្នុងសៀវភៅគ្រប់យ៉ាង ទាំងនោះហើយជាចំណុចចាប់ផ្តើមនៃការសិក្សាស្រាវជ្រាវលើមុខវិជ្ជា រូបវិទ្យា និងគីមីវិទ្យារបស់គាត់។ ឪពុកម្តាយបានអនុញ្ញាតឲ្យគាត់ធ្វើបន្ទប់ក្រោមដីមួយដើម្បីពិសោធវត្ថុផ្សេងៗ អេឌីសាន់ នៅតែក្នុងបន្ទប់ក្នុងមួយថ្ងៃៗដើម្បីធ្វើការពិសោធវត្ថុធាតុផ្សេងៗ។ ឪពុករបស់គាត់បាននិយាយថា «គេចំណាយពេលស្ទើរតែទាំងអស់ដើម្បីនៅក្នុងបន្ទប់ពិសោធនោះ គេមិនដែលចេញមកលេងជាមួយក្មេងៗនៅផ្ទះក្បែរខាងឡើយ គេមិនដែលបានស្គាល់រស់ជាតិជីវិតកូនក្មេងបែបណាទេ»។

នៅពេល អេឌីសាន់ មានអាយុ ១២ ឆ្នាំ គាត់បានធ្វើការជាអ្នកលក់ស្ករគ្រាប់តាមរថភ្លើង នៅចន្លោះពេលដែលគ្មានអតិជន ឬពេលប្តូរខ្សែរថភ្លើងគាត់តែងតែឆ្លៀតពេលអានសៀវភៅ ក្រោយពីនោះគាត់បានធ្វើការជាអ្នកបញ្ជូនទូរសាររមួយកន្លែង។ នៅកន្លែងធ្វើការរបស់មានបញ្ហាសត្វកណ្តុររាត្បាតកាត់របស់របរគ្រប់យ៉ាង គាត់ក៏បានរិះរកមធ្យោបាយដើម្បីកម្ចាត់សត្វកណ្តុរ ទើបច្នៃប្រឌិតបានជាអង្គប់កណ្តុរអគ្គិសនីឡើងដោយប្រើដែកលោហៈចំនួនពីរបន្ទះជាកន្លែងផ្ទុកថាមពល និងខ្សែភ្លើងតភ្ជាប់ជាមួយថ្ម (Battary) ប្រើសិនជាសត្វកណ្តុររត់កាត់នោះវានឹងឆក់ស្លាប់ភ្លាមៗ នេះគឺជាវត្ថុច្នៃប្រឌិតដំបូងគេបង្អស់ដែលបង្កើតឡើងដោយដៃលោក ថូម៉ាស់ អេឌីសាន់ អ្នកច្នៃប្រឌិតដ៏ល្បីល្បាញបំផុតក្នុងសតវត្សរ៍ទី២០។

# អាល់ហ្វ្រែត ណូបែល

( Alfred Nobel, Sweden ) គ.ស. ១៨៣៣ - ១៨៩៦

គាត់ជាអ្នករកឃើញ
និងផលិតគ្រាប់បែកដាយណាម៉ែត៍
ដើម្បីប្រើប្រាស់ក្នុងការសាងសងផ្លូវក្រោមដី
និងប្រព័ន្ធធារាសាស្ត្រ
ប៉ុន្តែមនុស្សបាននាំយកទៅធ្វើសង្គ្រាម
ដែលនេះខុសពីគោលបំណងរបស់អ្នកប្រឌិត។



គីមីវិទូ និងជាអ្នកឧស្សាហកម្មជនជាតិ ស៊ុយអែត អាល់ហ្វ្រែត ណូបែល អ្នករកឃើញ និងបង្កើតគ្រាប់បែកដាយណាម៉ែត៍ និងជាអ្នកបង្កើតនូវមូលនិធិ ណូបែល មានជីវិតកាលនៅវ័យកុមារគួរឲ្យរន្ធត់។ ឪពុករបស់គាត់ជាអ្នករកស៊ីផលិតជ័រដំបូងគេនៅប្រទេសស៊ុយអែត តែត្រូវបានបរាជ័យខាតបង់ប្រាក់ច្រើន។ ដោយសារតែបញ្ហានេះបានភៀសខ្លួនទៅរស់នៅក្នុងប្រទេស រុស្ស៊ី ដោយទុកឲ្យភរិយានៅចិញ្ចឹមបីបាច់ថែរក្សាកូនចំនួន ៤ នាក់តែម្នាក់ឯង ហើយបានបើកតូបលក់អីវ៉ាន់មួយដើម្បីរកប្រាក់ចិញ្ចឹមកូនៗ ដែលទទួលបានប្រាក់កម្រៃតិចតួចបានព្រឹកខ្វះល្ងាច។

បងប្រុសរបស់គាត់ឈ្មោះ លុយស៍ បាននិទានឲ្យគាត់ស្តាប់ថា កូនៗទាំងអស់ត្រូវចេញទៅលក់ឈើគូសនៅតាមដងផ្លូវសាធារណៈ ដែលធ្វើឲ្យគាត់នឹកឃើញដល់រឿង «ក្មេងស្រីនិងឈើគូស» របស់កវីនិពន្ធហាន់គ្រីស្ទៀន អែនឌ័រសាន់ (ក្នុងរឿងនោះ នៅទីបំផុតក្មេងស្រីនោះក៏ស្លាប់ដោយសារអាកាសធាតុត្រជាក់ខ្លាំងពេក)។

អាល់ហ្វ្រែត ណូបែល ជាកូនទី ៤ ក្នុងត្រកូលណូបែល កើតនៅថ្ងៃទី ២១ ខែតុលា គ.ស. ១៨៣៣ នាទីក្រុងស្តុកហូម ក្នុងអំឡុងពេលដែលឪពុកជួបបញ្ហារឿងលុយកាក់យ៉ាងធ្ងន់ធ្ងរ។ អាល់ហ្វ្រែត ជាក្មេងទន់ខ្សោយតាំងពីទើបនឹងកើតមកម្ល៉េះ គាត់ធ្លាប់បាននិយាយថា «អង្រឹងរបស់ខ្ញុំប្រៀបដូចជាគ្រែ ម្តាយរបស់ខ្ញុំត្រូវភ្ញាក់ឡើងទាំងសេចក្តីខ្នះខ្នែងដើម្បីការពារមិនឲ្យអណ្តាតភ្លើងនៃជីវិត ដែលកំពុងភ្លឹបភ្លែតៗនឹងរលត់បាត់ទៅចាកលោកនេះ។ ខ្ញុំអស់កម្លាំងកំហែងសូម្បីតែហាមាត់បៅដោះម្តាយក៏ស្ទើរតែហាមាត់ពុំរួចដែរ ខ្ញុំត្រដរខ្យល់រកកល់នឹងដាច់ដង្ហើមគ្រប់ពេលវេលា ពេលខ្ញុំនឹកដល់រឿងនេះ ខ្ញុំស្រក់ទឹកភ្នែក»។

គាត់មិនចង់រំឭករឿងរ៉ាវកាលពីនៅវ័យកុមាររបស់គាត់នោះទេ។ ក្នុងមួយឆាកជីវិតរបស់គាត់ត្រូវរងទុក្ខដោយសារជំងឺឈឺថ្កាត់ និងភាពឯកាគ្រប់ពេលវេលា។ កាលគាត់អាយុ ៨ ឆ្នាំបានចូលរៀនសាលារៀនហ្សិនត៍ជេមស៍ នាទីក្រុង ស្តុកហូម ហើយរៀនពូកែគ្រប់មុខវិជ្ជាដោយសេចក្តីឧស្សាហ៍ព្យាយាម គាត់ប្រឡងជាប់លេខ ៣ ក្នុងចំណោមសិស្សចំនួនជាង ៨០ នាក់ ប៉ុន្តែត្រូវបានចេញពីសាលារៀនក្រោយពេលចូល

រៀនបានមួយឆ្នាំ ព្រោះតែឪពុករបស់គាត់បានប្ដូរទៅធ្វើជំនួញនៅទីក្រុងភីធើស្បឺក ហើយក្រុមគ្រួសារទាំងមូលត្រូវផ្លាស់ទៅរស់នៅទីនោះ។

តាំងពីពេលនោះមក អាល់ហ្វ្រែត ពុំមានឱកាសបានចូលរៀននៅសាលាដទៃណាទៀតឡើយ ប៉ុន្តែលោកឪពុករបស់គាត់បានជួលគ្រូពិសេសមកបង្រៀនភាសា ស៊ុយអែត និងគីមីវិទ្យាផ្ទាល់នៅផ្ទះ។ គាត់បានព្យាយាមសិក្សាស្រាវជ្រាវរៀនសូត្រគ្រប់យ៉ាងដោយខ្លួនឯង រហូតក្លាយជាមនុស្សពោរពេញទៅដោយចំណេះដឹង, មានសមត្ថភាព, និយាយ, អាន, អាចសរសេរភាសាបរទេសបានជាច្រើនភាសា, ទទួលជោគជ័យក្នុងមុខជំនួញឧស្សាហ៍កម្ម និងអាចច្នៃប្រឌិតបង្កើតវត្ថុផ្សេងៗយ៉ាងច្រើនប្រភេទ រហូតក្លាយជាបុរសអ្នកមានមហាសាលដ៏ជោគជ័យបំផុតនៅក្នុងលោក តែជាអកុសល គាត់គ្មានកូនដើម្បីទទួលមរតកឡើយហើយគាត់ក៏បានសម្រេចសរសេរសំបុត្របណ្ដាំមរតកឲ្យនាំយកប្រាក់ និងរោងចក្រឧស្សាហកម្មរបស់គាត់ទៅវិនិយោគ ដើម្បីទទួលបានប្រាក់កម្រៃសម្រាប់ប្រគល់ជារង្វាន់ដល់បណ្ដាអ្នកជំនាញ និងបញ្ញវ័ន្តទាំងឡាយណា ដែលមានសមត្ថភាព និងដែលបានសិក្សាស្រាវជ្រាវរកឃើញរបបគំហើញថ្មីដើម្បីភាពរីកចម្រើនដល់មនុស្សជាតិទូទៅ។

ក្នុងលិខិតបណ្ដាំមរតករបស់គាត់មានខ្លឹមសារថា «ខ្ញុំមានបំណងជួយដល់អ្នកដែលស្រមើស្រមៃចង់បានសម្រេចគោលបំណង តែខ្វះខាតបច្ច័យ ដែលអាចធ្វើឲ្យក្ដីសុបិននោះប្រែក្លាយជាការពិតបាននៅក្នុងឆាកជីវិត»។

បើទោះជាមនុស្សជំនាន់ក្រោយ បាននាំយកនូវអ្វីដែលជាស្នាដៃរបស់គាត់ទៅប្រើប្រាស់ក្នុងផ្លូវខុស ហើយត្រូវបានគេថ្កោលទោសខ្លះៗក៏ដោយចុះ ប៉ុន្តែគោលបំណងបង្កើតគ្រាប់ដាយណាម៉ែត៍ របស់គាត់គឺដើម្បីប្រើប្រាស់ក្នុងការកសាងផ្លូវក្រោមដី និងកសាងប្រព័ន្ធធារាសាស្ត្រដែលផ្តល់ផលប្រយោជន៍ដល់សាធារណជនតែប៉ុណ្ណោះ មិនមែនដើម្បីយកទៅប្រើក្នុងសង្គ្រាមទេ។

គាត់ធ្លាប់បាននិយាយពីបញ្ហាសង្គ្រាមទុកយ៉ាងច្បាស់លាស់ថា «សង្គ្រាមជាប្រភពនៃភាពវិនាសកម្មដ៏អាក្រក់ជាងអ្វីៗទាំងអស់ ហើយសង្គ្រាមនេះជាអំពើឧក្រិដ្ឋកម្មដែលគ្មានអ្វីមកប្រៀបផ្ទឹមបានឡើយ»។

# អាប្រាហាំ លីនខុន

(Abraham Lincoin, U.S) គ.ស. ១៨០៩ - ១៨៦៥



កើតនៅក្នុងត្រកូលក្រីក្រ
ប៉ុន្តែប្រកបដោយសេចក្តីព្យាយាម
ខំស្វែងរកចំណេះដឹងរហូតបាន
ទទួលជោគជ័យដ៏អស្ចារ្យគឺលោក
បានក្លាយជាប្រធានាធិបតីសហរដ្ឋអាមេរិក
និងជាបុគ្គលដែលបញ្ចប់របបវណ្ណៈទាសករ។

ស្ថិតនៅក្នុប្រទេសដែលពោរពេញទៅឱកាសគ្មានទីបំផុត ដូចជាសហរដ្ឋអាមេរិក តែងមានរឿងប្លែកៗដែលនឹកស្មានមិនដល់កើតឡើងជាញឹកញាប់។ មនុស្សដែលធ្លាប់ក្រីក្រលំបាកតោកយ៉ាកកាលពីនៅវ័យក្មេង អាចក្លាយជាមហាសេដ្ឋីបានក្នុងថ្ងៃអនាគតដូចជា អ៊ែនឌ្រូ ខានេគី ឬដូចជាបុរសកំសត់ម្នាក់ ដែលកើតក្នុងគ្រួសារក្រីក្រតោកយ៉ាកស្ទើរតែមិនបានសិក្សារៀនសូត្រ ក៏អាចក្លាយជាប្រធានាធិបតីនៃសហរដ្ឋអាមេរិក ជាប្រធានាធិបតីដែលមានឈ្មោះបោះសំឡេងបំផុត និងទទួលបាននូវភាពជោគជ័យខ្លាំងបំផុត បុគ្គលម្នាក់នោះគឺលោក អាប្រាហាំ លីនខុន។ ប្រវត្តិសាស្ត្របានចារឈ្មោះរបស់គាត់ថា ជាបុគ្គលដែលបានដោះលែងវណ្ណៈទាសករឲ្យមានសិទ្ធសេរីភាព គាត់បានសាងសេចក្តីសុខសន្តិភាពបង្រួបបង្រួមជាតិមិនរើសអើងជាតិពូជសាសន៍ និងសាងអំពើល្អជាច្រើន

អនេកប្បការ ប៉ុន្តែជាអកុសលផលកម្មពីបុព្វេតាមមកសង (បើនិយាយតាមទ្រឹស្តីព្រះពុទ្ធសាសនា) គាត់ត្រូវបានស្លាប់ដោយសារតែគេលបធ្វើឃាតដោយមិនដឹងខ្លួន និងមិនដឹងពីមូលហេតុ។

អាប្រាហាំ លីនខុន ជាកូនរបស់អ្នកតាំងលំនៅឋាននៅក្នុងព្រៃនៃរដ្ឋ ខេនតាក់គី ហើយមិនធ្លាប់បានសិក្សារៀនសូត្រនៅសាលាបឋមសិក្សាណានីមួយឡើយ ប៉ុន្តែជាបុគ្គលដែលប្រាថ្នាចង់សិក្សារៀនសូត្រយ៉ាងខ្លាំង។ យុវជនកូនអ្នកស្រែចម្ការម្នាក់នេះតែងតែឆ្លៀតពេលឈប់សម្រាកពីការងារ ដើម្បីបំពេញបន្ថែមនូវចំណេះដឹងសម្រាប់ខ្លួនឯងយ៉ាងតក់ក្រហល់។ មិត្តរបស់គាត់ម្នាក់ធ្លាប់បាននិយាយថា «គាត់តែងតែអានសៀវភៅរហូតដល់យប់រំលងអាធ្រាតជារៀងរាល់យប់ បើទោះបីជាគាត់ធ្វើការងារពេញមួយថ្ងៃនឿយហត់អស់កម្លាំងយ៉ាងណាក៏ដោយ លុះព្រឹកឡើងគាត់រួសរាន់ក្រោកពីព្រលឹមចាប់ផ្តើមធ្វើការមុនគេជានិច្ច»។

បន្ទាប់ពីគាត់ចេះអាននិងចេះសរសេរហើយ មិនយូរប៉ុន្មានគាត់បានសរសេរអត្ថបទមួយស្តីអំពីទោសនៃការសេពសុរា ហើយបានផ្ញើទៅកាន់ក្រុមហ៊ុនទស្សនាវដ្តីមួយ គេក៏យល់ព្រមបោះពុម្ពផ្សាយដូចបំណង។ ជោគជ័យលើកដំបូងនេះហើយ ដែលជំរុញទឹកចិត្តរបស់គាត់ឲ្យប្រឹងប្រែងសរសេរអត្ថបទផ្សេងៗទៀតជាច្រើន ហើយបានបោះពុម្ពផ្សាយជាលំដាប់លំដោយ។

គាត់បានផ្លាស់ប្ដូរពីរដ្ឋ អូហៃយ៉ូ ទៅរស់នៅឯរដ្ឋ អ៊ីលីណយស៍ ដែលជារដ្ឋដែលមានការប៉ះទង្គិចគ្នា (សង្គ្រាម) រវាងក្រុមអ្នកដែលចូលទៅតាំងលំនៅឋាន និងពួកឥណ្ឌាក្រហមយ៉ាងធ្ងន់ធ្ងរ។ គាត់ស្ម័គ្រចិត្តចូលធ្វើជាទាហានស្ម័គ្រចិត្ត បន្ទាប់ពីស្ថានការណ៍មានភាពស្ងប់ស្ងាត់ គាត់បានធ្វើជាអ្នករត់សំបុត្រ។ បន្ទាប់មកទៀត គាត់បានបើកហាងលក់អីវ៉ាន់ដោយខ្លួនឯងតែគាត់ក៏មិនបោះបង់ចំណាប់អារម្មណ៍ចំពោះនយោបាយដែរ។

នៅពេលគាត់មានអាយុ ២៦ ឆ្នាំ ត្រូវបានជ្រើសតាំងជាតំណាងរាស្ត្ររដ្ឋ អ៊ីលីណយស៍ ហើយមិត្តសមាជិកសភាម្នាក់បានណែនាំគាត់ឲ្យបន្តការសិក្សាផ្នែកច្បាប់ ដោយគាត់បានចំណាយពេលត្រឹមពីរឆ្នាំប៉ុណ្ណោះដើម្បីសិក្សាឯកទេសច្បាប់ហើយបានប្រឡងធ្វើជាមេធាវីជោគជ័យ។

លុះ ១៤ ឆ្នាំក្រោយមកប្រជាជនអាមេរិក បានផ្ដល់សេចក្ដីជឿទុកចិត្តចំពោះរូបគាត់ ហើយបានជ្រើសតាំង អាប្រាហាំ លីនខន ឱ្យជាប្រធានាធិបតីនៃសហរដ្ឋអាមេរិកទី១៦។ ការដែល អាប្រាហាំ លីនខន ជាបុគ្គលដែលមកពីត្រកូលកសិករ និងវណ្ណៈកណ្ដាលនោះ គាត់ជួបនូវបញ្ហាខ្លះៗក្នុងការសម្របខ្លួនក្នុងសង្គម ពេលគាត់ក្លាយជាប្រធានាធិបតី ប៉ុន្តែគាត់មិនសូវខ្វាយខ្វល់ចំពោះរឿងទាំងនោះទេ បើទោះបីជាបណ្ដាគូបដិបក្ខក្នុងឆាកនយោបាយរបស់គាត់ មើលបំណាំរង់ចាំចាប់កំហុសគ្រប់ពេលវេលាយ៉ាងណាក៏ដោយ។

បញ្ហាដែលគាត់ជួបប្រទះដូចជា គាត់ជាមនុស្សមិនចូលចិត្តពាក់ស្រោមដៃ ហើយគាត់តែងថ្កោលទោសថាការធ្វើដូច្នោះវាហាក់ដូចជាធ្វើបាបខ្លួនឯង។ នៅសម័យថ្ងៃមួយ គាត់បានអញ្ជើញចូលរួមក្នុងពិធីជប់លៀងមួយ គាត់ក៏មានបំណងចង់ពាក់ស្រោមដៃដូចគេដូចឯងបានម្តងដែរ ប៉ុន្តែគាត់មិនបានពាក់ស្រោមដៃឲ្យបានត្រឹមត្រូវដូចដែលពិធីការគេបានកំណត់នោះទេ (ត្រូវពាក់ស្រោមដៃពណ៌ស) គាត់បែរជាពាក់ស្រោមដៃពណ៌ខ្មៅ ដែលជាហេតុធ្វើឲ្យពួកបក្សប្រឆាំងនាំគ្នាខ្សឹបខ្សៀវនិងរិះគន់ហៅគាត់ថាជា «អ្នកដុតខ្មោចប្រចាំប្រទេស»។

ក្រក៏ក្រចុះ ឲ្យតែមាន

«ខ្លួនក្រីក្រពិត តែចិត្តតស៊ូ មិនឆាប់មិនយូរ គង់បានជោគជ័យ»។

## ម៉ាក ធ្វេន

(Mark Twain, U.S) គ.ស. ១៨៣៥ - ១៩១០

ពេលដែលគាត់នៅផ្ទះ
ស្ទើរតែធ្វើឲ្យខ្ញុំបែកទ្រូង
ដោយសារតែភាពរបុិលរប៉ូច
ហើយពេលគេមិននៅផ្ទះ
ខ្ញុំបារម្ភពីគេខ្លាំងណាស់។



ជនជាតិអាមេរិកមួយរូបទៀត ដែលមានឈ្មោះបោះសំឡេងនិងមានគេស្រឡាញ់ចូលចិត្តច្រើនជាង អាប្រាហាំ លីនខន បើទោះបីជាគាត់មិនសូវបានរៀនសូត្រនៅសាលារៀនក៏ដោយចុះ បុគ្គលម្នាក់នោះគឺ ម៉ាក ធ្វេន។ ស្នាដៃនិពន្ធរបស់គាត់មានចំនួនពីររឿងដែលល្បីល្បាញ់គឺ Adventures of Huckleberry Finn និង the Adventures of Tom Sawyer ជាសៀវភៅដែលលក់ដាច់បំផុតក្នុងសហរដ្ឋអាមេរិកតាំងពីដើមរហូតមកដល់សម័យបច្ចុប្បន្ននេះ។ ម៉ាក ធ្វេន កើតនៅថ្ងៃទី ៣០ ខែវិច្ឆិកា គ.ស. ១៨៣៥ ក្នុងរដ្ឋ មិសួរី ឈ្មោះពិតរបស់គាត់គឺ ហ្សៃមម្បូល ឡាំងហានឃ្លីមែនស៍ ជាក្មេងដែលមិនចះនៅស្ងៀម។ ម្តាយរបស់គាត់ធ្លាប់បាននិយាយថា «ពេលគេនៅផ្ទះ គេស្ទើរតែធ្វើឲ្យខ្ញុំឆ្កួតដោយសារតែភាពរពឹសរបស់គេ ហើយពេលដែលគេមិននៅផ្ទះ ខ្ញុំបារម្ភពីគេយ៉ាងខ្លាំង»។

ពេល ម៉ាក ផ្ទៃន មានអាយុ ៥ ឆ្នាំម្ដាយរបស់គាត់បានបញ្ជូនឲ្យចូលរៀននៅសាលាអចិន្ត្រៃយ៍នៅក្នុងភូមិ ដោយឲ្យប្រាក់ដាក់ជាប់តាមខ្លួនសម្រាប់ចាយវាយចំនួន ២៥ សេនក្នុង ១ សប្ដាហ៍។ នៅសាលារៀនគេតែងលេងបិទពួន និងធ្វើខុសវិន័យសាលា ហើយមានការដាក់ទោសទណ្ឌកម្មជាញឹកញាប់ ប៉ុន្តែរូបគេមិរាងចាលឡើយ។ គេមិនសូវជាបានរៀនសូត្រនៅសាលារៀនបានច្រើនណាស់ណាទេ ព្រោះក្នុងសម័យនោះមានការបើកបង្រៀនចំពោះតែរដូវក្ដៅ និងរៀនពីរទៅបីថ្ងៃតែប៉ុណ្ណោះក្នុងមួយសប្ដាហ៍។

ក្រុមគ្រួសាររបស់គាត់ជួបបញ្ហាលុយកាក់ជាខ្លាំង ក្រោយពេលឪពុករបស់គាត់ទទួលអនិច្ចកម្មចោលទៅ ក្នុងខណៈដែលគាត់មានអាយុ ១២ ឆ្នាំ ហើយគាត់ក៏បានឈប់រៀនដើម្បីទៅហ្វឹកហាត់ធ្វើការខាងផ្នែកបោះពុម្ពនៅក្នុងក្រុមហ៊ុនទស្សនាវដ្ដីមួយ ដោយទទួលបានការហូបចុក និងសម្លៀកបំពាក់ ក៏ប៉ុន្តែមិនមានប្រាក់ឈ្នួលទេ។ ផ្ទៃន បានរំឭកដល់បទពិសោធជីវិតក្នុងពេលនោះថា «ថៅហ្វាយរបស់ខ្ញុំបានសន្យាជាមួយខ្ញុំថាគាត់នឹងផ្ដល់សម្លៀកបំពាក់ចំនួនពីរឈុតដល់ខ្ញុំក្នុងមួយឆ្នាំ មួយឈុតគឺនៅក្នុងកិច្ចសន្យានោះឯង រីឯមួយឈុតទៀតជារបស់ដែលគាត់បានប្រើប្រាស់រួចហើយ។ ខ្ញុំទាបត្រឹមចង្កេះគាត់ពេលខ្ញុំពាក់អាវនោះ ខ្ញុំមានអារម្មណ៍ថាចម្លែកក្នុងចិត្តយ៉ាងខ្លាំង ចំណែកខោវិញខ្ញុំស្លៀកត្រូវល្មមបើសិនជាខ្ញុំទាញចង្កេះខោដល់ត្រចៀករបស់ខ្ញុំ» រីឯអាហារក៏មិសូវជាអន់ប៉ុន្មានដែរ «ពួកយើងញ៉ាំអាហារដដែលៗជារៀងរាល់ថ្ងៃ ហើយចំនួន

អាហារក៏តិចហូបមិនឆ្អែតទៀត។ នៅពេលខ្លះ ពួកយើងលបលួចចូលក្នុងបន្ទប់ដាក់អាហារក្នុងវេលាយប់ ដើម្បីលួចដំឡូងបារាំង ខ្ទឹមបារាំង និងរបស់ផ្សេងទៀតយកមកធ្វើម្ហូបញ៉ាំក្នុងបន្ទប់បោះពុម្ព»។ ម៉ាក ធ្វែន តស៊ូហ្វឹកហាត់ការងារក្នុងរោងពុម្ពនោះបានរយៈពេល ២ ឆ្នាំ ហើយបានប្តូរទៅជួយបងប្រុសរបស់ខ្លួនដែលទើបបើករោងពុម្ពថ្មី ប៉ុន្តែក៏ត្រូវបានដួលរលំទៅវិញក្នុងរយៈពេល ១ ឆ្នាំក្រោយមក។ ចាប់ពីពេលនោះមក គាត់បានសាកល្បងធ្វើការខុសពីជំនាញចាស់ ដោយគាត់បានសម្រេចចិត្តធ្វើអ្នកបម្រើការងារតាមនាវា ហើយគាត់ធ្វើការងារនោះអស់រយៈពេលជាច្រើនឆ្នាំ។ នៅក្នុងទឹកទន្លេក្នុងអំឡុងពេលនោះសម្បូរទៅដុំថ្មធំៗ ដែលអាចបង្កគ្រោះថ្នាក់ដល់ការធ្វើនាវាចរ ដូច្នឹងហើយទើបគាត់ត្រូវវាស់ស្ទង់ពីជម្រៅទឹកជាប្រចាំ ដោយសារតែតួលេខដែលប្រើប្រាស់សម្រាប់វាស់ជម្រៅទឹកនុំងហើយ បានក្លាយមកជារហស្សនាមកវីនិពន្ធរបស់គាត់ថា ម៉ាក ធ្វែន ពេលដែលគាត់បានសរសេរអត្ថបទផ្សាយតាមរយៈកាសែតហើយទទួលជោគជ័យ និងមានឈ្មោះល្បីល្បាញតាំងតែពីពេលនោះជារៀងរហូតមក។

# ឆាលស៍ ឌិខែនស៍

( Charles Dickens, England ) គ.ស. ១៨១២ - ១៨៧០

ឪពុកម្តាយ បងប្អូនត្រូវបានគេចាប់ដាក់គុក ដោយសារករណីជំពាក់បំណុលគេ គាត់ក៏បានទៅជួលបន្ទប់នៅក្បែរមន្ទីរឃុំឃាំង និងត្រូវរកទទួលទានចិញ្ចឹមជីវិតដោយខ្លួនឯង ខណៈនោះអ្វីដែលគាត់មានគឺសៀវភៅពេញមួយហិប។



កវីល្បីឈ្មោះជនជាតិអង់គ្លេស ដ៏ល្បីរន្ទឺរូបនេះ រៀនសូត្របានតិចតួចណាស់ បើប្រៀបធៀបជាមួយនឹងកវីនិពន្ធអច្ឆរិយៈទាំងឡាយក្នុងលោក។ គាត់គឺជាអ្នកចាប់ផ្តើមសរសេររឿងប្រលោមលោកដែលបង្ហាញពីតថភាពសង្គម ភាគច្រើនស្តីពីជនវណ្ណៈកណ្តាលដែលត្រូវរងសម្ពាធក្នុងយុគសម័យការបដិវត្តឧស្សាហកម្មក្នុងប្រទេសអង់គ្លេស។ សម្រាប់ខ្លួនគាត់ផ្ទាល់កើតមកក្នុងសភាពក្រីក្រលំបាកលំបិន ដូច្នឹងហើយគាត់ពុំសូវបានសិក្សារៀនសូត្រដិតដល់ឡើយ។ គ្រួសាររបស់គាត់ក្រីក្រលំបាកតោកយ៉ាក ក៏ព្រោះតែឪពុករបស់គាត់មិនស្គាល់ពីគុណតម្លៃលុយកាក់។ គាត់កើតនៅថ្ងៃទី ៧ ខែកុម្ភៈ គ.ស. ១៨១២ នាទីក្រុង ឡៃនផត ជាកូនទី២ ក្នុងចំណោមបងប្អូន ៧ នាក់ គាត់បានចូលរៀនថ្នាក់ដំបូងនៅទីក្រុងខាត់ហែម ពីព្រោះឪពុកត្រូវប្រចាំការនៅទីនោះនៅឆ្នាំ ១៨១៧។

គាត់រៀនដោយពុំសូវមានសេចក្ដីសុខទេ នេះក៏មិនគួរឲ្យចម្លែកអ្វីដែរ។ ព្រោះប្រព័ន្ធអប់រំក្នុងប្រទេសអង់គ្លេសនាសម័យនោះប្រកបទៅដោយបទបញ្ជាយ៉ាងតឹងរ៉ឹង។ នៅក្នុងរឿង «ដេវិដ ខបភើ ហ្វិលដ៍» គាត់បានរៀបរាប់អំពីលក្ខណៈរបស់គ្រូមួយរូប ដែលមានឈ្មោះថា ឃ្រិហ្គឹល (ដែលអាចជាគ្រូបង្រៀនគាត់ផ្ទាល់) នៅក្នុងរឿងនោះ គាត់បានសរសេរថា «ខ្ញុំគិតថាប្រហែលជាគ្មានបុគ្គលណាម្នាក់នៅក្នុងលោកនេះ ដែលមានមោទនភាពក្នុងអាជីពរបស់ខ្លួនស្មើនឹងលោក ឃ្រិហ្គឹល ឡើយ គាត់វាយក្មេងៗដោយភាពជឿជាក់ក្នុងអារម្មណ៍ ពេលខ្លះស្ទើរតែធ្វើឲ្យគាត់ឈានដល់ចំណុចកំពូលនៃកាមារម្មណ៍តែម្ដង។ ខ្ញុំជឿជាក់ថា គាត់មិនអាចនឹងរម្ងាប់ចិត្តបានឡើយ នៅពេលគាត់ឃើញថ្ពាល់ដ៏ក្រហមឆ្អៅរបស់ក្មេងៗ បើមិនបានទះថ្ពាល់ដ៏ក្រហមនៃក្មេងៗទាំងនោះ ឲ្យជាំខៀវក្នុងរំពេចនោះទេ ខ្លួនខ្ញុំផ្ទាល់ក៏ធ្លាប់ស្គាល់រសជាតិបែបនោះដែរ រហូតមកដល់ពេលនេះ បើខ្ញុំនឹកឃើញដល់ឈ្មោះបុរសម្នាក់នេះកាលណា ខ្ញុំនៅតែមានអារម្មណ៍ខឹងនឹងគាត់ជានិច្ច»។

ឌិខែនស៍ ជាសិស្សដែលឱហាតសង្វាត់ព្យាយាមសិក្សារៀនសូត្រគ្រប់ពេលវេលា។ នៅពេលគាត់មានអាយុ ១១ ឆ្នាំ ឪពុករបស់គាត់បានផ្លាស់ទៅនៅទីក្រុងឡុងដ៍ ហើយជំពាក់បំណុលគេវ័ណ្ឌក គាត់បានយករបស់របរទាំងអស់ទៅបញ្ចាំ ជាហេតុធ្វើឲ្យកុមារតូច ឌិខែនស៍ មិនអាចបន្តការសិក្សាបានទៀតឡើយ។ ឆាកស៍ ឌិខែនស៍ បានបង្ហូរទឹកប៉ាកការៀបរាប់ដោយសេចក្ដីតូចចិត្តថា ឪពុករបស់គាត់ប្រហែលជាភ្លេចអស់

ហើយមើលទៅថា រូបគាត់គួរតែមានឱកាសបានសិក្សាបន្ត ដូចបងស្រី ដែលបានអាហារូបករណ៍រៀនបន្តផ្នែកតូរ្យតន្ត្រីដែរ។ គ្មាននរណាយកចិត្ត ចំពោះគាត់ទេ ជារៀងរាល់ព្រឹកត្រូវខាត់ស្បែកជើងឲ្យឪពុក និងខ្លួនឯង បន្ទាប់មកត្រូវជួយកិច្ចការងារផ្ទះ ជួយមើលប្អូនៗ ហើយអ្វីដែលធ្ងន់ធ្ងរ ជាងនេះទៅទៀតនោះគឺ នៅពេលដែលកុមារតូចវ័យ ១២ ឆ្នាំ ឌិខែនស៍ បានទៅធ្វើការជាក្នុងរោងចក្រផលិតសារ៉ាស្បែកជើង គេត្រូវច្រកថ្នាំសារ៉ា ទៅក្នុងកំប៉ុងតាំងពីព្រលឹមទល់ព្រលប់ ឥតមានពេលឈប់សម្រាកឡើយ។ គាត់យល់ឃើញថា ការងារដែលគាត់ធ្វើជាសភាវៈគាបសង្កត់ដែលរក ច្រកចេញមិនឃើញទាល់តែសោះ ធ្វើឲ្យគាត់អស់សង្ឃឹមបន្តិចម្តងៗ ជា រៀងរាល់ថ្ងៃ។ ក្រោយពេលធ្វើការនៅទីនោះមិនយូរប៉ុន្មាន ឪពុករបស់ គាត់ក៏ត្រូវបានរាជការចាប់ខ្លួនពីបទជំពាក់បំណុល ហើយត្រូវបានដាក់ ឃុំឃាំងនៅក្នុងគុកទាំងម្តាយនិងបងស្រីរបស់គាត់ ប៉ុន្តែមានរូបគាត់តែ ម្នាក់គត់ ដែលមិនត្រូវបានគេចាប់ខ្លួនយកទៅឃុំនៅពន្ធនាគារដ៏គួរឲ្យ ព្រឺសម្បុរនោះ។ ឌិខែនស៍ បានជួលបន្ទប់តូចមួយនៅក្បែរពន្ធនាគារនោះ និងត្រូវមើលការខុសត្រូវចិញ្ចឹមជីវិតខ្លួនឯងយ៉ាងកណ្តោចកណ្តែង។

របស់នៅក្នុងផ្ទះទាំងអស់ ទោះជាត្រូវបានបញ្ចាំដូរយកប្រាក់មក សងរម្លស់គេក៏នៅតែមិនរួចខ្លួន។ មានវត្ថុតែម្យ៉ាងគត់ ដែលសេសសល់ ហើយ ឌិខែនស៍ អាចរក្សាទុកបានគឺហិបដែលផ្ទុកពេញដោយសៀវភៅ មានទាំងសៀវភៅប្រលោមលោកនិងសៀវភៅបណ្តុះគំនិត។ សៀវភៅ ទាំងនោះបានទាក់ទាញអារម្មណ៍ ឌិខែនស៍ ឲ្យធ្លាក់ចូលក្នុងសំណាញ់នៃ

ក្តីស្រមៃដ៏ស្រស់ត្រកាល ផ្ទុយពីសេចក្តីពិតនៃជីវិតដ៏ល្វីងជូចត់ ដែលខ្លួនកំពុងតែជួបប្រទះគ្រប់ទិវារាត្រី។ កាលនោះ ឌិខែនស៍ កំសត់បានតាំងសេចក្តីប្រាថ្នាថា ថ្ងៃណាមួយខ្ញុំនឹងធ្វើជាអ្នកនិពន្ធដ៏អង់អាចក្លាហានដូចកវីល្បីឈ្មោះដែលជាម្ចាស់ស្នាដៃដែលខ្ញុំបានអានឲ្យខានតែបាន។

ក្បួនជីវិតរបស់ ឆាលស៍ ឌិខែនស៍ បានប្រែក្លាយជាល្អប្រសើរឡើងវិញយ៉ាងឆាប់រហ័ស ដោយសារឪពុករបស់គាត់បានទទួលមរតកដ៏ច្រើនហើយអាចទូទាត់សងបំណុលរួចបានចេញពីពន្ធនាគារ ពេលនោះ ឆាលស៍ ក៏អាចបញ្ចប់នូវជីវិតនិងការងារដ៏គួរឲ្យធុញទ្រាន់នោះបាននិងបានចូលរៀនបន្តតាមបំណងប្រាថ្នា។ ឆាលស៍ ឌិខែនស៍ បានព្យាយាមសិក្សារៀនសូត្រយ៉ាងខ្ជាប់ខ្ជួនដើម្បីបានសម្រេចគោលបំណង ពោលគឺទទួលបានជោគជ័យក្នុងឆាកជីវិតអស់រយៈពេល ២ ឆ្នាំ ដោយបានធ្វើការជាស្មៀនឲ្យមេធាវីម្នាក់នៅពេលគាត់មានអាយុ ១៥ ឆ្នាំ។

ជារៀងរាល់ល្ងាច ឆាលស៍ ឌិខែនស៍ តែងតែបានឆ្លៀតទៅរៀនគណិតវិទ្យាបន្ថែមជានិច្ច លុះគាត់មានអាយុ ២០ ឆ្នាំបានចូលធ្វើការងារផ្នែកកាសែត ដោយគាត់ធ្វើជាអ្នកសារព័ត៌មានប្រចាំការនៅរដ្ឋសភា។ ស្របពេលជាមួយគ្នានោះដែរ ក៏បានចាប់សរសេររឿងប្រលោមលោកដែលឆ្លុះបញ្ចាំងពីតថភាពសង្គម នៅក្នុងចំណោមរឿងដែលគាត់និពន្ធដំបូងគេ មានរឿងមួយដែលសាងភាពល្បីល្បាយ៉ាងខ្លាំងបំផុតសម្រាប់រូបគាត់ នោះគឺ «អូលីវ៉ី ធ្វីសថ៍» លុះ ឆាលស៍ ឌិខែនស៍ មានអាយុ ៣០ ឆ្នាំក៏បានក្លាយជាអ្នកនិពន្ធអច្ឆរិយៈដ៏ល្បីមួយរូបនៅក្នុងសកលលោក។

# ហៃនរីច ស្ដីម៉ាន់ន៍

( Henrich Schiemann, Germany ) គ.ស. ១៨២២ - ១៨៩០

មានគោលបំណងប៉ងប្រាថ្នាថា
នឹងស្រាវជ្រាវរកទីក្រុងទ្រយ
តាំងតែពីអាយុ ៨ ឆ្នាំ
លុះគាត់ក្លាយជាមហាសេដ្ឋី
ក៏បានចាប់ផ្ដើមគម្រោងជីកស្រាវជ្រាវជាផ្លូវការ
ហើយបានរកឃើញទីក្រុងទ្រយ
ដូចដែលមានចារក្នុងប្រវត្តិសាស្ត្រពិតប្រាកដមែន។



ដូចលោក ឆាលស៍ ឌិខែនស៍ ដែរ ហៃនរីច ស្ដីម៉ាន់ន៍ ក៏ជាបុគ្គលដែលតាំងសេចក្ដីបំណងប៉ងប្រាថ្នា និងពុះពារនូវឧបសគ្គគ្រប់បែបយ៉ាង ដើម្បីបានទទួលជោគជ័យ ទោះបីជាគាត់ពុំសូវមានឱកាសសិក្សារៀនសូត្របានច្រើនក៏ដោយ។ បិតានៃបុរាណវិជ្ជាដែលបានស្រាវជ្រាវរកឃើញទីក្រុង ទ្រយ បុរាណរូបនេះកើតនៅថ្ងៃទី ៦ ខែមករា គ.ស. ១៨២២ នាទីក្រុង ណយប៊ូខូវ៍ ភាគខាងជើងនៃប្រទេស អាល្លឺម៉ង់។ ឪពុករបស់គាត់ជាអាចារ្យសាសនាគ្រិស្ត ជាអ្នកដែលបានបណ្ដុះសតិសម្បជញ្ញៈរបស់គាត់ឲ្យចាប់អារម្មណ៍ចំពោះបុរាណវិជ្ជា ដោយគាត់តែងនិយាយពីវីរកម្មរបស់បណ្ដាតួឯកក្នុងមហាវីរកថារបស់លោក ហូម័រ និងរឿងសង្គ្រាមនៅ

ទីក្រុង ថ្រយ ឲ្យ ហៃនរីច ស្លីម៉ាន់ន៍ ស្តាប់ជានិច្ច។ ទីក្រុង ថ្រយ នៅក្នុងខណៈនោះមានឈ្មោះតែនៅក្នុងរឿងនិទាន និងការនិយាយតៗប៉ុណ្ណោះ។ នៅពេល ហៃនរីច ស្លីម៉ាន់ន៍ មានអាយុ ៨ ឆ្នាំគាត់បានរូបគំនូរនៅក្នុងសៀវភៅហើយបាននិយាយជាឪពុកថា «ប្រសិនបើទីក្រុង ថ្រយ មានកំពែងដ៏ធំមហិមានិងរឹងមាំយ៉ាងនេះ ហេតុដូចម្តេចបានជាពុំឃើញមានសេសសល់គ្រឹះជាវត្ថុតាងអ្វីអ៊ុចឹង?»។

បើទោះបីជាឪពុកព្យាយាមអធិប្បាយពន្យល់ថា រូបនោះវាកើតចេញពីគំនិតស្រមើស្រមៃរបស់វិចិត្រករទេ វាមិនមែនជារូបដែលគូរតាមទិដ្ឋភាពទីក្រុងជាក់ស្តែងឡើយ ប៉ុន្តែ ហៃនរីច ស្លីម៉ាន់ន៍ នៅតែមិនជឿនិងយល់ឃើញដូច្នោះដែរ។ ឪពុកក៏បានសន្យាថា នៅថ្ងៃអនាគតនឹងអនុញ្ញាតឲ្យ ហៃនរីច ជីកកកាយស្រាវជ្រាវរកទីក្រុងឲ្យទាល់តែឃើញ ដែលកាលនោះក៏គ្រាន់តែនិយាយលេងតែប៉ុណ្ណោះ។

កាលនៅវ័យកុមារ ហៃនរីច មិនមានទំនោរជាអ្នកជោគជ័យដ៏អច្ឆរិយៈសូម្បីបន្តិចណាឡើយ។ ម្តាយរបស់គាត់បានធ្វើមរណកាលតាំងពី ហៃនរីច នៅតូចក្រូចឆ្មារ បន្ទាប់ពីនោះឪពុកក៏សម្រេចចិត្តឲ្យ ហៃនរីច ឈប់រៀនពីព្រោះជួបបញ្ហាកង្វះខាតលុយកាក់។ លុះ ហៃនរីច មានអាយុ ១៤ ឆ្នាំ ទើបបានចូលហ្វឹកហាត់រៀនជំនាញផ្នែកលក់អីវ៉ាន់ ដែលបញ្ជូនមកពីប្រទេសអាណានិគម ប៉ុន្តែនៅតែរក្សាក្តីស្រមៃក្នុងការស្រាវជ្រាវរកទីក្រុង ថ្រយ ឲ្យឃើញនៅថ្ងៃណាមួយ។ នៅទីបំផុត គាត់ក៏យល់ឃើញថាការដែលនឹងញ៉ាំងសេចក្តីស្រមៃឲ្យក្លាយជាការពិតបាន ត្រូវប្រើប្រាស់

នូវសក្តានុពលមហាសាលទើបនឹងសម្រេចបាន។ ដូច្នឹងគាត់ក៏បានផ្លាស់ទៅធ្វើការជាអ្នកបម្រើតាមទូកក្តោងទេសចរណ៍ ដោយមានគោលដៅឆ្ពោះទៅផ្សងព្រេងនៅសហរដ្ឋអាមេរិក ដែលឮល្បីតៗគ្នាមកថាជាទឹកដីដែលមនុស្សម្នាអាចធ្វើឲ្យសេចក្តីស្រមៃក្លាយជាការពិតបាន។ ក៏ប៉ុន្តែមិនបានដូចបំណងប្រាថ្នាទេ ព្រោះទូកដែលគាត់ធ្វើការនៅទីនោះបានលិចនៅតំបន់ក្បែរឆ្នេរសមុទ្រ ហូលឡង់ ទើបគាត់សម្រេចចិត្តស្នាក់អាស្រ័យនៅក្នុងប្រទេស ហូលឡង់ នោះទៅ។

គាត់ធ្វើការជាភ្នាក់ងារបញ្ជូនឯកសារនៅក្នុងក្រុមហ៊ុនមួយ នាទីក្រុង អាំស្ទែដាំ អស់រយៈពេល ៣ ឆ្នាំ ភាពអច្ឆរិយៈផ្នែកភាសារបស់គាត់ក៏បានកើតប្រាកដឡើងក្នុងអំឡុងនោះដោយគាត់ចេះអាន ចេះសរសេរ និងចេះនិយាយរហូតដល់ ៦ ភាសាគឺ ភាសាហូលឡង់ ភាសាអង់គ្លេស ភាសាបារាំង អេសប្បាញ និងព័រទុយកាល់។ ក្រោយពីនោះគាត់ក៏បានធ្វើការជាបុគ្គលិកផ្នែករត់សំបុត្រក្នុងក្រុមហ៊ុនមួយផ្សេងទៀត ហើយនៅពេលគាត់រៀនភាសារុស្ស៊ី ចេះស្ទាត់ជំនាញ ក្រុមហ៊ុនបានបញ្ជូនរូបគាត់ទៅប្រចាំការនៅឯទីក្រុង ហ្សិនភីធើស្បឺក។ នៅទីនេះឯងហើយដែល ហ៊ែនរីច ស្លីម៉ាន់ន៍ បានចាប់ផ្តើមអាជីពលក់ដូរផ្ទាល់ខ្លួន ហើយក៏បានក្លាយជាសេដ្ឋីប្រាក់លាននៅក្នុងវ័យ ២៦ ឆ្នាំ។

គាត់ធ្វើមុខជំនួញកាលនោះ ទទួលបានប្រាក់ចំណេញយ៉ាងច្រើនមហាសាលក្នុងអំឡុងពេលតែប៉ុន្មានឆ្នាំប៉ុណ្ណោះ។ ពេលនោះគាត់ក៏មានលទ្ធភាពអាចញ៉ាំងសេចក្តីស្រមៃតាំងពីនៅវ័យកុមារ ឲ្យក្លាយជាការពិត

តាមបំណងប្រាថ្នា។ គាត់បានរៀនភាសាអារ៉ាប់ និងភាសាក្រិច ជាភាសាទី ១៦ បន្ទាប់មកបានដកខ្លួនចេញពីជំនួញដើម្បីត្រៀមលក្ខណៈសម្រាប់ការសិក្សាស្រាវជ្រាវជីករកទីក្រុង ថ្រយ បុរាណជាផ្លូវការ។

ដំបូងឡើយ ហ៊ែនរីច បានធ្វើដំណើរទៅកាន់ប្រទេស អេហ្ស៊ីព ប៉ាឡេស្ទីន ស៊ីរី ឥណ្ឌា ចិន និងប្រទេសក្រិច គាត់ស្នាក់នៅអចិន្ត្រៃយ៍នាទីក្រុង អេថេនស៍ ហើយបានរៀបការជាមួយស្ត្រីជនជាតិក្រិចដ៏ស្រស់សោភា។ នៅចន្លោះពេលនោះគាត់មានអាយុ ៤៦ ឆ្នាំ ហើយបានសិក្សាស្វែងយល់មហាវីរកថារបស់កវីនិពន្ធ ហូម័រ យ៉ាងល្អិតល្អន់ដើម្បីស្វែងរកទីតាំងពិតប្រាកដនៃទីក្រុង ថ្រយ។ ជាលទ្ធផល គាត់បានរកឃើញថាទីក្រុង ថ្រយ ដែលកវី ហូម័រ បានសរសេរក្នុងរឿងប្រលោមលោកគួរតែស្ថិតនៅបរិវេណខ្ពង់រាប ហ៊ីសាលិខ នៃប្រទេស ទួរគី ហើយគាត់ក៏បានបើកការដ្ឋានធ្វើកំណាយស្រាវជ្រាវរកឃើញទីក្រុង ថ្រយ បុរាណបានសម្រេចពិតប្រាកដ សមដូចសេចក្តីស្រមៃរបស់គាត់តាំងពីនៅវ័យកុមារមកនោះ។ ភាពជោគជ័យដ៏ធំធេងរបស់គាត់គឺ កើតចេញពីការតាំងចិត្តដ៏ខ្ជាប់ខ្ជួនប្រកបដោយសេចក្តីព្យាយាមឥតនឿយណាយ នៃអច្ឆរិយបុគ្គលរូបនេះ ដែលមិនជឿថាអ្វីដែលពិពណ៌នារៀបរាប់ក្នុងមហាវីរកម្មរបស់កវី ហូម័រ មិនមែនជារឿងប្រឌិតនោះ។

ពីកំណាយក្លាយជាការពិតនោះ ក៏បានកើតឡើងប្រាកដជាតឹកតាងប្រវត្តិសាស្ត្រឃើញផ្ទាល់នឹងភ្នែកនៃមនុស្សទូទៅក្នុងសកលលោក។

# ចីន-ចាកស៍ រ៉ូហ្សូ

( Jean-Jacques Rousseau, Switzerland ) គ.ស. ១៧១២ - ១៧៧៨

ចីន-ឆាកស៍ រ៉ូហ្សូ ក្លាយជាបុគ្គលល្បីល្បាញ ក្នុងរយៈពេលតែមួយប៉ព្រិចភ្នែក នៅពេលដែលគាត់បានសរសេរអត្ថបទ ដែលមានចំណងជើងថា «ការយល់ឃើញទាក់ទងនឹងជំនាញ និងសិល្បៈ» ក្នុងឆ្នាំ១៧៥០។



អ្នកនិពន្ធកូនកាត់ស្វីស-បារាំង រូបនេះជាអ្នកប្រឆាំងចំពោះប្រព័ន្ធ អប់រំមើលថែរបៀបផ្ដាច់ការ នោះកើតចេញអំពីរបទពិសោធជីវិតកាល នៅក្នុងវ័យកុមាររបស់គាត់។

ចីន-ចាកស៍ រ៉ូហ្សូ កើតនៅថ្ងៃទី ២៨ ខែមិថុនា គ.ស. ១៧១២ នាទីក្រុង ចេនីវ៉ា អច្ឆរិយបុគ្គលរូបនេះរស់នៅត្រូវអាស្រ័យពឹងពាក់លើ ខ្លួនឯងទាំងស្រុងតាំងពីនៅវ័យក្មេង។ ម្ដាយរបស់គាត់បានស្លាប់ចោល តាំងពីថ្ងៃដែលគាត់ប្រសូត្រមកម្ល៉េះ ចំណែកលោកឪពុកមើលថែរូបគាត់ បានមួយរយៈខ្លីប៉ុណ្ណោះ ក៏បោះបង់រូបលោកចោលទៀតដោយសារតែ មានរឿងរ៉ាវវិវាទជាមួយនាយទាហានម្នាក់ ហើយបានរត់ភៀសខ្លួនទៅ

រស់នៅស្រុកផ្សេង ដោយបានប្រគល់កូនប្រុសតូចឲ្យទៅសាច់ញាតិម្នាក់ជាអ្នកមើលថែជំនួស។ សាច់ញាតិរបស់គាត់ម្នាក់នោះចិញ្ចឹមមិនបានយូរប៉ុន្មានក៏ប្រគល់ឲ្យទៅអ្នកផ្សេងទៀត។ កុមារកំសត់ រ៉ូហ្ស ត្រូវផ្លាស់អ្នកចិញ្ចឹមបីបាច់ជារឿយៗ ជាហេតុធ្វើឲ្យរូបគេមិនបានសិក្សារៀនសូត្រអ្វីឡើយ។ លុះក្រោយមកទៀតគាត់បានទៅរៀនធ្វើនាឡិកាជាមួយជាងធ្វើនាឡិកាម្នាក់ ហើយជាងរូបនោះចិត្តអាក្រក់ចំពោះគាត់យ៉ាងខ្លាំង រ៉ូហ្សបានសរសេរនៅក្នុងកំណត់ហេតុរបស់គាត់ថា «តាមការពិតទៅខ្ញុំក៏មានចំណងចំណូលចិត្តធ្វើនាឡិកាមិនតិចដែរ ខ្ញុំតាំងចិត្តរៀនឲ្យដល់ទីបំផុតទោះបីជាចៅហ្វាយមិនកាចដាក់ខ្ញុំក៏ដោយ។ ការដែលគាត់បញ្ជាធ្វើបាបខ្ញុំយ៉ាងទារុណ ខ្ញុំស្ទើរតែទ្រាំពុំបាន ដែលនេះមានចំណែកអូសទាញខ្ញុំឲ្យធ្លាក់ចូលក្នុងសំណាញ់នៃអំពើបាប ដែលសុទ្ធជារឿងដែលខ្ញុំមិនចូលចិត្តដូចជា ការកុហក ការខ្ជិលច្រអូស និងការលួចជាដើម»។

នៅពេលមានអាយុ ១៦ ឆ្នាំ គាត់សម្រេចចិត្តរត់គេចចេញពីសំណាក់ចៅហ្វាយដ៏កាចសាហាវរូបនោះ ក្រោយរូបគាត់ត្រូវវាយយ៉ាងធ្ងន់ធ្ងរ។ គាត់បានត្រាច់ចរទៅកាន់ទីកន្លែងផ្សេងៗស្ទើរទូទាំងប្រទេសចិញ្ចឹមជីវិតដោយការសុំទានគេ ជួនកាល លួចរបស់គេហូបទៀតផង។ នៅទីបំផុតក៏បានមកដល់ទីក្រុង អានហ្ស៊ី ក្នុងទឹកដី សាវ៉យ ក៏បានស្គាល់លោកស្រី ដឺ វ៉ារងដ៍ ជាមនុស្សមានចិត្តមេត្តាតែងជួយឧបត្ថម្ភសង្គ្រោះយកអាសាមនុស្សកំសត់ទុគ៌ត និងអនាថាឲ្យមានកន្លែងស្នាក់អាស្រ័យ។

គាត់ស្នាក់អាស្រ័យនៅជាមួយនឹងលោកស្ត្រីដ៏មានចិត្តម្នាក់នេះ ហើយបានរៀនវិធីនៃការអាន ការសរសេរ និងចំណេះវិជ្ជាផ្សេងទៀត បើទោះជាប្រព័ន្ធអប់រំនៅទីនោះ ពុំសូវសម្បូរបែបក៏ដោយចុះ។ ក្រោយមកទៀត គាត់បានសម្រេចចិត្តសុំចាកចេញពីទីនោះ ដើម្បីចូលប្រឡូកក្នុងសង្គមនិងរកទទួលទានចិញ្ចឹមជីវិតដោយខ្លួនឯង។ គាត់បានធ្វើជាគ្រូបង្រៀនពិសេស (បង្រៀនតាមផ្ទះ) គ្រូបង្រៀនតូរ្យតន្ត្រី។ ជួនកាលក៏ធ្វើជាលេខាធិការឲ្យគណៈទូត និងបាននិពន្ធបទភ្លេងផងចម្រៀងផង និងសរសេរសៀវភៅផងដែរ ក៏ប៉ុន្តែគាត់មិនដែលស្នាក់នៅជាប់លាប់កន្លែងណាទ្បើយព្រោះគាត់គិតថាប៉ូលីសតាមចាប់ខ្លួនគាត់គ្រប់ពេលវេលា។

ចឺន-ចាកស៍ រ៉ូហ្ស៊ូ ក្លាយជាបុគ្គលមានឈ្មោះល្បីល្បាញក្នុងរយៈពេលតែមួយប៉ប្រិចភ្នែក នៅពេលដែលគាត់បានសរសេរអត្ថបទស្តីអំពី «ការយល់ឃើញទាក់ទងនឹងវប្បធម៌និងជំនាញ» គឺនៅក្នុងឆ្នាំ ១៧៥០។ ក្នុងការប្រកួតដណ្តើមពានរង្វាន់នៅទីក្រុង ឌិចង ប្រធានបទដែលគេលើកទ្បើងសម្រាប់បញ្ចេញមតិគឺ «តើភាពរីកចម្រើនផ្នែកវប្បធម៌ និងជំនាញមានចំណែកក្នុងការលើកកម្ពស់ផ្លូវចិត្តមនុស្សដែរឬទេ ?»។

ចម្លើយរបស់គាត់គឺ «គ្មានទេ» គាត់បានបង្ហាញឲ្យឃើញច្បាស់ថាមនុស្សដែលមានជំនាញល្អ និងមានជីវភាពរស់នៅពោរពេញដោយសេចក្តីសុខដោយសារតែភាពរីកចម្រើនខាងផ្នែកវប្បធម៌នេះ អាចនឹងត្រូវបានការរីកចម្រើនទាំងឡាយនោះគ្របសង្កប់ផ្លូវចិត្ត និងនាំទៅកាន់ការចុះខ្សោយនៃផ្លូវចិត្តបាន នេះនាំឱ្យគាត់ទទួលបានជ័យលាភីទី១។

បើទោះជា រ៉ូហ្សូ មិនសិក្សារៀនសូត្រនៅសាលារៀនក៏ពិតមែន ប៉ុន្តែរូបគាត់ក៏ត្រូវបានរាប់បញ្ចូលជាអច្ឆរិយបុគ្គល ដ៏មានប្រាជ្ញាឈ្លាសវៃមួយរូបក្នុងសតវត្សរ៍ទី ១៨ ដែរ។ គាត់គឺជាបុគ្គលដែលបានត្រួសត្រាយផ្លូវឆ្ពោះទៅកាន់ការបដិវត្ត បារាំង និងការគ្រប់គ្រងបែបប្រជាធិបតេយ្យសម័យថ្មី។ ក្រៅពីនេះ គាត់ក៏ជាបុគ្គលដែលបានផ្តល់នូវផ្នត់គំនិតដ៏មានឥទ្ធិពលចំពោះលទ្ធិប្រជាធិបតេយ្យនិងប្រព័ន្ធអប់រំ ដែលទាំងអស់នោះវាកើតចេញពីបទពិសោធជីវិត ដែលគាត់បានឆ្លងកាត់ទាំងស្រុងក្នុងឆាកជីវិតរបស់គាត់នោះឯង។

ប៉ុន្តែ ទោះបីយ៉ាងនេះក្តី ខ្សែជីវិតរបស់គាត់ផ្ទាល់បានបង្ហាញឲ្យយើងឃើញក្នុងតំណាក់កាលចុងក្រោយយ៉ាងជាក់ស្តែង អំពីភាពផ្ទុយគ្នាស្រឡះពីទ្រឹស្តីនិងការអនុវត្តផ្ទាល់ទៅវិញ ព្រោះគាត់ជាអ្នកដែលបានបង្ហាញនូវផ្នត់គំនិត ដែលទាក់ទិនទៅនឹងការចិញ្ចឹមបីបាច់ថែរក្សា, អប់រំទូន្មាន និងប្រៀនប្រដៅកូនឲ្យបានល្អបំផុត ប៉ុន្តែខ្លួនគាត់ផ្ទាល់បែរជាបរាជ័យក្នុងការបំពេញតួនាទីជាឪពុក ក៏ព្រោះគាត់បានបញ្ជូនកូនរបស់គាត់ទាំង ៥ នាក់ឲ្យទៅមណ្ឌលចិញ្ចឹមក្មេងក្រោយពេលដែលភរិយារបស់គាត់ប្រសូត្របុត្រភ្លាមៗ។

ចីន-ចាកស៍ រ៉ូហ្សូ ធ្លាប់បានសរសេរទុកថា «បុគ្គលណាដែលមិនអាចបំពេញតួនាទីជាឪពុកដ៏ល្អបាន បុគ្គលនោះក៏គ្មានសិទ្ធធ្វើជាឪពុកគេឡើយ»។

ករណីនេះ ក្នុងផ្លូវព្រះពុទ្ធសាសនាក៏ចែងដែរថា ឪពុកម្តាយអាច មានឈ្មោះថាជាអ្នកមានគុណដ៏ពេញលក្ខណៈ លុះត្រាតែបង្កើតកូនមក ហើយបានចិញ្ចឹមបីបាច់ថែរក្សាកូនប្រុសស្រីប្រកបដោយព្រហ្មវិហារធម៌ ទាំងបួនគឺ មេត្តា ករុណា មុទតា និងឧបេក្ខា។

អ្នកជោគជ័យ អានសៀវភៅ ជាំដើមជីវិត

# ឯកសារយោង


Ball, Hugo : Hermann Hesse. Sein Leben und sein Werk. Berlin 1927.

Bergengren, Erik : Alfred Nobel. Eine Biographie. Muenchen-Esslingen 1965.

Bamm, Peter : Alexander und die Verwandlung der Welt. Muenchen-Zuerich 1965.

Bismarck, Otto Fuerst von : Gedanken und Erinnerungen. Stuttgart 1898.

Bowle, J : Henry VIII. A biography. London 1964.

Brocher, Tobias : Sigmund Freud. In: Die Grossen der Weltgeschichte, Bd.9. Zuerich 1970.

Churchill, Winston : Meine fruehen Jahre. Hamburg 1931.

Cronin, Vincent : Napoleon. Eine Biographie. Hamburg-Duesseldorf 1973.

Curie, Eve : Madame Curie. Frankfurt am Main 1938.

Curtius, Ernst Robert : Balzac. Bern 1950.

Darwin, Charles : Autobiographie. Leipzig-Jena 1959.

Erikson, Erik H. : Der junge Martin Luther. Eine psychoanalistische Studie. Muenchen 1958.

Fest, Joachim C. : Hitler. Frankfurt am Main-Berlin-Wien 1973.

Fodor, Stephan: Edison. Der Lebensweg eines Erfinders. Berlin 1927.

Frank, Philipp : Einstein-Sein Leben und seine Zeit. Muenchen-Leizig 1949.

Frazer, Antonia : Maria, Koenigin der Schotten. Hamburg-Duesseldorf 1959.

Gaxotte, Pierre : Friedrich der Grosse. Berlin-Frankfurt-Wien 1973.

Goerlitz, Walter : Abraham Lincoln. Heidelberg-Stuttgart 1946.

Gormann, Herbert : James Joyce. His First Forty Years. New York 1924.

Hampe, Karl: Deutsche Kaisergeschichte in der Zeit der Salier und Staufer. Leipzig 1945.

Johnson, E : Charles Dickens. 2 Baende 1953.

Kafka, Franz : Briefe an Milena. Frankfurt am Main 1952.

Lania, Leo : Hemingway. Eine Bildbiographie. Muenchen 1970.

Marabini, Jean : Lenin : Organisator der Russischen Revolution. Wiesbaden o.J.

Mayer, Hans : Thomas Mann. Werk und Entwicklung. Berlin 1950.

Mommsen, Theodor: Roemische Geschichte, Bd.3. Berlin 1922.

Paine, A.B. : Mark Twain. A Biography. 3 Baende 1912.

Paulsen, Friedrich : Immanuel Kant. Sein Leben und seine Lehre. Stuttgart 1924.

Pia, Pascal : Charles Baudelaire in Selbstzeunissen und Bilddokumenten. Reinbek bei Hamburg 1958.

Prause, Gerhard : Genies in der Schule. Legende und Wahrheit ueber den Erfolg im Leben. Muenchen 1991.

Rosenkranz, Karl : Georg Wilhelm Friedrich Hegels Leben. Berlin 1844.

Schiel, H. : Die Umwelt des jungen Marx. Trier 1954.

Sowein, Gerd: In Englisch war Kissinger keine Leuchte. In: Sueddeutsche Zeitung vom 20.9.1973.

Specht, Rainer : Rene' Decartes in Selbstzeugnissen und Bilddokumenten. Reinbek bei Hamburg 1966.

Streiff, Eric : Mahatma Gandhi. In : Die Grossen der Weltgeschichte, Bd.9. Zuerich 1970.

Valentin, Erich : Mozart. Eine Bildbiographie. Muenchen 1958.

Wassermann, Julie : Flaubert. Ein Selbstportrait nach seinem Briefen. Berlin 1907.

# ច័យក្មេង ច័យរៀន របស់ អច្ឆរិយបុគ្គល

ប្រសិនបើលោកអ្នកបានអានសៀវភៅមួយក្បាលនេះនឹងបាន យល់កាន់តែច្បាស់ថាអច្ឆរិយបុគ្គលដែលល្បីៗនៅក្នុងលោក មិនថាជាអ្នកដែលមានប្រវត្តិការសិក្សារៀនសូត្រពូកែឬខ្សោយ ស្រឡាញ់ឬស្អប់សាលារៀន ឬសូម្បីតែបុគ្គលដែលមិនធ្លាប់បាន សិក្សារៀនសូត្រទាល់តែសោះនោះក៏សុទ្ធតែមានចំណុចអច្ឆរិយៈ ដូចៗគ្នាគឺ សេចក្តីតាំងចិត្តខ្ជាប់ខ្ជួន និងសេចក្តីឧស្សាហ៍ព្យាយាម ពុះពារឧបសគ្គគ្រប់បែបយ៉ាងដើម្បីទទួលបានជោគជ័យក្នុងឆាក ជីវិតទាល់តែបានសម្រេចនៅថ្ងៃណាមួយ។

បើសិនជាលោកអ្នកឬបុត្រធីតារបស់លោកអ្នកមានការ តាំងចិត្តមោះមុតនិងប្រកបដោយសេចក្តីឧស្សាហ៍ព្យាយាមយ៉ាង ម៉ឺងម៉ាត់ នោះភាពអច្ឆរិយៈក៏ប្រហែលមិនមែនជារឿងដែលហួស វិស័យនោះឡើយ។



ISBN 978-999-63-42-64-6
9 789996 342646

១២០០០៛